PHNOM PENH AUTONOMOUS PORT

កំពង់ផែស្វយ័តភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

********

# របាយការណ៍ប្រចាំឆ្នាំ

# ២០១៥



ANNUAL REPORT 2015

## ទស្សនវិស័យ

ទស្សនវិស័យរបស់ ក.ស.ភ. គឺរក្សាភាពជាអ្នកគ្រប់គ្រងក្នុងអាជីវកម្មដឹកជញ្ជូនតាមដងទន្លេមេគង្គ និងដើរតួនាទីជាបណ្តាញដឹកជញ្ជូនតាមផ្លូវទឹកប្រកបដោយប្រសិទ្ធភាព និងសមត្ថភាព ដើម្បីភ្ជាប់ទំនាក់ទំនងជាមួយដៃគូពាណិជ្ជកម្មក្រៅប្រទេស។

## បេសកកម្ម

បេសកកម្មរបស់ ក.ស.ភ. គឺ គ្រប់គ្រង អភិវឌ្ឍ ធ្វើប្រតិបត្តិការហេដ្ឋារចនាសម្ព័ន្ធផែ និងបម្រើសេវាកម្មចម្បង និងសេវាកម្មពាក់ព័ន្ធដទៃទៀតដើម្បីធានាឱ្យមាននិរន្តរភាពនៃការលូតលាស់ផ្នែកសេដ្ឋកិច្ច និងការរីកចំរើនក្នុងសង្គមជាតិទាំងមូល។

## ១. ព័ត៌មានហិរញ្ញវត្ថុសង្ខេប

<table>
<tr><th colspan="2">បរិយាយ</th><th>ឆ្នាំ ២០១៥</th><th>ឆ្នាំ ២០១៤</th><th>ឆ្នាំ ២០១៣</th></tr>
<tr><td colspan="4">ស្ថានភាពហិរញ្ញវត្ថុ</td><td>(ពាន់រៀល)</td></tr>
<tr><td colspan="2">ទ្រព្យសកម្មសរុប</td><td>៦៤៧.៩០៩.៤៤៤</td><td>៦១២.៩៩០.២៩៤</td><td>៦១៣.៧៨៧.២២២</td></tr>
<tr><td colspan="2">បំណុលសរុប</td><td>១៣៤.៥០១.៣៧៥</td><td>១៣០.៥៨២.០៣៩</td><td>១៤២.៧៣១.០៧៥</td></tr>
<tr><td colspan="2">មូលធនសរុប</td><td>៥១៣.៤០៨.០៦៩</td><td>៤៨២.៤០៨.២៥៥</td><td>៤៧១.០៥៦.១៤៧</td></tr>
<tr><td colspan="4">លទ្ធផលហិរញ្ញវត្ថុ</td><td>(ពាន់រៀល)</td></tr>
<tr><td colspan="2">ចំណូលសរុប</td><td>៦១.៤៥៨.១៨៦</td><td>៥៣.៦៧៤.១២៦</td><td>៤៥.៩១៨.៩២៦</td></tr>
<tr><td colspan="2">ចំណេញមុនការបង់ពន្ធ</td><td>១៧.៧៣៦.០៧៧</td><td>១១.៣២៩.៧២៤</td><td>៦.១៤២.៩១១</td></tr>
<tr><td colspan="2">ចំណេញសុទ្ធក្រោយការបង់ពន្ធ</td><td>១២.៩២៣.៨៩៣</td><td>៨.៦៦១.៩៥១</td><td>៣.១០៩.៥៨៩</td></tr>
<tr><td colspan="5">អនុបាតហិរញ្ញវត្ថុ</td></tr>
<tr><td colspan="2">អនុបាតសាធនភាព (Solvency Ratio)</td><td>១៦,៥៧</td><td>១៣,៦៨</td><td>៧,៤៨</td></tr>
<tr><td rowspan="2">អនុបាត សន្ទនីយភាព (Liqiudity)</td><td>អនុបាតចរន្ត</td><td>៤៥៨,៩៧</td><td>១៦៤,០៦</td><td>៤៤,៥៧</td></tr>
<tr><td>អនុបាតចរន្តលឿន</td><td>៤៥៨,៩៧</td><td>១៦៤,០៦</td><td>៤៤,៥៧</td></tr>
<tr><td rowspan="5">អនុបាត ចំណេញភាព (Profitability)</td><td>ផលចំណេញក្នុងមួយឯកតាទ្រព្យសកម្ម</td><td>១,៩៩</td><td>១,៤១</td><td>០,៥១</td></tr>
<tr><td>ផលចំណេញក្នុងមួយឯកតាមូលធន</td><td>២,៥២</td><td>១,៨០</td><td>០,៦៦</td></tr>
<tr><td>គំលាតចំណេញដុល</td><td>៦៤,៤០</td><td>៦០,០៤</td><td>៥៩,៨៨</td></tr>
<tr><td>គំលាតចំណេញភាព</td><td>២១,០៣</td><td>១៦,១៤</td><td>៦,៧៧</td></tr>
<tr><td>ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (រៀល)</td><td>៧៦៩,២៧ រៀល</td><td>៥២៣,៤៦ រៀល</td><td>១៨៧,៩២ រៀល</td></tr>
</table>

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប









## ២. សមាសភាពក្រុមប្រឹក្សាភិបាល



ឯកឧត្តម ហ៊ី បាវី
ប្រធានក្រុមប្រឹក្សាភិបាល



ឯកឧត្តម សួន រចនា
សមាជិកក្រុមប្រឹក្សាភិបាល



ឯកឧត្តម លី ស៊ីវណ្ណា
សមាជិកក្រុមប្រឹក្សាភិបាល



ឯកឧត្តម កែន សម្បត្តិ
សមាជិកក្រុមប្រឹក្សាភិបាល



ឯកឧត្តម ប៉ែន សុវិជាតិ
សមាជិកក្រុមប្រឹក្សាភិបាល



លោក ហួត ហៃ
សមាជិកក្រុមប្រឹក្សាភិបាល



ឯកឧត្តម ព្រុំ សុខានី
សមាជិកក្រុមប្រឹក្សាភិបាល

## ៣. សេចក្ដីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយក ក.ស.ភ.

នៅក្នុងឆ្នាំ ២០១៥ នេះ កំពង់ផែស្វយ័តភ្នំពេញទទួលបានចំណូលសរុបចំនួន ៦១.៩៥៨.១៨៦.០០០ រៀល និងទទួលបានប្រាក់ចំណេញមិនទាន់បង់ពន្ធលើប្រាក់ចំណេញចំនួន ១៧.៧៣៦.០៧៧.០០០ រៀល។

កំពង់ផែស្វយ័តភ្នំពេញ បានយកចិត្តទុកដាក់ក្នុងការបម្រើសេវាកម្មប្រតិបត្តិការផែប្រកបដោយតម្លាភាព និងភាពឆាប់រហ័ស ដើម្បីឆ្លើយតបយ៉ាងមានប្រសិទ្ធភាព និងទំនុកចិត្តខ្ពស់ចំពោះតម្រូវការរបស់អតិថិជន។ ជាក់ស្ដែង ក.ស.ភ. បានប្រើប្រាស់គ្រប់យន្តការ តាមរយៈការពង្រឹងគុណភាពសេវាកម្ម ការពង្រីកសមត្ថភាពផ្ទុក ការជួសជុលថែទាំ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការងារជលធារសាស្ត្រ ការងារបំពាក់គ្រឿងចក្រ និងឧបករណ៍ថ្មីៗ ជាដើម។

ទិសដៅការងារអនុវត្តចម្បងរបស់ ក.ស.ភ. រួមមាន៖

- ពង្រឹងសមត្ថភាពការងាររដ្ឋបាល
- ពង្រឹងសមត្ថភាពការងារជំនាញ
- ពង្រឹងកិច្ចសហប្រតិបត្តិការភាពជាដៃគូយុទ្ធសាស្ត្រ ជាមួយបណ្ដាកំពង់ផែក្នុងតំបន់ និងបណ្ដាកំពង់ផែដទៃទៀតនៅលើពិភពលោក
- ពង្រីកសេវាកម្ម និងអាជីវកម្មដែលមានស្រាប់ ឱ្យមានលក្ខណៈកាន់តែទូលំទូលាយ និងបង្កើតឱ្យមានសេវាកម្មថ្មីបន្ថែមទៀតដែលពាក់ព័ន្ធនឹងវិស័យកំពង់ផែ និងភ័ស្តុភារកម្ម
- បន្តអនុវត្តផែនការសកម្មភាពការងារតាមផែនការដែលបានគ្រោងទុក
- ធានាគុណភាព តម្លាភាព ប្រសិទ្ធភាព និងភាពឆាប់រហ័ស នៃការផ្ដល់សេវាកម្មជូនអតិថិជន
- បង្កើនឧត្តមភាពប្រកួតប្រជែងដោយស្មោះត្រង់ ជាមួយកំពង់ផែក្នុងស្រុក និងក្រៅស្រុក
- ខិតខំ និងបន្តផ្ដោតការយកចិត្តទុកដាក់ លើការធ្វើទំនើបកម្មប្រតិបត្តិការផែ ឱ្យស្របតាមស្តង់ដា និងប្រព័ន្ធបច្ចេកវិទ្យា
- ចូលរួមក្នុងសកម្មភាពសង្គម និងសហគមន៍មូលដ្ឋាន។

### ៣.១. ការអនុវត្តការងាររបស់ក្រុមប្រឹក្សាភិបាល

នៅឆ្នាំ២០១៥នេះ ក្រុមប្រឹក្សាភិបាលបានជួបប្រជុំចំនួន ៧ លើក ដោយសម្រេចបាននូវកិច្ចការដូចខាងក្រោម៖

➢ **ប្រជុំលើកទី ១០ អាណត្តិទី៥ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៥**

- ពិនិត្យ និងឆ្លងរបាយការណ៍បូកសរុបការងារអាជីវកម្ម/សេវាកម្មប្រចាំឆ្នាំ២០១៤
- ពិនិត្យ និងឆ្លងរបាយការណ៍បិទបញ្ជីគណនេយ្យ សម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៤
- ពិនិត្យ និងពិភាក្សាលើការបែងចែកប្រាក់ចំណេញ ការិយបរិច្ឆេទឆ្នាំ២០១៤ ចូលក្នុងមូលនិធិនានារបស់ ក.ស.ភ. ព្រមទាំងកំណត់ប្រាក់រង្វាន់សរសើរជូនក្រុមប្រឹក្សាភិបាល ក្រុមលេខា និងបុគ្គលិកស្មើនឹង២ខែនៃប្រាក់បៀវត្សរ៍ និងបានពិនិត្យ និងពិភាក្សាលើលទ្ធផលប្រាក់ចំណេញ និងការបែងចែកប្រាក់ចំណេញ ចូលមូលនិធិនានាឡើងវិញ សម្រាប់ការិយបរិច្ឆេទរយៈពេល ០៥ ឆ្នាំ (២០០៩ ដល់២០១៣) ដែលរៀបចំដោយក្រុមហ៊ុន Premier និងសម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៤ ដែលរៀបចំឡើងដោយក្រុមហ៊ុន Grant Thornton
- ពិនិត្យ និងពិភាក្សាលើលទ្ធផលវាយតម្លៃអចលនទ្រព្យឆ្នាំ២០០៩ របស់ក.ស.ភ. ដោយក្រុមហ៊ុនVTrust

- ពិនិត្យ និងពិភាក្សាលើការផ្ទេរចេញពីបញ្ជីសារពើភ័ណ្ឌអចលនទ្រព្យរបស់ ក.ស.ភ. នូវម៉ាស៊ីន-ស្តែននំរមួយគ្រឿងដែលជាជំនួយឥតសំណងពីរដ្ឋាភិបាលចិន
- ពិនិត្យ និងពិភាក្សាលើការជ្រើសរើសយកក្រុមហ៊ុនគណនេយ្យ Grant Thornton ដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០១៤ និងត្រីមាសទី១ ឆ្នាំ២០១៥ ព្រមទាំងការងាររៀបចំគោលនយោបាយ និងនីតិវិធីគណនេយ្យជូន ក.ស.ភ.
- ពិនិត្យ និងពិភាក្សាលើសំណើសុំគោលការណ៍សម្រេចពីក្រសួងអាណាព្យាបាលទាំងពីរ (ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ចំពោះការជួលដីទំហំ ៩.៥ ហិកតាឲ្យទៅក្រុមហ៊ុន Daiwa Lease Co., Ltd. និងការស្នើសុំទិញដីទំហំ ០២ ហិកតា បន្ថែមវិញ
- ពិភាក្សាលើសំណើសុំទៅអគ្គនាយកដ្ឋានពន្ធដារ ដើម្បីស្នើសុំឲ្យចេញលិខិតបញ្ជាក់ថា ក.ស.ភ. ពុំមានបំណុលពន្ធនៅសេសសល់ទៀតទេ សម្រាប់រយៈពេល ០៥ ឆ្នាំ (២០០៩ដល់២០១៣) ដើម្បីទុកជាភស្តុតាងជូនខាងក្រុមហ៊ុនសវនកម្មឯករាជ្យចុះមកធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ
- ពិនិត្យ និងពិភាក្សាលើដំណើរការបណ្តុះបណ្តាលផ្នែកនាវាចរណ៍ របស់វិទ្យាស្ថាននាវាចរណ៍កម្ពុជា
- ពិនិត្យ និងពិភាក្សាលើវឌ្ឍនភាពនៃដំណើរការរៀបចំបែបបទក្នុងការស្នើសុំការអនុញ្ញាតបង្កើតតំបន់សេដ្ឋកិច្ចពិសេសរបស់ ក.ស.ភ.
- ពិនិត្យ និងពិភាក្សាលើការស្នើសុំការគិតតម្លៃ Lump Sum ចំពោះនាវាទេសចរណ៍ និងនាវាលើកដាក់ទំនិញ
- ពិនិត្យ និងពិភាក្សាលើការកែសម្រួលឡើងវិញនូវសមាសភាពនៃលេខាធិការដ្ឋានក្រុមប្រឹក្សាភិបាល ក.ស.ភ.
- ពិនិត្យ និងពិភាក្សាលើការស្នើសុំផ្តល់ប្រាក់បៀវត្សរ៍ ប្រាក់លាភការ ប្រាក់ទូរស័ព្ទ ប្រេងឥន្ធនៈ និងប្រាក់ឧបត្ថម្ភផ្សេងៗទៀត ជូនប្រធានការិយាល័យចំនួន០៤ ស្មើនឹងថ្នាក់នាយករងមាន ប្រធានការិយាល័យគណនេយ្យ/ហិរញ្ញវត្ថុ ប្រធានការិយាល័យបុគ្គលិក ប្រធានការិយាល័យសវនកម្មផ្ទៃក្នុង និងប្រធានការិយាល័យសុវត្ថិភាព សុខមាលភាព និងបរិស្ថានផែ (SHE)។

➢ **ប្រជុំវិសាមញ្ញ អាណត្តិទី៥ ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥**

- ពិភាក្សា និងសម្រេចលើការជួលដីរយៈពេលវែងពីម្ចាស់ដីនៅក្បែរតំបន់សេដ្ឋកិច្ចពិសេស លើផ្ទៃដីទំហំប្រមាណ ១.០០០ (មួយពាន់) ហិកតា ដែលមានទីតាំងស្ថិតក្នុងភូមិកណ្តាលក្រោម ឃុំបន្ទាយដែក និងភូមិជ័យឧត្តម ភូមិជ្រោយដង ភូមិស្ទឹង ភូមិព្រែកត្រែង ភូមិសំពោងក្អែរ ឃុំសំពោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល។

➢ **ប្រជុំលើកទី ១១ អាណត្តិទី៥ ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០១៥**

- ពិនិត្យ និងពិភាក្សាលើការធានាអត្រាទិន្នផលភាគលាភធានាជូនវិនិយោគិនសាធារណៈ ប្រចាំឆ្នាំយ៉ាងទាបបំផុត ៥% ក្នុងរយៈពេល ០៥ ឆ្នាំ
- ពិនិត្យ និងពិភាក្សាលើកម្រៃសេវាអប្បបរមារបស់ក្រុមហ៊ុន **យាន់តា ស៊ីយូរីធី** ជាក្រុមហ៊ុនធានាទិញមូលបត្ររបស់ ក.ស.ភ. ចំនួន ៧៥០.០០០ (ប្រាំពីររយ ហាសិបពាន់ ដុល្លារអាមេរិក) និងសុំគោលការណ៍សម្រេចលើកម្រៃសេវានេះទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ពិនិត្យ និងពិភាក្សាលើសំណើសុំមិនកត់ត្រាទឹកប្រាក់ចំនួន ១.៩៤០.១២៤.២០០រៀល ដែលជាចំណែកមួយនៃពន្ធលើការនាំចូលគ្រឿងចក្រ TCC គ្រឿងចក្រ RTG និង Reach Stacker ជាចំណាយ

នៅក្នុងឆ្នាំ២០១២

- ពិនិត្យ និងពិភាក្សាលើការស្នើទិញរថយន្ត Pick Up ចំនួន ៣ គ្រឿង និងអូប័រចម្លងចំនួន ២ គ្រឿង សម្រាប់បម្រើឲ្យការងារអាជីវកម្មបូមស្តារប្រឡាយនាវាចរណ៍ ដើម្បីយកខ្សាច់មកផ្គត់ផ្គង់តម្រូវការទីផ្សារប្រើប្រាស់ក្នុងស្រុក និងការងារវាស់ស្ទង់
- ពិនិត្យ និងពិភាក្សាលើតម្លៃសេវាកម្មរបស់ក្រុមហ៊ុនឯកជនសិក្សាផលប៉ះពាល់បរិស្ថាន (EIA) និងលើការស្នើបញ្ចូលខ្ទង់ចំណាយលើការងារសិក្សាផលប៉ះពាល់បរិស្ថាន (EIA) សម្រាប់ទីតាំងប្រឡាយឡូត៍ខ្សាច់ចំនួន ២ កន្លែងដែល ក.ស.ភ. ទទួលបានអាជ្ញាបណ្ណពីក្រសួងរ៉ែ និងថាមពលចូលក្នុងផែនការ ឆ្នាំ២០១៦ ខាងមុខ
- ពិនិត្យ និងពិភាក្សាលើការស្នើទិញសម្ភារ និងវិធានវាស់ស្ទង់ដើម្បីឆ្លើយតបទៅនឹងតម្រូវការសម្រាប់បម្រើឲ្យការងារអាជីវកម្មវាស់ស្ទង់របស់ ក.ស.ភ.
- ពិនិត្យ និងពិភាក្សាលើការស្នើឲ្យលោកជំទាវ **គីម សែន** ជាអគ្គនាយករងរដ្ឋបាល និងកញ្ញា **ឈាវ វណ្ណធា** ជាប្រធានការិយាល័យគណនេយ្យ/ហិរញ្ញវត្ថុ ជាតំណាងក.ស.ភ. សម្រាប់ធ្វើការ ទាក់ទងជាមួយធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា (FTB) ដើម្បីខ្ចីចងការប្រាក់ សម្រាប់ទិញនូវគ្រឿងចក្រលើកដាក់បន្ថែមទៀតសម្រាប់ប្រតិបត្តិការនៅចំណតផែកុងតឺន័រ LM១៧។

➢ **ប្រជុំលើកទី ១២ អាណត្តិទី៥ ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥**

- ពិនិត្យ និងពិភាក្សាលើលទ្ធផលរបាយការណ៍សវនកម្មរបស់ក្រុមហ៊ុនសវនកម្មឯករាជ្យ KPMG និងលើការស្នើបញ្ចូលប្រាក់ចំណេញរក្សាទុក (Retained Earning) ចូលក្នុងដើមទុន (Share Capital) គិតចាប់ពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤
- ពិនិត្យ និងពិភាក្សាលើលទ្ធផលអាជីវកម្ម/សេវាកម្មរយៈពេល ៦ខែ ដើមឆ្នាំ២០១៥ និងលទ្ធផលហិរញ្ញវត្ថុរយៈពេល ៦ ខែ ដើមឆ្នាំ២០១៥
- ពិនិត្យ និងពិភាក្សាលើការស្នើសុំគោលការណ៍ ដើម្បីឲ្យ ក.ស.ភ. បោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (IPO) ចំនួន ២០% នៅលើទីផ្សារមូលបត្រកម្ពុជា
- ពិនិត្យ និងសម្រេចលើការតែងតាំង ឯកឧត្តម ហ៊ី បាវី ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាប្រធានអគ្គនាយក ក.ស.ភ. ជាអ្នកតំណាងស្របច្បាប់ឲ្យ ក.ស.ភ. ក្នុងការបំពេញតួនាទីត្រួតពិនិត្យ និងចុះហត្ថលេខាលើឯកសារពាក់ព័ន្ធនឹងដំណើរការ IPO
- ពិនិត្យ និងសម្រេចលើការបង់ភាគលាភជាបណ្ដោះអាសន្នទៅតាមគម្រោងចំណូលថវិការដ្ឋឆ្នាំ២០១៦ និងស្នើសុំបង្វែរការបង់ភាគលាភលើប្រាក់ចំណេញជូនរដ្ឋទៅជាការបង់ភាគលាភលើប្រាក់ចំណេញ ទៅតាមសមាមាត្រនៃប្រាក់កាន់ភាគហ៊ុនដូចម្ចាស់ភាគហ៊ុនឯកជនដទៃទៀត បន្ទាប់ពីបានចូល IPO
- ពិនិត្យ និងពិភាក្សាលើការកំណត់មូលដ្ឋាននៃការគិតតម្លៃវាស់ស្ទង់ សម្រាប់ផ្តល់សេវាជូនដល់ក្រសួងរ៉ែ និងថាមពល និងក្រុមហ៊ុនឯកជនមួយចំនួនទៀត
- ពិនិត្យ និងពិភាក្សាលើការស្នើទិញរថយន្តទំនើប ១ គ្រឿង សម្រាប់ទុកទទួលភ្ញៀវអន្តរជាតិដែលអញ្ជើញមកទំនាក់ទំនងការងារជាមួយ ក.ស.ភ.។

➢ **ប្រជុំលើកទី ១៣ អាណត្តិទី៥ ថ្ងៃទី៥ ខែសីហា ឆ្នាំ២០១៥**

- ពិនិត្យ និងពិភាក្សាលើការកំណត់តម្លៃមូលធនូបនីយកម្មទីផ្សាររបស់ ក.ស.ភ. រចនាសម្ព័ន្ធនៃការ

បោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (IPO) និងរចនាសម្ព័ន្ធនៃមូលធនរបស់ ក.ស.ភ.

- ពិនិត្យ និងពិភាក្សាលើការស្នើកំណត់ចំនួនមូលបត្រកម្មសិទ្ធិដែលអាចធ្វើការបោះផ្សាយលក់បាន (Authorized Shares)
- ពិនិត្យ និងពិភាក្សាលើការស្នើលៃបម្រុងមូលបត្រកម្មសិទ្ធិជូននិយោជិតរបស់ ក.ស.ភ. ចំនួន ១០% នៃមូលបត្រកម្មសិទ្ធិដែលបោះផ្សាយលក់ជាសាធារណៈចំនួន ២០% និងបង្កើតគោលនយោបាយលៃបម្រុងទុកលក់ជូននិយោជិត
- ពិនិត្យ និងពិភាក្សាលើឯកសារផ្តល់ព័ត៌មាន (Disclosure Document) និងឯកសារភ្ជាប់ជាភាសាខ្មែរ សម្រាប់ដាក់ជូនគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.) ដើម្បីទទួលបាននូវការយល់ព្រមជាគោលការណ៍លើការបោះផ្សាយលក់មូលបត្រ
- ពិនិត្យ និងពិភាក្សាលើការស្នើជ្រើសរើសយកធនាគារអេសុីលីដា ភីអិលសុី ជាភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារផ្ទេរមូលបត្រ និង ភ្នាក់ងារទូទាត់ រួមនឹងជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងការជួញដូរមូលបត្រ (Cash Settlement Agent)
- ពិនិត្យ និងពិភាក្សាលើការស្នើសុំជម្រះបញ្ជីរថយន្តស្លាកលេខរដ្ឋ ២៥.២.០៣៧៨។

- **ប្រជុំលើកទី ១៤ អាណត្តិទី ៥ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥**

- ពិភាក្សា និងអនុម័តលក្ខន្តិកៈ របស់ ក.ស.ភ. ដែលត្រូវកែសម្រួលដោយបញ្ចូលបន្ថែមនូវប្រភេទ និងចំនួនភាគហ៊ុនដែលត្រូវធ្វើការបោះផ្សាយ និង សិទ្ធិ និងលក្ខណៈនៃប្រភេទភាគហ៊ុននីមួយៗ
- ពិនិត្យ និងអនុម័តក្រមសីលធម៌ សម្រាប់ក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ ក.ស.ភ.
- ពិនិត្យ និងពិភាក្សាលើកិច្ចព្រមព្រៀងធានាទិញមូលបត្ររវាង ក.ស.ភ. និងក្រុមហ៊ុនធានាទិញមូលបត្រ យាន់តា ស៊ីយ្យូរីធី
- ពិនិត្យ និងពិភាក្សាលើការស្នើសុំបញ្ចុះតម្លៃលើកដាក់លើទីលាន (LOLO) មកត្រឹមតម្លៃ ៣៦ ដុល្លារអាមេរិក ក្នុងមួយទូសម្រាប់កុងតឺន័រ ២០ ហ្វីត ដែលដឹកអង្ករតាម ក.ស.ភ. ហើយការបញ្ចុះតម្លៃនេះ និងអនុវត្តចំពោះក្រុមហ៊ុននាំអង្ករចេញ ដែលជាសមាជិកសហព័ន្ធស្រូវអង្ករកម្ពុជា និងចំពោះគ្រប់ផលិតផលកសិផលផ្សេងៗទៀត លើកលែងតែកៅស៊ូតែមួយមុខប៉ុណ្ណោះ
- ពិនិត្យ និងពិភាក្សាលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល សម្រាប់ត្រីមាសទី១ នៃការិយបរិច្ឆេទឆ្នាំ២០១៥ (ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥) និងរបាយការណ៍របស់សវនករឯករាជ្យ។

- **ប្រជុំលើកទី ១៥ អាណត្តិទី ៥ ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥**

- ពិភាក្សា និងសម្រេចលើការកំណត់ថ្លៃមូលបត្រកម្មសិទ្ធិរបស់ ក.ស.ភ. ជាមួយក្រុមហ៊ុន យាន់តា ស៊ីយ្យូរីធី សម្រាប់ចុះបញ្ជីលក់លើទីផ្សារមូលបត្រកម្ពុជា ដែលមានតម្លៃ៥.១២០ (ប្រាំពាន់ មួយរយម្ភៃ) រៀល ឬ ស្មើនឹង ១,២៥៦ (មួយដុល្លារអាមេរិក ពីររយហាសិបប្រាំមួយ) ក្នុងមួយមូលបត្រ និងពិភាក្សាអនុម័តលើឯកសារផ្តល់ព័ត៌មានចុងក្រោយជាមួយនឹងថ្លៃលក់មូលបត្រស្មើនឹង ៥.១២០ (ប្រាំពាន់ មួយរយម្ភៃ) រៀល ឬ ស្មើនឹង ១,២៥៦ (មួយដុល្លារអាមេរិក ពីររយហាសិបប្រាំមួយ) ក្នុងមួយមូលបត្រ ដើម្បីដាក់ជូនគណៈកម្មការមូលបត្រកម្ពុជា (គ.ម.ក.)
- ពិនិត្យ និងពិភាក្សាលើលទ្ធផលសម្រេចបានក្នុងរយៈពេល ៩ខែ ដើមឆ្នាំ២០១៥ របស់ ក.ស.ភ.
- ពិនិត្យ និងពិភាក្សាលើផែនការអាជីវកម្ម/សេវាកម្មរបស់ ក.ស.ភ. សម្រាប់ឆ្នាំ២០១៦

- ពិនិត្យ និងពិភាក្សាលើការបន្តជួលសេវារបស់ក្រុមហ៊ុនសវនកម្មឯករាជ្យ KPMG សម្រាប់ឆ្នាំ ២០១៥ និងឆ្នាំបន្តបន្ទាប់ ព្រមទាំងសេវាត្រួតពិនិត្យទៅលើស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេលត្រីមាសនីមួយៗ ក្រោយពេលចូល IPO រួច
- ពិនិត្យ និងពិភាក្សាលើការបន្តជួលសេវារបស់ក្រុមហ៊ុន Ernst & Young Hong Kong សម្រាប់ធ្វើការគណនាប្រាក់សោធននិវត្តន៍ សម្រាប់ត្រីមាសទី២ ឆ្នាំ២០១៥ និងប្រចាំឆ្នាំ២០១៥ និងជួលសេវារបស់ក្រុមហ៊ុន PWC នៅប្រទេសសិង្ហបុរី សម្រាប់មកធ្វើការបណ្តុះបណ្តាលបុគ្គលិក ក.ស.ភ. ទៅលើការគណនាប្រាក់សោធននិវត្តន៍
- ពិនិត្យ និងពិភាក្សាលើការចំណាយលើការផ្សព្វផ្សាយពាណិជ្ជកម្មអំពី IPO របស់ ក.ស.ភ.
- ពិនិត្យ និងពិភាក្សាលើការស្នើសុំទិញរថយន្តទេសចរណ៍ Land Cruiser ថ្មី ចំនួន ១ គ្រឿង សម្រាប់ទុកទទួលអតិថិជន ភ្ញៀវជាតិ និងវិនិយោគិនបរទេស ដែលមកទំនាក់ទំនងសួរព័ត៌មានអំពីអាជីវកម្ម និងអំពី IPO របស់ ក.ស.ភ.
- ពិនិត្យ និងពិភាក្សាលើការធ្វើកិច្ចសហប្រតិបត្តិការក្រោមទម្រង់ជា Joint Venture ជាមួយក្រុមហ៊ុន Morning Star Logistic JSC នៃប្រទេសវៀតណាម ដើម្បីបង្កើតសេវាកម្មថែទាំ-ជួសជុលសំបកកុងតឺន័រ
- ពិនិត្យ និងពិភាក្សាលើការធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុន Sung Kwang Heavy Equipment ក្នុងការបំពាក់រថស្ទូច TCC ចំនួន ០១ គ្រឿងទៀតនៅចំណតផែកុងតឺន័រ LM១៧
- ពិនិត្យ និងពិភាក្សាការស្នើសុំបង្កើតសេវាកម្មដឹកជញ្ជូនកុងតឺន័រតាមរថយន្ត ដោយស្នើសុំទិញកុងតឺន័រចំនួន ៦ គ្រឿង ក្នុងឆ្នាំ២០១៥ នេះ សម្រាប់បម្រើសេវាកម្មនេះ ជាដំណាក់កាលសាកល្បង
- ពិនិត្យ និងពិភាក្សាលើការស្នើសុំកែប្រែលើការគិតតម្លៃស្តុកកុងតឺន័រត្រជាក់រវាង ក.ស.ភ. និងក្រុមហ៊ុន PCF
- ពិនិត្យ និងពិភាក្សាលើការស្នើសុំចំណាយប្រាក់លើការជួសជុល និងប្តូរដំបូលអគារនៅអតីតប្លុកយានដ្ឋានស៊ីត្រូអែន និងស្នើសុំបញ្ចូលជាទ្រព្យសម្បត្តិរបស់ ក.ស.ភ.។

## ៣.២. ការកំណត់ទិសដៅសម្រាប់ឆ្នាំបន្ទាប់

ទស្សនវិស័យទៅអនាគត ក.ស.ភ. នឹងកំណត់ទិសដៅសម្រាប់អនុវត្តដែលរួមមាន៖

- ពង្រឹងការអភិវឌ្ឍធនធានមនុស្ស
- ជម្រុញការបង្កើតមជ្ឈមណ្ឌលភ័ស្តុភារកម្ម និងឃ្លាំងទំនើប
- ជម្រុញការបង្កើតតំបន់គាំទ្រកំពង់ផែ
- ជម្រុញការបង្កើតសេវាកម្ម Line ទៅកាន់ផែមេដទៃក្រៅពីផែកាយម៉េប
- បន្តផ្តោតការយកចិត្តទុកដាក់លើការបំពាក់នូវគ្រឿងចក្រលើកដាក់ទំនើបៗ ដើម្បីពង្រឹងសមត្ថភាពលើកដាក់របស់ ក.ស.ភ. ក្នុងការទទួលកំណើនកុងតឺន័រឆ្លងកាត់ជារៀងរាល់ឆ្នាំ
- សម្រួល និងធានាប្រសិទ្ធភាពក្នុងការផ្ទុក និងផ្ទេរទំនិញរាយប្រកបដោយទំនុកចិត្ត
- បង្កើនសមត្ថភាពលើកដាក់ទំនិញចាក់ធារ និងបង្កើតចំណតផែពិសេសសម្រាប់ទំនិញចាក់ធារដែលតម្រូវតាមកំណើននៃតម្រូវការលើកដាក់ទំនិញចាក់ធារក្នុងរយៈពេលវែង
- ធ្វើទំនើបកម្ម និងពង្រីកចំណតផែអ្នកដំណើរ និងទេសចរ

- បង្កើនសមត្ថភាពលើកដាក់ទំនិញ លើកដាក់ផលិតផលកសិកម្ម និងការដឹកជញ្ជូនទំនិញឱ្យមានប្រសិទ្ធភាព រវាងខេត្តនានានៅតាមភូមិភាគឦសាន និងមកភ្នំពេញតាមរយៈទន្លេមេគង្គ
- បូមស្តារ និងថែទាំផ្លូវនាវាចរណ៍ពីចំណតផែពហុបំណង TS៣ ដល់ព្រំដែនប្រទេសកម្ពុជា-វៀតណាម ដើម្បីបង្កើនលទ្ធភាពឱ្យនាវាអាចដឹកកុងតឺន័របានកាន់តែច្រើន។

កំពង់ផែស្វយ័តភ្នំពេញ មានជំនឿចិត្ត និងគោលជំហរយ៉ាងមុតមាំក្នុងការអនុវត្តការងារប្រចាំថ្ងៃ និងប្រតិបត្តិការនៅតាមបណ្តាចំណតផែ។ ដើម្បីបង្កើននូវទំនុកចិត្ត និងប្រសិទ្ធភាពការងារឱ្យកាន់តែល្អប្រសើរ ក.ស.ភ. នឹងខិតខំពង្រឹងសមត្ថភាពក្នុងការប្រកបអាជីវកម្ម និងផ្តល់សេវាកំពង់ផែឱ្យកាន់តែមានលក្ខណៈទំនើបប្រកបដោយស្តង់ដារជូនដល់អតិថិជន។ ក.ស.ភ. រំពឹងថា នៅបណ្តាឆ្នាំខាងមុខ ចំណូលនឹងមានការកើនឡើងជាលំដាប់គឺ មិនតិចជាង ១៥% ឡើយ។

ក.ស.ភ. សូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះក្រសួងអាណាព្យាបាលទាំងពីរ គឺក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងគណៈកម្មការមូលបត្រកម្ពុជា ទីផ្សារមូលបត្រកម្ពុជា និងភាគហ៊ុនិកទាំងអស់ ដែលបានផ្តល់សេចក្តីទុកចិត្ត និងគាំទ្រដល់ក.ស.ភ. រហូតមក។

ក.ស.ភ. សូមសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ ចំពោះការខិតខំប្រឹងប្រែងចូលរួមបំពេញការងារយ៉ាងសកម្មរបស់បុគ្គលិកគ្រប់ជាន់ថ្នាក់ តាមតួនាទី និងភារកិច្ច រហូតសម្រេចបាននូវលទ្ធផលយ៉ាងល្អប្រសើរ និងគួរជាទីមោទនភាព។

រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ២០១៦

**ប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយក**

ហ៊ី-បាវី

# មាតិកា


ទស្សនវិស័យ និងបេសកកម្ម ........ II

១. ព័ត៌មានហិរញ្ញវត្ថុសង្ខេប និងក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប ........ III

២. សមាសភាពក្រុមប្រឹក្សាភិបាល........ V

៣. សេចក្តីថ្លែងរបស់អគ្គនាយក និងជាប្រធានក្រុមប្រឹក្សាភិបាល ........ VI

ទំព័រ

**ផ្នែកទី ១ : ព័ត៌មានពាក់ព័ន្ធនឹងកំពង់ផែស្វយ័តភ្នំពេញ ........ ០១**

១- ព័ត៌មានទូទៅអំពីកំពង់ផែស្វយ័តភ្នំពេញ........ ០១

២- ដំណើរការធុរកិច្ចសង្ខេប ........ ០១

៣-ស្ថានភាពទីផ្សារ........ ០៥

៤- ស្ថានភាពប្រកួតប្រជែង........ ០៩

៥-ផែនការអនាគតសម្រាប់ឆ្នាំ២០១៦ ........ ១១

**ផ្នែកទី ២ : ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច........ ១៥**

១- លទ្ធផលប្រតិបត្តការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក ........ ១៥

២- ការប្រែប្រួលសំខាន់ៗពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ច........ ១៩

៣- រចនាសម្ព័ន្ធចំណូល ........ ១៩

**ផ្នែក ៣ : អភិបាលកិច្ចសាជីវកម្ម ........ ២០**

១- ភាគហ៊ុនិក ........ ២០

២- អង្គការលេខ ........ ២៤

៣- ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនានា ........ ២៥

៤- បុគ្គលិកជាន់ខ្ពស់........ ៣៦

៥- ការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់........ ៥៤

៦- លាភការ ឬប្រាក់បំណាច់ចំពោះអភិបាល និងបុគ្គលិកជាន់ខ្ពស់ ........ ៥៥

៧- ក្រមសីលធម៌សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់........ ៥៧

៨- សិទ្ធិភាគីពាក់ព័ន្ធ........ ៦២

**ផ្នែកទី ៤ : បញ្ជីរាយនាមភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធបោះឆ្នោតចំនួនច្រើនលើសលប់ និងភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន ........ ៦៣**

១- ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ ........ ៦៣

២- ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន ........ ៦៣

**ផ្នែកទី ៥ : ព័ត៌មានអំពីការជួញដូរមូលបត្ររបស់កំពង់ផែស្វយ័តភ្នំពេញ........ ៦៤**

១- ព័ត៌មានអំពីមូលបត្រកម្មសិទ្ធិ........ ៦៤

២- ថ្លៃ និងបរិមាណជួញដូរ........ ៦៤

**ផ្នែកទី ៦ : របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង ..............................៦៥**

**ផ្នែកទី៧ : របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្មដោយសវនករឯករាជ្យ ........................................៦៧**

**ផ្នែកទី៨ : ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ .................................................១២១**

១- ប្រតិបត្តិការជាមួយភាគហ៊ុនិក ..........................................................................................១២១

២- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬប្រតិបត្តិការសំខាន់ៗ ជាមួយបុគ្គលដែលអភិបាល ឬបុគ្គលិកជាន់ខ្ពស់មានផលប្រយោជន៍.........................................១២១

៣- ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់...១២១

៤- ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់កំពង់ផែស្វយ័តភ្នំពេញ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនហូលឌីងរបស់កំពង់ផែស្វយ័តភ្នំពេញ ដែលទំនាក់ទំនងរបស់បុគ្គលទាំងនោះកើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយដែលធ្វើឡើងដោយកំពង់ផែស្វយ័តភ្នំពេញ ...................................................................................១២១

៥- ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាលក្នុងរយៈពេល ០២ (ពីរ) ឆ្នាំចុងក្រោយ ..........................................................១២១

៦- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ ឬកម្រៃវិជ្ជាជីវៈ សម្រាប់សេវាដែលខ្លួនបានផ្តល់តាមរយៈក្រុមហ៊ុនណាមួយដល់កំពង់ផែស្វយ័តភ្នំពេញ ............១២២

៧- ប្រតិបត្តិការសំខាន់ៗជាមួយភាគីជាប់ពាក់ព័ន្ធផ្សេងទៀត ..........................................................១២២

**ផ្នែកទី ៩ : ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង ...................................................................១២៣**

១- ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ..........................................................................................................១២៣

២- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ .................................................................................១៣៩

៣-ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ...........................................................................១៤១

៤- ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ...................................................១៤១

៥- ផលប៉ះពាល់ពីអតិផរណា. .........................................................................................................១៤២

៦- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រដ្ឋាភិបាល ..........................................១៤២

**ផ្នែកទី ១០ : ស្ថិតិប្រចាំឆ្នាំសង្ខេបពីលទ្ធផលរបស់ ក.ស.ភ. ....................................................................១៤៤**

**ផ្នែកទី ១១ : ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន .........................................................១៤៥**

## ផ្នែកទី១ : ព័ត៌មានពាក់ព័ន្ធនឹងបុគ្គលបោះផ្សាយ

### ១- ព័ត៌មានទូទៅអំពីកំពង់ផែស្វយ័តភ្នំពេញ

ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ : **កំពង់ផែស្វយ័តភ្នំពេញ** ជាអក្សរឡាតាំង:**Phnom Penh Autonomous Port**
អក្សរកូដ : **KH1000040001**
អាសយដ្ឋាន : **អគារលេខ ៦៤៩ វិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**
លេខទូរស័ព្ទ : **+៨៥៥ (0) ២៣ ៤២៧ ៨០២** លេខទូរសារ : **+៨៥៥ (0) ២៣ ៤២៧ ៨០២**
គេហទំព័រ : **www.ppap.com.kh** អ៊ីម៉ែល : **ppapmpwt@online.com.kh**
លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម : **CO.៧១៧៤ Et/២០០៤** កាលបរិច្ឆេទ : **២៣/វិច្ឆិកា/២០០៤**
លេខអាជ្ញាបណ្ណអាជីវកម្ម : **០១២៧ ពណ.ចប** កាលបរិច្ឆេទ : **០៥/មករា/២០១៥**
សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន លេខ : **០៧៤/១៥/គ.ម.ក./ស.ស.រ**
ឈ្មោះបុគ្គលតំណាងបុគ្គលបោះផ្សាយ : **ឯកឧត្តម ហ៊ី បាវី**

### ២- ដំណើរការធុរកិច្ចសង្ខេប

កំពង់ផែស្វយ័តភ្នំពេញ គឺជាកំពង់ផែអន្តរជាតិមួយក្នុងចំណោមផែអន្តរជាតិទាំងពីររបស់ប្រទេសកម្ពុជា ដែលបម្រើឱ្យការនាំចូល នាំចេញកុងតឺន័រ និងទំនិញរាយ។ ដូចនេះ ក្នុងនាមជាប្រតិបត្តិករផែ និងអាជ្ញាធរផែ កំពង់ផែស្វយ័តភ្នំពេញកំពុងផ្តល់សេវាកម្មផែចម្បងៗ និងសេវាកម្មពាក់ព័ន្ធសំខាន់ៗដទៃទៀត ដែលជាដំណើរការធុរកិច្ចរបស់កំពង់ផែស្វយ័តភ្នំពេញ។

#### ក- ប្រតិបត្តិការក្នុងនាមជាប្រតិបត្តិករផែ

ក្នុងនាមជាប្រតិបត្តិករលើចំណតផែទាំង ០៤ អាជីវកម្មសំខាន់ៗរបស់ ក.ស.ភ. រួមមាន លើកដាក់ទំនិញ ការស្តុកទំនិញ ការច្រកនិងរើទំនិញ ការផ្ទេរនិងផ្ទុក និងការដឹកជញ្ជូនទំនិញកុងតឺន័រ សម្រាប់ការនាំចេញ និងនាំចូលទំនិញឆ្លងប្រទេស។ ចំណែកឯ ចំណតផែអ្នកដំណើរ និងទេសចរណ៍ TS១ ក៏ជាប្រភពចំណូលសំខាន់ដែលបានមកពីពន្ធនាវា និងថ្លៃចំណតអ្នកដំណើរ។

#### ខ- ប្រតិបត្តិការក្នុងនាមជាអាជ្ញាធរផែ

ក្នុងនាមជាអាជ្ញាធរផែ ក.ស.ភ. មានតួនាទីក្នុងការថែទាំផ្លូវនាវាចរណ៍ បំពាក់នូវឧបករណ៍ជំនួយដល់ការធ្វើនាវាចរណ៍ ដូចជាពោងសញ្ញា និងបង្គោលសញ្ញា សេវាកម្មកណ្តធារកិច្ច សេវាកម្មនាវាសណ្តោង សេវាកម្មចង/ដោះពួរនាវា រៀបចំការចូលចតនាវា និងថែរក្សាបរិស្ថានក្នុងមណ្ឌលអាជីវកម្មផែភ្នំពេញ។ ដូចនេះ តាមរយៈសកម្មភាពខាងលើ ក.ស.ភ. អាចបង្កើតចំណូលពន្ធនាវា ថ្លៃសេវាកម្មកណ្តធារកិច្ច ថ្លៃសេវាកម្មនាវាសណ្តោង និងថ្លៃសេវាកម្មចង/ដោះពួរនាវា។ល។

ក.ស.ភ. មានម៉ាស៊ីន និងគ្រឿងចក្របូមស្តារចំនួន ០២គ្រឿង ដែលត្រូវបានប្រើប្រាស់សម្រាប់បូមស្តារ និងថែទាំផ្លូវនាវាចរណ៍ ដើម្បីបង្កលក្ខណៈងាយស្រួលដល់នាវាចេញ-ចូលកំពង់ផែ។

យោងតាមប្រកាសលេខ ០០១ និង០០២ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ របស់ក្រសួងរ៉ែ និងថាមពល ក.ស.ភ. ទទួលបានការអនុញ្ញាតធ្វើការបូមស្តារនិងធ្វើអាជីវកម្មខ្សាច់។

ក្រៅពីអាជីវកម្មផែសំខាន់ៗ ក.ស.ភ. ក៏ទទួលបានចំណូលបន្ថែមផងដែរ តាមរយៈការប្រើប្រាស់

ទ្រព្យសកម្មរបស់ខ្លួន ដូចជា ការជួលអគារ ដីធ្លី និងទ្រព្យសម្បត្តិផ្សេងទៀត។

**គ- មណ្ឌលអាជីវកម្មផែ**

យោងតាមអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៩ មណ្ឌលអាជីវកម្មរបស់ ក.ស.ភ. មានប្រវែង ១៦០គីឡូម៉ែត្រ លាតសន្ធឹងពីខេត្តត្បូងឃ្មុំ (ចំណាតផែទន្លេបិទ UM២) ទៅដល់អ្នកលឿង ហើយក៏មានមុខងារជាអាជ្ញាធរគ្រប់គ្រងចំណាតផែឯកជននានា នៅក្នុងមណ្ឌលអាជីវកម្ម ដោយរាប់បញ្ចូលទាំងចំណតផែប្រេង និងចំណតផែទំនិញរាយដទៃទៀត។ ដោយឡែក ក.ស.ភ. គ្រប់គ្រង និងប្រតិបត្តិការដោយផ្ទាល់ទៅលើចំណតផែចម្បង ចំនួន ៤ ដែលរួមមាន៖

**គ.១. ចំណតផែកុងតឺន័រ LM១៧**

នៅដំណាក់កាលទី១ មានការសាងសង់ចំណតផែកុងតឺន័រ LM១៧ លើផ្ទៃដីទំហំ ១០ហិកតា នៃផ្ទៃដីសរុប ៣០ហិកតា ហើយត្រូវបានបើកឱ្យដំណើរការនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៣។ ក.ស.ភ. កំពុងប្រើប្រាស់ចំណតផែនេះ ធ្វើជាចំណតផែចម្បងសម្រាប់ទំនិញកុងតឺន័រ។ ចំណតផែនេះមានសមត្ថភាពលើកដាក់កុងតឺន័របាន ១៥០.០០០ TEUs ក្នុងមួយឆ្នាំ។ ចំណតផែកុងតឺន័រ LM១៧ មានស្ពានផែ ដែលមានបណ្តោយប្រវែង៣០០ម៉ែត្រ ទទឹង២២ម៉ែត្រ និងបំពាក់ដោយដងយោង TCC ចំនួន ៣គ្រឿង រថស្ទូច RTG ចំនួន ៤គ្រឿង គ្រឿងចក្រលើកដាក់លើទីលាន (Reach Stacker & Sky Stacker) ចំនួន ៥គ្រឿង។

| | |
|---|---|
| **អាសយដ្ឋាន** | ភូមិកណ្តាលលើ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល |
| **ទីតាំងចំណតផែ** | ស្ថិតនៅតាមដងទន្លេមេគង្គត្រើយខាងលិច ចម្ងាយ ២៥គីឡូម៉ែត្រ ពីទន្លេចតុមុខ ហើយស្ថិតក្នុងទីតាំងនៃរយៈទទឹងខាងជើង ១១°២៨' ២៣,៦" និង រយៈបណ្តោយខាងកើត ១០៥°០៨'៤៩,៨" |
| **ទំហំផ្ទៃដីសរុប** | ៣០១.០៧៩ម៉ែត្រការ៉េ |
| **ចំណតនាវា** | មាន ៣ ចំណត សម្រាប់នាវាចំណុះ ៥.០០០ DWT |
| **ទីតាំងបោះយុថ្កា** | ទីតាំងបោះយុថ្កា របស់ចំណតផែកុងតឺន័រ LM១៧ ស្ថិតក្នុងរយៈទទឹងខាងជើង ១១°២៨'២៨,១៩" និងរយៈបណ្តោយខាងកើត ១០៥°៩'២,៣២" ចន្លោះជម្រៅទឹកពី ៨ម៉ែត្រ ទៅ ១៧ម៉ែត្រ។ បាតទន្លេមានដីភក់ និងខ្សាច់ ហើយចរន្តទឹកមានកម្លាំងខ្លាំងនៅរដូវវស្សា។ |
| **រលក** | ផលប៉ះពាល់មានចាប់ពីខែកុម្ភៈ ដល់ ខែមេសា ដោយកម្ពស់រលកមានចាប់ពី ០,២០ម៉ែត្រ ដល់ ០,៤៥ម៉ែត្រ គិតនៅខែធ្នូ ឆ្នាំ២០១៤ |
| **ជម្រៅស៊ីទឹកនាវា** | ជម្រៅស៊ីទឹកនាវា ប្រែប្រួលពីកម្រិតអប្បបរមា ៤,៥ម៉ែត្រ ក្នុងខែ មីនា ដល់កម្រិតអតិបរមា ៥,៥ម៉ែត្រ ក្នុងខែកញ្ញា (ជម្រៅទឹកសម្រាប់ធ្វើនាវាចរមកចំណតផែកុងតឺន័រ LM១៧ គឺអាស្រ័យទៅលើជម្រៅទឹក នៅច្រកគូទីរ) |
| **ម៉ោងប្រតិបត្តិការ** | ៧/២៤ម៉ោង |
| **គ្រឿងចក្រលើកដាក់** | ដងយោង(Traveling Cargo Crane) រថស្ទូច(Rubber Tyred Gantry) គ្រឿងចក្រលើកដាក់លើទីលាន (Reach Stacker & Sky Stacker) |

### គ.២. ចំណតផែពហុបំណង TS៣

នៅមុនពេលស្ថាបនាចំណតផែកុងតឺន័រ LM១៧ ចំណតផែពហុបំណង TS៣ គឺជាចំណតផែចម្បងសម្រាប់ទទួលទំនិញរាយ និងទំនិញកុងតឺន័រឆ្លងកាត់។ ដោយសារសមត្ថភាពពង្រីកទីលានចំណតផែពហុបំណង TS៣ នៅមានកម្រិត ដើម្បីទទួលកំណើនចរាចរកុងតឺន័រប្រចាំឆ្នាំ ក.ស.ភ. បានវិនិយោគលើការអភិវឌ្ឍចំណតផែកុងតឺន័រ LM១៧។ ចាប់តាំងពីចំណតផែកុងតឺន័រ LM១៧នេះ ត្រូវបានស្ថាបនារួចរាល់ ចំណតផែ TS៣ ត្រូវបានក្លាយទៅជាចំណតផែពហុបំណង សម្រាប់បម្រើក្នុងការលើកដាក់ទំនិញរាយ កុងតឺន័រ និងប្រើជាចំណតផែអ្នកដំណើរ និងទេសចរ។

| | |
|---|---|
| **អាសយដ្ឋាន** | អគារលេខ ៦៤៩ វិថីព្រះស៊ីសុវត្ថិ (ផ្លូវលេខ១០១) សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| **ទីតាំងចំណតផែ** | ស្ថិតនៅតាមដងទន្លេសាប ត្រើយខាងលិច ចម្ងាយ ៣,២គីឡូម៉ែត្រ ពីទន្លេចតុមុខ ហើយស្ថិតក្នុងទីតាំងនៃរយៈទទឹងខាងជើង ១១° ៣៤'៥៩,៦៨" និងរយៈបណ្តោយខាងកើត ១០៤°៥៥' ១៧,៤១" |
| **ទំហំផ្ទៃដីសរុប**<br>**ទំហំផ្ទៃដីចុះបញ្ជី*** | ៨៨.៤៣៨,៧៦ ម៉ែត្រការ៉េ<br>៣២.៨៥៤ ម៉ែត្រការ៉េ |
| **ចំណតនាវា** | មាន ៣ ចំណត សម្រាប់នាវាចំណុះ ៥.០០០ DWT |
| **ទីតាំងបោះយុថ្កា** | ទីតាំងអាចបោះយុថ្កាបាន គឺនៅទន្លេសាបខាងមុខចំណតផែ និងមួយកន្លែងទៀតនៅទន្លេចតុមុខ ដែលស្ថិតក្នុងរយៈទទឹង ខាងជើង ១១°៣៣'៤៦,៩៨" និងរយៈបណ្តោយខាងកើត ១០៤°៥៦' ៣៤,៥៧" មានជម្រៅទឹកពី ៥ម៉ែត្រ ទៅ១៥ម៉ែត្រ។ បាតទន្លេមានដីភក់ និងខ្សាច់ ដែលអាចបោះយុថ្កាជាប់បានល្អ។ |
| **រលក** | ផលប៉ះពាល់ មានចាប់ពីខែកុម្ភៈ ដល់ខែមេសា ដោយកម្ពស់រលកមានចាប់ពី ០,១០ម៉ែត្រ ដល់ ០,៣៥ម៉ែត្រ គិតនៅខែធ្នូ ឆ្នាំ២០១៤ |
| **ជម្រៅស៊ីទឹកនាវា** | ជម្រៅស៊ីទឹកនាវា ប្រែប្រួលពីកម្រិតអប្បបរមា ៤,៥ម៉ែត្រ ក្នុងខែមីនា ដល់កម្រិតអតិបរមា៥,៥ម៉ែត្រ ក្នុងខែកញ្ញា (ជម្រៅទឹកសម្រាប់ធ្វើនាវាចរមកចំណតផែពហុបំណង TS៣ អាស្រ័យទៅលើជម្រៅ ទឹក នៅច្រកតួទីវ) |
| **ម៉ោងប្រតិបត្តិការ** | ៧/២៤ ម៉ោង |
| **គ្រឿងចក្រលើកដាក់** | ដងយោងចល័ត (Mobile crane និង Crawler crane) ដងយោង បណ្តែត (Floating crane) |

<u>**សម្គាល់៖**</u> *ទំហំដីខុសគ្នារវាងទំហំផ្ទៃដីសរុប និងទំហំផ្ទៃដីចុះបញ្ជី គឺដោយសារដី ដែលនៅជាប់នឹងផ្លូវ និងទន្លេមិនអាចទទួលបានប្លង់កម្មសិទ្ធិ។

### គ.៣ ចំណតផែទន្លេបិទ UM២

ក.ស.ភ. បានចុះហត្ថលេខាលើកិច្ចព្រមព្រៀង នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ ជាមួយក្រុមហ៊ុន មៀង លីហេង អ៊ិនវេសមិន ដើម្បីធ្វើកិច្ចសហប្រតិបត្តិការ និងអភិវឌ្ឍចំណតផែទន្លេបិទ។ កិច្ចព្រមព្រៀង នេះ មានសុពលភាពរយៈពេល ២០ឆ្នាំ គិតចាប់ពីថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ រហូតដល់ថ្ងៃទី២១ ខែតុលា ឆ្នាំ២០៣២។ យោងតាមកិច្ចព្រមព្រៀង នេះ ក.ស.ភ. ទទួលខុសត្រូវលើសេវាកម្មលើកដាក់ក្រោមដង យោង រីឯ ដៃគូឯកជនទទួលខុសត្រូវលើការផ្តល់សេវាកម្មស្តុកទំនិញ។ ចំណូលពីថ្លៃឈ្នួលទាំងនេះ ត្រូវ គិតដាច់ដោយឡែកពីគ្នា ផ្អែកលើសេវាកម្ម ដែលផ្តល់ដោយភាគីនីមួយៗ។ ក.ស.ភ. មិនទាន់ទទួលបាន សិទ្ធិជាម្ចាស់គ្រប់គ្រងទីតាំងដីនោះនៅឡើយទេ ប៉ុន្តែ ក.ស.ភ. បានសាងសង់ផែបណ្តែត និងបំពាក់ដង យោងចល័ត និងរថចូក។ គោលបំណងសំខាន់ក្នុងការបង្កើតចំណតផែនេះ គឺដើម្បីធ្វើជាកន្លែងប្រមូលផ្តុំ កសិផល និងលើកកម្ពស់ការដឹកជញ្ជូនតាមផ្លូវទឹក។ បច្ចុប្បន្ន ដំឡូងមី ជាប្រភេទផលិតផលសំខាន់ ដែល ត្រូវបាននាំចេញតាមចំណតផែនេះ។

| | |
|---|---|
| **អាសយដ្ឋាន** | ភូមិដូនម៉ៅលើ ឃុំទន្លេបិទ ស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ |
| **ទីតាំងចំណតផែ** | ចំណតផែទន្លេបិទUM២ ស្ថិតនៅតាមដងទន្លេមេគង្គត្រើយខាងកើត ចម្ងាយ ១០៣ គីឡូម៉ែត្រ ពីទន្លេចតុមុខ ហើយស្ថិតក្នុងទីតាំងនៃរយៈទទឹងខាងជើង ១១°៥៧'៤៧,៧៣" និងរយៈបណ្តោយខាងកើត ១០៥°២៨' ៣៣,១៣" |
| **ទំហំផ្ទៃដី** | ទំហំតូច ចំណតនៅតាមច្រាំងទន្លេប្រវែង ១០០ម៉ែត្រ (ដោយមានបំពាក់ប៉ង់តុង ដងយោងចល័ត និងកុងវ៉ូយ័រ) |
| **ចំណតនាវា** | ចំនួន ១ (ប៉ង់តុងបណ្តែតទំហំ៦ម៉ែត្រ x ២៨ម៉ែត្រ) |
| **ទីតាំងបោះយុថ្កា** | ទីតាំង ដែលអាចបោះយុថ្កានៅចំណតផែទន្លេបិទ UM២ ស្ថិតនៅក្នុងរយៈទទឹងខាងជើង ១១°៥៨'៤៣,៨១" និងរយៈបណ្តោយខាងកើត ១០៥°២៨' ៩,៥៨" ក្នុងចន្លោះជម្រៅទឹកពី ៦ម៉ែត្រ ទៅ ២០ម៉ែត្រ។ នារដូវវស្សា នៅបាតទន្លេមានដីភក់ និងខ្សាច់ ហើយមានចរន្តទឹកមានកម្លាំងខ្លាំង។ |
| **រលក** | មិនមានផលប៉ះពាល់ |
| **ជម្រៅស៊ីទឹកនាវា** | ជម្រៅស៊ីទឹកនាវា ប្រែប្រួលពីកម្រិតអប្បបរមា ៤,៥ម៉ែត្រ ក្នុងខែមីនា ដល់កម្រិតអតិបរមា ៥,៥ម៉ែត្រ ក្នុងខែកញ្ញា (ជម្រៅទឹកសម្រាប់ធ្វើនាវាចរមកចំណតផែទន្លេបិទ គឺអាស្រ័យទៅលើជម្រៅទឹក នៅច្រកគូទីវ) |
| **ជម្រៅទឹកផ្លូវនាវាចរ** | ចាប់ពីទន្លេចតុមុខទៅដល់ខេត្តត្បូងឃ្មុំ តាមប្រឡាយស្តៅមានទទឹង៦០ម៉ែត្រនិងបណ្តោយ ៣៥០០ម៉ែត្រ។ ជម្រៅទឹក មានជម្រៅ ៥ម៉ែត្រ ក្នុងរដូវប្រាំង (ដោយមានការថែទាំទៀងទាត់) |
| **ម៉ោងប្រតិបត្តិការ** | ៧/២៤ ម៉ោង |
| **គ្រឿងចក្រលើកដាក់** | ដងយោងចល័ត (Mobile crane) ដងយោងបណ្តែត (Floating crane) និងកុងវ៉ូយ័រ (Conveyer) |

### គ.៤. ចំណតអ្នកដំណើរ និងទេសចរ TS១

ចំណតផែអ្នកដំណើរ និងទេសចរ TS១ ជាចំណតផែអ្នកដំណើរចម្បងរបស់ក.ស.ភ.។ ចំណតផែនេះត្រូវបានប្រើប្រាស់ ដើម្បីធ្វើជាចំណតផែអ្នកដំណើរក្នុងស្រុក ក៏ដូចជាទៅកំពង់ផែនៃប្រទេសវៀតណាម។ ក្នុងឆ្នាំ២០១៤ ចំនួនអ្នកដំណើរឆ្លងកាត់ចំណតផែអ្នកដំណើរ និងទេសចរ TS១ មានចំនួន ៩៧.៨៦១នាក់។ តួលេខនេះ រាប់បញ្ចូលទាំងអ្នកដំណើរ ពីភ្នំពេញទៅចំណតផែក្នុងស្រុកនានា ពីភ្នំពេញទៅប្រទេសវៀតណាម ព្រមទាំងអ្នកទេសចរ ដែលធ្វើដំណើរឆ្លងកាត់តាមដងទន្លេមេគង្គ ក្បែររាជធានីភ្នំពេញ។

| | |
|---|---|
| **អាសយដ្ឋាន** | វិថីព្រះស៊ីសុវត្ថិ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ |
| **ទីតាំងចំណតផែ** | ចំណតអ្នកដំណើរ និងទេសចរ TS១ ស្ថិតនៅតាមដងទន្លេសាបត្រើយខាងស្តាំចម្ងាយ ០២គីឡូម៉ែត្រ ពីទន្លេចតុមុខ ហើយស្ថិតក្នុងទីតាំង រយៈទទឹងខាងជើង ១១°៣៤'៣២,៩៥" និងរយៈបណ្តោយខាងកើត ១០៤°៥៥'៣៦,៨៨។ |
| **ទំហំផ្ទៃដីសរុប**<br>**ទំហំផ្ទៃដីចុះបញ្ជី*** | ១.៦៩៩ ម៉ែត្រការ៉េ<br>៦.៦៧៦ ម៉ែត្រការ៉េ |
| **ចំណតនាវា** | មានប៉ង់តុងចំនួន ០២គ្រឿង |
| **ទីតាំងបោះយុថ្កា** | ទីតាំងអាចបោះយុថ្កាបាន គឺនៅខាងមុខចំណតផែ តំបន់ទន្លេសាប និងមួយកន្លែងទៀតនៅតំបន់ទន្លេចតុមុខ ដែលស្ថិតក្នុងរយៈទទឹងខាងជើង ១១°៣៣'៤៦,៩៨" និងរយៈបណ្តោយខាងកើត ១០៥°៥៦' ៣៤,៥៧" ចន្លោះជម្រៅទឹកពី ៥ម៉ែត្រ ទៅ ១៥ម៉ែត្រ។ នារដូវវស្សា បាតទន្លេមានដីភក់ និងខ្សាច់ ដែលជាផ្ទៃមានកម្លាំងទប់ជាប់ល្អ ហើយជម្រើសទីតាំងទី២ ដើម្បីបោះយុថ្កាមានចរន្តទឹកខ្លាំង។ |
| **រលក** | ផលប៉ះពាល់មានចាប់ពីខែកុម្ភៈ ដល់ខែមេសា ដោយកម្ពស់រលកមានចាប់ពី ០,១ម៉ែត្រ ដល់ ០,៣៥ម៉ែត្រ គិតនៅខែធ្នូ ឆ្នាំ២០១៤ |
| **ជម្រៅស៊ីទឹក** | ជម្រៅស៊ីទឹកប្រែប្រួលពី ៤,៥ម៉ែត្រ ក្នុងខែមីនា ដល់ ៥,៥ម៉ែត្រ ក្នុងខែកញ្ញា (ជម្រៅស៊ីទឹកសម្រាប់នាវាចរាចរមកចំណតផែពហុបំណង TS ៣ គឺអាស្រ័យទៅលើជម្រៅស៊ីទឹក នៅច្រកគូទីវ) |
| **ប្រតិបត្តិការ** | ៧/២៤ម៉ោង |
| **គ្រឿងចក្រលើកដាក់** | មានប៉ង់តុងចំនួន ០២គ្រឿង ដោយមានស្ពានតភ្ជាប់ទៅច្រាំងទន្លេ |

<u>សម្គាល់៖</u> * ទំហំដីខុសគ្នារវាងទំហំផ្ទៃដីសរុប និងទំហំផ្ទៃដីចុះបញ្ជី គឺដោយសារ ដីដែលនៅជាប់នឹងផ្លូវ និងទន្លេមិនអាចទទួលបានប្លង់កម្មសិទ្ធិ។

## ៣- ស្ថានភាពទីផ្សារ

ស្ថានភាពទីផ្សាររបស់ ក.ស.ភ. ពឹងផ្អែកសំខាន់ទៅលើទីផ្សារក្នុងប្រទេស និងទីផ្សារក្រៅប្រទេស។ ជាក់ស្តែង ទីផ្សារក្នុងប្រទេសពឹងផ្អែកសំខាន់ទៅលើការនាំចូលទំនិញក្នុងការបំពេញតម្រូវការចាំបាច់របស់ប្រជាពលរដ្ឋនៅក្នុងប្រទេស។ កំណើននៃតម្រូវការនេះបានកើនឡើងដោយសារអត្រាកំណើនរបស់ប្រជាជនដែលមានអត្រា ១,៦០% (ផ្អែកតាមរបាយការណ៍របស់ធនាគារពិភពលោកនៅឆ្នាំ២០១៤)។

ដោយឡែក ផលិតផលសរុបក្នុងស្រុកសម្រាប់មនុស្សម្នាក់ បានកើនឡើងដល់១.០៩៤,៦០ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៤ ដែលកំណើននេះកំពុងជម្រុញឲ្យមានអំណាចទិញជូរប្រចាំថ្ងៃ។ ជាមួយគ្នានេះដែរ ការកើនឡើងនៃតម្រូវការទំនិញនាំចូល ជាកត្តាជម្រុញកំណើននៃការដឹកជញ្ជូនទំនិញឆ្លងកាត់ ក.ស.ភ. ផងដែរ។

ផ្អែកតាមរបាយការណ៍របស់នាយកដ្ឋានផែនការ/ទីផ្សារ ប្រទេសកម្ពុជាបាននាំចូលនូវផលិតផលសម្រាប់បំពេញតម្រូវការក្នុងស្រុកជាច្រើនតាមរយៈ ក.ស.ភ. រួមមាន សម្ភារសំណង់ វត្ថុធាតុដើមសម្រាប់វិស័យវាយនភណ្ឌ ផលិតផលប្រើប្រាស់ទូទៅ សម្ភារកសិកម្ម ថ្នាំពេទ្យ ម្ហូបអាហារ និងភេសជ្ជៈ ។ល។ ដូចមានបង្ហាញនៅក្នុងក្រាហ្វិកដូចខាងក្រោម៖

**ក្រាហ្វិកលេខ១៖**




*(ប្រភពរបាយការណ៍ពីនាយកដ្ឋានផែនការ/ទីផ្សាររបស់ ក.ស.ភ.)*

**ក្រាហ្វិកលេខ២៖**




*(ប្រភពមកពី របាយការណ៍ប្រចាំឆ្នាំរបស់ធនាគារពិភពលោក)*

តាមរយៈការពិនិត្យលើក្រាហ្វិកលេខ១ បានបង្ហាញឲ្យឃើញថា កំណើននៃតម្រូវការរបស់ប្រជាពលរដ្ឋកម្ពុជា គឺជាប្រភពនៃកំណើនទីផ្សារក្នុងប្រទេសដែលបានជម្រុញឲ្យ ក.ស.ភ. នៅតែមានភាពចាំបាច់ និងរឹងមាំ ខណៈពេលដែល ក.ស.ភ. គឺជាចំណតផែអន្តរជាតិតាមដងទន្លេតែមួយគត់។

ម្យ៉ាងវិញទៀត ផលិតផលសរុបក្នុងស្រុកសម្រាប់មនុស្សម្នាក់បានកើនឡើងពី ១.០២៤ ដុល្លារអាមេរិក/ម្នាក់ ក្នុងឆ្នាំ២០១៣ ទៅដល់ ១.០៩៤ ដុល្លារអាមេរិក/ម្នាក់ ក្នុងឆ្នាំ២០១៤ ដែលអត្រាកំណើននេះជាកត្តាដែលបានជម្រុញឲ្យ ប្រជាពលរដ្ឋកម្ពុជាមានលទ្ធភាពទិញដូរនៅលើទីផ្សារកាន់តែខ្លាំង ខណៈពេលដែលអត្រាអតិផរណាពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៤ ជាមធ្យមគឺ៣,៨% (ផ្អែកលើរបាយការប្រចាំឆ្នាំរបស់ធនាគារពិភពលោក)។

ដោយឡែកចំពោះទីផ្សារនាំចេញ ប្រទេសកម្ពុជាក៏ជាប្រទេសមួយដែលបាន និងកំពុងផលិតនូវផលិតផលជាច្រើន សម្រាប់តម្រូវការទីផ្សារនៅក្រៅប្រទេស។ ផលិតផលសំខាន់ៗដែលបានធ្វើការនាំចេញតាមរយៈ ក.ស.ភ. រួមមានវាយនភណ្ឌ (៥២%) និងអង្ករ (៣៨%) ដូចមានបង្ហាញនៅក្នុងក្រាហ្វិកខាងក្រោម។

**ក្រាហ្វិកលេខ៣៖**




*(ប្រភពរបាយការណ៍ពីនាយកដ្ឋានផែនការ/ទីផ្សាររបស់ ក.ស.ភ.)*

**ក្រាហ្វិកលេខ៤៖**







*(ប្រភពរបាយការណ៍ពីនាយកដ្ឋានផែនការ/ទីផ្សាររបស់ ក.ស.ភ.)*

**<u>ក្រាហ្វិកលេខ៥៖</u>**




*(ប្រភពមកពីរបាយការណ៍ប្រចាំឆ្នាំរបស់ធនាគារពិភពលោក)*

តាមរយៈក្រាហ្វិកលេខ៤ បង្ហាញឲ្យឃើញថា សហរដ្ឋអាមេរិក និងប្រទេសចិន គឺជាទិសដៅចម្បងសម្រាប់ផលិតផលដែលបានធ្វើការនាំចេញតាមរយៈ ក.ស.ភ. ដោយក្នុងនោះ នៅឆ្នាំ២០១៥ ការនាំចេញទៅកាន់ប្រទេសចិនមានចំនួន ៣៤% និងសហរដ្ឋអាមេរិកមានចំនួន ២២% (ផ្អែកលើរបាយការណ៍របស់នាយកដ្ឋានផែនការ/ទីផ្សារ)។ ក្រាហ្វិកលេខ៥ បង្ហាញអំពីអត្រាកំណើននៃផលិតផលក្នុងស្រុកសរុប ដែលមានចំនួន ៧,១% ក្នុងឆ្នាំ២០១៤។ អត្រាកំណើនគួរឲ្យកត់សម្គាល់នេះ បានជម្រុញឲ្យអត្រានៃការនាំចេញកើនឡើងផងដែរ ស្របពេលដែល ក.ស.ភ. កំពុងដើរតួនាទីសំខាន់សម្រាប់ធ្វើការនាំចេញនូវផលិតផលកសិកម្ម និងផលិតផលវាយនភណ្ឌ។

ជារួម បើពិនិត្យមើលលើស្ថិតិរបស់នាយកដ្ឋានផែនការ/ទីផ្សារ ចំពោះកុងតឺន័រឆ្លងកាត់ ក.ស.ភ. បានបង្ហាញតួលេខដូចខាងក្រោម៖

**<u>ក្រាហ្វិកលេខ៦៖</u>**




*(ប្រភពមកពីរបាយការណ៍នាយកដ្ឋានផែនការ/ទីផ្សារ)*

ក្រាហ្វិកលេខ៦ខាងលើ បង្ហាញឲ្យឃើញថា កំណើនកុងតឺន័រឆ្លងកាត់ ក.ស.ភ. ជាមធ្យមមានចំនួន ២១% ដោយគិតចាប់ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៤ និងឆ្នាំ២០១៥ មានកំណើន ៨,៣៥% បើធៀបទៅនឹងឆ្នាំ២០១៤។ អត្រាកំណើននៅឆ្នាំ២០១៥ បានកើនឡើងត្រឹមតែ ៨,៣៥% ដោយសារការថយចុះទាបនៃកំណើនសេដ្ឋកិច្ចនៅអ៊ឺរ៉ុប និងប្រទេសចិន។ បន្ថែមលើនេះ ការកកស្ទះនៃកំពង់ផែនៅភាគខាងលិចនៃសហរដ្ឋអាមេរិចនៅចុងឆ្នាំ២០១៤ និងដើមឆ្នាំ២០១៥ ក៏បានរួមចំណែកជម្រុញឲ្យកំណើននៃបរិមាណកុងតឺន័រឆ្លងកាត់ ក.ស.ភ. ថយចុះផងដែរ ដោយហេតុថា ក្រុមហ៊ុនដឹកជញ្ជូនកុងតឺន័រ បានបង្វែរការដឹកជញ្ជូនកុងតឺន័រ ទៅភ្ជាប់នឹងកំពង់ផែនៅភាគខាងកើតនៃសហរដ្ឋអាមេរិចវិញ ដែលខ្សែរដឹកជញ្ជូននេះពុំបានឆ្លងកាត់ ក.ស.ភ. ឡើយ។ ដោយឡែកស្ថានភាពនៃការកកស្ទះនៅកំពង់ផែនៃភាគខាងលិចនៃសហរដ្ឋអាមេរិច បានត្រឡប់មករកស្ថានភាពធម្មតាវិញចាប់ពីពាក់កណ្តាលឆ្នាំ២០១៥។ មួយវិញទៀតក្រុមហ៊ុនដឹកជញ្ជូនកុងតឺន័រធំៗបាន និងកំពុងសិក្សារបង្កើតខ្សែរដឹកជញ្ជូនតភ្ជាប់ពីកំពង់ផែកាយម៉េប នៃប្រទេសវៀតណាម ទៅកាន់កំពង់ផែនៅភាគខាងកើតនៃសហរដ្ឋអាមេរិច។ ដូចនេះអត្រាកំណើននៃបរិមាណកុងតឺន័រឆ្លង ក.ស.ភ. អាចនឹងវិលត្រឡប់ទៅរកស្ថានភាពកំណើនដូចដើមវិញ។

## ៤- ស្ថានភាពប្រកួតប្រជែង

ក.ស.ភ. គឺជាចំណតផែអន្តរជាតិតាមដងទន្លេតែមួយគត់ក្នុងការផ្តល់សេវាកម្មចំណតនាវា និងការលើកដាក់ទំនិញរាយ និងទំនិញជាកុងតឺន័រជូនអតិថិជន។ ចំនួនកុងតឺន័រឆ្លងកាត់ ក.ស.ភ. មានអត្រាកំណើន ៨,៣៥% ក្នុងឆ្នាំ២០១៥ បើធៀបទៅនឹងឆ្នាំ២០១៤។ ប្រសិនបើពិនិត្យទៅលើស្ថានភាពដៃគូប្រកួតប្រជែង កំពង់ផែស្វយ័តភ្នំពេញ នៅតែដើរតួនាទីសំខាន់ និងរឹងមាំបំផុតក្នុងវិស័យកំពង់ផែដែលជាច្រកសំខាន់សម្រាប់ការដឹកជញ្ជូនទំនិញឆ្លងកាត់តែមួយគត់នៅតាមដងទន្លេ និងដោយផ្អែកលើហេតុផលសំខាន់ៗដូចខាងក្រោម៖

- ទីតាំងរបស់ ក.ស.ភ. ស្ថិតនៅក្នុង និងជិតទីក្រុងដែលជាកន្លែងមួយប្រមូលផ្តុំដោយអ្នកប្រើប្រាស់ផ្ទាល់ និងប្រយោល និងជាកន្លែងឧស្សាហកម្ម ផលិតកម្ម រោងចក្រ ឃ្លាំង និងតំបន់ឧស្សាហកម្មផ្សេងៗជាច្រើនទៀត
- រាជរដ្ឋាភិបាលកម្ពុជា បានកំពុងជម្រុញឲ្យមានការនាំចេញផលិតផលកសិកម្មពីប្រទេសកម្ពុជាទៅកាន់ប្រទេសដទៃទៀត ស្របពេលដែល ក.ស.ភ. មានចំណតផែតូចៗនៅតាមដងទន្លេក្នុងការប្រមូលផលិតផលកសិកម្មដើម្បីធ្វើការនាំចេញ
- ក.ស.ភ. ផ្តល់តម្លៃអនុគ្រោះក្នុងការគិតថ្លៃសេវាកម្មលើកដាក់កុងតឺន័រជាប្រភេទទំនិញកសិកម្មពី ៥៧,១០ ដុល្លារអាមេរិក មកត្រឹម ៣៩,៦០ ដុល្លារអាមេរិក ក្នុងមួយទូកុងតឺន័រ ២០ហ្វីត និងការអនុគ្រោះដល់ការស្តុកកុងតឺន័រជាប្រភេទទំនិញកសិកម្មនៅចំណតផែកុងតឺន័រ LM១៧ ពីរយៈពេល ៥ថ្ងៃ រហូតដល់ ១៨ថ្ងៃ សម្រាប់ការនាំចេញ
- ការដឹកជញ្ជូនទំនិញឆ្លងកាត់ពីកំពង់ផែស្វយ័តភ្នំពេញទៅប្រទេសដទៃទៀត ជាពិសេសការដឹកជញ្ជូនទៅកាន់ប្រទេសចិន និងសហរដ្ឋអាមេរិក ចំណាយថ្លៃទាប និងរយៈពេលបីថ្ងៃខ្លីជាងបើធៀបនឹងការដឹកជញ្ជូនតាមកំពង់ផែស្វយ័តក្រុងព្រះសីហនុ បើយោងតាមការសិក្សារបស់គណៈកម្មការទន្លេមេគង្គ (MRC)។ ដោយសារការដឹកជញ្ជូនពី ក.ស.ភ. ទៅកាន់ប្រទេសដទៃគ្រាន់តែធ្វើការផ្ទេរទំនិញពីនាវាតូចទៅកាន់នាវាធំនៅកំពង់ផែមេកាយម៉េប (Cai Mep Hub

Port)។ លើសពីនេះ ការនាំចូលទំនិញមកវិញក៏ដូចគ្នាផងដែរ ដោយធ្វើការផ្ទេរទំនិញនៅកំពង់ផែមេកាយម៉េបដូចគ្នា

- ការគ្រប់គ្រងនៅ ក.ស.ភ. មានគោលដៅ និងគោលការណ៍ច្បាស់លាស់ ដែលស៊ីសង្វាក់ជាមួយនឹងទីផ្សារ និងតម្រូវការរបស់អតិថិជន
- តម្លៃសេវាកម្មរបស់ ក.ស.ភ. មានភាពបត់បែនទៅតាមតម្លៃទីផ្សារ ដែលផ្តល់ឱកាស និងអំណោយផលដល់ដៃគូធ្វើអាជីវកម្ម ដើម្បីមានលទ្ធភាពធ្វើការប្រកួតប្រជែងនៅលើទីផ្សារ និងក្នុងគោលបំណងដើម្បីទាក់ទាញទំនិញឆ្លងកាត់ ក.ស.ភ. ឲ្យបានច្រើន។

ទោះបីជាអត្រាអតិផរណាប្រចាំឆ្នាំរបស់កម្ពុជាជាមធ្យម ៥,១៤% ប៉ុន្តែ ក.ស.ភ. នៅតែអាចអនុវត្ត និងផ្តល់ការអនុគ្រោះបន្ថែមតាមតារាងតម្លៃរបស់ ក.ស.ភ.។

ក.ស.ភ. មានចំណតផែតូចៗជាច្រើននៅតាមដងទន្លេ និងនៅចំណុចកណ្តាលនៃទីក្រុងភ្នំពេញ ដែលទីតាំងទាំងនេះ ផ្តល់ជម្រើសដល់អតិថិជនក្នុងការដឹកជញ្ជូនទំនិញឆ្លងកាត់ ក៏ដូចជាការលើកដាក់ជញ្ជូនទំនិញរបស់ខ្លួន។ ផ្អែកតាមស្ថិតិរបស់នាយកដ្ឋានផែនការ និងស្ថិតិរបស់កំពង់ផែស្វយ័តក្រុងព្រះសីហនុ បានបង្ហាញឲ្យឃើញថាចំនួនកុងតឺន័រឆ្លងកាត់ កំពង់ផែស្វយ័តក្រុងព្រះសីហនុ បានកើនឡើង ១៥% នៅក្នុងឆ្នាំ២០១៥ បើធៀបទៅនឹងឆ្នាំ២០១៤។ អត្រាកំណើននេះ គឺដោយសារតែមានកំណើននៃការដឹកជញ្ជូនទំនិញឆ្លងកាត់ទៅកាន់ប្រទេសសិង្ហបុរី ថៃ បណ្តាប្រទេសនៅទ្វីបអ៊ឺរ៉ុប និងប្រទេសដទៃផ្សេងទៀតដែលមានរយៈចំងាយនៃការដឹកជញ្ជូនខ្លី។ ប៉ុន្តែកំណើននេះមិនបានផ្តល់ផលប៉ះពាល់ដល់កំណើនកុងតឺន័រឆ្លងកាត់ ក.ស.ភ. ឡើយ ព្រោះថាកំណើនកុងតឺន័រដែលឆ្លងកាត់កំពង់ផែទាំងពីរ គឺអាស្រ័យទៅលើប្រភេទទំនិញ និងប្រទេសដែលត្រូវធ្វើចរាចរកុងតឺន័រឆ្លងកាត់តែប៉ុណ្ណោះ។ នេះមានន័យថា ការដឹកជញ្ជូនកុងតឺន័រឆ្លងកាត់ពីប្រទេសមួយទៅប្រទេសមួយគឺអាស្រ័យទៅតាមទីតាំងភូមិសាស្ត្រ និងប្រវែងផ្លូវនាវាចរសម្រាប់ការដឹកជញ្ជូនទំនិញឆ្លងកាត់។

ជាទូទៅ ក្រុមហ៊ុនភ័ស្តុភារកម្ម និងក្រុមហ៊ុនដឹកជញ្ជូន គឺជាក្រុមហ៊ុនដែលអាចសម្រេច និងផ្តល់យោបល់ដល់អ្នកមានតម្រូវការនាំចេញ និងនាំចូល ឲ្យជ្រើសរើសយកចំណតផែណាមួយដែលមានរយៈចំងាយជិត និងជាពិសេសការចំណាយថ្លៃដឹកជញ្ជូនសមរម្យ។ ឧទាហរណ៍: បើអតិថិជនមានតម្រូវការនាំចេញ និងនាំចូលទៅកាន់សហរដ្ឋអាមេរិក ឬប្រទេសចិន និងវៀតណាម ក្រុមហ៊ុនដឹកជញ្ជូននឹងជ្រើសរើសកំពង់ផែស្វយ័តភ្នំពេញសម្រាប់ធ្វើការដឹកជញ្ជូន ប៉ុន្តែបើអតិថិជនមានតម្រូវការដឹកជញ្ជូនទៅកាន់ទ្វីបអ៊ឺរ៉ុប សិង្ហបុរី ឬប្រទេសថៃ នោះក្រុមហ៊ុនដឹកជញ្ជូននឹងជ្រើសរើសកំពង់ផែស្វយ័តក្រុងព្រះសីហនុ។

ការដឹកជញ្ជូនតាមផ្លូវគោកៈ ទោះបីជារាជរដ្ឋាភិបាលដាក់ឲ្យដំណើរការនូវស្ពានអ្នកលឿងកាលពីខែមេសា ឆ្នាំ២០១៥ កន្លងមកក៏ដោយ ក៏ការធ្វើចរាចរនៃការដឹកជញ្ជូនកុងតឺន័រឆ្លងកាត់ផ្លូវជាតិលេខ១ ឬតាមស្ពានអ្នកលឿង នៅតែមិនមែនជាឧបសគ្គ ឬផ្តល់ផលប៉ះពាល់ខ្លាំងដល់កុងតឺន័រឆ្លងកាត់តាម ក.ស.ភ. ឡើយ ព្រោះកុងតឺន័រដែលធ្វើការដឹកជញ្ជូនតាមផ្លូវគោក គឺដោយសារតែមូលហេតុដូចជាៈ

- ម្ចាស់ទំនិញមានចំនួនកុងតឺន័រតិចតួច
- ចំនួនកុងតឺន័រដែលខកខានការដឹកជញ្ជូនតភ្ជាប់ពីកំពង់ផែស្វយ័តភ្នំពេញ និង
- ចំនួនកុងតឺន័រដែលត្រូវធ្វើការដឹកជញ្ជូនប្រញាប់ទៅកាន់ប្រទេសវៀតណាមដើម្បីតភ្ជាប់ជាមួយនាវាមេ។

ដូចនេះ រាល់ការដឹកជញ្ជូនកុងតឺន័រ ទៅកាន់ប្រទេសវៀតណាម ម្ចាស់ទំនិញត្រូវធ្វើការដឹកជញ្ជូនទំនិញតាមផ្លូវទឹក (ក.ស.ភ.) ព្រោះទទួលបានអត្ថប្រយោជន៍ច្រើនដូចខាងក្រោម៖

- ដឹកទំនិញជាកុងតឺន័របានចំនួនច្រើន
- តម្លៃដឹកជញ្ជូនទាបជាងការដឹកជញ្ជូនតាមផ្លូវគោក
- ការដឹកជញ្ជូនមានសុវត្ថិភាព
- ការដឹកជញ្ជូនមានភាពបត់បែនក្នុងការផ្ទេរទំនិញទៅកាន់ចំណតផែតូចៗផ្សេងទៀតនៅតាមដងទន្លេ
- ពុំមានការបាត់បង់ទំនិញនៅតាមផ្លូវក្នុងការដឹកជញ្ជូន
- ងាយស្រួលក្នុងការគ្រប់គ្រង និងតាមដានការចរាចររបស់កុងតឺន័រឆ្លងកាត់

ជារួម ការដឹកជញ្ជូនកុងតឺន័រតាមផ្លូវគោក មានផលប៉ះពាល់តិចតួចដល់ការដឹកជញ្ជូនកុងតឺន័រតាមផ្លូវទឹក ស្របពេលដែលមានចំណតផែកុងតឺន័រ LM១៧ តែមួយគត់នៅតាមដងទន្លេក្នុងការផ្តល់សេវាកម្មចំណតនាវា និងការលើកដាក់កុងតឺន័រតាមផ្លូវទឹក។

ផ្អែកលើការវិភាគខាងលើ បង្ហាញឲ្យឃើញថា ការដឹកជញ្ជូនតាមផ្លូវទឹក ផ្លូវគោក និងផ្លូវសមុទ្រមិនមានការប្រកួតប្រជែងខ្ពស់ណាមួយរវាងគ្នាឡើយ ជាពិសេសលើតម្លៃសេវាកម្ម ការអូសទាញអតិថិជនឲ្យមកប្រើប្រាស់កំពង់ផែរបស់ខ្លួន ឬការប្រកួតប្រជែងតាមរូបភាពណាផ្សេងៗ។ ប៉ុន្តែកំពង់ផែទាំងពីរអាចមានការប្រកួតប្រជែងគ្នាលើប្រភេទសេវាកម្ម ដែលទាមទារការខិតខំពង្រីកប្រភេទសេវាកម្មឲ្យបានកាន់តែច្រើនឡើង និងថ្មីរហូត ជាពិសេសការពង្រីកទំហំអាជីវកម្ម ការផ្តល់ការអនុគ្រោះ ការផ្តល់សេវាកម្មបន្ថែម និងមានភាពកាន់តែទាក់ទាញដល់អតិថិជន ក្នុងការប្រើប្រាស់សេវាកម្មរបស់ ក.ស.ភ.។

ជាមួយគ្នានេះផងដែរ ក.ស.ភ. បានកំពុងចាប់ផ្តើមពង្រីកគម្រោងអភិវឌ្ឍថ្មីសម្រាប់រយៈពេលខ្លី និងរយៈពេលវែង ដែលផែនការអភិវឌ្ឍនេះបានកំពុងជម្រុញ និងអូសទាញឱ្យអតិថិជនដែលបានកំពុងប្រើប្រាស់សេវាកម្មរបស់ ក.ស.ភ. នៅតែបន្ត និងពង្រីកទំហំអាជីវកម្មរបស់ក្រុមហ៊ុនបន្ថែមទៀតក្នុងការឆ្លើយតបនឹងផែនការអភិវឌ្ឍរបស់ ក.ស.ភ.។ ស្របពេលគ្នានេះដែរ គម្រោងអភិវឌ្ឍរបស់ ក.ស.ភ. បានកំពុងទាក់ទាញអតិថិជនថ្មីៗមកប្រើប្រាស់សេវាកម្មរបស់ ក.ស.ភ. បន្ថែមទៀត។

ដូចនេះ ស្ថានភាពប្រកួតប្រជែងរបស់ ក.ស.ភ. នៅតែមានភាពរឹងមាំ និងឈានទៅមុខជានិច្ចដើម្បីទាក់ទាញអតិថិជនឲ្យនៅតែបន្តប្រើប្រាស់សេវាកម្មរបស់ ក.ស.ភ.។

## ៥-ផែនការអនាគតសម្រាប់ឆ្នាំ ២០១៦

ខាងក្រោម គឺជាគម្រោងអនាគតដែលមានតម្លៃវិនិយោគលើសពី ១០០.០០០ ដុល្លារអាមេរិក ដែលនឹងត្រូវវិនិយោគក្នុងរយៈពេល ១ឆ្នាំ ទៅ ៥ឆ្នាំខាងមុខ។

### ក. គម្រោងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផែដំណាក់កាលទី២ របស់ចំណតផែកុងតឺន័រ LM១៧

| ឈ្មោះ | គម្រោងនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផែដំណាក់កាលទី២ |
|---|---|
| បរិយាយ | ចន្លោះពី ឆ្នាំ២០១០ ដល់ ឆ្នាំ២០១៤ ចំនួនកុងតឺន័រដែលឆ្លងកាត់ជាមធ្យមកើនឡើងប្រហែល ២១,០៥% រៀងរាល់ឆ្នាំ។ ដោយសារតែ កុងតឺន័រដែលឆ្លងកាត់បច្ចុប្បន្ននៅ LM១៧ មានចំនួន ១៣៣.៦៦ TEUs ក្នុងឆ្នាំ២០១៤ |

| ឈ្មោះ | គម្រោងនៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផែដំណាក់កាលទី២ |
|---|---|
| | ក.ស.ភ. ព្យាករណ៍ថាចំនួនកុងតឺន័រនឹងបន្តកើនឡើងដល់ ១៨០.០០០ TEUs ក្នុងឆ្នាំ២០១៦។ ដើម្បីទទួលបានកំណើននេះ ក.ស.ភ. ត្រូវធ្វើការពង្រីកឋបនីយកណ្តផែ និងបរិក្ខារបន្ថែមទៀត |
| **ដំហានទី ១ នៃដំណាក់កាលទី២ ពីឆ្នាំ (២០១៦-២០១៧)** | |
| គោលបំណង | ធានាសមត្ថភាពលើកដាក់របស់ផែក្នុងការទទួលកំណើនកុងតឺន័រឆ្លងកាត់ជារៀងរាល់ឆ្នាំ |
| លទ្ធផលរំពឹងទុក | បង្កើនសមត្ថភាពលើកដាក់របស់ចំណតផែកុងតឺន័រ LM១៧ ដល់កម្រិត ២៣០.០០០ TEUs ក្នុងមួយឆ្នាំ |
| ទីតាំងគម្រោង | ភាគខាងកើតចំណតផែកុងតឺន័រ LM១៧ |
| ទំហំនៃគម្រោង | ៥ ហិកតា |
| ភ្នាក់ងារអនុវត្តគម្រោង | កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) |
| ថវិកាត្រូវចំណាយ | - ពង្រីកទីលានកុងតឺន័រ បរិមាត្រផ្ទៃសរុប (១៧.៨៥០ ម៉ែត្រការ៉េ) ដោយចាក់ថ្មម៉ិច៖ ៩៩៩.៨០០ ដុល្លារអាមេរិក<br>- សាងសង់ផ្លូវសម្រាប់រថស្ទូច RTG ចំនួន ២ ខ្សែ (ប្រវែង ៥៤៤ ម៉ែត្រ)៖ ៨៣៨.៥៦៥ ដុល្លារអាមេរិក<br>- សាងសង់ផ្លូវសម្រាប់រថយន្តកុងតឺន័រ ចំនួន ២ ខ្សែ (ប្រវែង ២៧២ម៉ែត្រ)៖ ៣៩៨.៣៩០ ដុល្លារអាមេរិក<br>- បំពាក់រថស្ទូច RTG ចំនួន ២ គ្រឿង៖ ២.៩០០.០០០ ដុល្លារអាមេរិក<br>- បំពាក់ដងយោង TCC ចំនួន ១ គ្រឿង៖ ១.៩២៥.០០០ដុល្លារអាមេរិក<br>- សាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹក និងអគ្គិសនី៖ ៧៥៩.០០០ ដុល្លារអាមេរិក<br>- សាងសង់ទំនប់ (៣០០ម x ៣១ ម)៖ ១.៧៩៨.៨៥៨ ដុល្លារអាមេរិក<br>- សាងសង់របង (៧៥០ ម)៖ ៧៩.៨២៨ ដុល្លារអាមេរិក |
| ប្រភពហិរញ្ញវត្ថុ | - មូលធនទទួលបានពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង<br>- មូលនិធិបម្រុងរបស់ ក.ស.ភ. |
| រយៈពេលអនុវត្តគម្រោង | ២០១៦-២០១៧ |
| កម្មសិទ្ធិដី | កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) |
| បញ្ហាសង្គម | ការអនុវត្តគម្រោងដំណាក់កាលទី២នៃចំណតផែកុងតឺន័រ LM១៧ នឹងបង្កើតការងារបន្ថែម តាមរយៈការជ្រើសរើសបុគ្គលិកបន្ថែម |
| បញ្ហាបរិស្ថាន | គ្មានការបង្ហាញណាមួយដែលបញ្ជាក់ថាអាចមានផលប៉ះពាល់ដល់ផ្នែកបរិស្ថានឡើយ |
| ការតាមដានសកម្មភាព | បង្កើតក្រុមការងារមួយដើម្បីតាមដានការអនុវត្តគម្រោង |

### ខ.គម្រោងបំពាក់កុងរ្ទ័រនៅចំណតផែកុងតឺន័រ LM១៧

| ឈ្មោះ | គម្រោងបំពាក់កុងរ្ទ័រនៅចំណតផែកុងតឺន័រ LM១៧ |
|---|---|
| បរិយាយ | ក្រៅពីលើកដាក់ទំនិញជាកុងតឺន័រនៅចំណតផែកុងតឺន័រ LM១៧ ក.ស.ភ. ពុំទាន់មានឧបករណ៍សម្រាប់ផ្ទុក និងផ្ទេរទំនិញរាយទេ។ ដូច្នេះ ក.ស.ភ. មានគម្រោងក្នុងការបំពាក់កុងរ្ទ័រ ដើម្បីឆ្លើយតបទៅនឹងការកើនឡើងនៃតម្រូវការសេវាកម្មលើកដាក់ទំនិញរាយនៅចំណតផែកុងតឺន័រ LM១៧ |
| គោលបំណង | សម្រួល និងធានាប្រសិទ្ធភាពក្នុងការផ្ទុក និងផ្ទេរទំនិញរាយប្រកបដោយទំនុកចិត្ត |
| លទ្ធផលរំពឹងទុក | ផ្តល់ឧបករណ៍សមស្របសម្រាប់ផ្ទុក និងផ្ទេរទំនិញរាយ |
| ទីតាំងគម្រោង | ភាគខាងកើតចំណតផែកុងតឺន័រ LM១៧ |
| ភ្នាក់ងារអនុវត្តគម្រោង | កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) |
| ថវិកាចំណាយ | ១៦០.០០០ ដុល្លារ សម្រាប់កុងរ្ទ័រ ៤ខ្សែ |
| ប្រភពហិរញ្ញវត្ថុ | មូលធនទទួលបានពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង និងមូលនិធិបម្រុង ក.ស.ភ. |
| រយៈពេលអនុវត្តគម្រោង | ២០១៦ |
| កម្មសិទ្ធិដី | កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) |
| បញ្ហាសង្គម | បង្កើតការងារបន្ថែម |
| បញ្ហាបរិស្ថាន | មិនមានការបង្ហាញណាមួយថាមានបញ្ហាបរិស្ថាននោះទេ |
| សកម្មភាពតាមដាន | បង្កើតក្រុមការងារដើម្បីតាមដានការអនុវត្តគម្រោង |

### គ.គម្រោងបំពាក់កុងរ្ទ័រនៅចំណតផែពហុបំណង TS៣

| ឈ្មោះ | គម្រោងបំពាក់កុងរ្ទ័រនៅចំណតផែពហុបំណង TS៣ |
|---|---|
| បរិយាយ | មុនការស្ថាបនាចំណតផែកុងតឺន័រ LM១៧ ក្នុងដំណាក់កាលទី១ ចំណតផែពហុបំណង TS៣ គឺជាផែចម្បងសម្រាប់ការលើកដាក់ទំនិញកុងតឺន័រ និងទំនិញរាយ។ ដោយសារ ការពង្រីកទីលានកុងតឺន័រមានកម្រិតដើម្បីទទួលចរាចរណ៍កុងតឺន័រដែលកើនឡើងជារៀងរាល់ឆ្នាំ ក.ស.ភ. បានវិនិយោគលើការអភិវឌ្ឍចំណតផែកុងតឺន័រ LM១៧។ នៅខែធ្នូ ឆ្នាំ២០១៤ ចំណតផែពហុបំណង TS៣ បានប្រើប្រាស់សម្រាប់ទទួលទំនិញរាយ និងអ្នកដំណើរជាចម្បង។ ដូច្នេះហើយ ក.ស.ភ. មានគម្រោងបំពាក់កុងរ្ទ័រដើម្បីជម្រុញប្រតិបត្តិការ និងបង្កើនប្រសិទ្ធភាពក្នុងការទទួលទំនិញរាយ។ |
| គោលបំណង | សម្រួល និងធានាប្រសិទ្ធភាពក្នុងការផ្ទុក និងផ្ទេរទំនិញរាយប្រកបដោយទំនុកចិត្ត |

| ឈ្មោះ | គម្រោងបំពាក់កុងរ្វយ័រនៅចំណតផែពហុបំណង TS៣ |
| --- | --- |
| លទ្ធផលរំពឹងទុក | ផ្តល់ឧបករណ៍សមស្របសម្រាប់ផ្ទុក និងផ្ទេរទំនិញរាយ |
| ទីតាំងគម្រោង | លើស្ពានផែដែលមានស្រាប់នៅចំណតផែពហុបំណង TS៣ |
| អង្គភាពអនុវត្តគម្រោង | កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) |
| ថវិកាត្រូវចំណាយ | ១៦០.០០០ ដុល្លារ សម្រាប់កុងរ្វយ័រ ៨ខ្សែ |
| ប្រភពហិរញ្ញវត្ថុ | មូលធនទទួលបានពីការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិសាធារណៈលើកដំបូង និងមូលនិធិបម្រុង ក.ស.ភ. |
| រយៈពេលអនុវត្តគម្រោង | ២០១៦ |
| កម្មសិទ្ធិដី | កំពង់ផែស្វយ័តភ្នំពេញ (ក.ស.ភ.) |
| បញ្ហាសង្គម | បង្កើតការងារបន្ថែម |
| បញ្ហាបរិស្ថាន | មិនមានការបង្ហាញណាមួយថាមានការប៉ះពាល់ដល់បរិស្ថាននោះទេ |
| សកម្មភាពតាមដាន | បង្កើតក្រុមការងារមួយដើម្បីតាមដានការអនុវត្តគម្រោង |

## ផ្នែកទី២ : ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

### ១- លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

| លរ. | បរិយាយ | ឯកតា | អនុវត្ត ឆ្នាំ២០១៤ | ផែនការ ឆ្នាំ ២០១៥ | អនុវត្ត ឆ្នាំ២០១៥ | ផែនការ ឆ្នាំ ២០១៦ | កើនថយ(%) | | |
|---|---|---|---|---|---|---|---|---|---|
| ក | ខ | គ | ១ | ២ | ៣ | ៤ | ៥=(៣/១)-១០០% | ៦=(៣/១)-១០០% | ៧=(៤/៣)-១០០% |
| I | បរិមាណទំនិញ និងប្រេងឥន្ធនៈឆ្លងកាត់ | តោន | ១.៨៩២.៨២៣ | ២.៥០០.០០០ | ២.១៦១.៣៥១ | ២.៤៩០.០០០ | +១៤,១៩% | -១៣,៥៥% | +១៥,២១% |
| | ក. បរិមាណទំនិញឆ្លងកាត់ | - | ១.០២១.៩៣៨ | ១.៤០០.០០០ | ១.១៩៦.៨២៨ | ១.៤០០.០០០ | +១៧,១១% | -១៤,៥១% | +១៦,៩៨% |
| | - ទំនិញនាំចូល | - | ៦១៥.២៦៨ | ៨០០.០០០ | ៧៧៨.៩៥៧ | ៨០០.០០០ | | | |
| | - ទំនិញនាំចេញ | - | ៤០៦.៦៧០ | ៦០០.០០០ | ៤១៧.៨៧១ | ៦០០.០០០ | | | |
| | ខ. បរិមាណទំនិញលើកដាក់ចល័ត | - | ២៦៥.៧០១ | ៣០០.០០០ | ២៩៩.០៣០ | ៣៤០.០០០ | +១២,៥៤% | -០,៣២% | +១៣,៧០% |
| | - ទំនិញលើកដាក់ក្នុងផែ | - | ៤៤.០៧៩ | ៦០.០០០ | ១៥.០៣១ | ៦០.០០០ | | | |
| | - ទំនិញលើកដាក់ក្រៅផែ | - | ២២១.៦២២ | ២៤០.០០០ | ២៨៣.៩៩៩ | ២៨០.០០០ | | | |
| | គ.បរិមាណប្រេងឥន្ធនៈ និងហ្គាសឆ្លងកាត់ | - | ៦០៥.១៨៤ | ៨០០.០០០ | ៦៦៥.៤៩៣ | ៧៥០.០០០ | +៩,៩៧% | -១៦,៨១% | +១២,៧០% |
| | បរិមាណកុងតឺន័រឆ្លងកាត់ | TEU | ១៣៣.៦៦៦ | ១៥៧.០០០ | ១៤៤.៨១៣ | ១៦៥.០០០ | +៨,៣៤% | -៧,៧៦% | +១៣,៩៤ |
| | -មានទំនិញ | - | ៩៨.៤១៥ | ១០០.០០០ | ១០៤.៥០៧ | ១២០.០០០ | | | |
| | -គ្មានទំនិញ | - | ៣៥.២៥១ | ៥៧.០០០ | ៤០.៣០៦ | ៤៥.០០០ | | | |
| II | បរិមាណទំនិញលើកដាក់ | តោន | ១.៣២១.៦៥១ | ១.៧០០.០០០ | ១.៤៩៥.៨៥៨ | ១.៧៤០.០០០ | +១៣,១៨% | -១២,០១% | +១៦,៣២% |
| | -ប្រគល់ផ្ទាល់ | - | ២៦៥.៧០១ | ៣០០.០០០ | ២៩៩.០៣០ | ៣៤០.០០០ | | | |
| | -ឆ្លងកាត់ឃ្លាំង-ទីលាន | - | ១.០២១.៩៣៨ | ១.៤០០.០០០ | ១.១៩៦.៨២៨ | ១.៤០០.០០០ | | | |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| III | <u>បរិមាណនាវាសរុប</u> | <u>គ្រឿង</u> | <u>១.៤៦២</u> | <u>១.៦០០</u> | <u>១.៥៩៦</u> | <u>១.៥៧០</u> | <u>+៩,១៧%</u> | <u>-០,២៥%</u> | <u>-១,៦៣%</u> |
| | -នាវា-សាឡង់បណ្តាប្រទេសផ្សេងៗ | - | ៨៦៥ | ៨៥០ | ៩៩០ | ៨៧០ | | | |
| | -នាវា-សាឡង់កម្ពុជា | - | ១១៣ | ១៥០ | ១០១ | ១២០ | | | |
| | -នាវា-សាឡង់ប្រេងឥន្ទនៈ | - | ៤៨៤ | ៦០០ | ៥០៥ | ៥៨០ | | | |
| IV | <u>បរិមាណនាវាអ្នកដំណើរទេសចរក្នុងស្រុក (ចេញ-ចូល)</u> | <u>ជើង</u> | <u>២.៩២៥</u> | <u>២.៨០០</u> | <u>៣.២០៧</u> | <u>២.៧៥០</u> | <u>+៩,៦៤%</u> | <u>+១៤,៥៤%</u> | <u>-១៤,២៥%</u> |
| | - ភ្នំពេញសៀមរាប-សៀមរាបភ្នំពេញ | - | ៣៩៥ | ៣០០ | ២៨៧ | ២៥០ | | | |
| | - នាវាទេសចរណ៍ក្នុងក្រុង | - | ២.៥៧០ | ២.៥០០ | ២.៩២០ | ២.៥០០ | | | |
| V | <u>បរិមាណអ្នកដំណើរ និងទេសចរក្នុងស្រុក (ចេញ-ចូល)</u> | <u>នាក់</u> | <u>២៥.៥២៣</u> | <u>២២.០០០</u> | <u>២២.១៨១</u> | <u>២០.១០០</u> | <u>-១៣,០៩%</u> | <u>+០,៨២%</u> | <u>-៩,៣៨%</u> |
| | - ភ្នំពេញសៀមរាប-សៀមរាបភ្នំពេញ | - | ១៦.១៣៣ | ១៣.០០០ | ១១.០០៦ | ១១.០០០ | | | |
| | - ទេសចរក្នុងក្រុង | - | ៩.៣៩០ | ៩.០០០ | ១១.១៧៥ | ៩.១០០ | | | |
| VI | <u>បរិមាណនាវាអ្នកដំណើរបរទេស និងទេសចរឆ្លងកាត់ (វៀតណាម)</u> | <u>ជើង</u> | <u>២.៣៤៦</u> | <u>២.១០០</u> | <u>២.៣៨៧</u> | <u>២.២៥០</u> | <u>+១,៧៥%</u> | <u>+ ១៣,៦៧%</u> | <u>-៥,៧៤%</u> |
| | - ចំនួននាវាភ្នំពេញ-ចូវដុក-ភ្នំពេញ | - | ១.៨២៣ | ១.៦៥០ | ១.៧៨៣ | ១.៧០០ | | | |
| | - ចំនួននាវាទេសចរណ៍ | - | ៥២៣ | ៤៥០ | ៦០៤ | ៥៥០ | | | |
| | <u>បរិមាណអ្នកដំណើរបរទេស និងទេសចរឆ្លងកាត់ (វៀតណាម)</u> | <u>នាក់</u> | <u>៤៦.៦៥៥</u> | <u>៤០.០០០</u> | <u>៣៦.៧០៨</u> | <u>៣៧.០០០</u> | <u>-២១,៣២%</u> | <u>-៨,២៧%</u> | <u>+០,៨០%</u> |
| | - ចំនួននាវាភ្នំពេញ-ចូវដុក-ភ្នំពេញ | - | ២២.៣៣៨ | ២០.០០០ | ១១.៦៧៥ | ១២.០០០ | | | |
| | - ចំនួនភ្ញៀវទេសចរណ៍ | - | ២៤.៣១៧ | ២០.០០០ | ២៥.០៣៣ | ២៥.០០០ | | | |

*(ប្រភពមកពីរបាយការណ៍នាយកដ្ឋានផែនការ/ទីផ្សារ)*

- បរិមាណទំនិញ-ប្រេងឥន្ធនៈឆ្លងកាត់មាន ២.១៦១.៣៥១តោន កើនឡើង១៤,១៩% ធៀបនឹងការអនុវត្តឆ្នាំ២០១៤ (១.៨៩២.៨២៣តោន) ថយចុះ ១៣,៥៤% ធៀបនឹងផែនការឆ្នាំ២០១៥ (២.៥០០.០០០តោន)
- នាវាឆ្លងកាត់មាន ១.៥៩៦ គ្រឿង កើនឡើង ៩,១៧% ធៀបនឹងការអនុវត្តឆ្នាំ២០១៤ (១.៤៦២គ្រឿង) សម្រេចបាន ៩៩,៧៥% ធៀបនឹងផែនការឆ្នាំ ២០១៥ (១.៦០០គ្រឿង)
- នាវាអ្នកដំណើរ និងទេសចរណ៍អន្តរជាតិមាន ២.៣៨៧គ្រឿង កើនឡើង ១,៧៥% ធៀបនឹងការអនុវត្តឆ្នាំ២០១៤ (២.៣៤៦គ្រឿង) កើនឡើង ១៤% ធៀបនឹងផែនការឆ្នាំ២០១៥ (២.១០០គ្រឿង)
- បរិមាណកុងតឺន័រមាន ១៤៤.៨១៣TEUs កើនឡើង ៨,៣៤% ធៀបនឹងការអនុវត្តឆ្នាំ២០១៤ (១៣៣.៦៦៦TEUs) ថយចុះ ៨% ធៀបនឹងផែនការឆ្នាំ ២០១៥ (១៥៧.០០០ TEUs)
- បរិមាណអ្នកដំណើរ និងទេសចរឆ្លងកាត់មាន ៣៦.៧០៨នាក់ ថយចុះ ២១,៣២% ធៀបនឹងការអនុវត្តឆ្នាំ២០១៤ (៤៦.៦៥៥នាក់) ថយចុះ ៨,២៧% ធៀបនឹងផែនការឆ្នាំ២០១៥ (៤០.០០០នាក់)។

ការងារជលធារសាស្ត្រ

- ទទួលបានអាជ្ញាបណ្ណបូមស្តារប្រឡាយចំនួន ២ ទីតាំង (ប្រឡាយស្តៅតាឯក និងប្រឡាយខ្សុំ កោះកែវ) ពីក្រសួងរ៉ែ និងថាមពល ក្នុងគោលបំណងស្តារផ្លូវនាវាចរណ៍ និងយកខ្សាច់ផ្គត់ផ្គង់តម្រូវការក្នុងស្រុក។ គិតចាប់ពីពេលដែល ក.ស.ភ. បានទទួលអាជ្ញាបណ្ណ (ថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥) រហូតដល់បំណាច់ឆ្នាំ២០១៥ (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥) ការងារបូមយកខ្សាច់សម្រាប់ទីតាំងទាំងពីរខាងលើសម្រេចនូវបរិមាណខ្សាច់សរុបចំនួន ៨.៤២២.៦៩០ម៉ែត្រគ្រីគុណ (ខ្សាច់សំណង់ចំនួន ១.១០២.៦៦៦ម៉ែត្រគ្រីគុណ និងល្បាយខ្សាច់ចំនួន ៧.៣២០.០២៤ម៉ែត្រគ្រីគុណ)
- បានអនុវត្តការងារបូមស្តារប្រឡាយស្តៅ លើបរិមាណខ្សាច់ ២៧៦.០០០ម៉ែត្រគ្រីគុណ ដើម្បីធ្វើការសម្រួលផ្លូវនាវាចរណ៍ភ្នំពេញ-កំពង់ចាម
- ទទួលផ្តល់សេវាវាស់ស្ទង់លើទីតាំងចំនួន ១៦ទីតាំង ជូនក្រសួងរ៉ែ និងថាមពល និងក្រុមហ៊ុនឯកជនមួយចំនួន។

ការងារសាងសង់ហេដ្ឋារចនាសម្ព័ន្ធ

- បញ្ចប់ការសាងសង់ផ្លូវតាមមាត់ទន្លេភ្ជាប់ពីប្លង់Aទៅប្លង់C ទំហំ៨មx៤១៨ម នៅចំណតផែកុងតឺន័រ LM១៧
- បញ្ចប់ការងារសាងសង់ទំនប់សណ្តតាមមាត់ទន្លេភ្ជាប់ពីប្លង់ A ទៅប្លង់ C ប្រវែង ៤១៨ម នៅចំណតផែកុងតឺន័រ LM១៧
- បញ្ចប់ការងារធ្វើរបាំងសុវត្ថិភាពក្បាលម៉ាស៊ីនពន្លត់អគ្គីភ័យ ចំនួន៣ និងទូភ្លើងចំនួន ៣កន្លែង នៅចំណតផែកុងតឺន័រ LM១៧
- បញ្ចប់ការងារសាងសង់បង្កាន់ដៃស្ពាននៅក្រោមចំណតផែពហុបំណង TS៣ ដើម្បីសម្រួលដល់ការធ្វើដំណើរឡើងចុះរបស់ភ្ញៀវទេសចរអន្តរជាតិ
- បញ្ចប់ការសាងសង់របងអមចូលចំណតផែកុងតឺន័រ LM១៧ ប្រវែង ២៩៥ម៉ែត្រ កំពស់ ៣,៦ម៉ែត្រ
- បញ្ចប់ការងារតម្លើងបង្គោលភ្លើង ចំនួន ៦បង្គោល នៅតាមផ្លូវជាតិលេខ១ ត្រង់ច្រកចេញចូលចំណតផែកុងតឺន័រ LM១៧
- បញ្ចប់ការងារសាងសង់បន្ទប់ទំហំ ៣,៧៣ម x ៥,៩៤ម ក្រោមអគាររដ្ឋបាលចំនួន ២បន្ទប់ នៅចំណតផែផែកុងតឺន័រ LM១៧
- បានទិញដីទំហំ ៩.៥៣៩ម៉ែត្រការ៉េ ដើម្បីពង្រីកហេដ្ឋារចនាសម្ព័ន្ធបន្ថែមដោយបង្កើតជាច្រកចេញ-ចូល នៅចំណតផែកុងតឺន័រ LM១៧
- បញ្ចប់ការងារសាងសង់ប៊ីតបេតុងអាម៉េ ចំនួន ២គ្រឿងទំហំ២មx២មx២ម នៅ MSL
- បញ្ចប់ការងាររំកិលផែបណ្តែតនៅចំណតផែអ្នកដំណើរ និងទេសចរ (TS១) ប្រវែង ៧ម៉ែត្រ ទៅមុខពីច្រាំង

- បាន និងកំពុងអនុវត្តការងារសាងសង់ស្ពានផែបណ្តែតថ្មីចំនួន ១កន្លែង បន្ថែមលើទីតាំងដែលមានស្រាប់នៅចំណតផែអ្នកដំណើរ និងទេសចរ (TS១)
- បញ្ចប់ការសាងសង់ប៊ីតបេតុងអាម៉េ ចំនួន២គ្រឿង ទំហំ ២មx២មx២ម ប៊ីតដែកចំនួន ២គ្រឿង ដើម្បីទប់នាវាធំដែលចលតពីចំណតផែពហុបំណង TS៣ ទៅផែក្នុងស្រុក។

## ២- ការប្រែប្រួលសំខាន់ៗ ពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ច

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ពុំមានការប្រែប្រួលសំខាន់ៗពាក់ព័ន្ធនឹងប្រតិបត្តិការធុរកិច្ចនោះទេ។

## ៣- រចនាសម្ព័ន្ធចំណូល

| បរិយាយ | ៣១ ធ្នូ ២០១៣ | | ៣១ ធ្នូ ២០១៤ | | ៣១ ធ្នូ ២០១៥ | |
|---|---|---|---|---|---|---|
| | ពាន់រៀល | ប្រៀបធៀបនឹងប្រាក់ចំណូលសរុប | ពាន់រៀល | ប្រៀបធៀបនឹងប្រាក់ចំណូលសរុប | ពាន់រៀល | ប្រៀបធៀបនឹងប្រាក់ចំណូលសរុប |
| ចំណូលលើកដាក់ក្រោមដងយោង (Stevedoring) | ១៨.៦៧២.៣២៩ | ៤០,៦៦% | ២២.៧២៤.១០៣ | ៤២,៣៤% | ២៤.៤៨៧.៣២៦ | ៣៩,៨៤% |
| ចំណូលលើកដាក់នៅទីលាន(LOLO) | ១៥.០៨៧.៩៤៩ | ៣២,៨៦% | ១៨.១៨៦.៨២១ | ៣៣,៨៨% | ២០.០១១.៣០៦ | ៣២,៥៦% |
| ចំណូលកិច្ចការផែ | ៨.០៤៣.៥២៦ | ១៧,៥២% | ៨.៥៨៧.១៩១ | ១៦,០០% | ១០.១២៨.៥៣១ | ១៦,៤៨% |
| ចំណូលពីការគ្រប់គ្រងអាជីវកម្មខ្សាច់ | - | ០,០០% | - | ០,០០% | ២.៩១៧.១៦៧ | ៤,៧៥% |
| ចំណូលពីច្រកទ្វារ | - | ០,០០% | ១.៧៣៣.៩២៩ | ៣,២៣% | ១.៩៨៧.០៧៤ | ៣,២៣% |
| ចំណូលពីស្តុកទំនិញ/កុងតឺន័រ | ១.០៣៩.៨៣២ | ២,២៦% | ២.២១៦.៩២៧ | ៤,១៣% | ១.១៨៣.៤៤៥ | ១,៩៣% |
| ចំណូលពីការវាស់ស្ទង់ | - | ០,០០% | - | ០,០០% | ៧២៩.៦១០ | ១,១៩% |
| ចំណូលពីការដឹកជញ្ជូន | ១៦.៤៩៨ | ០,០៤% | - | ០,០០% | - | ០,០០% |
| ចំណូលផ្សេងៗ | ៣.០៥៨.៧៩២ | ៦,៦៦% | ២២៥.១៥៥ | ០,៤២% | ១៣.៧២៧ | ០,០២% |
| **ចំណូលសរុប** | ៤៥.៩១៨.៩២៦ | ១០០,០០% | ៥៣.៦៧៤.១២៦ | ១០០,០០% | ៦១.៤៥៨.១៨៦ | ១០០,០០% |

## ផ្នែកទី ៣ : អភិបាលកិច្ចសាជីវកម្ម

### ១- ភាគហ៊ុនិក

#### ក- ការការពារសិទ្ធិរបស់ភាគហ៊ុនិក

សិទ្ធិរបស់ភាគហ៊ុនិក ត្រូវបានធានាដោយមហាសន្និបាតភាគហ៊ុនិក ដោយក្រុមប្រឹក្សាភិបាល និងដោយអគ្គនាយក ដែលមានកំណត់នៅក្នុងលក្ខន្តិកៈរបស់ ក.ស.ភ. ដូចខាងក្រោម៖

- ភាគហ៊ុនិកប្រភេទ "ក" និងប្រភេទ "ខ" មានសិទ្ធិបោះឆ្នោតពេញលេញ ដោយ ១ (មួយ) ភាគហ៊ុនស្មើនឹង ១ (មួយ) សម្លេង ក្នុងមហាសន្និបាតភាគហ៊ុនិករបស់ ក.ស.ភ. ទៅលើបញ្ហាដែលបានលើកឡើងក្នុងការប្រជុំ ដែលក្នុងនោះមានដូចជា លទ្ធផលសកម្មភាពការងារប្រចាំឆ្នាំ គម្រោងផែនការវិនិយោគប្រចាំឆ្នាំ ការបោះឆ្នោតជ្រើសរើសអភិបាលឯករាជ្យ និងអភិបាលមិនប្រតិបត្តិ ព្រមទាំងទៅលើបញ្ហា ដែលពាក់ព័ន្ធផលប៉ះពាល់ដល់ប្រយោជន៍របស់ភាគហ៊ុនិក ដូចជាការកាត់បន្ថយការតម្លើង ឬការកែប្រែផ្សេងទៀតទៅលើដើមទុនរបស់ ក.ស.ភ. ឬការផ្លាស់ប្តូរសិទ្ធិដែលពាក់ព័ន្ធនឹងប្រភេទមូលបត្រដែលមានក្នុងដើមទុនរបស់ក្រុមហ៊ុន ឬការទិញមកវិញ ការទទួលយកដោយ ក.ស.ភ. នូវមូលបត្រណាមួយ ឬមូលបត្រដទៃទៀតរបស់ ក.ស.ភ. ការរំលាយបញ្ចូលគ្នារវាង ក.ស.ភ. និងក្រុមហ៊ុនដទៃទៀត ការរំលាយ ឬការជម្រះបញ្ជី ក.ស.ភ. ការធ្វើវិសោធនកម្មលក្ខន្តិកៈ។ ដោយឡែក ភាគហ៊ុនិកប្រភេទ "គ" មិនមានសិទ្ធិបោះឆ្នោតនោះទេ លើកលែងតែពាក់ព័ន្ធនឹងបញ្ហាមួយចំនួនដូចជា ការរំលាយបញ្ចូលគ្នារវាង ក.ស.ភ. និង ក្រុមហ៊ុនដទៃទៀត ការរំលាយ ឬការជម្រះបញ្ជី ក.ស.ភ. ការធ្វើវិសោធនកម្មលក្ខន្តិកៈ។
- ភាគហ៊ុនិកប្រភេទ "ក" និងប្រភេទ "ខ" មានសិទ្ធិទទួលភាគលាភដែលប្រកាសដោយក្រុមប្រឹក្សាភិបាលរបស់ ក.ស.ភ.។ លើសពីនេះទៀត ភាគហ៊ុនិកប្រភេទ "ក" ត្រូវបានធានានូវទិន្នផលភាគលាភប្រចាំឆ្នាំអប្បបរមាក្នុងអត្រា ៥% ក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ។ រីឯ ភាគហ៊ុនិកប្រភេទ "គ" មិនមានសិទ្ធិទទួលបានភាគលាភនោះទេ។
- ភាគហ៊ុនិករបស់ ក.ស.ភ. មានសិទ្ធិទទួលបាននូវព័ត៌មានដែលទាក់ទងនឹង ក.ស.ភ. តាមរយៈការផ្តល់ព័ត៌មានទាន់ពេល ព័ត៌មានដែលផ្សព្វផ្សាយនៅលើគេហទំព័ររបស់ ក.ស.ភ. របាយការណ៍សមាយិករួមមានរបាយការណ៍ប្រចាំត្រីមាស និងរបាយការណ៍ប្រចាំឆ្នាំ ព្រមទាំងព័ត៌មានដទៃទៀត តាមការស្នើសុំរបស់ភាគហ៊ុនិក។
- ភាគហ៊ុនិករបស់ ក.ស.ភ. មានសិទ្ធិបុព្វក្រ័យក្នុងការជាវបានមុននូវភាគហ៊ុនថ្មីដែលក្នុងប្រភេទតែមួយជាមួយនឹងភាគហ៊ុនដែលខ្លួនកំពុងកាន់កាប់ ដែលបោះចេញដោយ ក.ស.ភ. ស្របតាមសមាមាត្រនៃការកាន់កាប់ភាគហ៊ុនរបស់ខ្លួន។
- ភាគហ៊ុនិកប្រភេទ "ក" និងប្រភេទ "ខ" មានសិទ្ធិទទួលបានទ្រព្យសម្បត្តិដែលនៅសល់ បន្ទាប់ពីមានការជម្រះបញ្ជី ការរំលាយ ឬការបញ្ចប់របស់ ក.ស.ភ. បន្ទាប់ពីភាគហ៊ុនិកប្រភេទ "គ" ដែលមានសិទ្ធិបុរិមាក្នុងការទទួលទ្រព្យសម្បត្តិដែលនៅសល់នេះ។
- ភាគហ៊ុនិកប្រភេទ "ខ" មានសិទ្ធិធ្វើបរិវត្តន៍ភាគហ៊ុនទាំងអស់របស់ខ្លួនទៅជាភាគហ៊ុនប្រភេទ "ក" ដោយ ១ ភាគហ៊ុនប្រភេទ "ខ" ទៅជាភាគហ៊ុនប្រភេទ "ក" លុះត្រាតែមានលក្ខខណ្ឌ៖
    - បន្ទាប់ពីរយៈពេល ៥ឆ្នាំ ចាប់ពីពេល ក.ស.ភ. បានចុះបញ្ជីលក់លើទីផ្សារមូលបត្រកម្ពុជា
    - ភាគលាភអប្បបរមាដែលធានាជូនភាគហ៊ុនិកប្រភេទ "ក" ត្រូវបានបែងចែករួចរាល់

- សិទ្ធិបរិវត្តន៍ ត្រូវអនុវត្តចំពោះភាគហ៊ុនប្រភេទ “ខ” ទាំងអស់ដោយក្នុងនោះមានភាគហ៊ុនប្រភេទ “ខ” ដែលបោះផ្សាយ និងដែលត្រូវបានអនុញ្ញាតឱ្យបោះផ្សាយ។

**ខ- ការបែងចែកប្រភេទភាគហ៊ុនិក** (គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៥)

| បរិយាយ | សញ្ជាតិ | ប្រភេទភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ |
|---|---|---|---|---|---|
| តិចជាង ៥% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ២៤៣ | ៩៤៧.៧២២ | ៤,៥៨% |
| | | នីតិបុគ្គល | ៤ | ៧០៦.៧៣៣ | ៣,៤២% |
| | មិនមានសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | ៤២ | ១.២៨៧.៦៩២ | ៦,២៣% |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |
| ចាប់ពី ៥% ដល់តិចជាង ៣០% | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | មិនមានសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | ១ | ១.១៩៤.៧២៦ | ៥,៧៨% |
| ចាប់ពី ៣០% ឡើងទៅ | សញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | ១ | ១៦.៥៤៧.៤៩២ | ៨០,០០% |
| | មិនមានសញ្ជាតិខ្មែរ | រូបវន្តបុគ្គល | គ្មាន | គ្មាន | គ្មាន |
| | | នីតិបុគ្គល | គ្មាន | គ្មាន | គ្មាន |

**គ- អភិបាល បុគ្គលិកជាន់ខ្ពស់ និងនិយោជិតដែលកាន់កាប់មូលបត្រកម្មសិទ្ធិរបស់ ក.ស.ភ.**

| ភាគហ៊ុនិក | ចំនួនភាគហ៊ុនិក | ចំនួនមូលបត្រ | ភាគរយ* |
|---|---|---|---|
| អភិបាល | ៥ | ១២៦.៣៦៣ | ០,៦១% |
| បុគ្គលិកជាន់ខ្ពស់ | ១៤ | ១១៦.៦៤៩ | ០,៥៦% |
| និយោជិត | ១១៦ | ២៦២.៥៦៨ | ១,២៧% |
| **សរុប** | **១៣៥** | **៥០៥.៥៨០** | **២,៤៤%** |

**ទិន្នន័យភាគរយត្រូវបានយកចំនួនមូលបត្រប្រៀបធៀបនឹងចំនួនមូលបត្រមានសិទ្ធិបោះឆ្នោតសរុប (២០.៦៨៤.៣៦៥)។*

**ឃ-ការផ្លាស់ប្តូរភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន និងភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់**

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ពុំមានការផ្លាស់ប្តូរភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន និងភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ទេ។

**ង- អត្តសញ្ញាណភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅ ស្ថិតក្នុងស្ថានភាពអសាធនភាព**

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ពុំមានភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនចាប់ពី ៥ (ប្រាំ) ភាគរយឡើងទៅ ស្ថិតក្នុងស្ថានភាពអសាធនភាពនោះទេ។

### ច- កិច្ចប្រជុំមហាសន្និបាតភាហ៊ុនិក

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ក.ស.ភ. ពុំទាន់បានរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកនៅឡើយទេ។

### ឆ- គោលនយោបាយភាគលាភ

### ឆ-១- គោលនយោបាយភាគលាភរបស់កំពង់ផែស្វយ័តភ្នំពេញ

ដើម្បីលើកទឹកចិត្តដល់វិនិយោគិនដែលទិញភាគហ៊ុនប្រភេទ"ក" របស់ ក.ស.ភ. ក្រុមប្រឹក្សាភិបាលបានអនុម័តគោលនយោបាយភាគលាភពិសេស ដែលធានានូវទិន្នផលភាគលាភអប្បបរមាប្រចាំឆ្នាំស្មើនឹងចំនួន ៥% នៃទំហំវិនិយោគដោយគិតតាមថ្លៃមូលបត្រនៃ IPO សម្រាប់រយៈពេល ៥ឆ្នាំបន្ទាប់ពីការចុះបញ្ជីលក់លើទីផ្សារមូលបត្រកម្ពុជា។ ការធានាទិន្នផលភាគលាភអប្បបរមាស្មើនឹងចំនួន ៥% នេះគឺនឹងផ្តល់ជូនចំពោះមូលបត្រកម្មសិទ្ធិដែលមានសិទ្ធិបោះឆ្នោតប្រភេទ "ក" តែប៉ុណ្ណោះ។ រាជរដ្ឋាភិបាល ដែលជាភាគហ៊ុនិកកាន់កាប់មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ "ខ" និងមូលបត្រកម្មសិទ្ធិគ្មានសិទ្ធិបោះឆ្នោតប្រភេទ "គ" មិនទទួលបានការធានាភាគលាភនេះទេ។

ក្នុងករណីដែលភាគលាភជាសាច់ប្រាក់ដែលបានប្រកាស មានទំហំតិចជាងភាគលាភអប្បបរមាដែលបានធានា ក.ស.ភ. ត្រូវបែងចែកភាគលាភជាភាគហ៊ុនប្រភេទ "ក" ថ្មី ជូនម្ចាស់ភាគហ៊ុនប្រភេទ "ក" ដោយគណនាចំនួនភាគហ៊ុនដែលត្រូវផ្តល់ ស្មើនឹងទំហំភាគលាភអប្បបរមាដែលនៅសល់ ចែកនឹងថ្លៃបិទផ្សារនៅថ្ងៃជួញដូរ ១ថ្ងៃមុនថ្ងៃ អិចឌីវីឌិនដ៍ (Ex-Dividend Date)។ បើភាគលាភអប្បបរមាដែលធានាចំពោះម្ចាស់ភាគហ៊ុនប្រភេទ "ក" មិនត្រូវបានបង់ពេញនៅក្នុងឆ្នាំសារពើពន្ធ ដោយសារទំហំភាគលាភសរុបប្រចាំឆ្នាំអាចធ្វើការបែងចែកត្រឹមតែស្មើនឹងទំហំប្រាក់ចំណេញ ដែលមានសម្រាប់ការបែងចែកភាគលាភនោះភាគលាភដែលមិនបានបង់នឹងត្រូវបង្គរទៅឆ្នាំសារពើពន្ធបន្តបន្ទាប់ទៀត។ មានន័យថា ភាគលាភអប្បបរមាដែលត្រូវបានធានាសម្រាប់ឆ្នាំបន្តបន្ទាប់នឹងត្រូវកើនឡើង ដោយចំនួននៃភាគលាភដែលមិនទាន់បានបង់នៅឆ្នាំមុន។

ទំហំប្រាក់ចំណេញដែលមានសម្រាប់ការបែងចែកភាគលាភ គឺជាទំហំទឹកប្រាក់ដែលនៅសល់បន្ទាប់ពីធ្វើការលៃបម្រុងទុកដែលត្រូវបានកំណត់ដោយលក្ខន្តិកៈស្តីពីការបែងចែកប្រាក់ចំណេញ។

ក្រោយពីបានអនុម័តលើគណនីប្រចាំឆ្នាំ បើពិនិត្យឃើញថាមានប្រាក់ចំណេញ ក្រុមប្រឹក្សាភិបាលនៃ ក.ស.ភ. អាចសម្រេចផ្ទេរទឹកប្រាក់ទាំងនោះដើម្បី៖

- កាត់ទូទាត់នូវការខាតបង់កាលពីឆ្នាំសារពើពន្ធមុន
- ក្រោយពីបានទូទាត់នូវការខាតបង់ឆ្នាំសារពើពន្ធមុនហើយ បើនៅមានប្រាក់ចំណេញ នោះក្រុមប្រឹក្សាភិបាលអាចប្រើប្រាស់ប្រាក់ចំណេញនេះសម្រាប់៖
  - ថ្លែងសរសើរដល់ថ្នាក់ដឹកនាំនិងនិយោជិតតាមលក្ខខណ្ឌ៖
    - បើប្រាក់ចំណេញនៅសល់មានចំនួនពី៥% ទៅ១០%នៃចំណាយសរុបរបស់ ក.ស.ភ. ក្នុងឆ្នាំនោះ ត្រូវថ្លែងសរសើរស្មើមួយ (១) ខែនៃប្រាក់បៀវត្សរ៍សរុបជាមធ្យមប្រចាំឆ្នាំ
    - បើប្រាក់ចំណេញនៅសល់មានចំនួនពី១១% ទៅ២០% នៃចំណាយសរុបរបស់ ក.ស.ភ. ក្នុងឆ្នាំនោះថ្លែងសរសើរស្មើពីរ (២) ខែនៃប្រាក់បៀវត្សរ៍សរុបជាមធ្យមប្រចាំឆ្នាំ
    - បើប្រាក់ចំណេញលើសពី២១% នៃចំណាយសរុបរបស់ ក.ស.ភ. ក្នុងឆ្នាំនោះ ត្រូវថ្លែងសរសើរ ស្មើបី (៣) ខែនៃប្រាក់បៀវត្សរ៍សរុបជាមធ្យមប្រចាំឆ្នាំ។

- បង្កើតមូលនិធិបម្រុងតាមច្បាប់ចំនួន ៥% នៃប្រាក់ចំណេញដែលនៅសល់ក្រោយពីការបែងចែក សម្រាប់ការថ្លែងសរសេរខាងលើ
- បង្កើតមូលនិធិបម្រុងសេរីចំនួន ៥% នៃប្រាក់ចំណេញ ដែលនៅសល់ក្រោយពីការបែងចែកសម្រាប់ ការថ្លែងសរសេរខាងលើ
- បង្កើតមូលនិធិអភិវឌ្ឍន៍ ក.ស.ភ.។

ចំនួនប្រាក់ចំណេញ ដែលនៅសល់ក្រោយការបែងចែកខាងលើ ត្រូវបែងចែកជាភាគលាភ ទៅឱ្យម្ចាស់ភាគហ៊ុន ទៅតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល ដោយអនុលោមតាមលក្ខខណ្ឌ ដូចមានចែងក្នុងលក្ខន្តិកៈរបស់ ក.ស.ភ.។

**ឆ-២- ព័ត៌មានប្រវត្តិសាស្ត្រអំពីការបែងចែកភាគលាភក្នុងរយៈពេល ៣ (បី) ឆ្នាំចុងក្រោយ**

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ក.ស.ភ. ពុំទាន់បានបែងចែកភាគលាភជូនភាគហ៊ុនិករបស់ខ្លួននៅឡើយទេ។

## ២- **អង្គភាពលេខ**(គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥)



## ៣- ក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការនានា

### ក- សមាសភាពក្រុមប្រឹក្សាភិបាល

| ល.រ | ឈ្មោះអភិបាល | តំណែង | កាលបរិច្ឆេទ ក្លាយជាអភិបាល | កាលបរិច្ឆេទ បញ្ចប់អាណត្តិបច្ចុប្បន្ន |
|---|---|---|---|---|
| ១. | ឯកឧត្តម **ហ៊ី បាវី** | ប្រធាន | ១៨ កុម្ភៈ ២០១៣ | ១៨ កុម្ភៈ ២០១៦ |
| ២. | ឯកឧត្តម **សួន រចនា** | សមាជិក | ១៨ កុម្ភៈ ២០១៥ | ១៨ កុម្ភៈ ២០១៦ |
| ៣. | ឯកឧត្តម **លី ស៊ីវណ្ណា** | សមាជិក | ១៨ កុម្ភៈ ២០១៣ | ១៨ កុម្ភៈ ២០១៦ |
| ៤. | ឯកឧត្តម **កែន សម្បត្តិ** | សមាជិក | ១៨ កុម្ភៈ ២០១៣ | ១៨ កុម្ភៈ ២០១៦ |
| ៥. | ឯកឧត្តម **ប៉ែន សុវិជាតិ** | សមាជិក | ២៨ មេសា ២០១៤ | ១៨ កុម្ភៈ ២០១៦ |
| ៦. | លោក **ហួត ហៃ** | សមាជិក | ១៨ កុម្ភៈ ២០១៣ | ១៨ កុម្ភៈ ២០១៦ |
| ៧. | ឯកឧត្តម **ព្រុំ សុខានី** | សមាជិក | ១៨ កុម្ភៈ ២០១៣ | ១៨ កុម្ភៈ ២០១៦ |

*ឈ្មោះលេខាធិការរបស់កំពង់ផែស្វយ័តភ្នំពេញ គឺលោក **គង់ ចាន់នី** ប្រធានលេខាធិការដ្ឋាន។*

### ខ- ប្រសិនបើអភិបាលណាម្នាក់ ជាអភិបាល ជាភាគហ៊ុនិក ជាកម្មសិទ្ធិករ ឬសហាកម្មសិទ្ធិកររបស់ក្រុមហ៊ុន ឬរបស់សហគ្រាសផ្សេងទៀត

| ល.រ | ឈ្មោះរបស់អភិបាល | ឈ្មោះក្រុមហ៊ុនពាក់ព័ន្ធ | អភិបាល ឬភាគហ៊ុនិក ឬកម្មសិទ្ធិករ ឬសហាកម្មសិទ្ធិករ |
|---|---|---|---|
| ១ | ឯកឧត្តម **សួន រចនា** | ក្រុមហ៊ុន Star Shipping | ភាគហ៊ុនិក |

### គ- តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលមានតួនាទី និងភារកិច្ចកំណត់ទិសដៅអភិវឌ្ឍន៍ និងត្រួតពិនិត្យការគ្រប់គ្រងទូទៅរបស់ ក.ស.ភ.។ ក្នុងក្របខ័ណ្ឌនេះ ក្រុមប្រឹក្សាភិបាល មានអំណាចៈ

- សម្រេចលើផែនការអភិវឌ្ឍន៍ ក្នុងក្របខ័ណ្ឌនៃការតម្រង់ទិស កំណត់ដោយរាជរដ្ឋាភិបាល
- ពិនិត្យអនុម័តផែនការអាជីវកម្ម សេវាកម្ម ផែនការហិរញ្ញវត្ថុ និងវិនិយោគរបស់ ក.ស.ភ.
- អនុម័តលើរបាយការណ៍ សកម្មភាពការងារ និងរបាយការណ៍គណនេយ្យ ហិរញ្ញវត្ថុប្រចាំឆ្នាំ
- កំណត់ការចាត់ចែង និងភារកិច្ចទូទៅរបស់ ក.ស.ភ.
- ចាត់ចែងឱ្យដំណើរការនូវគណៈកម្មាធិការ និងគណៈកម្មការដូចមានកំណត់ដោយអត្ថបទស្ដីពីការបង្កើត ក.ស.ភ. ឬដោយលក្ខន្តិកៈរបស់ ក.ស.ភ. និងបង្កើតបន្ថែមទៀតប្រសិនបើចាំបាច់
- សម្រេចចំនួនក្របខ័ណ្ឌបុគ្គលិក ដែលអនុញ្ញាតសម្រាប់ ក.ស.ភ.
- វាយតម្លៃក្នុងចន្លោះពេលទៀងទាត់នូវកម្រិតទំហំនៃការធ្វើឱ្យសម្រេចនូវគោលដៅដែលកំណត់ដោយ ក.ស.ភ. និងដាក់ចុះនូវវិធានការសម្រាប់កែលម្អចាំបាច់

- សម្រេចតាមសំណើរបស់អគ្គនាយក នូវរចនាសម្ព័ន្ធ និងបទបញ្ជាផ្ទៃក្នុងរបស់ ក.ស.ភ. ព្រមទាំងលក្ខន្តិកៈ និងកាំបៀវត្សរ៍ ប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភផ្សេងៗ និងលាភការសម្រាប់បុគ្គលិក ដោយអនុលោមតាមច្បាប់ និងបទបញ្ញាត្តិទាំងឡាយជាធរមាន
- កំណត់របបផែនការជ្រើសរើស ការតម្លើងឋានៈ និងការផ្តល់លាភការសម្រាប់ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់
- ជ្រើសរើស និងកំណត់លាភការសម្រាប់ផ្តល់ឱ្យស្នងការគណនី
- ធ្វើសំណើកែសម្រួលលក្ខន្តិកៈ
- កំណត់ថ្លៃឈ្នួលពាក់ព័ន្ធនឹងការធ្វើអាជីវកម្ម សេវាកម្មលើកំពង់ផែ
- អនុម័តលើលទ្ធកម្មនានា យោងតាមច្បាប់ និងបទបញ្ញាត្តិជាធរមាន
- សម្រេចលើការបើក និងបិទគ្រប់ការិយាល័យ សេវាដ្ឋាន សាខា ទីភ្នាក់ងារ ឬតំណាងទាំងអស់ដែលចាំបាច់សម្រាប់អនុវត្តឱ្យសម្រេចគោលដៅ និងភារកិច្ចរបស់ ក.ស.ភ.
- អនុម័តរាល់កិច្ចសន្យាទាំងឡាយណាដែលពុំអាចអនុវត្តតាមតារាងថ្លៃឈ្នួល និងតាមប្រកាសស្តីពីការគ្រប់គ្រងលទ្ធកម្មនៃសហគ្រាសសាធារណៈ ដែលអគ្គនាយកឆ្លងយោបល់ក្រុមប្រឹក្សាភិបាល។

# ក្រុមប្រឹក្សាភិបាល



ឯកឧត្តម **ហ៊ី បាទី**
**ប្រធានក្រុមប្រឹក្សាភិបាល**
**អគ្គនាយកកំពង់ផែស្វយ័តភ្នំពេញ**

ជនជាតិខ្មែរ សញ្ជាតិខ្មែរ ឯកឧត្តម កើតនៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៥៥ និងបានទទួលសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនៅវិទ្យាល័យដូនពេញ ក្នុងឆ្នាំ១៩៧៤ សញ្ញាបត្រអនុបណ្ឌិតផ្នែករដ្ឋបាលធុរកិច្ចពីសកលវិទ្យាល័យ Charles Sturt ប្រទេសអូស្ត្រាលី ក្នុងឆ្នាំ២០០៨ និងសញ្ញាបត្របណ្ឌិតផ្នែកវិទ្យាសាស្ត្រសេដ្ឋកិច្ច ពីសកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យាកម្ពុជា ក្នុងឆ្នាំ២០០៩។ ពីឆ្នាំ២០០០ ដល់បច្ចុប្បន្ន ឯកឧត្តមបម្រើការងារជាអគ្គនាយក និងជាប្រធានក្រុមប្រឹក្សាភិបាល។



ឯកឧត្តម **សួន រចនា**
**សមាជិកក្រុមប្រឹក្សាភិបាល**
**តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន**

ជនជាតិខ្មែរ សញ្ជាតិខ្មែរ ឯកឧត្តមកើតនៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ១៩៥៤ និងបានបញ្ចប់ការសិក្សាសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ពីវិទ្យាល័យ ១៨ មីនា (បច្ចុប្បន្នវិទ្យាល័យព្រះយុគន្ធរ) ភ្នំពេញ ក្នុងឆ្នាំ១៩៧៣។ ក្នុងឆ្នាំ១៩៧៥ ឯកឧត្តម បានបញ្ចប់ការសិក្សាពីមហាវិទ្យាល័យវេជ្ជសាស្ត្រ។ ពីឆ្នាំ២០០៩ ដល់បច្ចុប្បន្ន ឯកឧត្តម បំពេញតួនាទីជារដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន និងជាសមាជិកក្រុមប្រឹក្សាភិបាល នៃ ក.ស.ភ. អាណត្តិទី៥ ចាប់ពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៥ រហូតមកដល់បច្ចុប្បន្ន។



ឯកឧត្តម **លី ស៊ីវណ្ណា**

**សមាជិកក្រុមប្រឹក្សាភិបាល**

**តំណាងទីស្តីការគណៈរដ្ឋមន្ត្រី**

ជនជាតិខ្មែរ សញ្ជាតិខ្មែរ ឯកឧត្តមកើតនៅថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៥៥ និងបញ្ចប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (ផ្នែកវិទ្យាសាស្ត្រ) វិទ្យាល័យ១៨មីនា (បច្ចុប្បន្នព្រះយុគន្ធរ) នៅឆ្នាំ១៩៧៤។ ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៤ ឯកឧត្តម បំពេញតួនាទីជាអគ្គលេខាធិការរងនៃក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី និងពីឆ្នាំ២០១៤ ដល់បច្ចុប្បន្ន ជាទីប្រឹក្សាអមទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិកចំណុចការងារតាមដាន ត្រួតពិនិត្យ និងការរាយការណ៍បទល្មើសព្រៃឈើនៃទីស្តីការគណៈរដ្ឋមន្ត្រី និងជាសមាជិកនៃលេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ។ ឯកឧត្តមជាសមាជិកក្រុមប្រឹក្សាភិបាលនៃ ក.ស.ភ. អាណត្តិទី៥ ចាប់ពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៣ រហូតមកដល់បច្ចុប្បន្ន។



ឯកឧត្តម **កែន សម្បត្តិ**

**សមាជិកក្រុមប្រឹក្សាភិបាល**

**តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

ជនជាតិខ្មែរ សញ្ជាតិខ្មែរ ឯកឧត្តមកើតនៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ១៩៦៨ និងទទួលបានសញ្ញាបត្រអនុបណ្ឌិតផ្នែកសេដ្ឋកិច្ច ពីសកលវិទ្យាល័យ Lomonosov State ប្រទេសរុស្ស៊ី ក្នុងឆ្នាំ១៩៩៥។ សញ្ញាបត្រអនុបណ្ឌិត ផ្នែកគោលនយោបាយសាធារណៈ ពីសកលវិទ្យាល័យ Saitama ប្រទេសជប៉ុន ក្នុងឆ្នាំ២០០០ និងសញ្ញាបត្របណ្ឌិតផ្នែកសេដ្ឋកិច្ចពីសកលវិទ្យាល័យ International ប្រទេសអង់គ្លេស ក្នុងឆ្នាំ២០០៨។ ចាប់ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៣ ឯកឧត្តម បំពេញតួនាទីជាទីប្រឹក្សា និងនាយករងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងពីឆ្នាំ២០១៣ ដល់បច្ចុប្បន្ន ជាទីប្រឹក្សា និងនាយកខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រីប្រចាំការប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអនុប្រធានទី១ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ជាអគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ។ ឯកឧត្តម ជាសមាជិកក្រុមប្រឹក្សាភិបាលនៃក.ស.ភ. អាណត្តិទី៥ ចាប់ពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៣ រហូតមកដល់ បច្ចុប្បន្ន។



ឯកឧត្តម **ប៉ែន សុវិជាតិ**

**សមាជិកក្រុមប្រឹក្សាភិបាល**

**តំណាងក្រសួងពាណិជ្ជកម្ម**

ជនជាតិខ្មែរ សញ្ជាតិខ្មែរ ឯកឧត្តម កើតនៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ១៩៦៣ និងទទួលបានបរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច ពីវិទ្យាស្ថានសេដ្ឋកិច្ច ប្រទេសកម្ពុជា នៅក្នុងឆ្នាំ១៩៩០ ព្រមទាំង បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកពាណិជ្ជសាស្ត្រ ពីសកលវិទ្យាល័យ New England ប្រទេសអូស្ត្រាលីក្នុងឆ្នាំ១៩៩៧។ ចាប់ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០០០ ឯកឧត្តមបានបំពេញតួនាទីជាអនុប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម។ ពីឆ្នាំ២០០០ ដល់ឆ្នាំ២០០៧ ឯកឧត្តមជាអនុប្រធាននាយកដ្ឋានកម្មសិទ្ធិបញ្ញា និង ពីឆ្នាំ២០០៧ ដល់ឆ្នាំ២០១២ ឯកឧត្តមជាប្រធាននាយកដ្ឋានផ្តល់ព័ត៌មាន និងផ្ទៀងផ្ទាត់ច្បាប់នៃក្រសួងពាណិជ្ជកម្ម ។ ចាប់ពីដើមឆ្នាំ២០១២ ដល់ឆ្នាំ២០១៤ ឯកឧត្តមបានបម្រើការងារជាអគ្គនាយករងនៃអគ្គនាយកដ្ឋានពាណិជ្ជកម្មក្នុងប្រទេស ហើយពីឆ្នាំ២០១៤ ដល់បច្ចុប្បន្ន ឯកឧត្តមត្រូវបានតម្លើងតួនាទីជាអគ្គនាយកពាណិជ្ជកម្មក្នុងប្រទេសនៃក្រសួងពាណិជ្ជកម្ម។ ឯកឧត្តម មានបទពិសោធន៍ជាអ្នកចរចាពាណិជ្ជកម្ម និងជាសមាជិកក្រុមការងារចរចារបស់កម្ពុជា ក្នុងការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក និងជាសមាជិកក្រុមការងារនៃការចរចាអាស៊ាន និងវេទិកាដទៃទៀត។ បច្ចុប្បន្ននេះ ឯកឧត្តម ជាសមាជិកគណៈកម្មាធិការជាតិគ្រប់គ្រងកម្មសិទ្ធិបញ្ញាកម្ពុជា។ ឯកឧត្តម ជាសមាជិកក្រុមប្រឹក្សាភិបាល នៃ ក.ស.ភ. អាណត្តិទី៥ ចាប់ពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៤ រហូតមកដល់បច្ចុប្បន្ន។



លោក **ហួត ហៃ**

**សមាជិកក្រុមប្រឹក្សាភិបាល**

**តំណាងសាលារាជធានីភ្នំពេញ**

ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោកកើតនៅថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៧៥ និងទទួលបានបរិញ្ញាបត្រផ្នែកច្បាប់ មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងជាមន្ត្រីថ្នាក់មធ្យមសាលាភូមិន្ទរដ្ឋបាល (ERA) ក្នុងឆ្នាំ១៩៩៨។ ក្នុងឆ្នាំ២០០៥ លោកទទួលបានសញ្ញាបត្រអនុបណ្ឌិតផ្នែកច្បាប់ពីសកលវិទ្យាល័យ Nagoya ប្រទេសជប៉ុន ហើយបច្ចុប្បន្ន លោកជាបេក្ខបណ្ឌិតច្បាប់ឆ្នាំទី៣ សកលវិទ្យាល័យបៀលប្រាយ។ ពីឆ្នាំ២០០៩ ដល់បច្ចុប្បន្ន លោកបំពេញតួនាទីជា នាយករងរដ្ឋបាល នៃសាលារាជធានីភ្នំពេញ និងជាសមាជិកក្រុមប្រឹក្សាភិបាល នៃ ក.ស.ភ. អាណត្តិទី៥ ចាប់ពីថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៣ រហូតមកដល់បច្ចុប្បន្ន។



ឯកឧត្តម **ព្រុំ សុខានី**
**សមាជិកក្រុមប្រឹក្សាភិបាល**
**តំណាងនិយោជិត ក.ស.ភ**

ជនជាតិខ្មែរ សញ្ជាតិខ្មែរ ឯកឧត្តម កើតនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៥៦ ។ នៅឆ្នាំ១៩៨៩ ឯកឧត្តម ទទួលបានបរិញ្ញាបត្រសេដ្ឋកិច្ចឯកទេសផែនការ ពីវិទ្យាស្ថានសេដ្ឋកិច្ច បន្ទាប់មក នៅឆ្នាំ២០០៤ ឯកឧត្តម ទទួលបានសញ្ញាបត្រអនុបណ្ឌិតគ្រប់គ្រងពាណិជ្ជសាស្ត្រ ពីសកលវិទ្យាល័យជាតិគ្រប់គ្រង និងពីឆ្នាំ២០០៧ ដល់ឆ្នាំ២០០៥ ឯកឧត្តមជាបេក្ខបណ្ឌិតផ្នែកទស្សនវិជ្ជា ជំនាញរដ្ឋបាលសាធារណៈ នៅសកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា។ នៅឆ្នាំ១៩៩២ ឯកឧត្តមបានចូលបម្រើការងារនៅ ក.ស.ភ.។ ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១០ ឯកឧត្តម ជាប្រធានការិយាល័យគណនេយ្យ និងក្រោយមក ជាប្រធានសេវាដ្ឋានឃ្លាំងទំនិញ។ ពីឆ្នាំ២០១០ ដល់ខែឧសភា ឆ្នាំ២០១៥ ឯកឧត្តម ជានាយកប្រតិបត្តិការផែ TS៣ និងក្រោយមក ជានាយកជលធារសាស្ត្រ។ ពីខែកក្កដា ឆ្នាំ២០១៥ រហូតដល់បច្ចុប្បន្ន ឯកឧត្តមជាអគ្គនាយករងទទួលបច្ចេកទេស។

**ឃ- សេចក្តីសម្រេច និងលទ្ធផលការងាររបស់ក្រុមប្រឹក្សាភិបាល**

ក្នុងឆ្នាំ២០១៥ ក្រុមប្រឹក្សាភិបាលកំពង់ផែស្វយ័តភ្នំពេញអាណត្តិទី៥ បានជួបប្រជុំដើម្បីពិនិត្យ និងសម្រេចលើការងារដូចខាងក្រោម៖

➢ **ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៥**

ក្រុមប្រឹក្សាភិបាល បានជួបប្រជុំដើម្បីពិនិត្យ និងសម្រេចលើការងារដូចខាងក្រោម៖

- ពិនិត្យ និងឆ្លងរបាយការណ៍បូកសរុបការងារអាជីវកម្ម/សេវាកម្មប្រចាំឆ្នាំ២០១៤ (ឯកភាព)
- ពិនិត្យ និងឆ្លងរបាយការណ៍បិទបញ្ជីគណនេយ្យ សម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៤ (ទទួលស្គាល់ជ្រាបជារបាយការណ៍)
- ពិនិត្យ និងពិភាក្សាលើការបែងចែកប្រាក់ចំណេញ ការិយបរិច្ឆេទឆ្នាំ២០១៤ ចូលក្នុងមូលនិធិនានារបស់ ក.ស.ភ. ព្រមទាំងកំណត់ប្រាក់រង្វាន់សរសើរជូនក្រុមប្រឹក្សាភិបាល ក្រុមលេខា និងបុគ្គលិកស្មើនឹង២ខែនៃប្រាក់បៀវត្សរ៍ និងបានពិនិត្យពិភាក្សាលើលទ្ធផលប្រាក់ចំណេញ និងការបែងចែកប្រាក់ចំណេញ ចូលមូលនិធិនានាឡើងវិញ សម្រាប់ការិយបរិច្ឆេទរយៈពេល ០៥ ឆ្នាំ (២០០៩ ដល់ ២០១៣) ដែលរៀបចំដោយក្រុមហ៊ុន Premier និងសម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៤ ដែលរៀបចំឡើងដោយក្រុមហ៊ុន Grant Thornton (ឯកភាព)
- ពិនិត្យ និងពិភាក្សាលើលទ្ធផលនៃការវាយតម្លៃអចលនទ្រព្យឆ្នាំ២០០៩ របស់ ក.ស.ភ. ដោយក្រុមហ៊ុន VTrust (ទទួលស្គាល់ជ្រាបជារបាយការណ៍)
- ពិនិត្យ និងពិភាក្សាលើការផ្ទេរចេញពីបញ្ជីសារពើភ័ណ្ឌអចលនទ្រព្យរបស់ ក.ស.ភ. នូវម៉ាស៊ីនស្កែនន័រមួយគ្រឿងដែលជាជំនួយឥតសំណងពីរដ្ឋាភិបាលចិន (ឯកភាព)

- ពិនិត្យ និងពិភាក្សាលើការជ្រើសរើសយកក្រុមហ៊ុនគណនេយ្យ Grant Thornton ដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ឆ្នាំ២០១៤ និងត្រីមាសទី១ ឆ្នាំ២០១៥ ព្រមទាំងការងាររៀបចំគោលនយោបាយ និងនីតិវិធីគណនេយ្យជូន ក.ស.ភ. (ឯកភាព)
- ពិនិត្យ និងពិភាក្សាលើសំណើសុំគោលការណ៍សម្រេចពីក្រសួងអាណាព្យាបាលទាំងពីរ (ក្រសួងសាធារណការ និងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ចំពោះការជួលដីទំហំ ៩.៥ហិកតាឲ្យក្រុមហ៊ុន Daiwa Lease Co., Ltd. និងការស្នើសុំទិញដីទំហំ ២ ហិកតា បន្ថែមវិញ (ឯកភាព)
- ពិភាក្សាលើសំណើសុំទៅអគ្គនាយកដ្ឋានពន្ធដារ ដើម្បីស្នើសុំឲ្យចេញលិខិតបញ្ជាក់ថា ក.ស.ភ. ពុំមានបំណុលពន្ធនៅសេសសល់ទៀតទេ សម្រាប់រយៈពេល ៥ ឆ្នាំ (២០០៩-២០១៣) ដើម្បីទុកជាភស្តុតាងជូនខាងក្រុមហ៊ុនសវនកម្មឯករាជ្យចុះមកធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ (ឯកភាព)
- ពិនិត្យ និងពិភាក្សាលើដំណើរការបណ្តុះបណ្តាលផ្នែកនាវាចរណ៍របស់វិទ្យាស្ថាននាវាចរណ៍កម្ពុជា (ទទួលស្គាល់ជ្រាបជារបាយការណ៍)
- ពិនិត្យ និងពិភាក្សាលើវឌ្ឍនភាពនៃដំណើរការរៀបចំបែបបទក្នុងការស្នើសុំការអនុញ្ញាតបង្កើតតំបន់សេដ្ឋកិច្ចពិសេសរបស់ ក.ស.ភ. (ទទួលស្គាល់ជ្រាបជារបាយការណ៍)
- ពិនិត្យ និងពិភាក្សាលើការស្នើសុំការគិតតម្លៃ Lump Sum ចំពោះនាវាទេសចរណ៍ និងនាវាលើកដាក់ទំនិញ (ឯកភាព)
- ពិនិត្យ និងពិភាក្សាលើការកែសម្រួលឡើងវិញសមាសភាពនៃលេខាធិការដ្ឋានក្រុមប្រឹក្សាភិបាល ក.ស.ភ. (ទទួលស្គាល់ជ្រាបជារបាយការណ៍)
- ពិនិត្យ និងពិភាក្សាលើការស្នើសុំផ្តល់ប្រាក់បៀវត្សរ៍ ប្រាក់លាភការ ប្រាក់ទូរស័ព្ទ ប្រេងឥន្ធនៈ និងប្រាក់ឧបត្ថម្ភផ្សេងៗទៀតជូនប្រធានការិយាល័យចំនួន ៤ ស្មើនឹងថ្នាក់នាយករងមាន ប្រធានការិយាល័យគណនេយ្យ/ហិរញ្ញវត្ថុ, ប្រធានការិយាល័យបុគ្គលិក, ប្រធានការិយាល័យសវនកម្មផ្ទៃក្នុង និងប្រធានការិយាល័យសុវត្ថិភាព សុខមាលភាព និងបរិស្ថានផៃ (SHE) (ឯកភាព)។

➢ **ថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥**

- ក្រុមប្រឹក្សាភិបាលបានប្រជុំវិសាមញ្ញ ដើម្បីពិភាក្សា និងសម្រេចលើការជួលដីរយៈពេលវែងពីម្ចាស់ដីនៅក្បែរតំបន់សេដ្ឋកិច្ចពិសេស លើផ្ទៃដីទំហំប្រមាណ ១.០០០ (មួយពាន់) ហិកតា ដែលមានទីតាំងនៅភូមិកណ្តាលក្រោម ឃុំបន្ទាយដែក និងភូមិជ័យឧត្តម ភូមិជ្រោយដង ភូមិស្ទឹង ភូមិព្រៃកត្រែង ភូមិសំពោងក្អែរ ឃុំសំពោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល (បានឯកភាពដោយមតិភាគច្រើន)។

➢ **ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥**

ក្រុមប្រឹក្សាភិបាល បើកការប្រជុំពិនិត្យ និងសម្រេចលើការងារដូចខាងក្រោម៖

- ពិនិត្យ និងពិភាក្សាលើការធានានូវអត្រាទិន្នផលភាគលាភធានាជូនវិនិយោគិនសាធារណៈ ប្រចាំឆ្នាំយ៉ាងទាបបំផុត គឺ ៥% ក្នុងរយៈពេល 0៥ ឆ្នាំ (ឯកភាព)
- ពិនិត្យ និងពិភាក្សាលើកម្រៃសេវាអប្បបរមារបស់ក្រុមហ៊ុន យាន់តា ស៊ីយ្យូរីធី ជាក្រុមហ៊ុនធានាទិញមូលបត្ររបស់ ក.ស.ភ. ចំនួន ៧៥០.០០០,០០ (ប្រាំពីររយ ហាសិបពាន់ ដុល្លារអាមេរិក) និងសុំគោលការណ៍សម្រេចលើកំរៃសេវានេះទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ឯកភាព)

- ពិនិត្យ និងពិភាក្សាលើសំណើសុំមិនកត់ត្រាទឹកប្រាក់ចំនួន ១.៩៩០.១២៩.២០០,០០ រៀល ដែលជាចំណែកមួយនៃពន្ធលើការនាំចូលគ្រឿងចក្រ TCC គ្រឿងចក្រ RTG និង Reach Stacker ជាចំណាយក្នុងឆ្នាំ២០១២ (ឯកភាព)
- ពិនិត្យ និងពិភាក្សាលើការស្នើទិញរថយន្ត Pick Up ចំនួន៣ គ្រឿង និងអូប័រចម្លងចំនួន ២ គ្រឿង សម្រាប់បម្រើឲ្យការងារអាជីវកម្មបូមស្តារប្រឡាយនាវាចរណ៍ ប្រយោជន៍យកខ្សាច់ផ្គត់ផ្គង់ការប្រើប្រាស់ក្នុងស្រុក និងការងារវាស់ស្ទង់ (ឯកភាព)
- ពិនិត្យ និងពិភាក្សាលើតម្លៃសេវាកម្មរបស់ក្រុមហ៊ុនឯកជនសិក្សាផលប៉ះពាល់បរិស្ថាន (EIA) និងលើការស្នើបញ្ចូលខ្ទង់ចំណាយលើការងារសិក្សាផលប៉ះពាល់បរិស្ថាន (EIA) សម្រាប់ទីតាំងប្រឡាយឡូតិ៍ខ្សាច់ចំនួន ២ កន្លែង ដែល ក.ស.ភ. ទទួលបានអាជ្ញាបណ្ណពីក្រសួងរ៉ែ និងថាមពល ចូលក្នុងផែនការឆ្នាំ ២០១៦ ខាងមុខ (ឯកភាព)
- ពិនិត្យ និងពិភាក្សាលើការស្នើទិញសម្ភារ និងវិធានវាស់ស្ទង់ដើម្បីឆ្លើយតបនឹងតម្រូវការសម្រាប់បម្រើឲ្យការងារអាជីវកម្មវាស់ស្ទង់របស់ ក.ស.ភ. (ឯកភាព)
- ពិនិត្យ និងពិភាក្សាលើការស្នើឲ្យលោកជំទាវ **គីម សែន** ជាអគ្គនាយករងរដ្ឋបាល និងកញ្ញា **ឈាវ វណ្ណធា** ជាប្រធានការិយាល័យគណនេយ្យ/ហិរញ្ញវត្ថុ ជាតំណាង ក.ស.ភ. ដើម្បីធ្វើទំនាក់ទំនងជាធនាគារពាណិជ្ជកម្មក្រៅប្រទេសនៃកម្ពុជា (FTB) ក្នុងការខ្ចីចងការប្រាក់ សម្រាប់ទិញនូវគ្រឿងចក្រលើកដាក់បន្ថែមទៀតសម្រាប់ប្រតិបត្តិការនៅចំណតផែកុងតឺន័រ LM១៧ (ឯកភាព)។

➤ **ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៥**

ក្រុមប្រឹក្សាភិបាល បើកការប្រជុំពិនិត្យ និងសម្រេចលើការងារដូចខាងក្រោម៖
- ពិនិត្យ និងពិភាក្សាលើលទ្ធផលរបាយការណ៍សវនកម្មរបស់ក្រុមហ៊ុនសវនកម្មឯករាជ្យ KPMG និងលើការស្នើបញ្ចូលប្រាក់ចំណេញរក្សាទុក (Retained Earning) ចូលទៅក្នុងដើមទុន (Share Capital) ចាប់ពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ (ឯកភាព)
- ពិនិត្យ និងពិភាក្សាលើលទ្ធផលអាជីវកម្ម/សេវាកម្មរយៈពេល ៦ខែ ដើមឆ្នាំ២០១៥ និងលទ្ធផលហិរញ្ញវត្ថុរយៈពេល ៦ខែ ដើមឆ្នាំ២០១៥ (ទទួលស្គាល់ជ្រាបជារបាយការណ៍)
- ពិនិត្យ និងពិភាក្សាលើការស្នើសុំជាគោលការណ៍ឲ្យ ក.ស.ភ. បោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (IPO) ចំនួន ២០% នៅលើផ្សារមូលបត្រកម្ពុជា (ឯកភាព)
- ពិនិត្យ និងសម្រេចលើការតែងតាំង ឯកឧត្តម **ហ៊ី បាវី** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាប្រធានអគ្គនាយក ក.ស.ភ. ជាអ្នកតំណាងស្របច្បាប់ឲ្យ ក.ស.ភ. ក្នុងការបំពេញតួនាទីត្រួតពិនិត្យ និងចុះហត្ថលេខាលើឯកសារពាក់ព័ន្ធនឹងដំណើរការ IPO (ឯកភាព)
- ពិនិត្យ និងសម្រេចលើការបង់ភាគលាភជាបណ្តោះអាសន្ន តាមគម្រោងចំណូលថវិការដ្ឋ ឆ្នាំ២០១៦ និងស្នើសុំបង្វែរការបង់ភាគលាភលើប្រាក់ចំណេញ ជូនរដ្ឋទៅជាការបង់ភាគលាភលើប្រាក់ចំណេញតាមសមាមាត្រនៃការកាន់កាប់ភាគហ៊ុន ដូចម្ចាស់ភាគហ៊ុនឯកជនដទៃទៀត បន្ទាប់ពីចូល IPO (ឯកភាព)
- ពិនិត្យ និងពិភាក្សាលើការកំណត់មូលដ្ឋាននៃការគិតតម្លៃវាស់ស្ទង់ សម្រាប់ផ្តល់សេវាជូនដល់ក្រសួងរ៉ែ និងថាមពល និងក្រុមហ៊ុនឯកជនមួយចំនួនទៀត (ឯកភាព)

- ពិនិត្យ និងពិភាក្សាលើការស្នើទិញរថយន្តទំនើប ១ គ្រឿង សម្រាប់ទុកទទួលភ្ញៀវអន្តរជាតិដែលអញ្ជើញមកទំនាក់ទំនងការងារជាមួយ ក.ស.ភ. (ឯកភាព)។

- **ថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៥**

  ក្រុមប្រឹក្សាភិបាល បើកការប្រជុំពិនិត្យ និងសម្រេចលើការងារដូចខាងក្រោម៖

  - ពិនិត្យ និងពិភាក្សាលើការកំណត់តម្លៃមូលធនូបនីយកម្មទីផ្សាររបស់ ក.ស.ភ. រចនាសម្ព័ន្ធនៃការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈលើកដំបូង (IPO) និងរចនាសម្ព័ន្ធនៃមូលធនរបស់ ក.ស.ភ. (ឯកភាព)
  - ពិនិត្យ និងពិភាក្សាលើការស្នើកំណត់ចំនួនមូលបត្រកម្មសិទ្ធិដែលអាចធ្វើការបោះផ្សាយលក់បាន (Authorized Shares) (ឯកភាព)
  - ពិនិត្យ និងពិភាក្សាលើការស្នើលៃបម្រុងមូលបត្រកម្មសិទ្ធិជូននិយោជិតរបស់ ក.ស.ភ. ចំនួន ១០% នៃមូលបត្រកម្មសិទ្ធិដែលបោះផ្សាយលក់ជាសាធារណៈចំនួន ២០% និងបង្កើតគោលនយោបាយតាមលំនាំរបស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនាពេលកន្លងមក (ឯកភាព)
  - ពិនិត្យ និងពិភាក្សាលើឯកសារផ្តល់ព័ត៌មាន (Disclosure Document) និងឯកសារភ្ជាប់ជាភាសាខ្មែរសម្រាប់ដាក់ជូន គ.ម.ក. ដើម្បីទទួលបានការយល់ព្រមជាគោលការណ៍លើការបោះផ្សាយមូលបត្រ (ឯកភាព)
  - ពិនិត្យ និងពិភាក្សាលើការស្នើជ្រើសរើសយកធនាគារ អេស៊ីលីដា ភីអិលស៊ី ធ្វើជាភ្នាក់ងារបញ្ជិការមូលបត្រ ភ្នាក់ងារផ្ទេរមូលបត្រ និង ភ្នាក់ងារទូទាត់ រួមនឹងជាភ្នាក់ងារទូទាត់សាច់ប្រាក់ពាក់ព័ន្ធនឹងការជួញដូរមូលបត្រ (Cash Settlement Agent) (ឯកភាព)
  - ពិនិត្យ និងពិភាក្សាលើការស្នើសុំជម្រះបញ្ជីរថយន្តស្លាកលេខរដ្ឋ ២៥.២.០៣៧៨ (ឯកភាព)។

- **ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥**

  ក្រុមប្រឹក្សាភិបាល បើកការប្រជុំពិនិត្យ និងសម្រេចលើការងារដូចខាងក្រោម៖

  - ពិភាក្សា និងអនុម័តលក្ខន្តិកៈបច្ចុប្បន្នរបស់ ក.ស.ភ. ដែលត្រូវកែសម្រួលដោយបញ្ចូលបន្ថែមនូវប្រភេទ និងចំនួនភាគហ៊ុនដែលត្រូវធ្វើការបោះផ្សាយ ព្រមទាំងសិទ្ធិ និងលក្ខណៈនៃប្រភេទភាគហ៊ុននីមួយៗ (អនុម័តយល់ព្រម)
  - ពិនិត្យ និងអនុម័តក្រមសីលធម៌ សម្រាប់ក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ ក.ស.ភ. (អនុម័តយល់ព្រម)
  - ពិនិត្យ និងពិភាក្សាលើកិច្ចព្រមព្រៀងធានាទិញមូលបត្ររវាង ក.ស.ភ. និងក្រុមហ៊ុនធានាទិញមូលបត្រ យាន់តា ស៊ីយូរីធី (ឯកភាព)
  - ពិនិត្យ និងពិភាក្សាលើការស្នើសុំបញ្ចុះតម្លៃលើកដាក់លើទីលាន (LOLO) មកត្រឹមតម្លៃ ៣៦ ដុល្លារអាមេរិក ក្នុងមួយទូរសម្រាប់កុងតឺន័រ ២០ ហ្វីត ដែលដឹកអង្ករតាម ក.ស.ភ. ហើយការបញ្ចុះតម្លៃនេះ នឹងត្រូវអនុវត្តចំពោះក្រុមហ៊ុននាំអង្ករចេញ ដែលជាសមាជិកសហព័ន្ធស្រូវអង្ករកម្ពុជា និងគ្រប់ផលិតផលកសិផលផ្សេងៗទៀត លើកលែងតែកៅស៊ូមួយមុខប៉ុណ្ណោះ (ឯកភាព)
  - ពិនិត្យ និងពិភាក្សាលើព័ត៌មានហិរញ្ញវត្ថុសង្ខេបចន្លោះពេល សម្រាប់ត្រីមាសទី១ នៃការិយបរិច្ឆេទឆ្នាំ២០១៥ (ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥) និងរបាយការណ៍របស់សវនកងកររាជ្យ (ឯកភាព)។

➢ **ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៥**

ក្រុមប្រឹក្សាភិបាល បានបើកការប្រជុំដើម្បីពិនិត្យ និងសម្រេចលើការងារដូចខាងក្រោម៖

- ពិភាក្សា និងសម្រេចលើការកំណត់ថ្លៃមូលបត្រកម្មសិទ្ធិរបស់ ក.ស.ភ. ជាមួយក្រុមហ៊ុន យ៉ាន់តាស៊ីយូរីធី សម្រាប់ចុះបញ្ជីលក់លើផ្សារមូលបត្រកម្ពុជា ដែលមានតម្លៃ ៥.១២០ (ប្រាំពាន់ មួយរយម្ភៃ) រៀល ឬ ស្មើនឹង ១,២៥៦ ដុល្លារ (មួយដុល្លារអាមេរិក ពីររយហាសិបប្រាំមួយសេន) ក្នុងមួយមូលបត្រ និងពិភាក្សាអនុម័តលើឯកសារផ្តល់ព័ត៌មានចុងក្រោយជាមួយនឹងថ្លៃលក់មូលបត្រ ស្មើនឹង ៥.១២០ (ប្រាំពាន់ មួយរយម្ភៃ) រៀល ឬ ស្មើនឹង ១,២៥៦ (មួយដុល្លារអាមេរិក ពីររយហាសិបប្រាំមួយ) ក្នុងមួយមូលបត្រ ដើម្បីដាក់ជូន គ.ម.ក. (ឯកភាព)
- ពិនិត្យ និងពិភាក្សាលើលទ្ធផលសម្រេចបានក្នុងរយៈពេល ៩ខែដើមឆ្នាំ២០១៥ របស់ ក.ស.ភ. (ទទួលស្គាល់ជ្រាបជារបាយការណ៍)
- ពិនិត្យ និងពិភាក្សាលើផែនការអាជីវកម្ម/សេវាកម្មរបស់ ក.ស.ភ. សម្រាប់ឆ្នាំ២០១៦ (ឯកភាព)
- ពិនិត្យ និងពិភាក្សាលើការបន្តជួលសេវារបស់ក្រុមហ៊ុនសវនកម្មឯករាជ្យ KPMG សម្រាប់ឆ្នាំ ២០១៥ និងឆ្នាំបន្តបន្ទាប់ ព្រមទាំងសេវាត្រួតពិនិត្យទៅលើស្ថានភាពហិរញ្ញវត្ថុសង្ខេបចន្លោះពេលត្រីមាសនីមួយៗ ក្រោយពេលចូល IPO រួច (ឯកភាព)
- ពិនិត្យ និងពិភាក្សាលើការបន្តជួលសេវារបស់ក្រុមហ៊ុន Ernst & Young Hong Kong សម្រាប់គណនាប្រាក់សោធននិវត្តន៍ សម្រាប់ត្រីមាសទី២ ឆ្នាំ២០១៥ និងប្រចាំឆ្នាំ២០១៥ និងជួលសេវារបស់ក្រុមហ៊ុន PWC នៅប្រទេសសិង្ហបុរី សម្រាប់ធ្វើការបណ្តុះបណ្តាលបុគ្គលិករបស់ ក.ស.ភ. (ឯកភាព)
- ពិនិត្យ និងពិភាក្សាលើការចំណាយផ្សព្វផ្សាយពាណិជ្ជកម្មអំពី IPO របស់ ក.ស.ភ. (ឯកភាព)
- ពិនិត្យ និងពិភាក្សាលើការស្នើសុំទិញរថយន្តទេសចរណ៍ Land Cruiser ថ្មី ចំនួន១ គ្រឿង សម្រាប់ទុកទទួលអតិថិជន ភ្ញៀវជាតិ និងវិនិយោគិនបរទេស ដែលមកទំនាក់ទំនងសួរព័ត៌មានអំពីអាជីវកម្ម និងអំពី IPO របស់ ក.ស.ភ. (ឯកភាព)
- ពិនិត្យ និងពិភាក្សាលើការធ្វើកិច្ចសហប្រតិបត្តិការក្រោមទម្រង់ជា Joint Venture ជាមួយក្រុមហ៊ុន Morning Star Logistic JSC នៃប្រទេសវៀតណាមក្នុងការបង្កើតសេវាកម្មថែទាំ និងជួសជុលសំបកកុងតឺន័រ (ឯកភាព)
- ពិនិត្យ និងពិភាក្សាលើការធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រុមហ៊ុនSung Kwang Heavy Equipment ក្នុងការបំពាក់រថស្ទូច TCC ចំនួន១ គ្រឿងទៀតនៅចំណតផែកុងតឺន័រ LM១៧ (ឯកភាព)
- ពិនិត្យ និងពិភាក្សាការស្នើសុំបង្កើតឲ្យមានសេវាកម្មដឹកជញ្ជូនកុងតឺន័រតាមរថយន្ត ដោយស្នើសុំទិញកុងតឺន័រចំនួន ៦ គ្រឿង ក្នុងឆ្នាំ២០១៥ នេះ សម្រាប់បម្រើសេវាកម្មនេះ ជាដំណាក់កាលសាកល្បង (ឯកភាព)
- ពិនិត្យ និងពិភាក្សាលើការស្នើសុំកែប្រែលើការគិតតម្លៃស្តុកកុងតឺន័រត្រជាក់រវាង ក.ស.ភ. និងក្រុមហ៊ុន PCF (ឯកភាព)
- ពិនិត្យ និងពិភាក្សាលើការស្នើសុំចំណាយប្រាក់លើការជួសជុល និងប្តូរដំបូលអគារនៅអតីតប្លុកយានដ្ឋានស៊ីត្រូអែន និងស្នើសុំបញ្ចូលជាទ្រព្យសម្បត្តិរបស់ ក.ស.ភ. (ឯកភាព)។

### ង- ការបណ្តុះបណ្តាលអភិបាល

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៥ ក.ស.ភ. ពុំមានការបណ្តុះបណ្តាលដល់អភិបាលនោះទេ។

### ច- គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាភិបាល

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៥ ក.ស.ភ. ពុំទាន់បានបង្កើតគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា-ភិបាលនៅឡើយទេ។

## ៤- បុគ្គលិកជាន់ខ្ពស់

### ក- សមាសភាពបុគ្គលិកជាន់ខ្ពស់



ឯកឧត្តម **ហ៊ី បាវី**
**អគ្គនាយកកំពង់ផែស្វយ័តភ្នំពេញ**

ជនជាតិខ្មែរ សញ្ជាតិខ្មែរ ឯកឧត្តម កើតនៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៥៥ និងបានទទួលសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិនៅវិទ្យាល័យដូនពេញ ក្នុងឆ្នាំ១៩៧៤ សញ្ញាបត្រអនុបណ្ឌិតជំនាញរដ្ឋបាលធុរកិច្ច ពីសកលវិទ្យាល័យ Charles Sturt ប្រទេសអូស្រ្តាលី ក្នុងឆ្នាំ២០០៨ និងសញ្ញាបត្របណ្ឌិតផ្នែកវិទ្យាសាស្រ្តសេដ្ឋកិច្ច ពីសកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា។ ពីឆ្នាំ២០០០ ដល់បច្ចុប្បន្ន ឯកឧត្តមបម្រើការងារជាប្រធានអគ្គនាយក នៃកំពង់ផែស្វយ័តភ្នំពេញ។ ឯកឧត្តម **ហ៊ី បាវី** ជាប្រធានក្រុមប្រឹក្សាភិបាលអាណត្តិទី១ ដល់អាណត្តិទី៤ និងអាណត្តិទី៥នៃ ក.ស.ភ. ចាប់ពី១៨ ខែកុម្ភៈ ឆ្នាំ ២០១៣ រហូតមកដល់បច្ចុប្បន្ន។



លោក **ម៉ម រិទ្ធី**
**មន្ត្រីត្រួតពិនិត្យរដ្ឋ**

ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោកកើតនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ១៩៧២ និងបានបញ្ចប់សញ្ញាបត្រមធ្យមសិក្សាកំរិត២ នៅសាលាដូនពេញ នៅឆ្នាំ១៩៨៥។ លោកបានបញ្ចប់បរិញ្ញាបត្រសេដ្ឋកិច្ចកសិកម្ម ពីសាកលវិទ្យាល័យកសិកម្ម និងព្រៃឈើ ទីក្រុងហូជីមិញ ប្រទេសវៀតណាម នៅឆ្នាំ១៩៩៦។ លោកទទួលបានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ ពីសាកលវិទ្យាល័យឯកទេសនៃកម្ពុជា នៅឆ្នាំ ២០០៧។ នៅឆ្នាំ១៩៩១ លោកបានចូលបម្រើការងារជាមន្ត្រីនៅនាយកដ្ឋានរបបគណនេយ្យ នៃក្រសួងហិរញ្ញវត្ថុ។ ពីឆ្នាំ២០១៣ រហូតដល់បច្ចុប្បន្ន លោកជាអនុប្រធាននាយកដ្ឋានចំណូលពីទ្រព្យសម្បត្តិរដ្ឋ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ចាប់ពីឆ្នាំ២០០១ មកដល់បច្ចុប្បន្ន លោកត្រូវបានតែងតាំងជា មន្ត្រីត្រួតពិនិត្យរដ្ឋអម ក.ស.ភ.។



លោកជំទាវ **គីម សែន**
**អគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ**

ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោកជំទាវ កើតនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៥៧ ។ នៅឆ្នាំ ១៩៧៥ មុនរបបប៉ុល ពត លោកជំទាវបានបញ្ចប់ថ្នាក់ទី២ទំនើប នៅវិទ្យាល័យ១៨ មីនា និងបានបន្តការសិក្សាយកសញ្ញាបត្រថ្នាក់អនុបណ្ឌិតជំនាញរដ្ឋបាលសាធារណៈ ពីសកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា នៅឆ្នាំ២០០៨។ អំឡុងឆ្នាំ១៩៧៩ លោកជំទាវ បានចូលបម្រើការងារ នៅកំពង់ផែស្វយ័តភ្នំពេញ និងមានតួនាទីជាប្រធានការិយាល័យរដ្ឋបាល/បុគ្គលិក។ ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១០ លោកជំទាវត្រូវបានតែងតាំងជា នាយករដ្ឋបាល/ហិរញ្ញវត្ថុ និងចាប់ពីឆ្នាំ២០១១ រហូតដល់បច្ចុប្បន្ន លោកជំទាវមានតួនាទីជាអគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ ។



ឯកឧត្តម **ព្រុំ សុខានី**
**អគ្គនាយករងបច្ចេកទេស**

ជនជាតិខ្មែរ សញ្ជាតិខ្មែរ ឯកឧត្តម កើតនៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៥៦ ។ នៅឆ្នាំ១៩៨៩ ឯកឧត្តម ទទួលបានបរិញ្ញាបត្រសេដ្ឋកិច្ចឯកទេសផែនការ ពីវិទ្យាស្ថានសេដ្ឋកិច្ច បន្ទាប់មក នៅឆ្នាំ២០០៤ ឯកឧត្តម ទទួលបានសញ្ញាបត្រអនុបណ្ឌិតគ្រប់គ្រងពាណិជ្ជសាស្ត្រ ពីសកលវិទ្យាល័យជាតិគ្រប់គ្រង និងពីឆ្នាំ២០០៧ ដល់ឆ្នាំ២០០៥ ឯកឧត្តមជាបេក្ខបណ្ឌិតផ្នែកទស្សនវិជ្ជា ជំនាញរដ្ឋបាលសាធារណៈ នៅសកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា។ នៅឆ្នាំ១៩៩២ ឯកឧត្តមបានចូលបម្រើការងារនៅ ក.ស.ភ.។ ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១០ ឯកឧត្តម ជាប្រធានការិយាល័យគណនេយ្យ និងក្រោយមក ជាប្រធានសេវាដ្ឋានឃ្លាំងទំនិញ។ ពីឆ្នាំ២០១០ ដល់ខែឧសភា ឆ្នាំ២០១៥ ឯកឧត្តម ជានាយកប្រតិបត្តិការផែ TS៣ និងក្រោយមក ជានាយកជលធារសាស្ត្រ។ ពីខែកក្កដា ឆ្នាំ២០១៥ រហូតដល់បច្ចុប្បន្ន ឯកឧត្តមជាអគ្គនាយករងទទួលបច្ចេកទេស។



ឯកឧត្តម **ណែម ធីម**
**អគ្គនាយករងអាជីវកម្ម/ប្រតិបត្តិការផែ**

ជនជាតិខ្មែរ សញ្ជាតិខ្មែរ ឯកឧត្តម កើតនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៥៧ និងទទួលបានបរិញ្ញាបត្រផ្នែកគ្រប់គ្រងពាណិជ្ជកម្ម នៃវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ។ បន្ទាប់មក ឯកឧត្តម ទទួលបានសញ្ញាបត្រអនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ពីសកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា។ ឯកឧត្តម បានចូលបម្រើការងារនៅកំពង់ផែភ្នំពេញ នៅឆ្នាំ១៩៧៩។ ឆ្នាំ២០០២ ឯកឧត្តមមានតួនាទីជាប្រធានសេវាដ្ឋានប្រគល់-ទទួល និងឃ្លាំងទំនិញ។ ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០០៧ ឯកឧត្តមជាប្រធានការិយាល័យកិច្ចការជំនួញ។ ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១០ ឯកឧត្តម ជានាយកអាជីវកម្ម។ ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៥ ឯកឧត្តម ជានាយករដ្ឋបាល និងចាប់ពីខែមិថុនា ឆ្នាំ២០១៥ ឯកឧត្តមជាអគ្គនាយករងអាជីវកម្ម/ប្រតិបត្តិការផែ រហូតមកដល់ពេលបច្ចុប្បន្ន។



លោក **ហៀក តិរុណា**
**អគ្គនាយករងកិច្ចការផែ**

ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៧២ លោកបានទទួលសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ នៅឆ្នាំ១៩៩០។ នៅឆ្នាំ១៩៩៧ លោកបានទទួលសញ្ញាបត្រអនុបណ្ឌិតផ្នែកវិទ្យាសាស្ត្របើកបរនាវាផ្លូវសមុទ្រ (Master of Science Degree in Engineering of Navigation on Sea Routes) ពីសកលវិទ្យាល័យ Murmansk State Technical នៃប្រទេសរុស្ស៊ី។នៅឆ្នាំ២០០១ លោកទទួលបានសញ្ញាបត្រអនុបណ្ឌិត (MBA-Maritime Management) ពីសកលវិទ្យាល័យ Australian Maritime នៃប្រទេសអូស្ត្រាលី។ នៅថ្ងៃទី០១ ខែសីហា ឆ្នាំ១៩៩៧ លោកបានចាប់ផ្តើមចូលបម្រើការងារនៅកំពង់ផែស្វយ័តភ្នំពេញ និងមានតួនាទីជានាយក ផ្នែកជលធារ-សាស្ត្រ នៅខែធ្នូ ឆ្នាំ២០១១។ ចាប់ពីថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១៤ លោកត្រូវបានតែងតាំងជាអគ្គនាយករងកិច្ចការផែនៃកំពង់ផែស្វយ័តភ្នំពេញ ។



លោក **កែវ សុផាណ្ណារ៉ា**
**ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង**

ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៣ លោកបានទទួលសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ នៅឆ្នាំ១៩៩១ នៅវិទ្យាល័យព្រះស៊ីសុវត្ថិ ក្រោយមកនៅឆ្នាំ២០០៥ លោកបានទទួលបរិញ្ញាបត្រផ្នែកវិស្វករ ពីវិទ្យាស្ថានពហុបច្ចេកវិទ្យាភ្នំពេញ និងទទួលបានសញ្ញាបត្រអនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ពីសកលវិទ្យាល័យជាតិគ្រប់គ្រង នៃព្រះរាជាណាចក្រកម្ពុជា។ លោកបានបម្រើការងារឱ្យកំពង់ផែស្វយ័តភ្នំពេញ ពីខែមករា ឆ្នាំ១៩៩៧ និងមានតួនាទីជាប្រធានការិយាល័យផែនការ នៅឆ្នាំ២០១០។ ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៥ លោកកាន់តំណែងជាប្រធានអង្គភាពលទ្ធកម្ម និងចាប់ពីឆ្នាំ២០១៥ មកដល់ពេលបច្ចុប្បន្ន លោកជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង។



លោកស្រី **ជួន សុខេម**
**ប្រធាននាយកដ្ឋានរដ្ឋបាល**

ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៦៨ លោកស្រីបានទទួលបរិញ្ញាបត្រផ្នែកគណនេយ្យ/ហិរញ្ញវត្ថុ ពីសកលវិទ្យាល័យធនធានមនុស្ស នៅឆ្នាំ២០០៧ បន្ទាប់មក លោកស្រីបានទទួលសញ្ញាបត្រអនុបណ្ឌិតផ្នែករដ្ឋបាលសាធារណៈ នៅសកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា។ នៅឆ្នាំ១៩៨៦ លោកស្រីបានចូលបម្រើការងារនៅកំពង់ផែស្វយ័តភ្នំពេញ និងបន្តបន្ទាប់ លោកស្រីមានតួនាទីជាអនុប្រធានការិយាល័យគណនេយ្យ/ហិរញ្ញវត្ថុ នៅឆ្នាំ២០០៩។ ពីឆ្នាំ២០១០ លោកស្រីបានកាន់តំណែងជាប្រធានការិយាល័យរដ្ឋបាល និងចាប់ពីខែសីហា ឆ្នាំ២០១៥ លោកស្រីជាប្រធាននាយកដ្ឋានរដ្ឋបាល រហូតមកដល់បច្ចុប្បន្ន។



លោក **គង់ សុធា**
**ប្រធាននាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស**

ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោក កើតនៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៦៨ និងទទួលបានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ នៅឆ្នាំ១៩៨៨ នៅវិទ្យាល័យបឹងត្របែក។ ក្នុងឆ្នាំ២០០២ លោកបានទទួលបរិញ្ញាបត្រផ្នែកគ្រប់គ្រងសហគ្រាស ពីមហាវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។ បន្ទាប់មក លោកបានទទួលសញ្ញាបត្រអនុបណ្ឌិត ផ្នែកវិទ្យាសាស្រ្តសេដ្ឋកិច្ច នៅឆ្នាំ២០០៦ នៅសកលវិទ្យាល័យចំរើនពហុបច្ចេកវិទ្យា។ លោកបានចាប់ផ្តើមបម្រើការងារនៅកំពង់ផែស្វយ័តភ្នំពេញ នៅឆ្នាំ១៩៨៩ ហើយពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៣ លោកជាប្រធានការិយាល័យគណនេយ្យ/ហិរញ្ញវត្ថុ។ ចាប់ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៥ លោកបានកាន់តំណែងជាប្រធានការិយាល័យបុគ្គលិក និងជាប្រធាននាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស ចាប់ពីខែសីហា ឆ្នាំ២០១៥ រហូតមកដល់បច្ចុប្បន្ន។



កញ្ញា **ឈាវ វណ្ណធា**
**ប្រធាននាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ**

ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៨៣ កញ្ញា បានទទួលសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ នៅវិទ្យាល័យ ហ៊ុន សែន ខ្សាច់កណ្តាល និងបន្តយកបរិញ្ញាបត្រផ្នែកគណនេយ្យពីសកលវិទ្យាល័យន័រតុន។ ខែសីហា ឆ្នាំ២០០៨ កញ្ញាបានចូលបម្រើការងារជាបុគ្គលិកការិយាល័យគណនេយ្យ នៃកំពង់ផែស្វយ័តភ្នំពេញ។ មកដល់ឆ្នាំ២០១០ កញ្ញាត្រូវបានតែងតាំងតួនាទី ជាអនុប្រធានការិយាល័យគណនេយ្យ/ហិរញ្ញវត្ថុ និងនៅឆ្នាំ២០១៤ កញ្ញាបានកាន់តួនាទីជាប្រធានការិយាល័យគណនេយ្យ/ហិរញ្ញវត្ថុ។ ចាប់ពីខែសីហា ឆ្នាំ២០១៥ កញ្ញាជាប្រធាននាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ នៃកំពង់ផែស្វយ័តភ្នំពេញ ។



លោក **កុយ ប៊ុនធន**
**ប្រធាននាយកដ្ឋានវិស្វកម្ម**

ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៦៤ និងបានទទួលសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ នៅឆ្នាំ១៩៨៨ ។ នាឆ្នាំ១៩៩៤ លោកបានទទួលសញ្ញាបត្រអនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រម៉ាស៊ីន ពីសកលវិទ្យាល័យសំណង់ម៉ាស៊ីនលើកដាក់ និងបន្តយកសញ្ញាបត្របណ្ឌិតផ្នែកវិទ្យាសាស្ត្របច្ចេកទេស នៅសកលវិទ្យាល័យសាន់ពៃទ្បេប្បូកនៃប្រទេសរុស្ស៊ី ក្នុងឆ្នាំ២០០០។ លោកបានចូលបម្រើការងារ នៅកំពង់ផែស្វយ័តភ្នំពេញ តាំងពីឆ្នាំ១៩៨៥។ ចាប់ពីឆ្នាំ២០០៩ ដល់ឆ្នាំ ២០១៥ លោកមានតួនាទីជានាយកផ្នែកវិស្វកម្ម បន្ទាប់មក លោកត្រូវបានតែងតាំងជាប្រធាននាយកដ្ឋានវិស្វកម្ម នៅខែសីហា ឆ្នាំ២០១៥ រហូតមកដល់បច្ចុប្បន្ន។



លោក **យឹម ឿន**
**ប្រធាននាយកដ្ឋានសេវាកម្មនាវាចរណ៍**

ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៦២។ នាឆ្នាំ១៩៨៦ លោកបានទទួលសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិពីសាលាបំពេញវិជ្ជាមជ្ឈឹម និងបានទទួលសញ្ញាបត្រអនុបណ្ឌិតផ្នែកវិទ្យាសាស្ត្របើកបរនាវាផ្លូវសមុទ្រ (Master of Science Degree in Engineering of Navigation on Sea Routes) នៅសកលវិទ្យាល័យ Odessa State Maritime Academy នៃប្រទេសអ៊ុយក្រែន។ លោកបានចាប់ផ្តើមចូលបម្រើការងារ នៅកំពង់ផែស្វយ័តភ្នំពេញ ចាប់ពីឆ្នាំ១៩៧៩ រហូតដល់ឆ្នាំ២០០៩ លោកជាប្រធានការិយាល័យនាវាចរណ៍ និងត្រូវបានតម្លើងតួនាទីជានាយកសេវាកម្មនាវាចរណ៍ នៅឆ្នាំ២០១១។ លោកក៏បានកាន់តំណែងជាប្រធាននាយកដ្ឋានសេវាកម្មនាវាចរណ៍ ចាប់ពីឆ្នាំ២០១៥ រហូតមកដល់ពេលបច្ចុប្បន្ន។



លោក **វៀម ទីរ៉ាយ៉ា**
**ប្រធាននាយកដ្ឋានជលធារសាស្ត្រ**

ជនជាតិខ្មែរ សញ្ជាតិខ្មែរ កើតនៅថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៨៧ លោកបានទទួលសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ នៅវិទ្យាល័យបាក់ទូក នៅឆ្នាំ២០០៤ បន្តយកបរិញ្ញាបត្រ ផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រពីសកលវិទ្យាល័យភូមិន្ទភ្នំពេញ។ លោកបានចូលបម្រើការងារជាបុគ្គលិកកំពង់ផែស្វយ័តភ្នំពេញចាប់ពីខែកញ្ញា ឆ្នាំ២០០៩ នៅឆ្នាំ២០១២ លោកត្រូវបានតែងតាំងជាអនុប្រធានសេវាដ្ឋាននាវាចរណ៍ នៅឆ្នាំ២០១៤ លោកជាប្រធានសេវាដ្ឋានថៃទាំពោងសញ្ញា។ បច្ចុប្បន្ន លោកជាប្រធាននាយកដ្ឋានជលធារសាស្ត្រចាប់តាំងពីខែសីហា ឆ្នាំ២០១៥ ។



លោក **សយ សេរីសុខឡុន:**
**ប្រធាននាយកដ្ឋានមណ្ឌលអាជីវកម្មផៃ/ផែក្នុងស្រុក**

ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោក កើតនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៨៤ និងទទួលបានសញ្ញាមធ្យមសិក្សាទុតិយភូមិ ពីវិទ្យាល័យព្រះស៊ីសុវត្ថិ ក្នុងឆ្នាំ២០០០ លោកបានបន្តការសិក្សាថ្នាក់បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រ ពីសកលវិទ្យាល័យកូឡូញ ប្រទេសអាល្លឺម៉ង់ ក្នុងឆ្នាំ២០០៩។ អំឡុងឆ្នាំ២០១២ លោកបានទទួលសញ្ញាបត្រអនុបណ្ឌិតជំនាញហិរញ្ញវត្ថុ ពីសកលវិទ្យាល័យ Chales Sturt University of Australia។ លោកបានចូលបម្រើការងារនៅកំពង់ផែស្វយ័តភ្នំពេញ ពីខែកញ្ញា ឆ្នាំ២០០៩ រហូតដល់ឆ្នាំ២០១០ លោកជាអនុប្រធានការិយាល័យគណនេយ្យ/ហិរញ្ញវត្ថុ ដល់ឆ្នាំ២០១៣ លោកត្រូវបានតែងតាំងតួនាទីជាប្រធានសេវាដ្ឋានផៃក្នុងស្រុក។ ចាប់ពីខែសីហា ឆ្នាំ២០១៥ រហូតដល់បច្ចុប្បន្ន លោកមានមុខតំណែងជាប្រធាននាយកដ្ឋានមណ្ឌលអាជីវកម្មផៃ/ផែក្នុងស្រុក។



លោកស្រី **ហ៊ី ផានិន**
**ប្រធាននាយកដ្ឋានផែនការ/ទីផ្សារ**

ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោកស្រី កើតនៅថ្ងៃទី០៨ ខែតុលា ឆ្នាំ១៩៨៥ ។ លោកស្រី បានទទួលសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ពីវិទ្យាល័យ Killester នៅឆ្នាំ២០០៣ បន្តបន្ទាប់ លោកស្រីបានទទួលបរិញ្ញាបត្រផ្នែកភ័ស្តុភារ និងការគ្រប់គ្រងបណ្តាញផ្គត់ផ្គង់ នៅសកលវិទ្យាល័យ RMIT ក្នុងឆ្នាំ២០០៨ និងសញ្ញាបត្រអនុបណ្ឌិតជំនាញលើការគ្រប់គ្រង ពីសកលវិទ្យាល័យ Charles Sturt University ពីប្រទេសអូស្រ្តាលី នៅឆ្នាំ២០១២។ លោកស្រីបានចូលបម្រើការងារជាបុគ្គលិកនៅ ក.ស.ភ. នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០០៨។ ពីខែកញ្ញា ឆ្នាំ២០០៩ ដល់ខែធ្នូ ឆ្នាំ២០១១ លោកស្រីត្រូវបានតែងតាំតួនាទីជានាយកផែនការ/ទីផ្សារ និង នៅខែសីហា ឆ្នាំ២០១៥ លោកស្រី បានកាន់តំណែងជាប្រធាននាយកដ្ឋានផែនការ/ទីផ្សារ នៃក.ស.ភ.។



លោក **តុល សុខុម**
**ប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែ TS៣**

ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោកកើតនៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ១៩៦៦ ។ នាឆ្នាំ១៩៨៦ លោកបានទទួលសញ្ញាមធ្យមសិក្សាទុតិយភូមិពីវិទ្យាល័យព្រះយុគន្ធរ និងបានទទួលសញ្ញាបត្រអនុបណ្ឌិតផ្នែកវិទ្យាសាស្រ្តវិស្វកម្មបើកបរនាវាផ្លូវសមុទ្រ (Master of Science Degree in Engineering of Navigation on Sea Routes) ពីសកលវិទ្យាល័យ Odessa State Maritime Academy នៃប្រទេសអ៊ុយក្រែន។ នៅឆ្នាំ១៩៩៥ លោកទទួលបានសញ្ញាបត្របរិញ្ញាបត្រផ្នែកអក្សរសាស្រ្តអង់គ្លេសពីសកលវិទ្យាល័យអាស៊ីអឺរ៉ុប នៅឆ្នាំ២០០៩។ នៅឆ្នាំ១៩៨០ លោកបានចូលបម្រើការងារនៅ ក.ស.ភ.។ នៅឆ្នាំ២០០៩ លោកមានតួនាទីជាប្រធានសេវាដ្ឋាននាវាចរណ៍។ បន្ទាប់មក លោកបានកាន់តំណែងជានាយកប្រតិបត្តិការចំណតផែ TS៣ នៅឆ្នាំ២០១៤ និងចាប់ពីខែសីហា ឆ្នាំ២០១៥ លោកជាប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែ TS៣។



លោក **ជី ទិចិត្រ**
**ប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧**

ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោកកើតនៅថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ១៩៧៧។ លោកទទួលបានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិពីវិទ្យាល័យទួលទំពូង នៅឆ្នាំ១៩៩៥។ នៅឆ្នាំ២០០១ លោកទទួលបានសញ្ញាបត្របរិញ្ញាបត្រផ្នែកពាណិជ្ជកម្មពីសកលវិទ្យាល័យន័រតុន។ បន្ទាប់មក លោកបានបញ្ចប់ការសិក្សាថ្នាក់អនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រគ្រប់គ្រង និងដឹកជញ្ជូនតាមសមុទ្រ ពីសកលវិទ្យាល័យ Antwerp នៃប្រទេសប៊ែលហ្សិក នៅឆ្នាំ២០១០។ លោកបានចាប់ផ្ដើមបម្រើការងារនៅ ក.ស.ភ. នៅឆ្នាំ១៩៩៧។ បន្ទាប់មក លោកមានតួនាទីជាប្រធានការិយាល័យផែនការ នៅឆ្នាំ២០០៩។ នៅឆ្នាំ២០១៣ លោកត្រូវបានតែងតាំងជានាយកប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧ និងចាប់ពីខែសីហា ឆ្នាំ២០១៥ លោក បានកាន់តំណែងជាប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧។



លោក **គង់ ចាន់នី**
**ប្រធានលេខាធិការដ្ឋាន**

ជនជាតិខ្មែរ សញ្ជាតិខ្មែរ លោក កើតនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ១៩៨២។ នៅឆ្នាំ២០០៦ លោកបានទទួលបរិញ្ញាបត្រជំនាញនីតិសាស្ត្រ ពីសកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងទទួលបានសញ្ញាបត្រអនុបណ្ឌិតជំនាញនីតិសាស្ត្រ ពីសកលវិទ្យាល័យហ្សង់មូឡាំងលីយ៉ុង ៣ នៅ ទីក្រុងហាណូយ នៃប្រទេសវៀតណាម នៅឆ្នាំ២០០៨។ លោកបានចូលបម្រើការងារនៅ ក.ស.ភ. នៅខែកញ្ញា ឆ្នាំ២០០៩ និងមានឋានៈជាអនុប្រធានការិយាល័យរដ្ឋបាល នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១។ ចាប់ពីខែឧសភា ឆ្នាំ២០១៥ លោកត្រូវបានតែងតាំងជាប្រធានក្រុមលេខានៃក្រុមប្រឹក្សាភិបាល ក.ស.ភ. អាណត្តិទី៤។ ចាប់ពីខែសីហា ឆ្នាំ២០១៥ រហូតដល់បច្ចុប្បន្ន លោកត្រូវបានតែងតាំងជាប្រធានលេខាធិការដ្ឋាន។

## ខ- តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់បុគ្គលិកជាន់ខ្ពស់

តួនាទី និងការទទួលខុសត្រូវ របស់បុគ្គលិកជាន់ខ្ពស់ ក.ស.ភ. មានដូចខាងក្រោម៖

ខ.១ **ឯកឧត្តម ហ៊ី ចាវី** (អគ្គនាយក) មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំការប្រជុំនៃក្រុមប្រឹក្សាភិបាល
- ទទួលបន្ទុកប្រតិបត្តិនូវសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល និងការដាក់ឱ្យអនុវត្តនូវគោលនយោបាយ ដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ ក.ស.ភ. ហើយដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- រៀបចំរបាយការណ៍សកម្មភាពការងារប្រចាំឆ្នាំ និងរបាយការណ៍គណនេយ្យ/ហិរញ្ញវត្ថុប្រចាំឆ្នាំ ហើយដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងអនុម័ត
- អនុវត្តតួនាទីជាអាជ្ញាធរ ដើម្បីគ្រប់គ្រងសណ្តាប់ធ្នាប់ទូទៅក្នុងមណ្ឌលអាជីវកម្មផែរបស់ ក.ស.ភ.
- កំណត់ចំនួនក្របខ័ណ្ឌបុគ្គលិក ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល និងដោយគោរពតាមលក្ខន្តិក:បុគ្គលិក
- អនុវត្តឋានានុក្រមរបស់ ក.ស.ភ. ចំពោះបុគ្គលិកទាំងអស់
- សម្រេច និងចុះហត្ថលេខាលើកិច្ចសន្យា ដោយអនុលោមតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលស្តីពីការបែងចែកអំណាច
- បំពេញកិច្ចការទូទៅក្នុងដំណើរការមុខងាររដ្ឋបាល និងការគ្រប់គ្រង ដែលចាំបាច់ក្នុងដំណើរការប្រក្រតីរបស់ ក.ស.ភ.។

### ខ.២ តួនាទី និងការទទួលខុសត្រូវរបស់អគ្គនាយករង

❖ ឯកឧត្តម **ណែម ធីម** (អគ្គនាយករង)

- ទទួលបន្ទុកការងារប្រតិបត្តិការ និងអាជីវកម្ម។

❖ លោកជំទាវ **គីម សែន** (អគ្គនាយករង)

- ទទួលបន្ទុកការងាររដ្ឋបាល និងហិរញ្ញវត្ថុ។

❖ លោក **ហៀក តិរុណា** (អគ្គនាយករង)

- ទទួលបន្ទុកការងារកិច្ចការផែ និងចរាចរណ៍នាវា។

❖ ឯកឧត្តម **ព្រុំ សុខានី** (អគ្គនាយករង)

- ទទួលបន្ទុកការងារបច្ចេកទេស។

### ខ.៣ តួនាទី និងការទទួលខុសត្រូវរបស់ប្រធាននាយកដ្ឋាន

❖ លោក **កែវ សុផាណ្ណារ៉ា** (ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង)

- **ការងារគ្រប់គ្រង**
  - ជាសេនាធិការផ្ទាល់ឱ្យអគ្គនាយក លើការងារសវនកម្ម
  - ផ្តល់ការណែនាំ និងកំណត់ទិសដៅការងារដល់អង្គភាពក្រោមឱវាទ។

- **ការងារជំនាញ**
  - រៀបចំផែនការកម្មវិធីចុះធ្វើសវនកម្មប្រចាំឆ្នាំ
  - ធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ឱ្យស្របតាមស្តង់ដារគណនេយ្យអន្តរជាតិ (CIFRS)
  - ធ្វើសវនកម្មលើកិច្ចប្រតិបត្តិការ
  - ធ្វើសវនកម្មលើការគ្រប់គ្រង និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង
  - ធ្វើរបាយការណ៍ប្រចាំឆ្នាំស្តីអំពីការចុះធ្វើសវនកម្មជូនថ្នាក់ដឹកនាំជ្រាប និងមានវិធានការកែលំអចំណុចខ្វះខាត
  - ធ្វើអធិការកិច្ចលើករណីសង្ស័យ ឬវិវាទណាមួយដែលចង្អុលបង្ហាញដោយអគ្គនាយក
  - សម្របសម្រួលការងារសវនកម្មជាមួយនឹងសវនកម្មផ្ទៃក្រៅ។
- **ការងារវាយតម្លៃ**
  - ពិនិត្យ និងតាមដានផែនការដែលបានដាក់ចេញ
  - តាមដានការអនុវត្តសកម្មភាព ឬអនុសាសន៍កែលំអលើចំណុចខ្វះខាតរបស់អង្គភាព ដែលរកឃើញដោយសវនកម្មផ្ទៃក្រៅ ឬសវនកម្មជំនាញ
  - តាមដានត្រួតពិនិត្យគោលការណ៍ណែនាំ ឬគោលនយោបាយ ដែលដាក់ចេញដោយអង្គភាព
  - ពិនិត្យ និងវាយតម្លៃសមត្ថភាពការងាររបស់បុគ្គលិកក្រោមឱវាទដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការតម្លើងឋានៈ ការដាក់ពិន័យ ឬមានវិធានការដោះស្រាយ
  - រៀបចំបូកសរុបរបាយការណ៍សកម្មភាពការងារប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំ ដើម្បីជូនថ្នាក់ដឹកនាំបានជ្រាប។

❖ លោកស្រី **ជួន សុខេម** (ប្រធាននាយកដ្ឋានរដ្ឋបាល)

- **ការងារគ្រប់គ្រង**
  - ជាសេនាធិការឱ្យអគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ លើការងាររដ្ឋបាល ការងារសន្តិសុខ/សណ្តាប់ធ្នាប់ និងការងារព័ត៌មានវិទ្យា
  - អនុវត្ត និងតាមដានការគោរពន្ទរបទបញ្ជាផ្ទៃក្នុងរបស់ ក.ស.ភ.។
- **ការងារជំនាញ**
  - ត្រួតពិនិត្យ និងរៀបចំតាក់តែងឯកសាររដ្ឋបាល
  - គ្រប់គ្រងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ ក.ស.ភ.
  - រៀបចំសេវាផ្តល់ព័ត៌មានអំពីសេវាកម្មរបស់ ក.ស.ភ. ជូនអតិថិជន
  - ធ្វើទំនាក់ទំនង និងសហការជាមួយស្ថាប័នរដ្ឋ-ឯកជន ដែលពាក់ព័ន្ធនឹងវិស័យគ្រប់គ្រងថែរក្សា និងការពារទ្រព្យសម្បត្តិទាំងឡាយ ព្រមទាំងការរៀបចំបញ្ជីសារពើភ័ណ្ឌរបស់ ក.ស.ភ.
  - ត្រួតពិនិត្យ និងរៀបចំសំណើសុំទិញ និងសំណើសុំដកសាច់ប្រាក់រាល់ការចំណាយការងាររដ្ឋបាល និងទិញសម្ភារការិយាល័យ សម្រាប់ការប្រើប្រាស់ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
  - រៀបចំទីកន្លែងប្រជុំ និងការងារពិធីការសម្រាប់គ្រប់កម្មវិធីរបស់ ក.ស.ភ.

- ត្រួតពិនិត្យគ្រប់គ្រង និងថែទាំប្រព័ន្ធទឹក និងប្រព័ន្ធអគ្គិសនី ព្រមទាំងអនាម័យ
- គ្រប់គ្រង និងត្រួតពិនិត្យលើការប្រើប្រាស់ប្រេងឥន្ធនៈ
- គ្រប់គ្រង និងចាត់ចែងការងារអន្តរាគមន៍សណ្តាប់ធ្នាប់រួម និងការពារសុវត្ថិភាពជូនថ្នាក់ដឹកនាំ និងបុគ្គលិករបស់ ក.ស.ភ.
- រៀបចំបទបញ្ជាផ្ទៃកសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់របស់ ក.ស.ភ.
- ដឹកនាំ ត្រួតពិនិត្យការរៀបចំយុទ្ធសាស្ត្រគ្រប់គ្រងកិច្ចដំណើរការប្រព័ន្ធព័ត៌មានវិទ្យា ការបែងចែកសិទ្ធិប្រើប្រាស់អ៊ីនធឺណែត និងបណ្តាញ Network សម្រាប់អង្គភាពនានា និងការតបណ្តាញប្រព័ន្ធត្រួតពិនិត្យសុវត្ថិភាព
- សម្របសម្រួល និងដោះស្រាយវិវាទនានាពាក់ព័ន្ធការងាររដ្ឋបាល។

- **ការងារវាយតម្លៃ**
  - វាយតម្លៃនិងគ្រប់គ្រងការងារលើបុគ្គលិកក្រោមឱវាទ អនុលោមតាមច្បាប់ការងារ និងលក្ខន្តិកៈសហគ្រាស ព្រមទាំងលក្ខន្តិកៈបុគ្គលិករបស់ ក.ស.ភ.
  - ពិនិត្យ និងវាយតម្លៃសមត្ថភាពការងារបុគ្គលិកក្រោមឱវាទដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំ ក្នុងការលើកទឹកចិត្ត ការតម្លើងឋានៈ និងការដាក់ពិន័យ
  - ពិនិត្យ និងវាយតម្លៃដំណើរការប្រព្រឹត្តទៅនៃការងាររដ្ឋបាល ការងារសន្តិសុខ និងការងារព័ត៌មានវិទ្យា ជូនថ្នាក់ដឹកនាំដើម្បីជ្រាប និងមានវិធានការដោះស្រាយឱ្យបានទាន់ពេលវេលា
  - ពិនិត្យ និងវាយតម្លៃលើសំណើសុំផ្សេងៗពីគ្រប់អង្គភាព ដែលពាក់ព័ន្ធនឹងការចំណាយរដ្ឋបាលជូនថ្នាក់ដឹកនាំ ពិនិត្យ និងសម្រេច
  - ពិនិត្យ និងវាយតម្លៃលើគម្រោងរៀបចំកម្មវិធីជប់លៀងអាហារសាមគ្គី និងរង្វាន់លើកទឹកចិត្ត ប្រចាំឆ្នាំរបស់ ក.ស.ភ.
  - ពិនិត្យ និងវាយតម្លៃលើគម្រោងទិញសម្ភារការិយាល័យ សម្រាប់ការប្រើប្រាស់ក្នុងនាយកដ្ឋានចំណុះ និងគម្រោងរៀបចំឯកសណ្ឋានប្រចាំឆ្នាំ ជូនថ្នាក់ដឹកនាំ និងបុគ្គលិក ក.ស.ភ.
  - តាមដាន និងវាយតម្លៃ ព្រមទាំងបូកសរុបជារបាយការណ៍ការងាររដ្ឋបាលជូនថ្នាក់ដឹកនាំជ្រាប មានវិធានការដោះស្រាយ។

❖ លោក **គង់ សុធា** (ប្រធាននាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស)

- **ការងារគ្រប់គ្រង**
  - ជាសេនាធិការឱ្យអគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ លើការងារគ្រប់គ្រងធនធានមនុស្ស និងការងារបណ្តុះបណ្តាល
  - ពិនិត្យ និងតាមដានការគោរពន្ទវបទបញ្ជាផ្ទៃក្នុង របស់ ក.ស.ភ.
  - គ្រប់គ្រងជីវប្រវត្តិ និងពិនិត្យរាល់សកម្មភាពការងាររបស់បុគ្គលិក ក.ស.ភ.។
- **ការងារជំនាញ**
  - ធានាដំណើរការនៃការគ្រប់គ្រងបុគ្គលិក ដោយអនុលោមទៅតាមលក្ខន្តិកៈ ក.ស.ភ. និងលក្ខន្តិកៈបុគ្គលិក ក.ស.ភ. ព្រមទាំងច្បាប់ការងារ

- រៀបចំប្រាក់បេសកកម្មក្នុងនិងក្រៅប្រទេស ប្រាក់បៀវត្សរ៍ ប្រាក់បន្ថែមម៉ោង ប្រាក់រង្វាន់សរសើរប្រចាំឆ្នាំជូនបុគ្គលិក ក.ស.ភ.
- គ្រប់គ្រងបញ្ជីវត្តមានរបស់បុគ្គលិក ក.ស.ភ.
- រៀបចំសំណុំបែបបទនិវត្តជន ជនបាត់បង់សម្បទាវិជ្ជាជីវៈ គ្រោះថ្នាក់ការងារ មរណភាព
- ពិនិត្យ និងធ្វើសំណើលើការងារតម្លើងកាំថ្នាក់ប្រចាំឆ្នាំជូនបុគ្គលិក ក.ស.ភ.
- ពិនិត្យ និងផ្តល់យោបល់ជូនថ្នាក់ដឹកនាំលើសំណើសុំព្យួរការងារ ផ្ទេរការងារ និងការតម្លើងឋានៈតួនាទី
- រៀបចំផែនការបណ្តុះបណ្តាលធនធានមនុស្សទាំងក្នុង និងក្រៅប្រទេស
- រៀបចំជ្រើសរើសបុគ្គលិកតាមផែនការប្រចាំឆ្នាំរបស់ ក.ស.ភ.។

- **ការងារវាយតម្លៃ**
  - ពិនិត្យ និងវាយតម្លៃលើសមត្ថភាព និងសកម្មភាពការងាររបស់បុគ្គលិក ក.ស.ភ. ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ឬតម្លើងឋានៈតួនាទី។

❖ កញ្ញា **ឈាវ វណ្ណធា** (ប្រធាននាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ)

- **ការងារគ្រប់គ្រង**
  - ជាសេនាធិការឱ្យអគ្គនាយករងរដ្ឋបាល/ហិរញ្ញវត្ថុ លើការងារគណនេយ្យ និងហិរញ្ញវត្ថុ
  - ផ្តល់ការណែនាំ និងកំណត់ទិសដៅការងារដល់អង្គភាពក្រោមឱវាទ។
- **ការងារជំនាញ**
  - ធ្វើការកត់ត្រាបញ្ជីគណនេយ្យប្រចាំថ្ងៃរបស់អង្គភាព
  - អនុវត្តគោលនយោបាយ និងនីតិវិធីចុះបញ្ជីការគណនេយ្យរបស់អង្គភាព
  - អនុវត្តគោលការណ៍នៃការប្រមូលចំណូល និងបំណុលពីអតិថិជន
  - ធានាអនុវត្តការបង់ពន្ធរបស់អង្គភាពឱ្យបានទាន់ពេលវេលាតាមការកំណត់របស់ច្បាប់ពន្ធដារ
  - គ្រប់គ្រង និងត្រួតពិនិត្យសាច់ប្រាក់ (ប្រចាំខែ)
  - ត្រួតពិនិត្យ និងផ្ទៀងផ្ទាត់គណនីធនាគាររបស់អង្គភាព (ប្រចាំខែ)
  - រៀបចំរបាយការណ៍ហិរញ្ញវត្ថុប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
  - វិភាគ និងផ្តល់យោបល់ជូនថ្នាក់ដឹកនាំលើលទ្ធផលហិរញ្ញវត្ថុ និងបម្រែបម្រួល ព្រមទាំងប្រតិបត្តិការអាជីវកម្មរបស់អង្គភាព។
- **ការងារវាយតម្លៃ**
  - តាមដានត្រួតពិនិត្យគោលការណ៍ណែនាំ ឬគោលនយោបាយគណនេយ្យ
  - ធ្វើបច្ចុប្បន្នភាពគោលនយោបាយ និងនីតិវិធីចុះបញ្ជីការគណនេយ្យប្រចាំឆ្នាំ
  - ពិនិត្យ និងវាយតម្លៃសមត្ថភាពការងាររបស់បុគ្គលិកក្រោមឱវាទ ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការតម្លើងឋានៈ ការដាក់ពិន័យ ឬមានវិធានការដោះស្រាយ
  - រៀបចំបូកសរុបរបាយការណ៍សកម្មភាពការងារប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីជូនថ្នាក់ដឹកនាំបានជ្រាប។

❖ លោក **ភុយ ម៉ិនធន** (ប្រធាននាយកដ្ឋានវិស្វកម្ម)

- **ការងារគ្រប់គ្រង**
  - ជាសេនាធិការឱ្យអគ្គនាយករងបច្ចេកទេស លើការងារបច្ចេកទេស រួមមានការងារហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយគ្រឿងចក្រ
  - ផ្តល់ការណែនាំ និងកំណត់ទិសដៅការងារដល់អង្គភាពក្រោមឱវាទ។
- **ការងារជំនាញ**
  - រៀបចំកំណត់ស្តង់ដារបច្ចេកទេសសម្រាប់ហេដ្ឋារចនាសម្ព័ន្ធផែ និងមធ្យោបាយគ្រឿងចក្ររបស់ ក.ស.ភ.
  - សិក្សា និងរៀបចំគម្រោងអភិវឌ្ឍន៍ផែលើផ្នែកបច្ចេកទេស
  - ត្រួតពិនិត្យ ថែទាំ និងជួសជុលហេដ្ឋារចនាសម្ព័ន្ធផែ និងមធ្យោបាយគ្រឿងចក្រ
  - រៀបចំផែនការសម្ភារ និងគ្រឿងបន្លាស់សម្រាប់ការជួសជុលហេដ្ឋារចនាសម្ព័ន្ធផែ និងមធ្យោបាយគ្រឿងចក្រ។
- **ការងារវាយតម្លៃ**
  - ពិនិត្យ និងវាយតម្លៃសមត្ថភាពការងារបុគ្គលិកក្រោមឱវាទ ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការតម្លើងឋានៈ ការដាក់ពិន័យ ឬមានវិធានការដោះស្រាយ
  - ដឹកនាំប្រជុំផ្ទៃក្នុងរៀងរាល់ខែ ដើម្បីដកពិសោធន៍លើការងារជំនាញបច្ចេកទេសវិស្វកម្ម។

❖ លោក **ឡៀច ទីរ៉ាយ៉ា** (ប្រធាននាយកដ្ឋានជលធារសាស្ត្រ)

- **ការងារគ្រប់គ្រង**
  - ជាសេនាធិការឱ្យអគ្គនាយករងបច្ចេកទេស លើការងារជលធារសាស្ត្រ រួមមានការងារវាស់ស្ទង់ ការងារបំពាក់ពោងសញ្ញា និងការងារបូមស្តារប្រឡាយ
  - ផ្តល់ការណែនាំ និងកំណត់ទិសដៅការងារដល់អង្គភាពក្រោមឱវាទ។
- **ការងារជំនាញ**
  - រៀបចំផែនការប្រចាំឆ្នាំលើការងារវាស់ស្ទង់ និងការងារបូមស្តារប្រឡាយនាវាចរណ៍
  - រៀបចំគម្រោងផែនការប្រចាំឆ្នាំលើការបំពាក់ ការថែទាំ និងការជួសជុលពោងសញ្ញា និងបង្គោលសញ្ញាតាមផ្លូវនាវាចរណ៍ក្នុងដែនអាជីវកម្មរបស់ ក.ស.ភ.
  - សិក្សា និងវាស់ស្ទង់ជម្រៅទឹកក្នុងមណ្ឌលអាជីវកម្ម និងវាស់ស្ទង់ទីតាំងអភិវឌ្ឍន៍របស់ ក.ស.ភ.
  - អនុវត្តការងារបូមស្តារប្រឡាយនាវាចរណ៍ និងការងារបូមខ្សាច់ធ្វើអាជីវកម្ម
  - គ្រប់គ្រងលើមធ្យោបាយបូមស្តារ និងមធ្យោបាយអូសទាញគ្រឿងចក្រ
  - បំពាក់ពោងសញ្ញា និងបង្គោលសញ្ញាតាមផ្លូវនាវាចរណ៍ក្នុងមណ្ឌលអាជីវកម្ម
  - គ្រប់គ្រង ថែរក្សា និងជួសជុលរាល់ពោងសញ្ញា បង្គោលសញ្ញា តាមផ្លូវនាវាចរណ៍ក្នុងមណ្ឌលអាជីវកម្មរបស់ ក.ស.ភ.។
- **ការងារវាយតម្លៃ**

- ពិនិត្យ និងវាយតម្លៃសមត្ថភាពការងាររបស់បុគ្គលិកក្រោមឱវាទ ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការតម្លើងឋានៈ ការដាក់ពិន័យ
- សិក្សាស្រាវជ្រាវបច្ចេកទេស និងឧបករណ៍វាស់ស្ទង់គ្រប់ប្រភេទ
- ប្រមូលចងក្រងព័ត៌មាន និងឯកសារនានាពាក់ព័ន្ធនឹងផ្នែកជលធារសាស្ត្រ
- រៀបចំបូកសរុបរបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីរាយការណ៍ជូនអគ្គនាយក ក.ស.ភ.។

❖ លោក **យឹម ឡឿន** (ប្រធាននាយកដ្ឋានសេវាកម្មនាវាចរណ៍)

- **ការងារគ្រប់គ្រង**
  - ជាសេនាធិការឱ្យអគ្គនាយករងកិច្ចការផែ លើការងារនាវាចរណ៍ ការងារកណ្តធារ និងការងារ SHE
  - ផ្តល់ការណែនាំ និងកំណត់ទិសដៅការងារដល់អង្គភាពក្រោមឱវាទ។
- **ការងារជំនាញ**
  - ធានាការពារសុវត្ថិភាពដែនទឹកកំពង់ផែ និងគ្រប់គ្រងចលនានាវា
  - តាមដានត្រួតពិនិត្យការបំពុលទឹក
  - អនុវត្តបទបញ្ជា និងផ្តល់ការឯកភាពលើសកម្មភាពផ្សេងៗក្នុងតំបន់កំពង់ផែ
  - ធានាសុវត្ថិភាពប្រតិបត្តិការកំពង់ផែ និងនាវាទាំងឡាយនៅកំពង់ផែ
  - ដឹកនាំគណៈកម្មការធ្វើបែបបទចូល/ចេញកំពង់ផែរបស់នាវា
  - ធ្វើការណែនាំអំពីករណីនាវាដឹកជញ្ជូនទំនិញគ្រោះថ្នាក់
  - បដិសេធមិនឱ្យនាវាចាកចេញពីកំពង់ផែ ក្នុងករណីមិនទូទាត់ប្រាក់កម្រៃ ឬថ្លៃប្រើប្រាស់សេវាកម្មផ្សេងៗ
  - ផ្តល់លិខិតអនុញ្ញាតចេញពីកំពង់ផែ (Port clearance) ដល់នាវា
  - បញ្ជូនវិញ្ញាបនបត្រ (Certificate Manifest) ដល់អង្គភាពពាក់ព័ន្ធ និងបញ្ជូនវិញ្ញាបនបត្រប៉ាន់ស្មានសេវាកម្មទៅការិយាល័យកិច្ចការជំនួញដើម្បីចេញវិក្កយបត្រផ្លូវការជូនអតិថិជន
  - បែងចែកកណ្តធារនាំផ្លូវនាវាចេញ-ចូល ក្នុងមណ្ឌលអាជីវកម្ម និងតាមបណ្តាខេត្តផ្សេងៗ
  - គ្រប់គ្រង និងចាត់ចែងមធ្យោបាយនាវាសណ្តោង និងមធ្យោបាយនាវាចម្លង
  - ពិនិត្យ និងបញ្ជូនព័ត៌មានមកដល់ និងចេញដំណើររបស់នាវា ដែលបានពីទីភ្នាក់ងារកម្ពុជានាវាចរណ៍កាំសាបឱ្យទៅអង្គភាពពាក់ព័ន្ធអនុវត្ត
  - រៀបចំ និងគ្រប់គ្រងសណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយ សន្តិសុខ និងសុវត្ថិភាពរបស់នាវាចរណ៍ និងបរិស្ថានល្អក្នុងមណ្ឌលអាជីវកម្ម
  - ចាត់ចែងសកម្មភាពនាវាតាមផែក្នុងមណ្ឌលអាជីវកម្មផែភ្នំពេញ និងចំណតផែអ្នកដំណើរ
  - ណែនាំ និងត្រួតពិនិត្យការអនុវត្តគោលនយោបាយសុវត្ថិភាព សុខមាលភាព និងបរិស្ថានផែ ធានាឱ្យដំណើរការប្រតិបត្តិការផែ អនុលោមតាមស្តង់ដារអន្តរជាតិជាអាទិ៍ SHE (Safety, Health and Environment) ISPS Code IMDG Cod
  - ប្រតិបត្តិច្បាប់ តាមបទប្បញ្ញត្តិជាតិ និង បទប្បញ្ញត្តិអន្តរជាតិលើនាវាជាតិអន្តរជាតិ និងចំណតផែ។

- **ការងារវាយតម្លៃ**
  - ពិនិត្យ និងវាយតម្លៃសមត្ថភាពការងាររបស់បុគ្គលិកក្រោមឱវាទ ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការតម្លើងឋានៈ ការដាក់ពិន័យ
  - វាយតម្លៃរាល់ការប៉ះទង្គិចគ្រោះថ្នាក់ដែលបណ្តាលឱ្យខូចខាតនាវាសាឡង់ និងចំណតផែដែលស្ថិតនៅក្នុងព្រំប្រទល់ផ្ទៃទឹកកំពង់ផែ មណ្ឌលផែ ជូនថ្នាក់ដឹកនាំជ្រាប និងមានដំណោះស្រាយ
  - តាមដានស្ថានភាពច្រាំងទន្លេ និងសកម្មភាពយកដីពីបាតទន្លេ និងផលប៉ះពាល់ក្នុងការកសាងផែ និងចំណតផែដែលមានស្រាប់
  - តាមដានពិនិត្យកំពស់ទឹកឡើងចុះប្រចាំថ្ងៃ និងផ្តល់ជំរៅទឹកប្រចាំខែ ដល់ស្ថាប័នពាក់ព័ន្ធនានា តាមរយៈទីភ្នាក់ងារកម្ពុជានាវាចរណ៍កាំសាប សម្រាប់ការកំណត់ជម្រៅស៊ីទឹករបស់នាវាចេញ-ចូល ក.ស.ភ.
  - រៀបចំបូកសរុបរបាយការណ៍សកម្មភាពការងារប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីជូនថ្នាក់ដឹកនាំបានជ្រាប។

❖ លោក **សយ សេរីសុខឡុនៈ** (ប្រធាននាយកដ្ឋានមណ្ឌលអាជីវកម្មផែភ្នំពេញ/ផែក្នុងស្រុក)

- **ការងារគ្រប់គ្រង**
  - ជាសេនាធិការឱ្យអគ្គនាយករងកិច្ចការផែ លើការងារមណ្ឌលផែ/ផែក្នុងស្រុក ការងារផែទេសចរណ៍ ការងារចំណតផែទន្លេបិទ និងការងារផែប្រេង/ហ្គាស
  - ផ្តល់ការណែនាំ និងកំណត់ទិសដៅការងារដល់អង្គភាពក្រោមឱវាទ។
- **ការងារជំនាញ**
  - រៀបចំផែនការកម្មវិធីចុះធ្វើការគ្រប់គ្រង និងរៀបចំសណ្តាប់ធ្នាប់ និងចំណតផែក្នុងមណ្ឌលអាជីវកម្មផែ
  - គ្រប់គ្រងចំណត សេវាកម្មផែក្នុងស្រុក និងមណ្ឌលផែរាល់ការចូលចត របស់នាវា សាឡង់ ទូក កាណូតផ្សេងៗ
  - គ្រប់គ្រងចំណតចេញ-ចូលនាវា នាវាទេសចរណ៍ជាតិ និងអន្តរជាតិ គ្រប់គ្រងចំណតរថយន្ត និងច្រកទ្វារចេញ-ចូល ប្រមូលថ្លៃឈ្នួល រៀបចំសណ្តាប់ធ្នាប់នាវាដឹកអ្នកដំណើរនៅផែបណ្តែត
  - គ្រប់គ្រងចំណតផែទន្លេបិទលើការងារប្រតិបត្តិការ និងដើរតួនាទីជាអាជ្ញាធរផែ រួមមានការងារលើកដាក់ ការងាររៀបចំចំណតផែ ការងារគ្រប់គ្រងនាវាចេញ-ចូល និងគ្រប់គ្រងចំណតផែប្រេង/ហ្គាសលើការងារសណ្តាប់ធ្នាប់ឱ្យមានសុវត្ថិភាព និងបរិស្ថានល្អ
  - គ្រប់គ្រងនាវាចេញ-ចូល និងប្រមូលស្ថិតិទំនិញឆ្លងកាត់
  - ថែរក្សាបបនីយភណ្ឌផែ និងប្រឡាយនាវាចរណ៍នៅតាមចំណតផែទាំងនោះ ឱ្យមានរបៀបរៀបរយសម្រាប់នាវាធ្វើនាវាចរណ៍ ចងពួរនាវា បោះយុថ្កា ព្រមទាំង ផ្ទេរ និងផ្ទុកទំនិញ។
- **ការងារវាយតម្លៃ**
  - ពិនិត្យ និងវាយតម្លៃសមត្ថភាពការងាររបស់បុគ្គលិកក្រោមឱវាទ ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការតម្លើងឋានៈ និងការដាក់ពិន័យ

- វាយតម្លៃរាល់ផលប៉ះពាល់ដែលបណ្ដាលឱ្យខូចខាតដល់ចំណតផែ ដែលស្ថិតនៅក្នុងព្រំប្រទល់ផ្ទៃទឹកកំពង់ផែ និងមណ្ឌលផែ ជូនថ្នាក់ដឹកនាំជ្រាប និងមានដំណោះស្រាយ
- រៀបចំបូកសរុបរបាយការណ៍សកម្មភាពការងារប្រចាំសប្ដាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីជូនថ្នាក់ដឹកនាំបានជ្រាប។

❖ លោកស្រី **ហ៊ី ផានិន** (នាយកដ្ឋានផែនការ/ទីផ្សារ)

- **ការងារគ្រប់គ្រង**
  - ជាសេនាធិការឱ្យអគ្គនាយករងអាជីវកម្ម/ប្រតិបត្តិការផែ លើការងារផែនការ/ស្ថិតិ ការងារតម្លៃ/ទីផ្សារ ការងារកិច្ចការជំនួញ និងការងារសិក្សាស្រាវជ្រាវ/អភិវឌ្ឍន៍ថ្មី
  - ផ្ដល់ការណែនាំ និងកំណត់ទិសដៅការងារដល់អង្គភាពក្រោមឱវាទ។
- **ការងារជំនាញ**
  - រៀបចំផែនការអាជីវកម្ម សេវាកម្ម និងហិរញ្ញវត្ថុ រយៈពេលខ្លី មធ្យម និងវែង
  - តាមដានការងារអាជីវកម្ម ជាប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំសម្រាប់ ក.ស.ភ.
  - ចងក្រងទិន្នន័យ និងស្ថិតិរបស់ ក.ស.ភ. ដើម្បីធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ
  - រៀបចំផែនការយុទ្ធសាស្ត្រទីផ្សាររបស់ ក.ស.ភ. ដោយពឹងផ្អែកជាចម្បងទៅលើតម្លៃ គុណភាពសេវាកម្ម ការគ្រប់គ្រង និងបរិយាកាសបនីយកណ្ឌផែ
  - រៀបចំកិច្ចសន្យា កិច្ចព្រមព្រៀង និង MOU ជាមួយដៃគូអាជីវកម្មរបស់ ក.ស.ភ.
  - រៀបចំ និងចងក្រងបណ្ណផ្សាយពាណិជ្ជកម្ម (Brochure) និងប្រតិទិន (Calendar)
  - ផ្សព្វផ្សាយអំពីតារាងតម្លៃសេវាកម្មរបស់ ក.ស.ភ. ជូនអតិថិជន
  - បម្រើសេវាកម្ម (Customer Service) ជូនអតិថិជន
  - ផលិតវិក្កយបត្រ។
- **ការងារវាយតម្លៃ**
  - ពិនិត្យ និងផ្ដល់យោបល់លើគម្រោងសាងសង់ និងការចំណាយផ្សេងៗផ្នែកអាជីវកម្មរបស់ ក.ស.ភ. ជូនថ្នាក់ដឹកនាំ
  - វិភាគអំពីប្រសិទ្ធភាព និងផលប៉ះពាល់នៃគម្រោងអភិវឌ្ឍន៍នីមួយៗរបស់ ក.ស.ភ.
  - សិក្សាពីបរិយាកាសប្រកួតប្រជែង និងវិនិយោគក្នុងវិស័យដឹកជញ្ជូន វិស័យភ័ស្តុភារ និងវិស័យកំពង់ផែ
  - សិក្សា និងវិភាគតម្លៃដឹកជញ្ជូនតាមផ្លូវទឹក ផ្លូវគោក ផ្លូវដែក និងផ្លូវអាកាស
  - វិភាគលើផលប៉ះពាល់ ចំណុចខ្លាំង ចំណុចខ្សោយ និងឱកាស ដោយផ្អែកលើមជ្ឈដ្ឋានខាងក្នុង និងខាងក្រៅរបស់អង្គភាព
  - តាមដានស្ថានការ និងនិន្នាការអភិវឌ្ឍសេដ្ឋកិច្ចទាំងក្នុង និងក្រៅប្រទេស
  - តាមដានស្ថានការនៃការអភិវឌ្ឍ និងការប្រព្រឹត្តទៅរបស់កំពង់ផែនៅក្នុងប្រទេស និងកំពង់ផែនានានៅក្នុងប្រទេសជិតខាងក្នុងតំបន់ និងសកលលោក
  - សិក្សាអំពីភាពប្រកួតប្រជែងនៃតម្លៃសេវាកម្មរបស់ ក.ស.ភ.
  - សិក្សាលើគម្រោងស្រាវជ្រាវ និងការអភិវឌ្ឍថ្មីៗរបស់ ក.ស.ភ.

- ធ្វើការស្ទង់មតិអំពីការផ្តល់សេវាកម្មរបស់ ក.ស.ភ. ដើម្បីទទួលបានការវាយតម្លៃពីអ្នកប្រើប្រាស់លើចំណុចសកម្ម និងចំណុចអសកម្ម
- ពិនិត្យ និងវាយតម្លៃសមត្ថភាពការងាររបស់បុគ្គលិកក្រោមឱវាទ ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការតម្លើងឋានៈ និងការដាក់ពិន័យ
- រៀបចំបូកសរុបរបាយការណ៍សកម្មភាពការងារប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ដើម្បីជូនថ្នាក់ដឹកនាំបានជ្រាប។

❖ លោក **គុល សុខុម** (នាយកដ្ឋានប្រតិបត្តិការចំណតផែ TS៣)

- **ការងារគ្រប់គ្រង**
  - ជាសេនាធិការឱ្យអគ្គនាយករងប្រតិបត្តិការ លើការងារប្រតិបត្តិការចំណតផែ TS៣
  - ផ្តល់ការណែនាំដល់អង្គភាពក្រោមឱវាទអំពីលំហូរប្រតិបត្តិការ។
- **ការងារជំនាញ**
  - រៀបចំកាលវិភាគ និងចាត់ចែងនាវាចូលចត និងចេញពីផែនៅតាមដងយោងនីមួយៗ
  - រៀបចំ និងចាត់ចែងប្លង់របស់កុងតឺន័រទាំងនាំចូល និងនាំចេញ
  - ធានាឱ្យការធ្វើប្រតិបត្តិការលើកដាក់នៅលើទីលាន និងនៅស្ពានផែឱ្យស្របតាមស្តង់ដារអន្តរជាតិ និងលក្ខណៈបច្ចេកទេស
  - ផ្តល់ការណែនាំដល់កម្មករបម្រើការងារនៅលើចំណត អំពីគោលការណ៍ សន្តិសុខ និងសុវត្ថិភាព
  - ធានាឱ្យមានបរិយាកាសការងារល្អជាមួយបុគ្គលិកក្រោមឱវាទ
  - រក្សាទំនាក់ទំនងល្អក្នុងចំណោមថ្នាក់ដឹកនាំ និងកម្មករក្រោមឱវាទ
  - ជម្រុញការលើកទឹកចិត្តដល់បុគ្គលិកក្រោមឱវាទ
  - ជម្រុញគុណភាពការងារតាមរយៈការផ្តល់ការណែនាំ និងការបណ្តុះបណ្តាល
  - ធានាឱ្យការផ្តល់សេវាកាន់តែល្អ មានប្រសិទ្ធភាព និងផលិតភាពខ្ពស់
  - ធ្វើបញ្ជី Check List ផ្នែកប្រតិបត្តិការ
  - ល្បាត និងត្រួតពិនិត្យសកម្មភាពប្រតិបត្តិការ ដើម្បីធានាថាបុគ្គលិកផ្នែកប្រតិបត្តិការទាំងអស់ពាក់សម្ភារការពារពលកម្ម (PPE) និងប្រើប្រាស់សម្ភារគ្រឿងចក្របានត្រឹមត្រូវ
  - រៀបចំការប្រជុំប្រចាំខែជាមួយបុគ្គលិកក្រោមឱវាទ ដើម្បីពិភាក្សា និងដកពិសោធន៍ការងារកន្លងមក
  - ចូលរួមស៊ើបអង្កេតគ្រោះថ្នាក់ការងារដែលបានកើតឡើង
  - ត្រួតពិនិត្យមាត់ច្រកចេញ-ចូល។
- **ការងារវាយតម្លៃ**
  - បូកសរុបរបាយការណ៍ប្រតិបត្តិការប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ
  - គណនា និងវាយតម្លៃការប្រើប្រាស់ទីលាន ស្ពានផែ និងគ្រឿងចក្រលើកដាក់
  - ពិនិត្យ និងវាយតម្លៃសមត្ថភាពការងាររបស់កម្មករ និងនិយោជិតក្រោមឱវាទ ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការតម្លើងឋានៈ និងការដាក់ពិន័យ។

❖ លោក **ជី ទិចិត្រ** (នាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧)

- **ការងារគ្រប់គ្រង**
  - ជាសេនាធិការឱ្យអគ្គនាយករងប្រតិបត្តិការលើការងារប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧
  - ផ្តល់ការណែនាំដល់អង្គភាពក្រោមឱវាទអំពីលំហូរប្រតិបត្តិការ។
- **ការងារជំនាញ**
  - រៀបចំកាលវិភាគនិងចាត់ចែងនាវាចូលចត និងចេញពីផែនៅតាមដងយោងនីមួយៗ
  - រៀបចំ និងចាត់ចែងប្លង់របស់កុងតឺន័រទាំងនាំចូល និងនាំចេញ
  - ធានាឱ្យការធ្វើប្រតិបត្តិការលើកដាក់នៅលើទីលាន និងនៅស្ពានផែឱ្យស្របតាមស្តង់ដារអន្តរជាតិ និងលក្ខណៈបច្ចេកទេស
  - ណែនាំដល់កម្មករបម្រើការងារនៅលើចំណតអំពីគោលការណ៍សន្តិសុខ និងសុវត្ថិភាព
  - ធានាឱ្យមានបរិយាកាសការងារល្អជាមួយបុគ្គលិកក្រោមឱវាទ
  - រក្សាទំនាក់ទំនងល្អក្នុងចំណោមថ្នាក់ដឹកនាំ និងកម្មករក្រោមឱវាទ
  - ជម្រុញការលើកទឹកចិត្តដល់បុគ្គលិកក្រោមឱវាទ
  - ជម្រុញគុណភាពការងារតាមរយៈការផ្តល់ការណែនាំ និងការបណ្តុះបណ្តាល
  - ធានាឱ្យការផ្តល់សេវាកាន់តែល្អ ប្រកបដោយប្រសិទ្ធភាព និងផលិតភាពខ្ពស់
  - ធ្វើបញ្ជី Check List ផ្នែកប្រតិបត្តិការ
  - ល្បាត និងត្រួតពិនិត្យសកម្មភាពប្រតិបត្តិការដើម្បីធានាថា បុគ្គលិកផ្នែកប្រតិបត្តិការទាំងអស់ពាក់សម្ភារការពារខ្លួន (PPE) និងប្រើប្រាស់នូវសម្ភារគ្រឿងចក្រឱ្យបានត្រឹមត្រូវ
  - រៀបចំការប្រជុំប្រចាំខែជាមួយបុគ្គលិកក្រោមឱវាទ ដើម្បីពិភាក្សា និងដកពិសោធន៍ការងារកន្លងមក
  - ចូលរួមស៊ើបអង្កេតគ្រោះថ្នាក់ការងារដែលបានកើតឡើង
  - ត្រួតពិនិត្យមាត់ច្រកចេញ-ចូល។
- **ការងារវាយតម្លៃ**
  - គណនា និងវាយតម្លៃការប្រើប្រាស់ទីលាន ស្ពានផែ និងគ្រឿងចក្រលើកដាក់
  - ពិនិត្យ និងវាយតម្លៃសមត្ថភាពការងាររបស់បុគ្គលិកក្រោមឱវាទ ដើម្បីផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្នុងការលើកទឹកចិត្ត ការតម្លើងឋានៈ និងការដាក់ពិន័យ
  - បូកសរុបរបាយការណ៍ប្រតិបត្តិការប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំជូនថ្នាក់ដឹកនាំ។

**ឃ- ការបណ្តុះបណ្តាលបន្តសម្រាប់បុគ្គលិកជាន់ខ្ពស់**

លោកស្រី **ហ៊ី ផានិន** ប្រធាននាយកដ្ឋានផែនការ/ទីផ្សារ ត្រូវបានបញ្ជូនទៅចូលរួមការបណ្តុះបណ្តាលក្នុងវគ្គវិក្រឹត្យការថ្នាក់ឧត្តមមន្ត្រី នៅសាលាភូមិន្ទរដ្ឋបាល ក្នុងឆ្នាំ២០១៥។

## ៥- ការជាប់ពាក់ព័ន្ធរបស់អភិបាល និងបុគ្គលិកជាន់ខ្ពស់ក្នុងដំណើរការផ្លូវច្បាប់

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ក.ស.ភ. មិនមានការជាប់ពាក់ព័ន្ធក្នុងដំណើរការផ្លូវច្បាប់ ដែលធ្វើឡើងដោយអភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ ក.ស.ភ. នោះទេ។

## ៦- លាភការ ឬប្រាក់បំណាច់របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់

ក- ឈ្មោះ តំណែងអភិបាល និងបុគ្គលិកជាន់ខ្ពស់ និងប្រាក់បំណាច់ ឬលាភការ ដែលទទួលបានខ្ពស់បំផុត ៖ (ឯកតា៖ពាន់រៀល)

| ល.រ | ឈ្មោះអភិបាល និងបុគ្គលិកជាន់ខ្ពស់ | មុខតំណែងក្នុងក.ស.ភ. | ប្រាក់បៀវត្សរ៍ និងលាភការមធ្យមប្រចាំខែ | ចំនួនសរុប "ប្រាក់បៀវត្សរ៍ និងលាភការ" |
|---|---|---|---|---|
| | | | ២០១៥ | |
| ១ | ហ៊ី បារី | ប្រធានអគ្គនាយក | ១៣.៦៤៦ | ១៦៣.៧៥៥ |
| ២ | គីម សែន | អគ្គនាយករង | ៥.៨៣០ | ៦៩.៩៦៨ |
| ៣ | ព្រុំ សុខានី | អគ្គនាយករង | ១០.២១៥ | ១២២.៥៩១ |
| ៤ | ណែម ធីម | អគ្គនាយករង | ៥.៣៨៦ | ៦៤.៦៣២ |
| ៥ | ហៀក ភិរុណ | អគ្គនាយករង | ៦.០៨១ | ៧២.៩៧៦ |
| ៦ | គង់ ចាន់នី | ប្រធានលេខាធិការដ្ឋាន | ៥.៥៣២ | ៦៦.៣៨៧ |
| ៧ | កែវ សុផាណ្ណារ៉ា | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | ៤.៣២១ | ៥១.៨៥៨ |
| ៨ | ជួន សុខេម | ប្រធាននាយកដ្ឋានរដ្ឋបាល | ៤.៤០៤ | ៥២.៨៤៨ |
| ៩ | គង់ សុធា | ប្រធាននាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស | ៤.៤៩៩ | ៥៣.៩៩៧ |
| ១០ | ឈាវ វណ្ណធា | ប្រធាននាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ | ៤.៩៧២ | ៥៩.៦៧២ |
| ១១ | កុយ ប៊ុនធន | ប្រធាននាយកដ្ឋានវិស្វកម្ម | ៤.៨៤៤ | ៥៨.១២៨ |
| ១២ | ជៀប វីរ៉ាយ៉ា | ប្រធាននាយកដ្ឋានជលធារសាស្ត្រ | ៤.២២០ | ៥០.៦៤៥ |
| ១៣ | យឹម ជឿន | ប្រធាននាយកដ្ឋានសេវាកម្មនាវាចរណ៍ | ៤.៥៦៨ | ៥៤.៨២៥ |
| ១៤ | សយ សេរីសុវឌ្ឍនៈ | ប្រធាននាយកដ្ឋានមណ្ឌលអាជីវកម្មផែ/ផែក្នុងស្រុក | ៤.២៣៥ | ៥០.៨២២ |
| ១៥ | ហ៊ី ផានិន | ប្រធាននាយកដ្ឋានផែនការ/ទីផ្សារ | ៤.៦៤៣ | ៥៥.៧១៧ |
| ១៦ | តុល សុខុម | ប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែ TS៣ | ៤.៥៥៤ | ៥៤.៦៥០ |
| ១៧ | ជី វិចិត្រ | ប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧ | ៤.៤៨២ | ៥៣.៧៩០ |
| **សរុប** | | | **៩៦.៤៣២** | **១.១៥៧.២៦១** |

### ខ- ចំនួនប្រាក់បំណាច់ ឬលាភការសរុប ដែលបើកឱ្យអភិបាលមិនប្រតិបត្តិ

(ឯកតា៖ លានរៀល)

| ល.រ | ឈ្មោះអភិបាលមិនប្រតិបត្តិ | មុខតំណែងក្នុង ក.ស.ភ | ប្រាក់បៀវត្សរ៍ / ប្រាក់បំណាច់ ឆ្នាំ២០១៥ |
|---|---|---|---|
| ១* | ឯកឧត្តម ស្លុត សំបូរ | អភិបាល | ២.៥០០.០០០ |
| ២* | ឯកឧត្តម សួន រចនា | អភិបាល | ៥៥.០០០.០០០ |
| ៣ | ឯកឧត្តម លី ស៊ីវណ្ណា | អភិបាល | ៥៧.៥០០.០០០ |
| ៤ | ឯកឧត្តម កែន សម្បត្តិ | អភិបាល | ៥៧.៥០០.០០០ |
| ៥ | ឯកឧត្តម ប៉ែន សុវិជាតិ | អភិបាល | ៥៧.៥០០.០០០ |
| ៦ | លោក ហួត ហៃ | អភិបាល | ៥៧.៥០០.០០០ |
| ៧ | លោក ម៉ម រិទ្ធី | មន្ត្រីត្រួតពិនិត្យរដ្ឋ | ៥៧.៥០០.០០០ |
| **សរុប** | | | **៣៤៥.០០០.០០០** |

**សម្គាល់៖ ឯកឧត្តម សួន រចនា ចូលកាន់តំណែងជំនួសឯកឧត្តម ស្លុត សំបូរ ដែលបានទទួលមរណៈភាព នៅខែកុម្ភៈ ឆ្នាំ ២០១៥។*

### គ- ចំនួនប្រាក់បៀវត្សរ៍សរុបសម្រាប់រយៈពេល ០១ (មួយ) ឆ្នាំខាងមុខ ដែលត្រូវផ្តល់ជូនអភិបាល ឬ បុគ្គលិកជាន់ខ្ពស់

(ឯកតា៖ពាន់រៀល)

| ល.រ | ឈ្មោះអភិបាល និង បុគ្គលិកជាន់ខ្ពស់ | មុខតំណែងក្នុងក.ស.ភ. | ប្រាក់បំណាច់ និង លាភការសរុបសម្រាប់ រយៈពេល ០១ (មួយ) ឆ្នាំខាងមុខ |
|---|---|---|---|
| ១ | ឯកឧត្តម ហ៊ី បារី | អភិបាល | ១៧៣.០៣០ |
| ២ | ឯកឧត្តម សួន រចនា | អភិបាល | ៩៦.០០០ |
| ៣ | ឯកឧត្តម លី ស៊ីវណ្ណា | អភិបាល | ៩៦.០០០ |
| ៤ | ឯកឧត្តម កែន សម្បត្តិ | អភិបាល | ៩៦.០០០ |
| ៥ | ឯកឧត្តម ប៉ែន សុវិជាតិ | អភិបាល | ៩៦.០០០ |
| ៦ | លោក ហួត ហៃ | អភិបាល | ៩៦.០០០ |
| ៧ | លោក ម៉ម រិទ្ធី | មន្ត្រីត្រួតពិនិត្យរដ្ឋ | ៩៦.០០០ |
| ៨ | លោកជំទាវ គីម សែន | អគ្គនាយករង | ១០៦.៦៦៤ |
| ៩ | ឯកឧត្តម ព្រុំ សុខានី | អគ្គនាយករង | ១២៩.១០០ |
| ១០ | ឯកឧត្តម ណៃម ធីម | អគ្គនាយករង | ៧១.០៩៥ |
| ១១ | លោក ហៀក ភិរុណ | អគ្គនាយករង | ៨០.២៧៣ |
| ១២ | លោក គង់ ចាន់នី | ប្រធានលេខាធិការដ្ឋាន | ៧១.៥៧៥ |
| ១៣ | លោក កែវ សុផាណ្ណារ៉ា | ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | ៥៧.០៤៣ |
| ១៤ | លោកស្រី ជួន សុខេម | ប្រធាននាយកដ្ឋានរដ្ឋបាល | ៥៨.១៣២ |
| ១៥ | លោក គង់ សុធា | ប្រធាននាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស | ៥៩.៣៩៦ |
| ១៦ | កញ្ញា ឈាវ វណ្ណធា | ប្រធាននាយកដ្ឋានគណនេយ្យ/ហិរញ្ញវត្ថុ | ៦៥.៦៣៩ |

| | | | |
|---|---|---|---|
| ១៧ | លោក កុយ ប៊ុនធន | ប្រធាននាយកដ្ឋានវិស្វកម្ម | ៦៣.៩៤០ |
| ១៨ | លោក ជៀប វីរ៉ាយ៉ា | ប្រធាននាយកដ្ឋានជលធារសាស្ត្រ | ៥៥.៧០៩ |
| ១៩ | លោក យឹម ជឿន | ប្រធាននាយកដ្ឋានសេវាកម្មនាវាចរណ៍ | ៦០.៣០៧ |
| ១៤ | លោក សយ សេរីសុវឌ្ឍនៈ | ប្រធាននាយកដ្ឋានមណ្ឌលអាជីវកម្មផែ/ផែក្នុងស្រុក | ៥៥.៩០៤ |
| ១៥ | លោកស្រី ហ៊ឺ ផានិន | ប្រធាននាយកដ្ឋានផែនការ/ទីផ្សារ | ៦១.២៨៨ |
| ១៦ | លោក គុល សុខុម | ប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែ TS៣ | ៦០.១១៥ |
| ១៧ | លោក ជី វិចិត្រ | ប្រធាននាយកដ្ឋានប្រតិបត្តិការចំណតផែកុងតឺន័រ LM១៧ | ៥៩.១៦៩ |
| **សរុប** | | | **១.៨៦៤.៣៧៩** |

**សម្គាល់៖ ការប៉ាន់ស្មានប្រាក់បៀវត្សរ៍របស់បុគ្គលិកជាន់ខ្ពស់សម្រាប់រយៈពេល ១ឆ្នាំទៅមុខ ផ្អែកលើកំណើន ១០% នៃប្រាក់បៀវត្សរ៍មូលដ្ឋាន និងកំណើនអាជីវកម្មកុងតឺន័រ TEUs។*

**ឃ- ការបង្កើនប្រាក់បំណាច់ ឬលាភការសរុបក្នុងចំនួនច្រើន ដល់អភិបាល ឬបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុននៅក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន ឬអនាគត**

តាមរយៈកិច្ចប្រជុំ នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ ក្រុមប្រឹក្សាភិបាលបានឯកភាពអនុម័តលើលក្ខន្តិកៈបុគ្គលិកថ្មីរបស់ ក.ស.ភ. ក្នុងគោលបំណងឆ្លើយតបនឹងការអភិវឌ្ឍ និងការវិវត្តរបស់ ក.ស.ភ. និងសំដៅធ្វើយ៉ាងណាឱ្យការគ្រប់គ្រង និងប្រតិបត្តិការរបស់ ក.ស.ភ. មានតម្លាភាព អភិបាលកិច្ចល្អ និងប្រសិទ្ធភាពខ្ពស់។ តាមរយៈលក្ខន្តិកៈបុគ្គលិកថ្មី ប្រាក់បៀវត្សរ៍ប្រចាំខែរបស់សមាជិកក្រុមប្រឹក្សាភិបាលបានកើនឡើងជាមធ្យម ២២១,៦៧% បើប្រៀបធៀបប្រាក់បៀវត្សរ៍ចុងក្រោយមុនមានការតម្លើង។ ទន្ទឹមនេះ ប្រាក់បៀវត្សរ៍ប្រចាំខែរបស់សមាជិកបុគ្គលិកជាន់ខ្ពស់បានកើនឡើងជាមធ្យម ៣៨,៦០% បើប្រៀបធៀបប្រាក់បៀវត្សរ៍ចុងក្រោយមុនមានការដំឡើង ដោយសារការបង្កើននាយកដ្ឋានថ្មី និងការដំឡើងឋានៈរបស់បុគ្គលិកជាន់ខ្ពស់។

## ៧- ក្រមសីលធម៌សម្រាប់អភិបាល និងបុគ្គលិកជាន់ខ្ពស់

### ក- គោលការណ៍នៃក្រមសីលធម៌

ក្រមសីលធម៌នេះ ជាក្រមប្រតិបត្តិ ដែលត្រូវអនុវត្តចំពោះក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ ក.ស.ភ.។

រាល់ការបំពានលើក្រមសីលធម៌នេះ អាចនឹងត្រូវទទួលទណ្ឌកម្មនានាទៅតាមនីតិវិធី ដែលប្រតិបត្តិដោយក្រុមប្រឹក្សាភិបាល។ គោលការណ៍ និងលក្ខខណ្ឌដែលមានចែងនៅក្នុងក្រមសីលធម៌នេះ ត្រូវបានតាក់តែងឡើង ដោយអនុលោមតាមច្បាប់ជាធរមាន ដើម្បីឱ្យអភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ ក.ស.ភ. គោរពប្រតិបត្តិតាម។ ក្រមសីលធម៌នេះ មិនត្រូវបានប្រើ ដើម្បីជំនួសការដោះស្រាយវិវាទតាមផ្លូវតុលាការនោះទេ។

យន្តការតាមដាន និងរក្សាតុល្យភាព (Checks and Balances) ដែលមានក្នុងក្រមសីលធម៌នេះ ត្រូវបានរៀបចំឡើង ដើម្បីធានាតុល្យភាពក្នុងការគ្រប់គ្រង និងការគោរពកាតព្វកិច្ចកំណត់ដោយច្បាប់ ព្រមទាំងការពារក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់ពីការចោទប្រកាន់មិនត្រឹមត្រូវ ឬគ្មានហេតុផលណាមួយ។ ការចោទប្រកាន់បែបនេះ នឹងអាចមានផលប៉ះពាល់ដល់អាជីវកម្មរបស់ ក.ស.ភ. ឬ ប៉ះពាល់ផលប្រយោជន៍

ដល់បុគ្គលណាម្នាក់។ សមាជិកក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់ ក.ស.ភ. អះអាង និងប្តេជ្ញាថានឹងគោរពតាមគោលការណ៍ និងកាតព្វកិច្ច ដូចមានចែងនៅក្នុងក្រមសីលធម៌នេះ។

❖ **និយមន័យ**

**ក្រុមប្រឹក្សាភិបាល** ៖ សំដៅដល់ក្រុមប្រឹក្សាភិបាលនៃកំពង់ផែស្វយ័តភ្នំពេញ។

**អភិបាល** ៖ សំដៅដល់សមាជិកនៃក្រុមប្រឹក្សាភិបាល ហើយអាចជាអភិបាលប្រតិបត្តិ អភិបាលមិនប្រតិបត្តិ ឬ អភិបាលឯករាជ្យ។

**អភិបាលឯករាជ្យ** ៖ សំដៅដល់សមាជិកឯករាជ្យ ដែលបំពេញតាមលក្ខខណ្ឌនៃជំពូកទី៥ នៃប្រកាសស្តីពី អភិបាលកិច្ចអាជីវកម្ម សម្រាប់សហគ្រាសសាធារណៈបោះផ្សាយលក់មូលបត្រជាសាធារណៈ និងដែលជាទូទៅសំដៅដល់អភិបាល ដែលអាចមានភារកិច្ចដោយមិនមានទំនាស់ផលប្រយោជន៍ដែលកើតឡើងពាក់ព័ន្ធជាមួយ ក.ស.ភ.។

**អភិបាលប្រតិបត្តិ** ៖ សំដៅដល់អភិបាលដែលកាន់តំណែងជាបុគ្គលិកជាន់ខ្ពស់នៅក្នុង ក.ស.ភ.។

**អភិបាលមិនប្រតិបត្តិ** ៖ សំដៅដល់អភិបាលដែលមិនអនុវត្តនូវប្រតិបត្តិការប្រចាំថ្ងៃក្នុង ក.ស.ភ. ឬក៏ជាអភិបាលមិនប្រតិបត្តិជាតំណាងភាគហ៊ុនិកឯកជន និងសាធារណៈ។

**បុគ្គលិកជាន់ខ្ពស់** ៖ សំដៅដល់បុគ្គលទាំងឡាយណាដែលមានមុខតំណែងចាប់ពីប្រធាននាយកដ្ឋាន រហូតដល់អគ្គនាយក រួមទាំងលេខាធិការរបស់ ក.ស.ភ. និងប្រធានសវនកម្មផ្ទៃក្នុងនិងអ្នកដែលមានមុខតំណែងសំខាន់ផ្សេងទៀតក្នុងក្រុមហ៊ុន។

❖ **ការបំពេញកាតព្វកិច្ចតាមច្បាប់ និងតាមក្រមសីលធម៌**

អភិបាល និង បុគ្គលិកជាន់ខ្ពស់ទាំងអស់ ត្រូវតែប្រតិបត្តិតាមក្រមសីលធម៌ និងគោរពតាមច្បាប់ព្រមទាំងលិខិតបទដ្ឋានគតិយុត្តទាំងឡាយជាធរមានក្នុងព្រះរាជាណាចក្រកម្ពុជា។

❖ **ការធ្វើអាជីវកម្ម**

អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវបំពេញការងារក្នុងអាជីវកម្មរបស់ ក.ស.ភ. ដោយស្មោះត្រង់ គោរពតាមច្បាប់។

ភាពស្មោះត្រង់ និងការបំពេញកាតព្វកិច្ចតាមច្បាប់ មានន័យថា អភិបាល ឬបុគ្គលិកជាន់ខ្ពស់ត្រូវ ៖

- បំពេញតួនាទីជាមួយនឹងព័ត៌មានពេញលេញទាក់ទងនឹងកម្មវត្ថុពាក់ព័ន្ធ នឹងសេចក្តីសម្រេចណាមួយ
- បំពេញតួនាទីប្រកបដោយសុចរិត និងក្នុងគោលបំណងត្រឹមត្រូវ
- បំពេញតួនាទីដោយមិនគិតពីផលប្រយោជន៍ផ្ទាល់ខ្លួនដែលនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍អង្គភាព
- អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវមានគោលជំហរច្បាស់លាស់ ក្នុងការបម្រើផលប្រយោជន៍របស់ភាគហ៊ុនិកទាំងអស់ ជាពិសេស ក្នុងពេលធ្វើការសម្រេចចិត្ត។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ មិនត្រូវជាប់ពាក់ព័ន្ធ ទោះបីដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ជាមួយនឹងការជួញដូរផ្ទៃក្នុង ឬស៊ែហ្វ៍ដៀលីង (Self-Dealing) ដែលមិនត្រឹមត្រូវ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវធ្វើសេចក្តីប្រកាសជាសាធារណៈមួយអំពីទំនាស់ផលប្រយោជន៍របស់ខ្លួន ដែលកើតមានឡើងពាក់ព័ន្ធនឹង ក.ស.ភ.។ អភិបាល និងបុគ្គលិកជាន់ខ្ពស់នៃ ក.ស.ភ. ពុំត្រូវបានអនុញ្ញាតឱ្យធ្វើ

ការជួញដូរមូលបត្រកម្មសិទ្ធិរបស់ ក.ស.ភ. ឡើយ ក្នុងកំឡុងពេលដូចខាងក្រោម៖

- ដប់ (១០) ថ្ងៃ នៃថ្ងៃធ្វើការ មុនការចេញផ្សាយព័ត៌មានហិរញ្ញវត្ថុ រហូតដល់មួយ (០១)ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីការចេញផ្សាយព័ត៌មានហិរញ្ញវត្ថុ និង
- ប្រាំពីរ (០៧) ថ្ងៃ នៃថ្ងៃធ្វើការ មុនកិច្ចប្រជុំនៃក្រុមប្រឹក្សាភិបាល រហូតដល់មួយ (០១)ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយកិច្ចប្រជុំនៃក្រុមប្រឹក្សាភិបាល។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ អាចចូលរួមក្នុងកិច្ចការជំនួញក្នុងនាម ក.ស.ភ. ដែលពួកគេមានផលប្រយោជន៍ លុះត្រាតែអភិបាល ឬបុគ្គលិកជាន់ខ្ពស់ទាំងនោះ អនុវត្តតាមគោលការណ៍ និងបែបបទទាំងអស់ ដែលបានអនុម័ត ព្រមទាំងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយ ក្នុងព្រះរាជាណាចក្រកម្ពុជា។

❖ **ការរក្សាការសម្ងាត់**

គ្មានអភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាម្នាក់ មានសិទ្ធិចែកចាយ ថតចម្លង ផលិតជាថ្មី បញ្ជូន បង្ហាញ ឬលាតត្រដាង រាល់ព័ត៌មានសម្ងាត់ណាមួយ ដែលពាក់ព័ន្ធនឹងកិច្ចការរបស់ ក.ស.ភ.។ អភិបាល ឬបុគ្គលិកជាន់ខ្ពស់ ត្រូវរក្សាយ៉ាងម៉ឺងម៉ាត់ នូវការសម្ងាត់នៃកិច្ចប្រជុំទាំងអស់ និងការពិភាក្សាផ្សេងៗ ព្រមទាំងការទំនាក់ទំនងនៃក្រុមប្រឹក្សាភិបាល លើកលែងតែក្រុមប្រឹក្សាភិបាល ឬច្បាប់តម្រូវផ្សេងពីនេះ ។

គ្មានអភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាម្នាក់ ប្រើប្រាស់នូវរាល់ព័ត៌មានណាមួយ ដែលផ្តល់ដោយ ក.ស.ភ. ឬទទួលបានតាមរយៈការបំពេញការងារជាអភិបាលទៅឱ្យ ក.ស.ភ. ទោះបីក្រោមរូបភាពណាក៏ដោយ លើកលែងតែក្នុងគោលបំណងជួយសម្រួលដល់កាតព្វកិច្ចរបស់ខ្លួននៅក្នុងក្រុមប្រឹក្សាភិបាល។ អភិបាល ឬបុគ្គលិកជាន់ខ្ពស់ ត្រូវយកចិត្តទុកដាក់ ជាពិសេស ក្នុងពេលបំពេញការងារទាក់ទងនឹងលទ្ធផលរបស់ក្រុមហ៊ុន ការប៉ាន់ស្មានព័ត៌មានហិរញ្ញវត្ថុផ្សេងទៀត ចំណេះដឹង និងបច្ចេកវិទ្យា ព្រមទាំងព័ត៌មានធនធានមនុស្ស។ អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវគោរពកាតព្វកិច្ចរក្សាការសម្ងាត់ ទោះបីក្រោយពីបានបញ្ចប់ការងាររបស់ខ្លួននៅ ក.ស.ភ. ក៏ដោយ។

❖ **ការគោរពសិទ្ធិចំពោះបុគ្គលិក ក.ស.ភ.**

អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវអនុវត្តអំណាចរបស់ខ្លួនឱ្យបានត្រឹមត្រូវ និងធ្វើការវិនិច្ឆ័យឱ្យបានល្អ ចំពោះបុគ្គលិករបស់ ក.ស.ភ. ព្រមទាំងត្រូវឆ្លើយតបទៅតាមតម្រូវការនៃសមាជិករបស់ ក.ស.ភ. ដោយភាពទទួលខុសត្រូវ ការគោរព និងដោយមានវិជ្ជាជីវៈខ្ពស់។

ទំនាក់ទំនងរវាងមន្ត្រី និយោជិត និងអភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវធ្វើឡើងដោយឈរលើគោលការណ៍នៃការជឿទុកចិត្ត ការគោរពគ្នាទៅវិញទៅមក និងស្មារតីគោរពសេចក្តីថ្លៃថ្នូររបស់បុគ្គលិកម្នាក់ៗ។

ក.ស.ភ. ត្រូវគោរពតាមគោលនយោបាយធនធានមនុស្សរបស់ខ្លួនដោយឥតលម្អៀង និងគោរពតាមច្បាប់ ដោយមិនត្រូវបង្អាក់បង្អួច ឬមានការរើសអើងឡើយ។ រាល់ការគាបសង្កត់ ការរំខាន ការធ្វើទុក្ខបុកម្នេញ ឬការធ្វើទារុណកម្មខាងផ្លូវចិត្ត ឬផ្លូវកាយ ត្រូវបានហាមឃាត់។

គោលការណ៍ទាំងនេះ អនុវត្តលើអភិបាល និងបុគ្គលិកជាន់ខ្ពស់ ទាក់ទងនឹងការប្រព្រឹត្តរបស់ខ្លួនចំពោះបុគ្គលិករបស់ ក.ស.ភ. និងបុគ្គលដែលមិនមែនជាបុគ្គលិកក្នុង ក.ស.ភ. ផងដែរ ។

❖ **ការការពារទ្រព្យសម្បត្តិ**

អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវការពារទ្រព្យសម្បត្តិទាំងអស់របស់ ក.ស.ភ.។ ទ្រព្យសម្បត្តិទាំងនោះ រួមមាន ទ្រព្យរូបី និងទ្រព្យអរូបី ដូចជាគំនិត ជំនាញ ចំណេះដឹង ចំណេះធ្វើ ដែលបង្កើតឡើងដោយ ក.ស.ភ.។

អភិបាល ឬបុគ្គលិកជាន់ខ្ពស់ មិនត្រូវប្រើប្រាស់ទ្រព្យសម្បត្តិ ឬធនធានរបស់ ក.ស.ភ សម្រាប់ហេតុផលផ្ទាល់ខ្លួន ឬដើម្បីផលប្រយោជន៍ដល់តតិយជនឡើយ។ អភិបាល ឬបុគ្គលិកជាន់ខ្ពស់ ត្រូវរក្សាទ្រព្យសម្បត្តិរបស់ ក.ស.ភ. ឱ្យបានល្អគង់វង្ស គ្រប់ពេលវេលា និងមិនត្រូវឱ្យបុគ្គលណាម្នាក់ ដែលមិនទទួលបានការអនុញ្ញាតពីក្រុមប្រឹក្សាភិបាល មានសិទ្ធិប្រើប្រាស់ អាស្រ័យផល និងចាត់ចែងទ្រព្យសម្បត្តិរបស់ ក.ស.ភ. ឡើយ។

❖ **សវនកម្មផ្ទៃក្នុង**

អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវធានានូវតម្លាភាព និងភាពស្មោះត្រង់ នៅពេលបំពេញការងារទាក់ទងជាមួយនឹងសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ដើម្បីធានាថាភាពទន់ខ្សោយ និងគុណវិបត្តិចម្បងៗអាចត្រូវបានកំណត់ និងកែតម្រូវបាន។

អភិបាល និងបុគ្គលិកជាន់ខ្ពស់ មិនត្រូវធ្វើទង្វើណាមួយ ដែលនាំឱ្យរាំងស្ទះ ឬ លាក់បាំងព័ត៌មានណាមួយ ដល់ការធ្វើសវនកម្ម ឬការធ្វើអធិការកិច្ចណាមួយឡើយ ទោះបីជាការធ្វើឡើងនោះជាលក្ខណៈផ្ទៃក្នុង ដោយសវនករនៃ ក.ស.ភ. ក៏ដោយ។ រាល់ការប្រព្រឹត្តទង្វើទាំងនេះ គឺជាការបំពានយ៉ាងធ្ងន់ធ្ងរទៅលើក្រមសីលធម៌នេះ ហើយត្រូវបានហាមឃាត់ ។

❖ **សកម្មភាពអភិវឌ្ឍន៍**

អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវចូលរួមឱ្យអស់ពីលទ្ធភាពរបស់ខ្លួនជាប្រចាំ នៅក្នុងសកម្មភាពអភិវឌ្ឍន៍វិជ្ជាជីវៈ ព្រមទាំងបំពេញភារកិច្ចរបស់ខ្លួនឱ្យមានលក្ខណៈវិជ្ជាជីវៈ និងឱ្យបានទាន់ពេលវេលាទៅតាមការណែនាំ និងការគ្រប់គ្រងរបស់ក្រុមប្រឹក្សាភិបាល។

❖ **ផលប្រយោជន៍របស់ ក.ស.ភ.**

អភិបាល និងបុគ្គលិកជាន់ខ្ពស់ ត្រូវធ្វើការលះបង់ ដើម្បីបំពេញតាមតម្រូវការរបស់ ក.ស.ភ.។

អភិបាល ត្រូវបំពេញតួនាទីគ្រប់ពេលទាំងអស់ ដើម្បីជាឧត្តមប្រយោជន៍របស់ ក.ស.ភ. ហើយមិនមែនដើម្បីផលចំណេញ ឬការបង្កើនប្រយោជន៍ហិរញ្ញវត្ថុផ្ទាល់ខ្លួន ឬតតិយជនណាមួយឡើយ។ បុគ្គលិកទាំងអស់របស់ ក.ស.ភ. ដោយរាប់បញ្ចូលទាំងអភិបាល និងបុគ្គលិកជាន់ខ្ពស់ផង ត្រូវបំពេញនូវតួនាទីដោយស្មោះត្រង់ និងដើម្បីផលប្រយោជន៍របស់ ក.ស.ភ. គ្រប់កាលៈទេសៈទាំងអស់។ បុគ្គលិកទាំងអស់មិនត្រូវបរិហារជាសាធារណៈ និងវាយប្រហារណាមួយមកលើកិត្តិនាម និងភាពស្មោះត្រង់របស់ ក.ស.ភ. និងការវាយប្រហារមកលើវិជ្ជាជីវៈការងាររបស់បុគ្គលិក ក.ស.ភ.។

❖ **ទំនាស់ផលប្រយោជន៍**

អភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ ក.ស.ភ. ត្រូវធានាថាសកម្មភាពខាងក្រៅ និងផលប្រយោជន៍ផ្ទាល់ខ្លួនត្រូវបានចែកឱ្យដាច់ពីតួនាទីនៅក្នុង ក.ស.ភ. និងមិនត្រូវប្រើឥទ្ធិពលទៅលើការសម្រេចអាជីវកម្មក្នុងនាម ក.ស.ភ. ឡើយ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់ ចាំបាច់ត្រូវប្រើនូវសុភវិនិច្ឆ័យ និងរក្សាផលប្រយោជន៍ ក.ស.ភ. ជាធំ។ ដើម្បីកុំឱ្យមានទំនាស់ផលប្រយោជន៍ អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវជៀសវាងចេញពីស្ថានភាពណាមួយ ដែលអាចបណ្តាលឲ្យកើតមានទំនាស់ផលប្រយោជន៍។

នៅពេលដែលទំនាស់ផលប្រយោជន៍អាចនឹងកើតមានឡើង នោះអភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ ក.ស.ភ. ត្រូវកំណត់ទំនាស់ផលប្រយោជន៍នោះ ហើយធ្វើការប្រកាសជាសាធារណៈ អំពីទំនាស់ផលប្រយោជន៍ និងធ្វើការដកខ្លួនចេញពីការពិភាក្សា និងការបោះឆ្នោតលើបញ្ហាទាំងនោះ (បើអនុវត្តបាន)។

❖ **អំពើពុករលួយ**

អភិបាល និងបុគ្គលិកជាន់ខ្ពស់ មិនត្រូវផ្តល់ប្រាក់ឧបត្ថម្ភ ឬអំណោយដោយផ្ទាល់ ឬដោយប្រយោល មិនត្រូវធ្វើការសន្យា ឬផ្តល់ផលប្រយោជន៍ណាមួយទៅកាន់មន្ត្រីសាធារណៈ ឬប្រជាពលរដ្ឋដែលទទួលការទុកចិត្តក្នុងអាណត្តិសាធារណៈ តាមរយៈការបោះឆ្នោតដើម្បីឲ្យមន្ត្រីសាធារណៈនោះ ឬមន្ត្រីដែលជាប់ឆ្នោតនោះ (១)អនុវត្តសកម្មភាពណាមួយក្នុងតួនាទីរបស់គេ ឬក៏សម្របសម្រួលការងារណាមួយក្នុងតួនាទីរបស់ពួកគេ ឬ (២)មិនអនុវត្តកាតព្វកិច្ច ឬសម្របសម្រួលការងារណាមួយក្នុងតួនាទីរបស់ពួកគេ ។

អភិបាល ឬបុគ្គលិកជាន់ខ្ពស់ មិនត្រូវទទួលយកអំណោយ ដែលត្រូវបានផ្តល់ឱ្យ ឬនឹងត្រូវផ្តល់ឱ្យដោយសារតែតួនាទីរបស់ខ្លួននៅក្នុង ក.ស.ភ.។

❖ **សកម្មភាពនយោបាយ**

ក.ស.ភ. គោរពតាមការប្តេជ្ញាចិត្តរបស់ក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់ ដែលចង់ចូលរួមក្នុងកិច្ចការសាធារណៈ ប៉ុន្តែ ក.ស.ភ. ត្រូវប្រកាន់គោលការណ៍អព្យាក្រឹតចំពោះវិស័យនយោបាយ។ ដូចនេះ អភិបាល ឬបុគ្គលិកជាន់ខ្ពស់របស់ ក.ស.ភ. អាចអនុវត្តសេរីភាពបញ្ចេញមតិ និងធ្វើសកម្មភាពនយោបាយបាននៅក្រៅពីម៉ោងធ្វើការ ដោយចំណាយផ្ទាល់ខ្លួន និងផ្អែកលើគំនិតផ្ទាល់ខ្លួនប៉ុណ្ណោះ។

អភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ ក.ស.ភ. មិនត្រូវភ្ជាប់ ក.ស.ភ. ទៅនឹងសកម្មភាពផ្ទាល់ខ្លួនរបស់ពួកគេទេ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់ ពុំត្រូវពិភាក្សាពីសមាជិកភាពរបស់ ក.ស.ភ. ទៅក្នុងបរិបទនយោបាយណាមួយឡើយ។

❖ **ការបញ្ចប់អាណត្តិ**

ក្រោយពីបញ្ចប់ភារកិច្ចរបស់ខ្លួន អភិបាល និងបុគ្គលិកជាន់ខ្ពស់ ដែលចូលនិវត្តត្រូវប្រគល់ភ្លាមទៅឱ្យ ក.ស.ភ. វិញនូវឯកសារអេឡិចត្រូនិច និងឯកសារ ជាក្រដាស ឯកសារយោង និងឯកសារផ្សេងៗទៀត ដែលត្រូវបានផ្តល់ជូនក្នុងគោលបំណងបំពេញការងារ។ ការប្រគល់ជូនទៅវិញនូវឯកសារទាំងនេះ មិនបានលុបចោលនូវកាតព្វកិច្ចរក្សាការសម្ងាត់នូវព័ត៌មាន ដែលទទួលបានក្នុងរយៈពេលនៃការកាន់មុខតំណែងនៅក្នុងក្រុមប្រឹក្សាភិបាល ឬតួនាទីជាន់ខ្ពស់នៅក្នុង ក.ស.ភ. នោះទេ។

❖ **ការបកស្រាយ**

អភិបាល និងបុគ្គលិកជាន់ខ្ពស់ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមស្មារតី និងខ្លឹមសារនៃក្រមសីលធម៌នេះ។ អភិបាល និងបុគ្គលិកជាន់ខ្ពស់ មានភារកិច្ចយល់ដឹងអំពីក្រមសីលធម៌នេះ។ អភិបាល ឬបុគ្គលិកជាន់ខ្ពស់ណាម្នាក់ ដែលមានភាពស្រពិចស្រពិល ឬយល់មិនច្បាស់លើបទប្បញ្ញត្តិណាមួយ ត្រូវទាក់ទងទៅផ្នែកច្បាប់ ដោយផ្តល់ពេលវេលាគ្រប់គ្រាន់ឱ្យផ្នែកច្បាប់អាចផ្តល់យោបល់ ឬធ្វើការសម្រេចចិត្តសមស្របមួយ។

❖ ការកែប្រែ

ក្រមសីលធម៌នេះ អាចត្រូវបានធ្វើការកែប្រែ ដោយក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ដោយគោរពតាមលក្ខខណ្ឌតម្រូវក្នុងការផ្តល់ព័ត៌មាន ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងឡាយជាធរមាន។

### ខ- ការអនុវត្តក្រមសីលធម៌

ក្រមសីលធម៌នេះ ត្រូវបានអនុម័ត ដោយក្រុមប្រឹក្សាភិបាលនៃកំពង់ផែស្វយ័តភ្នំពេញ នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ និងមានអានុភាពចាប់ពីពេលក្រុមហ៊ុនទទួលបានការយល់ព្រមឱ្យធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិជាសាធារណៈ ដោយគណៈកម្មការមូលបត្រកម្ពុជា និងត្រូវបានចុះបញ្ជីលក់មូលបត្រនៅផ្សារមូលបត្រកម្ពុជា។ ក្រុមប្រឹក្សាភិបាល ត្រូវចាត់វិធានការសមស្រប ក្នុងករណីមានការបំពារបំពានក្រមសីលធម៌នេះ។

## ៨- សិទ្ធិភាគីពាក់ព័ន្ធ

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ សិទ្ធិភាគីពាក់ព័ន្ធមិនទាន់បានអនុវត្តនោះទេ។

## ផ្នែកទី ៤ : បញ្ជីរាយនាមភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ និងភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន

### ១- ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់

| ល.រ | ឈ្មោះ | សញ្ជាតិ | អាសយដ្ឋាន | លេខអត្តសញ្ញាណវិនិយោគិន (ប្រសិនបើមាន) | បរិមាណ | ភាគរយ |
|---|---|---|---|---|---|---|
| ១ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ខ្មែរ | ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ | គ្មាន | ១៦.៥៤៧.៤៩២ | ៨០% |
| សរុប | | | | | ១៦.៥៤៧.៤៩២ | ៨០% |

### ២- ភាគហ៊ុនិកកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើន

| ល.រ | ឈ្មោះ | សញ្ជាតិ | អាសយដ្ឋាន | លេខអត្តសញ្ញាណវិនិយោគិន (ប្រសិនបើមាន) | បរិមាណ | ភាគរយ |
|---|---|---|---|---|---|---|
| ១ | Mekong Strategic Infrastructure | បរទេស | Craigmor Chambers, Road Town, Tortola, Vg1110, British Virgin Isles | F៩១៨៧៦៧៨៩៧៨៦ | ១.១៩៩.៧២៦ | ៥,៧៨% |
| សរុប | | | | | ១.១៩៩.៧២៦ | ៥,៧៨% |

# ផ្នែកទី ៥ : ព័ត៌មានអំពីការជួញដូរមូលបត្ររបស់កំពង់ផែស្វយ័តភ្នំពេញ

## ១- ព័ត៌មានអំពីមូលបត្រកម្មសិទ្ធិ

**ឈ្មោះមូលបត្រកម្មសិទ្ធិ** : មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ "ក"
**អក្សរកូដមូលបត្រកម្មសិទ្ធិ** : KH1000040001
**ចំណាត់ថ្នាក់នៃមូលបត្រកម្មសិទ្ធិ** : មូលបត្រកម្មសិទ្ធិមានសិទ្ធិបោះឆ្នោតប្រភេទ "ក"
**តម្លៃចារឹកក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ** : ៤.០០០ រៀល
**ថ្លៃលក់ក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ** : ៥.១២០ រៀល
**បរិមាណមូលបត្រកម្មសិទ្ធិសរុបទាំងអស់ដែលកំពុងធ្វើចរាចរលើទីផ្សារ** : ៤.១៣៦.៨៧៣ មូលបត្រ
**មូលធនូបនីយកម្មទីផ្សារ** : ១០៥.៩០៣.៩៤៨.៨០០ រៀល
**ឈ្មោះទីផ្សារមូលបត្រប្រតិស្រុត** : ផ្សារមូលបត្រកម្ពុជា
**កាលបរិច្ឆេទនៃការចុះបញ្ជីលក់មូលបត្រ** : ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥

## ២- ថ្លៃ និងបរិមាណជួញដូរ

| មូលបត្រកម្មសិទ្ធ | | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ* |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ថ្លៃជួញដូរ | អតិបរមារ | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | ៥.៦៨០ |
| | អប្បបរមា | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | ៥.១២០ |
| | មធ្យម | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | ៥.៤០០ |
| បរិមាណជួញដូរ | អតិបរមារ | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | ៣១.៩២៩ |
| | អប្បបរមា | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | ១.០០០ |
| | មធ្យម | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | គ្មាន | ៨.៥១៣ |

***សំគាល់៖** *ទិន្នន័យក្នុងខែធ្នូត្រូវបានគិតត្រឹមថ្ងៃទី៩ រហូតដល់ ចុងឆ្នាំ ២០១៥។*

# ផ្នែកទី ៦ : របាយការណ៍សវនកម្មរបស់សវនករផ្ទៃក្នុងលើការត្រួតពិនិត្យផ្ទៃក្នុង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

កំពង់ផែស្វយ័តភ្នំពេញ
នាយកដ្ឋានសវនកម្មផ្ទៃក្នុង

**របាយការណ៍ស្តីពីការកែតម្រូវនូវចំណុចខ្វះខាត**
**លើអនុលោមភាព និងប្រតិបត្តិការ ឆ្នាំ ២០១៥**

ការងារត្រួតពិនិត្យផ្ទៃក្នុង គឺជាកត្តាចម្បងដ៏មានសារៈសំខាន់បំផុតដែលជួយជំរុញដល់កំពង់ផែស្វយ័តភ្នំពេញធ្វើប្រតិបត្តិការប្រចាំថ្ងៃមានប្រសិទ្ធិភាពប្រកបដោយជោគជ័យ និងសម្រេចបាននូវគោលដៅជាអាទិភាពរបស់ខ្លួនក្នុងសកម្មភាពអាជីវកម្ម ដើម្បីបំពេញតំរូវការអតិថិជនតាមរយៈការអភិវឌ្ឍ កែលំអឥតឈប់ឈរនូវសមត្ថភាពមន្ត្រី បុគ្គលិក កម្មករជំនាញ ការកែសំរួលបែបបទឯកសារតាមលិខិតបទដ្ឋានគតិយុត្តិ ការផ្តល់ទំនុកចិត្ត ភាពទន់ភ្លន់នៃតំលៃ និងសេវាកម្មសមស្របទៅនឹងទីផ្សារដែលប្រកបដោយគណនេយ្យភាព ។

យោងតាមផែនការឆ្នាំ ២០១៥ នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានចុះត្រួតពិនិត្យនៅៈ

១. នាយកដ្ឋានរដ្ឋបាល
- ១.១-ការិយាល័យសន្តិសុខប្រព័ន្ធ CCTV ចំណតផែកុងតឺន័រថ្មី (LM17)
- ១.២-ការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា

២.នាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស
- ២.១-ការិយាល័យបុគ្គលិក/បណ្តុះបណ្តាល
- ២.២-ការិយាល័យបៀវត្សរ៍ពលកម្ម

**១.នាយកដ្ឋានរដ្ឋបាល**

**១.១-ការិយាល័យសន្តិសុខប្រព័ន្ធ CCTV ចំណតផែកុងតឺន័រថ្មី (LM17)**

- ចំពោះការគ្រប់គ្រង និងរៀបចំរបាយការណ៍លម្អិតប្រចាំថ្ងៃ ឬឯកសារពាក់ព័ន្ធក្នុងប្រតិបត្តិការត្រូវថតចម្លង រក្សាទុកមួយច្បាប់ក្នុងការិយាល័យ ។
- គ្រប់របាយការណ៍បូកសរុបប្រចាំថ្ងៃ ប្រចាំខែ និងប្រចាំឆ្នាំ ត្រូវមានចុះហត្ថលេខាទទួលស្គាល់ពីប្រធាននាយកដ្ឋាន ឬប្រធានការិយាល័យ ។
- ប្រធានការិយាល័យសន្តិសុខគួរតែរៀបចំកាលវិភាគវេនយាមប្រចាំការឡើងវិញដោយមានផ្លាស់ប្តូរថ្ងៃឈប់សម្រាកដល់បុគ្គលិកសន្តិសុខទាំងអស់ ។
- គួរតែយកចិត្តទុកដាក់បណ្តុះបណ្តាលបន្ថែមទៀតដល់បុគ្គលិកដែលមានតួនាទីពាក់ព័ន្ធក្នុងការកត់ត្រាកុងតឺន័រចេញ-ចូលនៅច្រកទ្វារ ឱ្យត្រឹមត្រូវតាមបទដ្ឋានក្នុងការសរសេរនិងរៀបចំរបាយការណ៍ ។

- គួរតែមានបន្ទប់ត្រួតពិនិត្យ CCTV Camera ដាច់ដោយឡែកងាយស្រួលតាមដានរាល់សកម្មភាពសន្តិសុខក្នុងតំបន់កំពង់ផែ និងទីលានស្តុកកុងតឺន័រ ជៀសវាងមានបញ្ហាកើតឡើងជាយថាហេតុ ។

**១.២-ការិយាល័យបច្ចេកវិទ្យា/ព័ត៌មានវិទ្យា**

- គួរតែរៀបចំធ្វើរបាយការណ៍សកម្មភាពការងារ ក្រោយពេលជួសជុលថែទាំផ្លាស់ប្តូរឧបករណ៍សំរាប់ប្រព័ន្ធព័ត៌មានវិទ្យាតាមបណ្តានាយកដ្ឋានក្នុង ក.ស.ភ ។
- រាល់ឯកសារដែលពាក់ព័ន្ធដូចជា ការរៀបចំផែនការប្រចាំឆ្នាំ សំណើសុំទិញសំភារៈគ្រប់ប្រភេទ និងឯកសារដែលពាក់ព័ន្ធ ទៅនិងដំណើរការប្រតិបត្តិការងារផ្នែកព័ត៌មានវិទ្យាគួរតែថតចម្លងរក្សាទុកនៅក្នុងការិយាល័យដើម្បីងាយស្រួលតាមដានការងារនៅឆ្នាំបន្ទាប់ ។

## ២.នាយកដ្ឋានបុគ្គលិក/ធនធានមនុស្ស

**២.១-ការិយាល័យបុគ្គលិក/បណ្តុះបណ្តាល**

- ជំរុញការធ្វើបច្ចុប្បន្នភាពលើការកំណត់អំពីតួនាទីនិងភារកិច្ចអោយបានគ្រប់នាយកដ្ឋានដើម្បីងាយស្រួលក្នុងការប្រតិបត្តិការការងារប្រចាំថ្ងៃ ។
- ការងារបណ្តុះបណ្តាលក្នុងនិងក្រៅប្រទេសគឺនៅមានកម្រិតនៅឡើយបើប្រៀបធៀបជាមួយនិងគម្រោងផែនការឆ្នាំដែលបានលើកឡើង ។
- ក្រោយពីបញ្ចប់បេសកកម្មក្នុង និងក្រៅប្រទេសរាល់ការបណ្តុះបណ្តាល និងកិច្ចការងារផ្សេងៗ ការិយាល័យត្រូវឱ្យសាម៉ីជនសរសេររបាយការណ៍ ឬកំណត់ហេតុរបស់ខ្លួនឱ្យបានគ្រប់ៗគ្នាសម្រាប់ទុកជាឯកសារ ។
- រាល់ការសុំច្បាប់ទៅពិនិត្យសុខភាពក្នុង ឬក្រៅប្រទេសគួរតែមានលិខិតបញ្ជាក់ពិនិត្យសុខភាពអមជាមួយនៅពេលត្រលប់មកវិញ ។

**២.២-ការិយាល័យបៀវត្សរ៍ពលកម្ម**

- ចំពោះការចុះបេសកកម្មក្នុង និងក្រៅប្រទេសគួរតែមានការចុះហត្ថលេខារបស់សាម៉ីខ្លួនលើឯកសារតារាងចំណាយឱ្យបានគ្រប់ៗគ្នា ។

រាជធានីភ្នំពេញ, ថ្ងៃទី 25 ខែ 4 ឆ្នាំ ២០១៦

**ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង**

កែវ សុផាន់ណារ៉ា

## ផ្នែកទី ៧ : របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មដោយសវនករឯករាជ្យ

### របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលមានក្តីសោមនស្សរីករាយ សូមដាក់ជូនពិនិត្យនូវរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុរបស់ **កំពង់ផែ ស្វយ័តភ្នំពេញ** ហៅកាត់ថា ("ក.ស.ភ" ឬ "ក្រុមហ៊ុន") ដែលបានធ្វើសវនកម្មរួច សម្រាប់ការិយបរិច្ឆេទ ដែល បានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ ។

### សកម្មភាពចម្បងៗ

**កំពង់ផែស្វយ័តភ្នំពេញ** ជាកំពង់ផែអន្តរជាតិមួយដែលស្ថិតនៅក្រោមការគ្រប់គ្រងបច្ចេកទេសរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន និងអភិបាលដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

រាជរដ្ឋាភិបាលកម្ពុជាបានផ្តល់សិទ្ធិ និងកាតព្វកិច្ចជូន **កំពង់ផែស្វយ័តភ្នំពេញ** ដើម្បីបំពេញបេសកកម្មស្របតាមកម្មវត្ថុរបស់ខ្លួន ។ ក.ស.ភ មានទិសដៅ និងភារកិច្ច ដូចខាងក្រោម៖

- ធ្វើប្រតិបត្តិការកណ្តាធារកិច្ច និងផ្តល់ភ័ស្តុភាដល់នាវា ក្នុងប្រទេស និងក្រៅប្រទេស
- លើកដាក់ផ្ទេរ ផ្ទុក និងដឹកជញ្ជូនទំនិញ
- ផ្តល់សេវាបូមដី ដីខ្សាច់ជាអាជីវកម្ម និងបូមដីស្តារប្រឡាយ
- ការថែទាំជួសជុលមធ្យោបាយ ដឹកជញ្ជូនផ្លូវទឹក
- ការងារថៃរក្សា ស្តុកទំនិញ ឃ្លាំងទីលាន
- ការងារអភិវឌ្ឍន៍ ស្តារ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធ ក.ស.ភ
- ទទួលរ៉ាប់រងសេវាកម្ម គ្រប់គ្រងការដឹកជញ្ជូនផ្លូវទឹក
- ផ្តល់សេវាកម្មសម្រាប់ភ្ញៀវទេសចរណ៍ និងអ្នកដំណើរឆ្លងកាត់
- ទទួលខុសត្រូវ និងចាត់ចែងលើការងារការពារសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ក្នុងតំបន់គ្រប់គ្រង
- ធ្វើអាជីវកម្មផ្សេងៗ ក្នុងប្រភេទណាមួយ បន្ថែមលើប្រភេទខាងលើ ដើម្បីទ្រទ្រង់ និងជំនួយបន្ថែមដល់គោលបំណងរបស់ ក.ស.ភ ដែលចែងខាងលើតាមដែលក្រុមប្រឹក្សាភិបាលចាត់ទុកថាចាំបាច់ ឬសមស្រប ។

នៅថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១៥ ក.ស.ភ បានចុះបញ្ជីនៅលើផ្សារមូលបត្រកម្ពុជា ("ផ.ម.ក") ។

ពុំមានការផ្លាស់ប្តូរជាសារវន្តលើសកម្មភាពចម្បងរបស់ ក.ស.ភ នៅក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះទេ ។

### លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ ក.ស.ភ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ ត្រូវបានបង្ហាញក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗនៅទំព័រទី ១០ ។

## ភាគលាភ

ប្រាក់ចំណេញសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ ចំនួន ៣.១៨៣.២២១ ដុល្លារអាមេរិក គឺអាចបែងចែកភាគលាភបាន ។

នៅថ្ងៃទី ៥ ខែ កុម្ភៈ ឆ្នាំ ២០១៥ ភាគទុនិកបានឯកភាពបែងចែកភាគលាភ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤ ចំនួន ៩៩២.៣៦៨ ដុល្លារអាមេរិក ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ភាគលាភទាំងនោះបានបង់ជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរួចហើយ ក្នុងការិយបរិច្ឆេទ ។

## ដើមទុន

នៅថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៥ ក្រុមប្រឹក្សាភិបាល នៃ ក.ស.ភ បានសម្រេចផ្ទេរប្រាក់ចំណេញរក្សាទុកចំនួន ៨៣.៥៣៨.៧៤០ ដុល្លាអាមេរិក (ប្រហែល ៣៣៨.៥៨២.៥១៣ ពាន់រៀល) ទៅជាដើមទុន។ នៅថ្ងៃទី ១៤ តុលា ឆ្នាំ ២០១៥ ក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានសម្រេចអនុម័តលើការកែប្រែលក្ខន្តិកៈក្រុមហ៊ុន ដើម្បីឆ្លុះបញ្ចាំងពីបម្រែបម្រួលខាងលើ។ ការផ្ទេរនេះត្រូវបានទទួលការអនុម័ត ពីក្រសួងពាណិជ្ជកម្មនៅថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០១៥។ សូមមើលកំណត់សំគាល់ ៩ សម្រាប់ព័ត៌មានលម្អិតបន្ថែម ។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តនៃទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ ។

## ឥណទានអាក្រក់ និងជាប់សង្ស័យ

នៅមុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាវិធានការទាក់ទងទៅនឹងការធ្វើសំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថារាល់ឥណទានអាក្រក់ទាំងអស់ត្រូវបានលុបចោល និងសំវិធានធនគ្រប់គ្រាន់ត្រូវបានកំណត់ឡើងសម្រាប់ឥណទានអាក្រក់ និងជាប់សង្ស័យ ។

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានពិនិត្យឃើញមានស្ថានភាពណាមួយដែលអាចនឹងបណ្តាលឲ្យចំនួននៃការធ្វើសំវិធានធនលើឥណទានអាក្រក់ និងជាប់សង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ មានចំនួនខ្វះខាត ជាសារវន្តនោះឡើយ ។

## ទ្រព្យសកម្មចរន្ត

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មចរន្តដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ ក.ស.ភ. ហើយដែលមានតម្លៃមិនអាចប្រមូលបាននៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ត្រូវបានកាត់បន្ថយឲ្យនៅស្មើនឹងតម្លៃដែលគិតថានឹងអាចប្រមូលបានជាក់ស្តែង ។

## ទ្រព្យសកម្មចរន្ត (ត)

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឲ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្តនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ ថាមានភាពមិនត្រឹមត្រូវនោះទេ ។

## វិធីសាស្ត្រកំណត់តម្លៃ

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងធ្វើឲ្យប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្របច្ចុប្បន្ននៃការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ ថាមានភាពមិនត្រឹមត្រូវ និងមិនសមស្របនោះទេ ។

## បំណុលយថាហេតុ និងបំណុលផ្សេងៗទៀត

នាថ្ងៃចេញរបាយការណ៍នេះ ពុំមាន៖

(ក) ការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ ក.ស.ភ ដែលកើតមានឡើងចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទមកក្នុងការធានាចំពោះបំណុលរបស់បុគ្គលណាមួយឡើយ ឬ

(ខ) បំណុលយថាហេតុណាមួយដែលកើតមានឡើងចំពោះ ក.ស.ភ ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទមកក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ ក.ស.ភ ។

តាមមតិរបស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ ក.ស.ភ ត្រូវធ្វើការទូទាត់សង ឬទំនងជាត្រូវទូទាត់សងក្នុងរយៈពេល ១២ ខែ បន្ទាប់ពីថ្ងៃបញ្ចប់នៃការិយបរិច្ឆេទដែលនឹងមានផលប៉ះពាល់ ឬអាចនឹងប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ ក.ស.ភ ក្នុងការសងបំណុលនៅពេលដល់កាលកំណត់ត្រូវសង ។

## ការផ្លាស់ប្តូរនៃហេតុការណ៍

នាថ្ងៃចេញរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលមិនបានរែកញែកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ ក.ស.ភ ដែលនឹងបណ្តាលឲ្យមានតួលេខនៃចំនួនណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវនោះទេ ។

## ប្រការមិនប្រក្រតី

តាមមតិរបស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃប្រតិបត្តិការរបស់ ក.ស.ភ ក្នុងការិយបរិច្ឆេទ មិនទទួលរងនូវផលប៉ះពាល់ជាសារវន្តណាមួយពីសមាសធាតុប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេ ។

ក្រុមប្រឹក្សាភិបាលក៏មានមតិដែរថា នៅក្នុងចន្លោះពេលចាប់ពីចុងការិយបរិច្ឆេទដល់ថ្ងៃចេញរបាយការណ៍នេះ ពុំមានសមាសធាតុប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីកើតមានឡើង ដែលអាចនាំឲ្យប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ ក.ស.ភ ក្នុងការិយបរិច្ឆេទ ដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលបានបម្រើការនៅក្នុងការិយបរិច្ឆេទ និងថ្ងៃចេញរបាយការណ៍ចុងក្រោយមាន៖

ឯកឧត្តម ហ៊ី បាវី (ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយក)
ឯកឧត្តម សួន រចនា (សមាជិកក្រុមប្រឹក្សាភិបាលតំណាងក្រសួងសាធារណការ និងដឹកជញ្ជូន)
ឯកឧត្តម លី ស៊ីវណ្ណា (សមាជិកក្រុមប្រឹក្សាភិបាលតំណាងទីស្តីការគណៈរដ្ឋមន្ត្រី)
ឯកឧត្តម កែន សម្បត្តិ (សមាជិកក្រុមប្រឹក្សាភិបាលតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)
ឯកឧត្តម ប៉ែន សុវិជាតិ (សមាជិកក្រុមប្រឹក្សាភិបាលតំណាងក្រសួងពាណិជ្ជកម្ម)
ឯកឧត្តម ព្រំ សុខានី (សមាជិកក្រុមប្រឹក្សាភិបាលតំណាងនិយោជិត ក.ស.ភ)
លោក ហួត ហៃ (សមាជិកក្រុមប្រឹក្សាភិបាលតំណាងសាលារាជធានីភ្នំពេញ)

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុងអំឡុងការិយបរិច្ឆេទហិរញ្ញវត្ថុ និងចុងការិយបរិច្ឆេទហិរញ្ញវត្ថុ ពុំមានការរៀបចំណាមួយដែលមាន ក.ស.ភ ជាគូភាគីក្នុងគោលបំណងជួយដល់អភិបាលរបស់ ក.ស.ភ ដើម្បីទទួលបាននូវអត្ថប្រយោជន៍ ដោយមធ្យោបាយនៃការទិញយកភាគហ៊ុន ឬលិខិតបំណុលពី ក.ស.ភ ឬពីក្រុមហ៊ុនដទៃទៀតទេ ។

ចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទនៃឆ្នាំកន្លងទៅ ពុំមានអភិបាលរបស់ ក.ស.ភ ណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយ (ក្រៅពីអត្ថប្រយោជន៍ដែលបានរួមបញ្ចូលនៅក្នុងចំនួនបរិលាភសរុបទទួលបាន ដូចបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ) តាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយ ក.ស.ភ ឬដោយក្រុមហ៊ុនពាក់ព័ន្ធជាមួយនឹង ក.ស.ភ ដែលអភិបាលជាសមាជិក ឬក៏ជាមួយក្រុមហ៊ុន ដែលអភិបាលមានផលប្រយោជន៍ផ្នែកហិរញ្ញវត្ថុយ៉ាងច្រើននោះទេ លើកលែងតែការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

## សវនករ

ក្រុមហ៊ុនសវនករឯករាជ្យ ខេភីអឹមជី ខេមបូឌា ចំកាត់ បានសំដែងនូវឆន្ទៈរបស់ខ្លួន ដើម្បីទទួលយកការតែងតាំងជាសវនករជាថ្មីម្តងទៀតសម្រាប់ការិយបរិច្ឆេទបន្ទាប់ ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈធ្វើការអះអាងបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុបានរៀបចំឡើងយ៉ាងត្រឹមត្រូវដើម្បីចង្អុលបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ និងលទ្ធផលហិរញ្ញវត្ថុ និងស្ថានភាពលំហូរទឹកប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ។ នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលចាំបាច់ត្រូវ៖

## កំពង់ផែស្វយ័តភ្នំពេញ

### ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ (ត)

(i) អនុម័តគោលនយោបាយគណនេយ្យដែលសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រុងប្រយ័ត្ន ហើយធ្វើការអនុវត្តប្រកបដោយសង្គតភាព។

(ii) អនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ឬបើមានការផ្លាស់ប្តូរ ពីនេះដើម្បីបង្ហាញនូវភាពត្រឹមត្រូវ ក្រុមប្រឹក្សាភិបាល ត្រូវធ្វើការកំណត់បង្ហាញពន្យល់ឲ្យបានច្បាស់លាស់ និងកំណត់បរិមាណនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

(iii) រក្សាទុកបញ្ជីគណនេយ្យឲ្យបានគ្រប់គ្រាន់ និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធភាព ។

(iv) រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លុះត្រាតែមានករណីមិនសមរម្យក្នុងការសន្មតថា ក.ស.ភ នឹងបន្តធ្វើប្រតិបត្តិការអាជីវកម្មនាពេលអនាគតដែលអាចព្យាករណ៍បាន ។

(v) ត្រួតពិនិត្យ និងដឹកនាំ ក.ស.ភ ឲ្យមានប្រសិទ្ធិភាពលើរាល់សេចក្តីសម្រេច ដែលមានសារៈសំខាន់ទាំងអស់ដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងលទ្ធផល ហើយត្រូវធ្វើឲ្យប្រាកដថា កិច្ចការនេះ ត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថា បានអនុវត្តនូវរាល់តម្រូវការខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ ក. ស.ភ ។

### ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

យើងខ្ញុំ សូមធ្វើការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ រួមមានកំណត់សំគាល់ទាំងឡាយពីទំព័រទី ៨ ដល់ទី ៥៤ ដែលជាសារវន្តបានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុ នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ។

*ចុះហត្ថលេខាដោយយោងទៅលើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល:*

ឯកឧត្តម ហ៊ី បាវី
ប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយក

ធ្វើនៅរាជធានីភ្នំពេញ
ថ្ងៃទី: 29 MAR 2016

៥

KPMG Cambodia Ltd
4th floor, Delano Center
No. 144, Street 169
Sangkat Veal Vong
Khan 7 Makara, Phnom Penh
Kingdom of Cambodia

Telephone +855 (23) 216 899
Fax +855 (23) 217 279
Internet www.kpmg.com.kh

## របាយការណ៍របស់សវនករឯករាជ្យ
## ជូនចំពោះភាគទុនិក
## កំពង់ផែស្វយ័តភ្នំពេញ

យើងខ្ញុំ បានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់កំពង់ផែស្វយ័តភ្នំពេញ ហៅកាត់ថា ("ក.ស.ភ" ឬ "ក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ និងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ របាយការណ៍ស្ដីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរទឹកប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សំគាល់ដែលរួមមានសេចក្ដីសង្ខេបលើគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗដែលបានបង្ហាញនៅទំព័រទី ៨ ដល់ទី ៥៤ ។

### ការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រងលើរបាយការណ៍ហិរញ្ញវត្ថុ

អ្នកគ្រប់គ្រង មានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងបានកំណត់ថាមានភាពចាំបាច់ សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឲ្យជៀសផុតពីការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង ។

### ការទទួលខុសត្រូវរបស់សវនករ

ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺធ្វើការបញ្ចេញមតិលើរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើការធ្វើសវនកម្មរបស់យើងខ្ញុំ ។ យើងខ្ញុំបានធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ។ ស្តង់ដារទាំងនោះ តម្រូវឲ្យយើងខ្ញុំអនុវត្តទៅតាមតម្រូវការនៃក្រមសីលធម៌ និងគ្រោង និងធ្វើសវនកម្ម ដើម្បីទទួលបាននូវអំណះអំណាងយ៉ាងសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុ ពុំមានការបង្ហាញខុសជាសារវន្តឡើយ ។

ការធ្វើសវនកម្ម រួមមានការអនុវត្តនូវបណ្ដានីតិវិធីត្រួតពិនិត្យ ដើម្បីទទួលបាននូវភស្តុតាងដែលទាក់ទងទៅនឹងចំនួនទឹកប្រាក់ និងការលាតត្រដាងព័ត៌មានក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។ ការជ្រើសរើសនីតិវិធីទាំងនេះគឺផ្អែកទៅលើការវិនិច្ឆ័យរបស់យើងខ្ញុំ ដែលរួមមានការប៉ាន់ប្រមាណទៅលើហានិភ័យ ដែលធ្វើឲ្យមានផលប៉ះពាល់ដល់ការបង្ហាញខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ បណ្ដាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង ។ នៅក្នុងការប៉ាន់ប្រមាណហានិភ័យទាំងនោះ យើងខ្ញុំធ្វើការពិចារណាទៅលើការគ្រប់គ្រងផ្ទៃក្នុងដែលពាក់ព័ន្ធទៅនឹងការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដើម្បីធ្វើសវនកម្មឲ្យសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិទៅលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ ។ ការធ្វើសវនកម្ម ក៏រួមមានការវាយតម្លៃទៅលើភាពសមស្របនៃគោលនយោបាយគណនេយ្យដែលក្រុមហ៊ុនបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យដែលធ្វើឡើងដោយអ្នកគ្រប់គ្រង ព្រមទាំងការវាយតម្លៃលើការបង្ហាញនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ។



KPMG Cambodia Ltd., a Cambodian limited liability company and a member firm of the KPMG network of independent member firms affiliated with KPMG International Cooperative ("KPMG International"), a Swiss entity. All rights reserved.

KPMG

យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប សម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ ។

## មតិសវនកម្ម

តាមមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុជាសារវន្ត បានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ **កំពង់ផែស្វយ័តភ្នំពេញ** នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងស្ថានភាពលំហូរទឹកប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយស្របទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ។

តំណាងក្រុមហ៊ុន **ខេភីអឹមជី ខេមបូឌា ចំកាត់**

**ទែ ហ៊ុយ**

*Partner*

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៦

៧

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
## នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥

| | កំណត់សំគាល់ | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ ដុល្លារអាមេរិក | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ ពាន់រៀល (កំណត់សំគាល់ ៤) | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤ ដុល្លារអាមេរិក | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤ ពាន់រៀល (កំណត់សំគាល់ ៤) |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | | | |
| ទ្រព្យ រោងចក្រ និងបរិក្ខារ | ៥ | ១៤០.០១៣.៥៥៣ | ៥៦៨.៤៥៥.០២៥ | ១៤០.៧៦៧.១១៥ | ៥៦៨.៤១៧.៦១០ |
| ទ្រព្យវិនិយោគ | ៦ | ៧.៩០៧.៦៥៣ | ៣២.១០៥.០៧១ | ៧.៨៤២.១៦៤ | ៣១.៦៦៦.៦៥៨ |
| | | ១៤៧.៩២១.២០៦ | ៦០០.៥៦០.០៩៦ | ១៤៨.៦០៩.២៧៩ | ៦០០.០៨៤.២៦៨ |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | | | |
| គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ | ៧ | ២.៩១៣.១៨០ | ១១.៨២៧.៥១១ | ១.៣៧៥.២៣៣ | ៥.៥៥៣.១៩១ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ៨ | ៨.៧៤៩.២២១ | ៣៥.៥២១.៨៣៧ | ១.៨២០.៩១០ | ៧.៣៥២.៨៣៥ |
| | | ១១.៦៦២.៤០១ | ៤៧.៣៤៩.៣៤៨ | ៣.១៩៦.១៤៣ | ១២.៩០៦.០២៦ |
| **ទ្រព្យសកម្មសរុប** | | ១៥៩.៥៨៣.៦០៧ | ៦៤៧.៩០៩.៤៤៤ | ១៥១.៨០៥.៤២២ | ៦១២.៩៩០.២៩៤ |
| **មូលធន និងបំណុល** | | | | | |
| **មូលធន** | | | | | |
| ដើមទុន | ៩ | ១១០.៣១៦.៦១២ | ៤៤៧.៨៨៥.៤៨៥ | ២៦.៧៧៧.៨៧២ | ១០៨.១២៩.០៤៧ |
| មូលធនផ្សេងៗ | ៩ | ៤.២៩២.៣៧៥ | ១៧.៤២៧.០៤៣ | - | - |
| ទុនបម្រុងតាមច្បាប់ | | ៤៣១.៧៨០ | ១.៧៥៣.០២៧ | ៣៤៩.១៤៣ | ១.៤០៩.៨៣៩ |
| ទុនបម្រុងទូទៅ | | ៤៣១.៧៨០ | ១.៧៥៣.០២៧ | ៣៤៩.១៤៣ | ១.៤០៩.៨៣៩ |
| មូលនិធិអភិវឌ្ឍន៍សហគ្រាស | | ៧.៨២២.៦១៧ | ៣១.៧៥៩.៨២៥ | ៦.៣៣៥.១៥១ | ២៥.៥៨១.៣៤១ |
| ចំណេញរក្សាទុក | | ៣.១៦០.០២៥ | ១២.៨២៩.៧០២ | ៨៥.៦៥៥.៨១៧ | ៣៤៥.៨៧៨.១៨៩ |
| **សរុបមូលធន** | | ១២៦.៤៥៥.១៨៩ | ៥១៣.៤០៨.០៦៩ | ១១៩.៤៦៧.១២៦ | ៤៨២.៤០៨.២៥៥ |
| **បំណុល** | | | | | |
| **បំណុលរយៈពេលវែង** | | | | | |
| ប្រាក់កម្ចី | ១០ | ២៨.៩៧៩.៦៣៧ | ១១៧.៦៥៧.៣២៦ | ២៨.៩៧៩.៦៣៧ | ១១៧.០១៩.៧៧៤ |
| សំវិធានធនលើមូលនិធិសោធននិវត្តន៍ | ១១ | ៥២៥.១៩២ | ២.១៣២.២៨០ | ៧១៧.៤៦២ | ២.៨៩៧.១១២ |
| បំណុលពន្ធពន្យារសុទ្ធ | ១២ | ១.០៨២.៦១៧ | ៤.៣៩៥.៤២៥ | ៦៩៣.០៩៤ | ២.៧៩៨.៧១៣ |
| | | ៣០.៥៨៧.៤៤៦ | ១២៤.១៨៥.០៣១ | ៣០.៣៩០.១៩៣ | ១២២.៧១៥.៥៩៩ |

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
## នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥

| | កំណត់សំគាល់ | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ ដុល្លារអាមេរិក | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ ពាន់រៀល (កំណត់សំគាល់ ៤) | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤ ដុល្លារអាមេរិក | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤ ពាន់រៀល (កំណត់សំគាល់ ៤) |
|---|---|---|---|---|---|
| **បំណុលរយៈពេលខ្លី** | | | | | |
| គណនីអ្នកផ្គត់ផ្គង់ និង គណនីបំណុលផ្សេងៗ | ១៣ | ១.៩០០.០៩១ | ៧.៧១៤.៣៦៧ | ១.៦២៨.១២៨ | ៦.៥៧៤.៣៨១ |
| សំវិធានធនសម្រាប់ពន្ធលើប្រាក់ចំណេញ | ១២ | ៦៤០.៨៨១ | ២.៦០១.៩៧៧ | ៣១៩.៩៧៥ | ១.២៩២.០៥៩ |
| | | ២.៥៤០.៩៧២ | ១០.៣១៦.៣៤៤ | ១.៩៤៨.១០៣ | ៧.៨៦៦.៤៤០ |
| | | ៣៣.១២៨.៩១៨ | ១៣៤.៥០១.៣៧៥ | ៣២.៣៣៨.២៩៦ | ១៣០.៥៨២.០៣៩ |
| **មូលធន និងបំណុលសរុប** | | ១៥៩.៥៨៣.៦០៧ | ៦៤៧.៩០៩.៤៤៤ | ១៥១.៨០៥.៤២២ | ៦១២.៩៩០.២៩៤ |

កំណត់សំគាល់ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

## របាយការណ៍ចំណេញ ឬខាត និងចំណូលផ្សេងៗ
## នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥

| | | ២០១៥ | | ២០១៤ | |
|---|---|---|---|---|---|
| | កំណត់សំគាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| ចំណូល | ១៤ | ១៥.១៣៧.៨៨៤ | ៦១.៤៥៨.១៨៦ | ១៣.២៩២.២៥៥ | ៥៣.៦៧៤.១២៦ |
| ថ្លៃដើមនៃការលក់ និងសេវាកម្ម | ១៥ | (៥.៣៨៨.៥៨៥) | (២១.៨៧៧.៦៥៥) | (៥.៣១១.០៥៨) | (២១.៤៤៦.០៥២) |
| **ប្រាក់ចំណេញដុល** | | ៩.៧៤៩.២៩៩ | ៣៩.៥៨០.៥៣១ | ៧.៩៨១.១៩៧ | ៣២.២២៨.០៧៤ |
| ចំណូលផ្សេងៗ | ១៦ | ៣៦០.២៨៥ | ១.៤៦២.៧៥៧ | ៣០១.៣៣៦ | ១.២១៦.៧៩៥ |
| ចំណាយរដ្ឋបាលទូទៅ និងការលក់ | ១៧ | (៤.៥៨១.៥០៦) | (១៨.៦០០.៩១៦) | (៤.១៨៨.២១៦) | (១៦.៩១២.០១៦) |
| **ចំណេញសុទ្ធពីប្រតិបត្តិការ** | | ៥.៥២៧.៦៧៨ | ២២.៤៤២.៣៧២ | ៤.០៩៤.៣១៧ | ១៦.៥៣២.៨៥៣ |
| ចំណាយហិរញ្ញប្បទាន | | (១.១៥៩.១៨៦) | (៤.៧០៦.២៩៥) | (១.២៨៨.៥៤១) | (៥.២០៣.១២៩) |
| **ប្រាក់ចំណេញមុនដកពន្ធ** | | ៤.៣៦៨.៤៩២ | ១៧.៧៣៦.០៧៧ | ២.៨០៥.៧៧៦ | ១១.៣២៩.៧២៤ |
| ចំណាយពន្ធលើ ប្រាក់ចំណេញ | ១២ | (១.១៨៥.២៦៧) | (៤.៨១២.១៨៤) | (៦៦០.៦៦៧) | (២.៦៦៧.៧៧៣) |
| **ប្រាក់ចំណេញសុទ្ធ សម្រាប់ការិយបរិច្ឆេទ** | | ៣.១៨៣.២២៥ | ១២.៩២៣.៨៩៣ | ២.១៤៥.១០៩ | ៨.៦៦១.៩៥១ |
| **លទ្ធផលលម្អិតផ្សេងៗ** | | | | | |
| ការកំណត់ឡើងវិញនូវសំវិធានធន លើមូលនិធិសោធននិវត្តន៍ | | ៤.៨៣១ | ១៩.៦១៤ | (៤៩.០០៤) | (១៩៧.៨៧៨) |
| | | ៣.១៨៨.០៥៦ | ១២.៩៤៣.៥០៧ | ២.០៩៦.១០៥ | ៨.៤៦៤.០៧៣ |
| **ប្រាក់ចំណេញក្នុងមួយហ៊ុន** | ២២ | | | | |
| ចំណេញមូលដ្ឋានក្នុងមួយភាគហ៊ុន | | ០.១៩ | ០.៧៧ | | |
| ចំណេញក្នុងមួយសន្លឹកហ៊ុនថយចុះ | | ០.១៩ | ០.៧៧ | | |

កំណត់សំគាល់ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

# របាយការណ៍បម្រែបម្រួលមូលធន
# នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥

| | ដើមទុន<br>ដុល្លារអាមេរិក | ទុនបម្រុង<br>តាមច្បាប់<br>ដុល្លារអាមេរិក | ទុនបម្រុង<br>ទូទៅ<br>ដុល្លារអាមេរិក | មូលនិធិអភិវឌ្ឍន៍<br>សហគ្រាស<br>ដុល្លារអាមេរិក | ចំណេញ<br>រក្សាទុក<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|---|---|
| **នាថ្ងៃទី ១ខែមករាឆ្នាំ ២០១៤** | ២៥.៨៨៤.៦៦២ | ៣៣៥.៣៦៦ | ៣៣៥.៣៦៦ | ៦.០៨៧.១៦៨ | ៨៤.៣៣១.៨៩៧ | ១១៦.៩៧៤.៤៥៩ |
| *ប្រតិបត្តិការជាមួយភាគទុនិកនៃក្រុមហ៊ុន* | | | | | | |
| ដើមទុនបន្ថែម | ៨៩៣.២១០ | - | - | - | - | ៨៩៣.២១០ |
| *សរុបលទ្ធផលលម្អិត* | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - | ២.១៩៥.១០៩ | ២.១៩៥.១០៩ |
| លទ្ធផលលម្អិតផ្សេងៗខាត | - | - | - | - | (៩៩.០០៨) | (៩៩.០០៨) |
| ភាគលាភបានបង់ | - | - | - | - | (៤៩៦.៦៤៨) | (៤៩៦.៦៤៨) |
| ការផ្ទេរ | - | ១៣.៧៧៧ | ១៣.៧៧៧ | ២៤៧.៩៨៣ | (២៧៥.៥៣៧) | - |
| | - | ១៣.៧៧៧ | ១៣.៧៧៧ | ២៤៧.៩៨៣ | ១.៣២៣.៩២០ | ១.៥៩៩.៤៥៧ |
| **នាថ្ងៃទី ៣១ខែធ្នូ ឆ្នាំ ២០១៤** | ២៦.៧៧៧.៨៧២ | ៣៤៩.១៤៣ | ៣៤៩.១៤៣ | ៦.៣៣៥.១៥១ | ៨៥.៦៥៥.៨១៧ | ១១៩.៤៦៧.១២៦ |
| **នាថ្ងៃទី ៣១ខែធ្នូ ឆ្នាំ ២០១៤**<br>(គិតជាពាន់រៀល-កំណត់សំគាល់ ៤) | ១០៨.១២៩.០៤៧ | ១.៤០៩.៨៣៩ | ១.៤០៩.៨៣៩ | ២៥.៥៨១.៣៤១ | ៣៤៥.៨៧៨.១៨៩ | ៤៨២.៤០៨.២៥៥ |

# របាយការណ៍បម្រែបម្រួលមូលធន
# នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥

| | ដើមទុន<br>ដុល្លារអាមេរិក | មូលធនផ្សេងៗ<br>ដុល្លារអាមេរិក | ទុនបម្រុង<br>តាមច្បាប់<br>ដុល្លារអាមេរិក | ទុនបម្រុង<br>ទូទៅ<br>ដុល្លារអាមេរិក | មូលនិធិអភិវឌ្ឍន៍<br>សហគ្រាស<br>ដុល្លារអាមេរិក | ចំណេញ<br>រក្សាទុក<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|---|---|---|
| **នាថ្ងៃទី ១ខែមករាឆ្នាំ ២០១៥** | ២៦.៧៧៧.៨៧២ | - | ៣៤៩.១៤៣ | ៣៤៩.១៤៣ | ៦.៣៣៥.១៥១ | ៨៥.៦៥៥.៨១៧ | ១១៩.៤៦៧.១២៦ |
| *ប្រតិបត្តិការជាមួយភាគទុនិករបស់ក្រុមហ៊ុន* | | | | | | | |
| ទុនបន្ថែមតាមរយៈការលក់មូលបត្រ ជាសាធារណៈលើកដំបូង | - | ៥.១៩៣.៩១៥ | - | - | - | - | ៥.១៩៣.៩១៥ |
| ចំណាយប្រតិបត្តិការ | - | (៩០១.៥៤០) | - | - | - | - | (៩០១.៥៤០) |
| | - | ៤.២៩២.៣៧៥ | - | - | - | - | ៤.២៩២.៣៧៥ |
| *សរុបលទ្ធផលលម្អិត* | | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - | - | ៣.១៨៣.២២៥ | ៣.១៨៣.២២៥ |
| លទ្ធផលលម្អិតផ្សេងៗ | - | - | - | - | - | ៤.៨៣១ | ៤.៨៣១ |
| ភាគលាភបានបង់ | - | - | - | - | - | (៤៩២.៣៦៨) | (៤៩២.៣៦៨) |
| ការផ្ទេរ | ៨៣.៥៣៨.៧៤០ | - | ៨២.៦៣៧ | ៨២.៦៣៧ | ១.៤៨៧.៤៦៦ | (៨៥.១៩១.៤៨០) | - |
| | ៨៣.៥៣៨.៧៤០ | - | ៨២.៦៣៧ | ៨២.៦៣៧ | ១.៤៨៧.៤៦៦ | (៨២.៤៩៥.៧៩២) | ២.៦៩៥.៦៨៨ |
| **នាថ្ងៃទី ៣១ខែធ្នូ ឆ្នាំ ២០១៥** | ១១០.៣១៦.៦១២ | ៤.២៩២.៣៧៥ | ៤៣១.៧៨០ | ៤៣១.៧៨០ | ៧.៨២២.៦១៧ | ៣.១៦០.០២៥ | ១២៦.៤៥៥.១៨៩ |
| **នាថ្ងៃទី ៣១ខែធ្នូ ឆ្នាំ ២០១៥**<br>(គិតជាពាន់រៀល-កំណត់សំគាល់ ៤) | ៤៤៧.៨៨៥.៤៤៥ | ១៧.៤២៧.០៤៣ | ១.៧៥៣.០២៧ | ១.៧៥៣.០២៧ | ៣១.៧៥៩.៨២៥ | ១២.៨២៩.៧០២ | ៥១៣.៤០៨.០៦៩ |

កំណត់សំគាល់ គឺជាផ្នែកមួយនៃព័ត៌មានហិរញ្ញវត្ថុនេះ ។

# របាយការណ៍លំហូរសាច់ប្រាក់
## នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥

| | ២០១៥ | | ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| **សកម្មភាពប្រតិបត្តិការ** | | | | |
| ប្រាក់ចំណេញសុទ្ធ សម្រាប់ការិយបរិច្ឆេទ | ៣.១៨៣.២២៥ | ១២.៩២៣.៨៩៥ | ២.១៩៥.១០៩ | ៨.៦៦១.៩៥១ |
| និយ័តភាពលើៈ | | | | |
| ចំណាយពន្ធលើប្រាក់ចំណេញ | ១.១៨៥.២៦៧ | ៤.៨១២.១៨៤ | ៦៦០.៦៦៧ | ២.៦៦៧.៧៧៣ |
| រំលស់ | ២.៣០៥.៥៨៦ | ៩.៣៦០.៥១៧ | ២.២៧៩.៣៤៩ | ៩.២០៤.០១១ |
| ខាតពីការលក់ទ្រព្យ រោងចក្រ និងបរិក្ខារ | ៧.២១២ | ២៩.២៨១ | ២៥.២៩៤ | ១០២.១៣៧ |
| ខាតពីការលុបចោលទ្រព្យ រោងចក្រ និងបរិក្ខារ | ១៥.៣៧៦ | ៦២.៤២៧ | - | - |
| សំវិធានធនលើមូលនិធិសោធននិវត្តន៍ | (១៤៤.៨៥៣) | (៥៨៨.១០៣) | ៩២.២៦៨ | ៣៧២.៥៧៩ |
| ចំណាយហិរញ្ញប្បទាន | ១.១៥៩.១៨៦ | ៤.៧០៦.២៩៥ | ១.២៨៨.៥៩១ | ៥.២០៣.១២៩ |
| | ៧.៧១០.៩៥៩ | ៣១.៣០៦.៤៦៦ | ៦.៥៤១.២២៨ | ២៦.២១១.៥៨០ |
| ការប្រែប្រួលនូវៈ | | | | |
| គណនីអតិថិជន និងគណនី ត្រូវទទួលផ្សេងៗ | (១.៥៣៧.៩៤៧) | (៦.២៤៤.០៧០) | ៨៩០.៥៨៥ | ៣.៥៩៦.១៨១ |
| គណនីអ្នកផ្គត់ផ្គង់ និងគណនី បំណុលផ្សេងៗ | ២៧១.៩៦៣ | ១.១០៤.១៧០ | (៣៣៧.៨៨៥) | (១.៣៦៤.៣៨០) |
| | ៦.៤៤៤.៩៧៥ | ២៦.១៦៦.៥៦៦ | ៧.០៩៣.៩២៨ | ២៨.៤៤៣.៣៨១ |
| ការប្រាក់ដែលបានបង់ | (១.១៥៩.១៨៦) | (៤.៧០៦.២៩៥) | (១.២៨៨.៥៩១) | (៥.២០៣.១២៩) |
| ពន្ធលើប្រាក់ចំណេញដែលបានបង់ | (៤៧៤.៨៣៨) | (១.៩២៧.៨៤២) | (៣៩៩.៤៩៨) | (១.៥១១.០៧១) |
| មូលនិធិសោធននិវត្តន៍ដែលបានបង់ | (៤២.៥៨៦) | (១៧២.៨៩៩) | (៤៣.៦៥២) | (១៧៦.២៦៦) |
| សាច់ប្រាក់សុទ្ធទទួលបាន ពីសកម្មភាពប្រតិបត្តិការ | ៤.៧៦៨.៣៦៥ | ១៩.៣៥៩.៥៦០ | ៥.៣៦២.២៨៧ | ២១.៦៥២.៩១៥ |

## របាយការណ៍លំហូរសាច់ប្រាក់
## នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥

| | ២០១៥ | | ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| **សកម្មភាពវិនិយោគ** | | | | |
| ការទិញទ្រព្យ រោងចក្រ និងបរិក្ខារ | (១.៦៣១.៥៧៣) | (៦.៦២៣.៧៨០) | (៨៥៥.៩៥៥) | (៣.៤៥៤.៣២៧) |
| ការទិញទ្រព្យវិនិយោគ | (១១.៣១៩) | (៤៥.៩៣៥) | (៣៤.៣៣៩) | (១៣៨.៦៦១) |
| សាច់ប្រាក់ទទួលបានពីការលក់ ទ្រព្យ រោងចក្រ និងបរិក្ខារ | ២.៧២៦ | ១១.០៦៨ | ១.៣៦៨ | ៥.៥២៤ |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុង សកម្មភាពវិនិយោគ | (១.៦៤០.០៦១) | (៦.៦៥៨.៦៤៧) | (៨៨៨.៩២៦) | (៣.៥៨៧.៤៦៤) |
| **សកម្មភាពហិរញ្ញប្បទាន** | | | | |
| សាច់ប្រាក់បានពីការលក់មូលបត្រ ជាសាធារណៈលើកដំបូងបន្ទាប់ពី កាត់កងចំណាយប្រតិបត្តិការ | ៤.២៩២.៣៧៥ | ១៧.៤២៧.០៤៣ | ៨៩៣.២១០ | ៣.៦០៦.៧៨២ |
| ភាគលាភបានបង់ | (៤៩២.៣៦៨) | (១.៩៩៩.០១៤) | (៤៩៦.៦៤៨) | (២.០០៥.៤៦៥) |
| សាច់ប្រាក់សុទ្ធទទួលបានពី សកម្មភាពហិរញ្ញប្បទាន | ៣.៨០០.០០៧ | ១៥.៤២៨.០២៩ | ៣៩៦.៥៦២ | ១.៦០១.៣១៧ |
| **ការកើនឡើងសុទ្ធនូវសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | ៦.៩២៨.៣១១ | ២៨.១២៨.៩៤២ | ៤.៨៧០.៤២៣ | ១៩.៦៦៦.៧៦៨ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាដើមថ្ងៃទី ១ ខែ មករា** | ១.៨២០.៩១០ | ៧.៣៩២.៨៩៥ | (៣.០៤៩.៥១៣) | (១២.៣១៣.៩៣៣) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី ៣១ ខែធ្នូ** (កំណត់សំគាល់ ៨) | ៨.៧៤៩.២២១ | ៣៥.៥២១.៨៣៧ | ១.៨២០.៩១០ | ៧.៣៥២.៨៣៥ |

កំណត់សំគាល់ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ ។

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥

## ១. អំពីក្រុមហ៊ុន

កំពង់ផែស្វយ័តភ្នំពេញ ("ក.ស.ភ" ឬ "ក្រុមហ៊ុន") បានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្រោមអនុក្រឹតលេខ ៥១ អនក្រ នៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ១៩៩៨ ជាក្រុមហ៊ុនរបស់រដ្ឋ ក្រោមអភិបាលកិច្ចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន ។ ក.ស.ភ ទទួលពីរដ្ឋនូវសិទ្ធិ និងកាតព្វកិច្ចទាំងឡាយដើម្បីបំពេញបេសកកម្មស្របតាមកម្មវត្ថុរបស់ខ្លួន ។ នៅថ្ងៃទី ៩ ធ្នូ ២០១៥. ក.ស.ភ បានចុះបញ្ជីនៅលើផ្សារមូលបត្រកម្ពុជា ("ផ.ម.ក") និងមានលេខចុះបញ្ជី ០០៣ CSX/SC ។ ក.ស.ភ ទទួលពីរដ្ឋនូវសិទ្ធិ និងកាតព្វកិច្ចទាំងឡាយដើម្បីបំពេញបេសកកម្មស្របតាមកម្មវត្ថុរបស់ខ្លួន ។

ក.ស.ភ មានទិសដៅ និងភារកិច្ច ដូចខាងក្រោម៖

- ធ្វើប្រតិបត្តិការកណ្តធារកិច្ច និងផ្តល់ភ័ស្តុភាដល់នាវា ក្នុងប្រទេស និងក្រៅប្រទេស
- លើកដាក់ផ្ទេរ ផ្ទុក និងដឹកជញ្ជូនទំនិញ
- ផ្តល់សេវាបូមដី ដីខ្សាច់ជាអាជីវកម្ម និងបូមដីស្តារប្រឡាយ
- ការថែទាំជួសជុលមធ្យោបាយ ដឹកជញ្ជូនផ្លូវទឹក
- ការងារថែរក្សា ស្តុកទំនិញ ឃ្លាំងទីលាន
- ការងារអភិវឌ្ឍន៍ ស្តារ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធ ក.ស.ភ
- ទទួលរ៉ាប់រងសេវាកម្ម គ្រប់គ្រងការដឹកជញ្ជូនផ្លូវទឹក
- ផ្តល់សេវាកម្មសម្រាប់ភ្ញៀវទេសចរណ៍ និងអ្នកដំណើរឆ្លងកាត់
- ទទួលខុសត្រូវ និងចាត់ចែងលើការងារការពារសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ក្នុងតំបន់គ្រប់គ្រង
- ធ្វើអាជីវកម្មផ្សេងៗ ក្នុងប្រភេទណាមួយ បន្ថែមលើប្រភេទខាងលើ ដើម្បីទ្រទ្រង់ និងជំនួយបន្ថែមដល់គោលបំណងរបស់ ក.ស.ភ ដែលចែងខាងលើតាមដែលក្រុមប្រឹក្សាភិបាលចាត់ទុកថាចាំបាច់ ឬសមស្រប ។

ពុំមានការផ្លាស់ប្តូរជាសារវន្តលើសកម្មភាពចម្បងរបស់ ក.ស.ភ នៅក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះទេ ។

នៅថ្ងៃ ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ ក.ស.ភ មាននិយោជិតចំនួន ៩៧៨ នាក់ (២០១៤: និយោជិតមានចំនួន ៩៤៦ នាក់) ។

## ២. មូលដ្ឋាននៃការរៀបចំ

### (ក) របាយការណ៍អនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានរៀបចំឡើងស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ។ របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល និងផ្តល់សិទ្ធិផ្សាយនៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៦ ។

## ២. មូលដ្ឋាននៃការរៀបចំ (ត)

### (ខ) មូលដ្ឋាននៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងផ្អែកលើមូលដ្ឋានថ្លៃដើមដំបូង ។

### (គ) រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់ការកំណត់បង្ហាញ

រូបិយប័ណ្ណជាតិនៃព្រះរាជាណាចក្រកម្ពុជា គឺប្រាក់រៀល ។ ដោយសារក្រុមហ៊ុនធ្វើប្រតិបត្តិការអាជីវកម្ម និងកត់ត្រារាល់បញ្ជីគណនេយ្យរបស់ខ្លួនផ្អែកលើមូលដ្ឋានប្រាក់ដុល្លារអាមេរិក អ្នកគ្រប់គ្រងក៏បានកំណត់ថាប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណមុខងារ និងជារូបិយប័ណ្ណសម្រាប់ធ្វើការបង្ហាញ ព្រោះវាបានឆ្លុះបញ្ចាំងពីសារធាតុសេដ្ឋកិច្ចនៃប្រភពព្រឹត្តិការណ៍ និងកាលៈទេសៈរបស់ក្រុមហ៊ុន ។

របាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិកដែលជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន ។ តួលេខទាំងអស់ត្រូវបានកាត់ខ្ទង់ចំនួនមួយដុល្លារអាមេរិក ដែលជិតបំផុត ឬលុះត្រាមានការបង្ហាញផ្សេងពីនោះ ។

### (ឃ) ការប៉ាន់ស្មាន និងការវិនិច្ឆ័យ

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ អ្នកគ្រប់គ្រងបានធ្វើការវិនិច្ឆ័យ ការប៉ាន់ស្មាន និងការសន្មតដែលមានផលប៉ះពាល់ដល់ការអនុវត្តនូវគោលនយោបាយគណនេយ្យ និងចំនួននៃទ្រព្យសកម្ម បំណុល ចំណូល និងចំណាយដែលបានរាយការណ៍ ។ លទ្ធផលជាក់ស្តែងអាចខុសពីការប៉ាន់ស្មានទាំងនោះ ។

ការប៉ាន់ស្មាន និងការសន្មត ដែលពាក់ព័ន្ធត្រូវបានត្រួតពិនិត្យជាប្រចាំ ។ ការកែប្រែទៅលើការប៉ាន់ស្មានត្រូវបានទទួលស្គាល់តាមមូលដ្ឋានទស្សនវិស័យ ។

ព័ត៌មានស្តីពីការសន្មត និងការប៉ាន់ស្មានដែលមិនមានភាពប្រាកដប្រជា ដែលអាចបណ្តាលឲ្យមានហានិភ័យជាសារវន្តដែលធ្វើឲ្យមាននិយ័តភាពជាសារវន្ត នៅក្នុងការិយបរិច្ឆេទក្រោយ ហើយត្រូវបានដាក់បញ្ចូលនៅក្នុងកំណត់សំគាល់ដូចខាងក្រោមៈ

កំណត់សំគាល់ ១១ - សំវិធានធនលើមូលនិធិសោធននិវត្តន៍ ។

កំណត់សំគាល់ ២១ - យថាភាពលើពន្ធ ។

## ២. មូលដ្ឋាននៃការរៀបចំ (ត)

### (ឃ) ការប៉ាន់ស្មាន និងការវិនិច្ឆ័យ (ត)

#### ការវាស់វែងតម្លៃសមស្រប

គោលនយោបាយគណនេយ្យ និងការលាតត្រដាងព័ត៌មានមួយចំនួនរបស់ក្រុមហ៊ុន តម្រូវឲ្យមានការវាស់វែងតាមតម្លៃសមស្របទាំងទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ និងមិនមែនទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ ។

ក្រុមការងារផ្នែកហិរញ្ញវត្ថុ ធ្វើការត្រួតពិនិត្យលើការបញ្ចូលទិន្នន័យដែលមិនអាចអង្កេតបានសំខាន់ៗ និងនិយ័តភាពលើការវាស់វែងតម្លៃ ។ ប្រសិនបើព័ត៌មានពីអ្នកទីបី ដូចជាសម្រង់តម្លៃពីឈ្មួញកណ្តាល ឬសេវាកម្មផ្តល់តម្លៃត្រូវប្រើសម្រាប់ការវាស់វែងតម្លៃសមស្រប នោះអ្នកគ្រប់គ្រងនឹងវាយតម្លៃលើភស្តុតាងដែលបានមកពីភាគីទីបី ដើម្បីផ្តល់អំណះអំណាងដល់ការសន្និដ្ឋានថាតើការវាយតម្លៃនោះត្រឹមត្រូវតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ដោយរួមបញ្ចូលទាំងឋានានុក្រមនៃតម្លៃសមស្រប ដែលការវាយតម្លៃទាំងនោះត្រូវបានចាត់ថ្នាក់ ។

ក្នុងពេលវាស់វែងតម្លៃសមស្របនៃទ្រព្យ និងបំណុល ក្រុមហ៊ុនបានប្រើព័ត៌មានទីផ្សារកាន់តែច្រើនកាន់តែល្អ ។ តម្លៃសមស្រប ត្រូវបានចាត់ថ្នាក់ក្នុងកម្រិតខុសៗគ្នាតាមឋានានុក្រមតម្លៃសមស្រប ដោយយោងទៅលើទិន្នន័យដែលប្រើប្រាស់នៅក្នុងវិធីសាស្ត្រវាយតម្លៃ ដូចខាងក្រោម៖

- កម្រិតទី ១: តម្លៃដកស្រង់ (មិនទាន់មាននិយ័តភាព) នៅក្នុងទីផ្សារសកម្ម សម្រាប់ទ្រព្យសកម្ម បំណុលស្រដៀងគ្នា ។
- កម្រិតទី ២: ទិន្នន័យដែលមិនមែនជាតម្លៃដកស្រង់ដែលមាននៅក្នុងកម្រិតទី ១ ដែលអាចធ្វើការអង្កេតបានសម្រាប់ទ្រព្យសកម្ម ឬបំណុល ទោះបីដោយផ្ទាល់ (ឧទាហរណ៍ដូចជាតម្លៃ) ឬមិនផ្ទាល់ (ឧទាហរណ៍កើតចេញពីតម្លៃ) ។
- កម្រិតទី ៣: ទិន្នន័យសម្រាប់ទ្រព្យសកម្ម ឬបំណុល ដែលមិនអាស្រ័យទៅលើទិន្នន័យអង្កេតទីផ្សារ (ធាតុចូលមិនអាចអង្កេតបាន) ។

ប្រសិនបើការបញ្ចូលទិន្នន័យ ដើម្បីវាយតម្លៃនូវតម្លៃសមស្រប ទ្រព្យ និងបំណុល ត្រូវបានចាត់ថ្នាក់ក្នុងកម្រិតខុសៗគ្នាតាមឋានានុក្រមតម្លៃសមស្រប នោះការវាស់វែងតម្លៃសមស្របត្រូវបានចាត់ថ្នាក់ស្ថិតនៅក្នុងកម្រិតដូចគ្នានៃឋានានុក្រមតម្លៃសមស្របទាំងមូល ក៏ដូចជាការបញ្ចូលទិន្នន័យកម្រិតទាបបំផុតសំខាន់ៗ សម្រាប់ការវាស់វែងទាំងមូលដែរ ។

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥

### ២. មូលដ្ឋាននៃការរៀបចំ (ត)

#### (ឃ) ការប៉ាន់ស្មាន និងការវិនិច្ឆ័យ (ត)

ក្រុមហ៊ុន ទទួលស្គាល់ការផ្ទេររវាងកម្រិតនៃឋានានុក្រមតម្លៃសមស្របនៅចុងការិយបរិច្ឆេទរបាយការណ៍ក្នុងអំឡុងពេលកែប្រែដែលបានកើតឡើង ។

ព័ត៌មានអំពីការសន្មតធ្វើឡើងសម្រាប់ការវាស់វែងនូវតម្លៃសមស្រប ត្រូវបានបង្ហាញក្នុងកំណត់សំគាល់ ១៩ - ឧបករណ៍ហិរញ្ញវត្ថុ ។

### ៣. គោលនយោបាយគណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យសំខាន់ៗខាងក្រោមនេះ ត្រូវបានយកមកអនុវត្ត ប្រកបដោយសង្គតិភាពនៅគ្រប់ការិយបរិច្ឆេទ និងក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ។

#### (ក) រូបិយប័ណ្ណសម្រាប់ការកំណត់បង្ហាញ

សកម្មភាពប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗទៀតក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិក ដោយប្រើប្រាស់អត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការនោះ ។

សមតុល្យនៃទ្រព្យសកម្មរូបិយវត្ថុ និងបំណុលរូបិយវត្ថុនាកាលបរិច្ឆេទរាយការណ៍ដែលជារូបិយប័ណ្ណក្រៅពីប្រាក់ដុល្លារអាមេរិក ក៏ត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិកដោយប្រើអត្រានាកាលបរិច្ឆេទរាយការណ៍ ។ ភាពលំអៀងពីការប្តូររូបិយប័ណ្ណបរទេស ដែលកើតមកពីការប្តូរនោះត្រូវបានទទួលស្គាល់ជាចំណេញ ឬខាតនៅក្នុងរបាយការណ៍លទ្ធផល ។ ទ្រព្យដែលមិនមែនរូបិយវត្ថុដែលបានវាស់វែងផ្អែកតាមថ្លៃដើមដំបូងជារូបិយប័ណ្ណបរទេសមិនបានប្តូរឡើយ ។ ភាពលំអៀងពីការប្តូររូបិយប័ណ្ណ ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាតនៅក្នុងរបាយការណ៍លទ្ធផល ។

#### (ខ) ឧបករណ៍ហិរញ្ញវត្ថុ

ក្រុមហ៊ុន បែងចែកអនិស្សន្ទទ្រព្យសកម្មហិរញ្ញវត្ថុជាឥណទាន និងគណនីត្រូវទទួល ។

ក្រុមហ៊ុន បែងចែកអនិស្សន្ទបំណុលហិរញ្ញវត្ថុជាបំណុលហិរញ្ញវត្ថុផ្សេងៗ ។

# ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

## (ខ) ឧបករណ៍ហិរញ្ញវត្ថុ (ត)

### (i) អនិស្សន្ទទ្រព្យសកម្មហិរញ្ញវត្ថុ និងអនិស្សន្ទបំណុលហិរញ្ញវត្ថុ - ការទទួលស្គាល់ និងការឈប់ទទួលស្គាល់

ក្រុមហ៊ុន ទទួលស្គាល់ដំបូងនូវឥណទាន និងគណនីត្រូវទទួលនៅកាលបរិច្ឆេទប្រតិបត្តិការបានចាប់ផ្តើម ។ រាល់ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុដទៃទៀត ត្រូវបានទទួលស្គាល់ដំបូងនៅកាលបរិច្ឆេទជួញដូរ ។

ក្រុមហ៊ុនឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិទទួលបានសាច់ប្រាក់តាមកិច្ចសន្យានៃទ្រព្យសកម្មនោះផុតកំណត់ ឬក្រុមហ៊ុនបានផ្ទេរសិទ្ធិក្នុងការទទួលបានសាច់ប្រាក់តាមកិច្ចសន្យា ក្នុងប្រតិបត្តិការដែលហានិភ័យ និងតម្លៃតបស្នងពីកម្មសិទ្ធិភាពសារវន្តនៃទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានផ្ទេរចេញ ឬមិនបានផ្ទេរ ឬមិនរក្សានូវហានិភ័យ និងតម្លៃតបស្នងពីកម្មសិទ្ធិភាពសារវន្ត និងមិនរក្សានូវការគ្រប់គ្រងទ្រព្យសកម្មដែលបានផ្ទេរ ។ រាល់អត្ថប្រយោជន៍ដែលបានកើតឡើង ឬក៏រក្សាទុកដោយក្រុមហ៊ុនតាមរយៈទ្រព្យសកម្មហិរញ្ញវត្ថុដែលបានផ្ទេរចេញ ត្រូវបានទទួលស្គាល់ជាទ្រព្យសកម្ម ឬបំណុលដាច់ដោយឡែក ។

ក្រុមហ៊ុនឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលកាតព្វកិច្ចកិច្ចសន្យាបានបញ្ចប់ លុបចោល ឬផុតកាលកំណត់ ។

ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុត្រូវបានកាត់កង ហើយចំនួននៅសល់សុទ្ធ ត្រូវបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលក្រុមហ៊ុនមានសិទ្ធិតាមផ្លូវច្បាប់ដើម្បីទូទាត់ និងមានបំណងធ្វើការទូទាត់លើមូលដ្ឋានកាត់កង ឬពេលទ្រព្យសកម្មទទួលបាន និងទូទាត់បំណុលកើតឡើងដំណាលគ្នា ។

### (ii) អនិស្សន្ទទ្រព្យសកម្មហិរញ្ញវត្ថុ និងអនិស្សន្ទបំណុលហិរញ្ញវត្ថុ - ការវាស់វែង

*ឥណទាន និងគណនីត្រូវទទួល*

ទ្រព្យសកម្មទាំងនោះ ត្រូវបានទទួលស្គាល់ជាដំបូងតាមតម្លៃសមស្របបូកចំណាយប្រតិបត្តិការពាក់ព័ន្ធ ។ បន្ទាប់ពីការទទួលស្គាល់លើកដំបូង វាត្រូវបានវាស់វែងតាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព ។

*សាច់ប្រាក់ និងសាច់ប្រាក់សមមូល*

នៅក្នុងរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមានសមតុល្យសាច់ប្រាក់ និងប្រាក់បញ្ញើតាមតម្រូវការដែលមាន កាលកំណត់ ៣ ខែ ឬតិចជាង គិតចាប់ពីថ្ងៃដែលបានទទួល ហើយដែលអាចប្តូរជាសាច់ប្រាក់ ដោយមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរតម្លៃ ហើយវាគឺជាផ្នែកមួយដ៏សំខាន់នៅក្នុងការគ្រប់គ្រងសាច់ប្រាក់របស់ក្រុមហ៊ុន ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ខ) ឧបករណ៍ហិរញ្ញវត្ថុ (ត)

**(ii) អនិស្សន្ទទ្រព្យសកម្មហិរញ្ញវត្ថុ និងអនិស្សន្ទបំណុលហិរញ្ញវត្ថុ - ការវាស់វែង (ត)**

*បំណុលហិរញ្ញវត្ថុផ្សេងៗ*

បំណុលហិរញ្ញវត្ថុទាំងនោះ ត្រូវបានទទួលស្គាល់ដំបូងតាមតម្លៃសមស្របដកថ្លៃដើមប្រតិបត្តិការដែលពាក់ព័ន្ធ ។ បន្ទាប់ពីការទទួលស្គាល់លើកដំបូងបំណុលហិរញ្ញវត្ថុទាំងនេះ ត្រូវបានវាស់វែងតាមរំលស់ថ្លៃដើមដោយប្រើវិធីសាស្រ្តការប្រាក់ប្រសិទ្ធភាព ។

**(iii) ដើមទុន - ភាគហ៊ុនធម្មតា**

តម្លៃបន្ថែមផ្ទាល់ដែលទាក់ទងនឹងការបោះផ្សាយ ភាគហ៊ុនត្រូវបានទទួលស្គាល់ដោយការដកចេញពីមូលធន ហើយកាត់កងនឹងពន្ធដែលពាក់ព័ន្ធនានា ។

### (គ) ទ្រព្យ រោងចក្រ និងបរិក្ខារ

**(i) ការទទួលស្គាល់ និងការវាស់វែង**

ផ្នែកនៃទ្រព្យ រោងចក្រ និងបរិក្ខារ ត្រូវបានកត់ត្រាតាមតម្លៃដើមដករំលស់បង្គរ និងការខាតបង់លើឱនភាពនៃតម្លៃបង្គរ ប្រសិនបើមាន ។

ថ្លៃដើមមានរួមបញ្ចូលនូវរាល់ចំណាយទាំងឡាយ ដែលទាក់ទងដោយផ្ទាល់ទៅនឹងការទិញទ្រព្យ ។ ទ្រព្យកំពុងបង្កើត រួមបញ្ចូលទាំងថ្លៃនៃការសាងសង់ បរិក្ខារ និងថ្លៃផ្សេងៗទៀត ត្រូវបានបញ្ចូលជាថ្លៃដើម ។ ថ្លៃដើមនៃការសាងសង់មានរួមបញ្ចូលទាំងថ្លៃកម្ចី ។

នៅពេលដែលធាតុនៃទ្រព្យ រោងចក្រ និងបរិក្ខារ មានអាយុកាលប្រើប្រាស់ខុសៗគ្នា ធាតុទាំងនោះ ត្រូវបានចាត់ទុកជាផ្នែកផ្សេងគ្នា (សមាសធាតុចម្បង) នៃទ្រព្យ រោងចក្រ និងបរិក្ខារ ។

ចំណេញ ឬខាតការលក់ចេញផ្នែកនៃទ្រព្យ រោងចក្រ និងបរិក្ខារ ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាតនៅក្នុងរបាយការណ៍លទ្ធផល ។

**(ii) ចំណាយបន្ទាប់**

ចំណាយបន្ទាប់ដែលពាក់ព័ន្ធទៅនឹងធាតុមួយនៃផ្នែកនៃទ្រព្យ រោងចក្រ និងបរិក្ខារដែលបានទទួលស្គាល់រួចមកហើយ ត្រូវបានបូកបញ្ចូលនៅក្នុងតម្លៃយោងនៃផ្នែកនោះ ប្រសិនបើវាអាចមានលទ្ធភាពផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដល់ក្រុមហ៊ុន ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (គ) ទ្រព្យ រោងចក្រ និងបរិក្ខារ (ត)

#### (iii) រំលស់

ទ្រព្យ រោងចក្រ និងបរិក្ខារត្រូវបានដករំលស់ចាប់ពីថ្ងៃដែលបានដំឡើង និងអាចប្រើប្រាស់បាន ។ ទ្រព្យសកម្ម កំពុងសាងសង់ មិនត្រូវបានធ្វើរំលស់នោះទេ រហូតដល់ការសាងសង់ទ្រព្យសកម្មនោះបានបញ្ចប់ និងដាក់ឲ្យប្រើប្រាស់ ។

រំលស់ត្រូវបានគណនាដើម្បីកាត់បន្ថយថ្លៃដើមនៃទ្រព្យ រោងចក្រ និងបរិក្ខារ ដកតម្លៃកាកសំណល់របស់វាដោយប្រើប្រាស់វិធីសាស្ត្ររំលស់ថេរ ទៅតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មាន ។ រំលស់ត្រូវបានទទួលស្គាល់ជាចំណោញ ឬខាតនៅក្នុងរបាយការណ៍លទ្ធផល ។ ដីធ្លីកម្មសិទ្ធិមិនត្រូវបានដករំលស់ទេ ។

ការប៉ាន់ស្មាន់អាយុកាលប្រើប្រាស់នៃទ្រព្យ រោងចក្រ និងបរិក្ខារសំខាន់ៗក្នុងការិយបរិច្ឆេទបច្ចុប្បន្ន និងការិយបរិច្ឆេទប្រៀបធៀបមានដូចខាងក្រោម៖

| | |
|---|---|
| ចំណតនាវា (ស្ពាន ផែ) និងអាគារ | ១០-៥០ ឆ្នាំ |
| គ្រឿងចក្រ និងគ្រឿងម៉ាស៊ីន | ១០-១៥ ឆ្នាំ |
| គ្រឿងសង្ហារឹមនិងគ្រឿងបំពាក់ | ៥ ឆ្នាំ |
| កុំព្យូទ័រ | ៥-១៥ ឆ្នាំ |
| សម្ភារការិយាល័យ និងផ្សេងៗ | ៥-១៥ ឆ្នាំ |
| យានយន្ត | ៨-១៥ ឆ្នាំ |

វិធីសាស្ត្ររំលស់ អាយុកាលប្រើប្រាស់ និងតម្លៃកាកសំណល់ ត្រូវបានពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ ហើយត្រូវកែសម្រួលប្រសិនបើសមស្រប ។

### (ឃ) ទ្រព្យវិនិយោគ

ទ្រព្យវិនិយោគ គឺជាទ្រព្យកាន់កាប់សម្រាប់ជារកចំណូលពីការជួល ឬកំណើនមូលធន ឬទាំងពីរប៉ុន្តែមិនមែនសម្រាប់លក់ជាដំណើរការអាជីវកម្មប្រចាំថ្ងៃ ការផលិត ឬផ្គត់ផ្គង់ ទំនិញ ឬសេវាកម្ម ឬសម្រាប់ការងាររដ្ឋបាលនោះទេ ។

ទ្រព្យវិនិយោគត្រូវបានកត់ត្រាតាមតម្លៃដើម ដករំលស់បង្គរ និងការខាតបង់លើឱនភាពនៃតម្លៃ ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ឃ) ទ្រព្យវិនិយោគ (ត)

ទ្រព្យវិនិយោគត្រូវបានរំលស់ រយៈពេលពី១០-៥០ ឆ្នាំ ។

វិធីសាស្ត្ររំលស់ អាយុកាលប្រើប្រាស់ និងតម្លៃកាកសំណល់ ត្រូវបានពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ ហើយត្រូវកែសម្រួលប្រសិនបើសមស្រប ។

### (ង) ឱនភាពនៃតម្លៃ

#### (i) អនិស្សន្ទទ្រព្យសកម្មហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាយតម្លៃនាកាលបរិច្ឆេទរាយការណ៍នីមួយៗ ដើម្បីកំណត់សញ្ញាណឱនភាពនៃតម្លៃ ។

សញ្ញាណដែលថាទ្រព្យសកម្មហិរញ្ញវត្ថុមានឱនភាពនៃតម្លៃរួមមាន៖

- ការខកខាន ឬយឺតយ៉ាវក្នុងការទូទាត់សងរបស់កូនបំណុល
- ការរៀបចំឡើងវិញនូវលក្ខខណ្ឌទូទាត់សង ដែលក្រុមហ៊ុនមិនបានរំពឹងទុក
- សញ្ញាណបង្ហាញថាកូនបំណុល នឹងជួបប្រទះការក្ស័យធន
- ការប្រែប្រួលជាអវិជ្ជមានស្ថានភាពទូទាត់របស់កូនបំណុល
- ការបាត់បង់ទីផ្សារសកម្ម សម្រាប់មូលបត្រ ឬ
- ស្ថិតិអង្កេត ដែលបង្ហាញថាមាន នឹងមានការថយចុះសាច់ប្រាក់ដែលអាចវាស់វែងបានពីក្រុមទ្រព្យសកម្មហិរញ្ញវត្ថុ ។

*ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមរំលស់ថ្លៃដើម*

ក្រុមហ៊ុន ពិចារណារាល់សញ្ញាណនៃឱនភាពតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុទាំងលើទ្រព្យសកម្មទោល និងជាក្រុម ។ រាល់ទ្រព្យសកម្មទោលសារវន្ត ត្រូវបានវាយតម្លៃឱនភាពជាច់ដោយឡែក ។ ទ្រព្យសកម្មហិរញ្ញវត្ថុទោលដែលមិនរកឃើញថា មានឱនភាពនៃតម្លៃក្នុងទម្រង់ ជាក់លាក់មួយនោះទេត្រូវបានវាយតម្លៃជាក្រុមសម្រាប់ឱនភាពនៃតម្លៃដែលបានកើតឡើង ប៉ុន្តែមិនទាន់កំណត់នៅឡើយ ។ គណនីមិនសារវន្ត ត្រូវបានវាយតម្លៃជាក្រុម ។ ការវាយតម្លៃជាក្រុម ត្រូវបានធ្វើឡើងដោយបញ្ចូលនូវទ្រព្យដែលមានចរិកលក្ខណៈហានិភ័យស្រដៀងគ្នា ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ង) ឱនភាពនៃតម្លៃ (ត)

#### (i) អនិស្សន្ទទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

*ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមរំលស់ថ្លៃដើម (ត)*

ក្នុងការវាយតម្លៃឱនភាពនៃតម្លៃជាក្រុម ក្រុមហ៊ុនប្រើប្រាស់ព័ត៌មានពីមុន លើថេរវេលានៃការប្រមូលបាន និងចំនួននៃការខាតបង់កើតឡើង និងធ្វើការវិនិច្ឆ័យលើសេដ្ឋកិច្ចបច្ចុប្បន្ន និងលក្ខខណ្ឌឥណទានបច្ចុប្បន្ន ដើម្បីប៉ាន់ស្មានពីការខាតបង់ជាក់ស្តែងអាចច្រើនជាង ឬតិចជាងចំនួនដែលបានកើតឡើងដោយយោងតាមនិន្នាការពីមុន ។

ការខាតបង់លើឱនភាពនៃតម្លៃលើទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានគណនាដោយផ្អែកលើភាពខុសគ្នារវាងតម្លៃយោង និងតម្លៃបច្ចុប្បន្ននៃលំហូរទឹកប្រាក់នាអនាគត ដែលធ្វើអប្បហារតាមអត្រាការប្រាក់ប្រសិទ្ធភាពដំបូង ។ ការខាងបង់ត្រូវបានទទួលស្គាល់ក្នុងចំណេញ ឬខាតក្នុងគណនីសំវិធានធន ។ នៅពេលដែលក្រុមហ៊ុនគិតថាមិនមានសង្ឃឹមក្នុងការទទួលបាននូវការទូទាត់សង ចំនួនដែលពាក់ព័ន្ធនឹងត្រូវបានលុបចោល ។ ប្រសិនបើការខាតបង់លើឱនភាពនៃតម្លៃមានការថយចុះនៅពេលបន្ទាប់ ហើយការថយចុះអាចពាក់ព័ន្ធនឹងព្រឹត្តការណ៍កើតឡើងបន្ទាប់ពីឱនភាពនៃតម្លៃបានទទួលស្គាល់នោះ ការខាតលើឱនភាពនៃតម្លៃដែលបានទទួលស្គាល់ពីមុន ត្រូវបានធ្វើនិយ័តកម្មក្នុងរបាយការណ៍លទ្ធផល ។

#### (ii) ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

នាកាលបរិច្ឆេទរាយការណ៍នីមួយៗ ក្រុមហ៊ុនពិនិត្យតម្លៃយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ដើម្បីកំណត់សញ្ញាណនៃឱនភាពនៃតម្លៃ ។ ក្នុងករណីដែលមានកត្តាទាំងនោះកើតឡើងចំនួននៃទ្រព្យសកម្មដែលអាចប្រមូលបានវិញ នឹងត្រូវបានប៉ាន់ស្មាន ។

សម្រាប់ការធ្វើតេស្តឱនភាពនៃតម្លៃ ទ្រព្យសកម្មត្រូវបានដាក់បញ្ចូលគ្នាជាក្រុម ដែលអាចបង្កើតសាច់ប្រាក់តូចបំផុតពីការបន្តការប្រើប្រាស់ ដោយមិនពឹងផ្អែកខ្លាំងលើលំហូរទឹកប្រាក់នៃទ្រព្យសកម្មដទៃទៀត ឬក្រុមទ្រព្យសកម្មដទៃទៀត ហៅកាត់ថា (“ឯកតាបង្កើតសាច់ប្រាក់”) ។

តម្លៃដែលអាចប្រមូលមកវិញបាននៃ ទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ គឺផ្អែកលើតម្លៃដែលធំជាងរវាងតម្លៃប្រើប្រាស់ និងតម្លៃសមស្រប ដកចំណាយការលក់ចេញ ។ តម្លៃប្រើប្រាស់ គឺអាស្រ័យលើការប៉ាន់ស្មាន នូវលំហូរទឹកប្រាក់នាពេលអនាគតអប្បហារទៅតម្លៃបច្ចុប្បន្ន ដោយប្រើប្រាស់អត្រាអប្បហាមុនដកពន្ធដែលឆ្លុះបញ្ចាំងពីការប៉ាន់ប្រមាណទីផ្សារបច្ចុប្បន្ននៃតម្លៃពេលវេលា និងហានិភ័យជាក់លាក់ សម្រាប់ទ្រព្យសកម្មទាំងនោះ ឬឯកតាបង្កើតសាច់ប្រាក់ ។

៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ង) ឱនភាពនៃតម្លៃ (ត)

(ii) **ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ (ត)**

ការខាតបង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់ ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្ម ឬ ឯកតាបង្កើតសាច់ប្រាក់ មានតម្លៃលើសតម្លៃដែលអាចប្រមូលមកវិញបាន ។

ការខាតបង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល ។ ការខាតបង់លើឱនភាព នៃតម្លៃ ត្រូវបានបែងចែក ដើម្បីកាត់បន្ថយតម្លៃយោងនៃទ្រព្យសកម្មក្នុងឯកតាបង្កើតសាច់ប្រាក់ តាមមូលដ្ឋានសមាមាត្រ ។

## (ច) អត្ថប្រយោជន៍របស់និយោជិត

(i) **អត្ថប្រយោជន៍របស់និយោជិតរយៈពេលខ្លី**

អត្ថប្រយោជន៍របស់និយោជិតរយៈពេលខ្លី គឺជាចំណាយនៅពេលសេវាកម្មពាក់ពន្ធត្រូវបានផ្តល់ ។ បំណុលត្រូវបានទទួលស្គាល់លើចំនួនដែលរំពឹងថានឹងត្រូវទូទាត់ប្រសិនបើក្រុមហ៊ុន មានកាតព្វកិច្ចផ្លូវច្បាប់ ឬប្រយោលក្នុងការទូទាត់ចំនួននេះ ដែលជាលទ្ធផលនៃសេវាកម្ម ដែលបានផ្តល់ដោយនិយោជិតរួចហើយ ហើយកាតព្វកិច្ចអាចប៉ាន់ស្មានដោយភាពជាក់លាក់ ។

(ii) **គម្រោងអត្ថប្រយោជន៍ដែលបានកំណត់**

កាតព្វកិច្ចរបស់ក្រុមហ៊ុនសម្រាប់អត្ថប្រយោជន៍និយោជិតនេះ ត្រូវបានគណនាដាច់ដោយឡែកសម្រាប់គម្រោងនីមួយៗ ដោយធ្វើការប៉ាន់ស្មានលើចំនួនអត្ថប្រយោជន៍អនាគតដែលនិយោជិត ត្រូវទទួលសម្រាប់ការបម្រើការងារនៅក្នុងឆ្នាំបច្ចុប្បន្ន និងឆ្នាំកន្លងទៅអប្បហារទូវចំនួននោះ និងដកតម្លៃទៅតាមគម្រោងទ្រព្យសកម្ម ។

ការគណនាកំណត់ពីកាតព្វកិច្ចនៃអត្ថប្រយោជន៍ ត្រូវបានធ្វើឡើងដោយកំណត់នូវភាពជាក់ស្តែងដោយប្រើរបៀបនៃការប៉ាន់ប្រមាណ ។ នៅពេលលទ្ធផលនៃការគណនា បង្ហាញថាជាទ្រព្យសកម្មរបស់ក្រុមហ៊ុន ការទទួលស្គាល់ទ្រព្យសកម្ម ត្រូវបានកំណត់ទៅតាមតម្លៃបច្ចុប្បន្ននៃអត្ថប្រយោជន៍សេដ្ឋកិច្ច ដែលមានក្នុងទម្រង់ប្រាក់បង្វិល គម្រោងនាពេលអនាគត ឬដកពីគម្រោងការចូលរួមចំណែកនាពេលអនាគត ។ ការគណនាតម្លៃបច្ចុប្បន្ននៃអត្ថប្រយោជន៍សេដ្ឋកិច្ច សាច់ប្រាក់ត្រូវបានផ្តល់ឲ្យទៅមូលនិធិអតិបរមា តាមតម្រូវការណាមួយដែលអនុវត្តបាន ។

# ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

## (ច) អត្ថប្រយោជន៍របស់និយោជិត (ត)

(ii) **គម្រោងអត្ថប្រយោជន៍ដែលបានកំណត់ (ត)**

កាកំណត់នៃការវាស់វែងបំណុល អត្ថប្រយោជន៍សុទ្ធឡើងវិញ ដោយរួមបញ្ចូលទាំងការចំណេញ ឬខាតជាក់ស្តែង ផែនការវិលត្រលប់មកលើទ្រព្យសកម្ម (មិនរួមបញ្ចូលការប្រាក់) និងផលប៉ះពាល់នៃកម្រិត

ទ្រព្យសកម្ម (ប្រសិនបើមាន មិនរួមបញ្ចូលការប្រាក់) ត្រូវទទួលស្គាល់ភ្លាមៗ ក្នុងលទ្ធផលលម្អិតផ្សេងៗ ។ ក្រុមហ៊ុនបានកំណត់ចំណូល ចំណាយការប្រាក់សុទ្ធលើការកំណត់បំណុល (ទ្រព្យសកម្ម) អត្ថប្រយោជន៍សុទ្ធសម្រាប់ការិយបរិច្ឆេទ ដោយអនុវត្តតាមអត្រាអប្បហាសម្រាប់ការវាស់វែងនូវការកំណត់ កាតព្វកិច្ចនៃអត្ថប្រយោជន៍នាដើមការិយបរិច្ឆេទប្រចាំឆ្នាំ បន្ទាប់មកកំណត់បម្រែបម្រួលនៅក្នុងការិយបរិច្ឆេទ ដែលជាលទ្ធផលបានមកពីការរួមចំណែកវិភាគទាននិងការបង់ប្រាក់ ។ ចំណាយការប្រាក់សុទ្ធ និងចំណាយទាំងអស់ដែលពាក់ព័ន្ធនឹងគម្រោងអត្ថប្រយោជន៍នេះ ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាតនៅក្នុងរបាយការណ៍លទ្ធផល ។

ក្រុមហ៊ុនទទួលស្គាល់ចំណេញ ឬខាតពី Curtailment ឬការទូទាត់ នៅពេលប្រតិបត្តិនោះកើតឡើង ។ ចំណេញ ឬខាតពី Curtailment ឬការទូទាត់រួមមានការប្រែប្រួលនូវតម្លៃបច្ចុប្បន្ន ឬចំណេញ ឬខាតពី Actuarial និងចំណាយនៃការបម្រើការរួចដែលមិនទាន់ទទួលស្គាល់ពីមុន ។

## (ឆ) សំវិធានធន

សំវិធានធន ត្រូវបានកំណត់ដោយអប្បហារលំហូរទឹកប្រាក់ដែលរំពឹងថានឹងទទួលបាន នាពេលអនាគតដោយប្រើអត្រាមុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងពីការប៉ាន់ប្រមាណនៃតម្លៃពេលវេលាក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់ចំពោះបំណុលទាំងនោះ ។ តម្លៃនៃអប្បហា ត្រូវបានទទួលស្គាល់ជាចំណាយហិរញ្ញប្បទាន ។

## (ជ) ទុនបម្រុងតាមច្បាប់ ទុនបម្រុងសេរី និងមូលនិធិអភិវឌ្ឍន៍សហគ្រាស

យោងតាមលក្ខន្តិកស្តីពីការបង្កើត ក.ស.ភ ជាសហគ្រាសសាធារណៈ ក.ស.ភ ត្រូវបែងចែកប្រាក់ចំណេញសុទ្ធនៃការិយបរិច្ឆេទចុងក្រោយទៅទុនបម្រុងតាមច្បាប់ ទុនបម្រុងសេរី និងមូលនិធិអភិវឌ្ឍន៍សហគ្រាសដូចខាងក្រោម៖

| | |
|---|---|
| ទុនបម្រុងតាមច្បាប់ | ៥% |
| ទុនបម្រុងសេរី | ៥% |
| មូលនិធិអភិវឌ្ឍន៍សហគ្រាស | ៩០% |

# ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

## (ឈ) ការទទួលស្គាល់ចំណូល

ចំណូល ត្រូវបានទទួលស្គាល់នៅពេលទទួលបាននូវតម្លៃសមស្រប ឬការលក់ទំនិញ និងសេវាកម្មដែលត្រូវទទួល ពីសកម្មភាពប្រចាំថ្ងៃរបស់ក្រុមហ៊ុន ។ ប្រាក់ចំណូល ត្រូវទទួលស្គាល់បន្ទាប់ពីដកពន្ធ ការបង្វិលឲ្យវិញ និងការបញ្ចុះតម្លៃ ។

ចំណូល ត្រូវបានទទួលស្គាល់ដូចខាងក្រោម៖

កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥

*(i)* *សេវាកម្មកិច្ចការផែ*

សេវាកម្មកិច្ចការផែ ត្រូវបានទទួលស្គាល់នៅពេលដែលសេវាកម្មដែលទាក់ទងបានផ្តល់សេវាកម្ម ។ នាកាលបរិច្ឆេទរាយការណ៍ បើសិនជាសេវាកម្មនៅកំពុងដំណើរការ ដូច្នេះចំណែកសេវាកម្មដែលបានផ្តល់រួចរាល់ត្រូវបានទទួលស្គាល់នៅក្នុងការិយបរិច្ឆេទ ។

*(ii)* *សេវាកម្មដឹកទំនិញ - សេវាលើកដាក់ទំនិញ (LoLo) ស្តុកទំនិញ និងសេវាលើកដាក់ទំនិញ (Stevedoring)*

សេវាកម្មដឹកទំនិញ ត្រូវបានទទួលស្គាល់នៅពេលដែលផ្តល់សេវាកម្ម ។ នាកាលបរិច្ឆេទរាយការណ៍ បើសិនជាសេវាកម្មនៅកំពុងដំណើរការ ដូច្នេះចំណែកសេវាកម្ម ដែលបានផ្តល់រួចរាល់ត្រូវបានទទួលស្គាល់នៅក្នុងការិយបរិច្ឆេទ។

*(iii)* *ការបូមខ្សាច់*

ចំណូលពីការបូមខ្សាច់ ត្រូវបានទទួលស្គាល់នៅពេលដែលផ្តល់សេវាកម្ម ។ នាកាលបរិច្ឆេទរាយការណ៍ បើសិនជាសេវាកម្មនៅកំពុងដំណើរការ ដូច្នេះចំណែកសេវាកម្មដែលបានផ្តល់រួចរាល់ ត្រូវបានទទួលស្គាល់នៅក្នុងការិយបរិច្ឆេទ ។

*(iv)* *ច្រកទ្វារ*

កម្រៃពីច្រកទ្វារ ត្រូវបានទទួលស្គាល់នៅពេលដែលផ្តល់សេវាកម្ម ។ នាកាលបរិច្ឆេទរាយការណ៍បើសិនជាសេវាកម្មនៅកំពុងដំណើរការ ដូច្នេះចំណែកសេវាកម្មដែលបានផ្តល់រួចរាល់ ត្រូវបានទទួលស្គាល់នៅក្នុងការិយបរិច្ឆេទ ។

*(v)* *សេវាកម្មវាស់ស្ទង់*

សេវាកម្មវាស់ស្ទង់ ត្រូវបានទទួលស្គាល់នៅពេលដែលផ្តល់សេវាកម្ម ។ នាកាលបរិច្ឆេទរាយការណ៍បើសិនជាសេវាកម្មនៅកំពុងដំណើរការ ដូច្នេះចំណែកសេវាកម្មដែលបានផ្តល់រួចរាល់ ត្រូវបានទទួលស្គាល់នៅក្នុងការិយបរិច្ឆេទ ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ញ) ចំណូលពីការជួល

ចំណូលពីការជួលទ្រព្យវិនិយោគស្ថិតក្រោមភតិសន្យាប្រតិបត្តិការ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលដោយផ្អែកលើមូលដ្ឋានរំលស់ថេរទៅតាមថេរវេលានៃភតិសន្យា ។ ប្រាក់លើកទឹកចិត្តភតិសន្យាដែលបានទទួល ត្រូវទទួលស្គាល់ជាផ្នែកមួយនៃចំណូលភតិសន្យាសរុបទៅតាមថេរវេលានៃភតិសន្យា ។

### (ដ) កម្រៃហិរញ្ញប្បទាន

កម្រៃហិរញ្ញប្បទាន រួមមានចំណាយការប្រាក់លើប្រាក់កម្ចី និងអប្បហារលើសំវិធានធន ។ កម្រៃហិរញ្ញប្បទាន

ដែលមិនពាក់ព័ន្ធដោយផ្ទាល់លើការទិញ ការសាងសង់ ឬការផលិតទ្រព្យសកម្មដែល មានលក្ខណៈសម្បត្តិត្រូវបានទទួលស្គាល់ជាចំណេញ ឬខាតដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព ។

## (ឋ) ភតិសន្យាប្រតិបត្តិការ

ការទូទាត់ក្រោមភតិសន្យាប្រតិបត្តិការ ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាតក្នុងរបាយការណ៍លទ្ធផលតាមវិធីសាស្ត្ររំលស់ថេរទៅតាមថេរវេលានៃភតិសន្យា ។ ការលើកទឹកចិត្តភតិសន្យាដែលទទួលបានត្រូវបានទទួលស្គាល់ជាផ្នែកនៃចំណាយភតិសន្យាតាមថេរវេលានៃភតិសន្យា ។

## (ឌ) ពន្ធលើប្រាក់ចំណេញ

ពន្ធលើប្រាក់ចំណេញរួមមានពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ ។ ពន្ធប្រចាំឆ្នាំ និងពន្ធពន្យារត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាតនៅក្នុងរបាយការណ៍លទ្ធផល លើកលែងតែជាតុណាបានទទួលស្គាល់ដោយផ្ទាល់ក្នុងមូលធន ឬនៅក្នុងរបាយការណ៍លម្អិតផ្សេងៗទៀត ។

### ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ គឺជាពន្ធដែលរំពឹងថា ត្រូវបង់ទៅលើប្រាក់ចំណេញជាប់ពន្ធប្រចាំឆ្នាំ ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទ៍នៅកាលបរិច្ឆេទរាយការណ៍ និងនិយ័តភាពទាំងឡាយទៅលើពន្ធត្រូវបង់ពីឆ្នាំមុនៗ ។

### ពន្ធពន្យារ

ពន្ធពន្យារ ត្រូវបានកំណត់ទៅលើភាពលំអៀងជាបណ្តោះអាសន្ន រវាងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលក្នុងគោលបំណងនៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃយោងសម្រាប់ការគិតពន្ធ ។

# ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

## (ឌ) ពន្ធលើប្រាក់ចំណេញ (ត)

### ពន្ធពន្យារ (ត)

ពន្ធពន្យារមិនត្រូវបានកំណត់សម្រាប់៖

- ពន្ធពន្យារខុសគ្នាទទួលស្គាល់ដំបូងជាទ្រព្យសកម្ម ឬបំណុល ក្នុងប្រតិបត្តិការវាមិនមែនរួមបញ្ចូលពាណិជ្ជកម្ម និងមិនមានផលប៉ះពាល់ទាំងគណនេយ្យ ឬពន្ធលើប្រាក់ចំណេញ ឬខាតនោះឡើយ ។
- ភាពខុសគ្នាជាបណ្តោះអាសន្នទាក់ទងជាមួយការវិនិយោគក្នុងបុត្រសម្ព័ន្ធ ក្រុមហ៊ុនសមាគម ការរៀបចំរួមទុន ក្នុងលក្ខខណ្ឌឲ្យក្រុមហ៊ុនអាចគ្រប់គ្រងទាំងពេលវេលានៃការចម្រាសមកវិញនៃភាពខុសគ្នាជាបណ្តោះអាសន្ន និងទំនងជាមិនអាចចម្រាសមកវិញ នាពេលអនាគត និង
- ភាពខុសគ្នាជាបណ្តោះអាសន្នកើតឡើងពីការទទួលស្គាល់ជាលើកដំបូងលើកេរ្តិ៍ឈ្មោះ ។

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥

ពន្ធជាបណ្តោះអាសន្ន ខុសគ្នាកើតឡើងពីលើការទទួលស្គាល់ដំបូងនៃមូលនិធិពាណិជ្ជកម្ម ។ ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានទទួលស្គាល់សម្រាប់ការខាតលើពន្ធ និងភាពលំអៀងជាបណ្តោះអាសន្ន ដែលអាចកាត់កងបានតែក្នុងករណីអាចនឹងកើតមានឡើងទៅលើប្រាក់ចំណេញជាប់ពន្ធ នាពេលអនាគត ដែលអាចប្រើប្រាស់បាន ។ ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យនៅរាល់កាលបរិច្ឆេទរាយការណ៍ ហើយត្រូវបានកាត់បន្ថយ ក្នុងករណីដែលវាមិនអាចកើតឡើងនូវអត្ថប្រយោជន៍ពន្ធដែលពាក់ព័ន្ធដែលអាចនឹងប្រើប្រាស់បាន ។

ពន្ធពន្យារ ត្រូវបានកំណត់ដោយប្រើអត្រាពន្ធដែលរំពឹងថានឹងប្រើទៅលើភាពលំអៀងជាបណ្តោះអាសន្ន ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទ៏នៅកាលបរិច្ឆេទរាយការណ៍ ។

ការវាស់វែងពន្ធពន្យារ ឆ្លុះបញ្ចាំងពីលទ្ធផលដែលក្រុមហ៊ុនរំពឹងថា (នាកាលបរិច្ឆេទរាយការណ៍) នឹងមានទទួលមកវិញ ឬការកាត់កងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុល ។

ពន្ធពន្យារជាទ្រព្យសកម្ម និងបំណុល ត្រូវកាត់កងក្នុងករណីដែលបានបំពេញនូវលក្ខណៈវិនិច្ឆ័យមួយចំនួន ។

## (ឍ) ស្តង់ដារថ្មី និងការស្រាយបំភ្លឺមិនទាន់អនុវត្ត

ស្តង់ដារថ្មី ការកែប្រែ និងការបកស្រាយថ្មីមួយចំនួន ទាក់ទងនឹងស្តង់ដារដែលមានស្រាប់ បានចូលជាធរមានសម្រាប់ការិយបរិច្ឆេទចាប់ផ្តើមបន្ទាប់ពីថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៥ ហើយមិនទាន់បានប្រើប្រាស់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះទេ ។ ស្តង់ដារដែលអាចពាក់ព័ន្ធ ត្រូវបាន បង្ហាញដូចខាងក្រោម ។

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ឈ) ស្តង់ដារថ្មី និងការស្រាយបំភ្លឺមិនទាន់អនុវត្ត (ត)

**ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ៩ ស្តីពីឧបករណ៍ហិរញ្ញវត្ថុ ("CIFRS ៩")**

CIFRS ៩ ដែលចេញផ្សាយនៅខែ កក្កដា ឆ្នាំ ២០១៤ ជំនួសឲ្យស្តង់ដាគណនេយ្យអន្តរជាតិនៃកម្ពុជា ៣៩ ស្តីពីឧបករណ៍ហិរញ្ញវត្ថុ - ការទទួលស្គាល់ និងការវាស់វែង ។ CIFRS ៩ រួមបញ្ចូលការកែប្រែនូវការណែនាំលើចំណាត់ថ្នាក់ និងការវាង់វែងនៃឧបករណ៍ហិរញ្ញវត្ថុ រួមមានគម្រូនៃការប៉ាន់ស្មានលើឥណទានខាតបង់សម្រាប់ការគណនាឱនភាពលើតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងតម្រូវការថ្មីនៃគណនេយ្យការពារទូទៅ ។ CIFRS ៩ ក៏បានបន្តការណែនាំលើការទទួលស្គាល់ និងឈប់ទទួលស្គាល់ឧបករណ៍ហិរញ្ញវត្ថុពី CIFRS ៣៩ ផងដែរ ។

CIFRS ៩ មានប្រសិទ្ធភាពអនុវត្តសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំដែលចាប់ផ្តើម ឬបន្ទាប់ពី ថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨ ជាមួយនឹងការអនុញ្ញាតក្នុងការអនុវត្តមុន ។

ក្រុមហ៊ុនកំពុងធ្វើការវិភាគលើសក្តានុពលនៃផលប៉ះពាល់លើរបាយការណ៍ហិរញ្ញវត្ថុ ដែលកើតឡើងពីការអនុវត្តនៃ CIFRS ៩។

**ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ១៥ ស្តីពីចំណូលពីកិច្ចសន្យាជាមួយអតិថិជន ("CIFRS ១៥")**

CIFRS ១៥ បានបង្កើតនូវទម្រង់ដ៏ទូលំទូលាយមួយសម្រាប់កំណត់ថាតើចំណូលចំនួនប៉ុន្មាន និងពេលណាត្រូវទទួលស្គាល់ ។ CIFRS ១៥ នឹងជំនួសការណែនាំក្នុងការទទួលស្គាល់ចំណូលដែលមានស្រាប់ រួមមានស្តង់ដារគណនេយ្យអន្តរជាតិនៃកម្ពុជា ១៨ ស្តីពីចំណូលលេខ ១១ ស្តីពីកិច្ចសន្យាសាងសង់ និងបំណកស្រាយ ១៣ របស់គណៈកម្មការបកស្រាយស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ("IFRIC") ១៣ ស្តីពីកម្មវិធីសម្រាប់អតិថិជនស្មោះស្ម័គ្រ ។

CIFRS ១៥ មានប្រសិទ្ធភាពអនុវត្តសម្រាប់ការិយបរិច្ឆេទប្រចាំឆ្នាំដែលចាប់ផ្តើម ឬបន្ទាប់ពី ថ្ងៃទី ១ ខែ មករា ឆ្នាំ ២០១៨ ជាមួយនឹងការអនុញ្ញាតក្នុងការអនុវត្តមុន ។

ក្រុមហ៊ុនកំពុងធ្វើការវិភាគលើសក្តានុពលនៃផលប៉ះពាល់លើរបាយការណ៍ហិរញ្ញវត្ថុ ដែលកើតឡើងពីការអនុវត្តនៃ CIFRS ១៥ ។

កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥

## ៣. គោលនយោបាយគណនេយ្យសំខាន់ៗ (ត)

### (ណ) ការរាយការណ៍តាមចំណែក

ចំណែកប្រតិបត្តិការ ត្រូវបានរាយការណ៍ ឲ្យស្របទៅនឹងរបាយការណ៍ផ្ទៃក្នុង ដែលដាក់ជូនអ្នកសម្រេចចិត្ត របស់ក្រុមហ៊ុន ។ អ្នកគ្រប់គ្រងសំខាន់ៗ គឺជាអ្នកទទួលខុសត្រូវលើការបែងចែកធនធាន និងវាយតម្លៃការអនុវត្តប្រតិបត្តិការរបស់ក្រុមហ៊ុន ។ ក្រុមហ៊ុនធ្វើប្រតិបត្តិការលើកំពង់ផែដែលពាក់ព័ន្ធនឹងអាជីវកម្ម ។

## ៤. ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិកទៅជាប្រាក់រៀល

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាដុល្លារអាមេរិក ។ ការប្តូររូបិយប័ណ្ណពីដុល្លារអាមេរិកទៅជាប្រាក់រៀល ត្រូវបានធ្វើឡើងដើម្បីឲ្យស្របទៅតាមច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យនៃព្រះរាជាណាចក្រកម្ពុជាពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ដោយប្រើប្រាស់អត្រាប្តូរប្រាក់ជាផ្លូវការ ប្រកាសដោយអគ្គនាយកដ្ឋានពន្ធដារកម្ពុជា នាថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ ដែល ១ ដុល្លារអាមេរិក ស្មើនឹង ៤.០៦០ រៀល (២០១៤: ៤.០៣៨ រៀល) ។ តួលេខជាប្រាក់រៀលនេះ គឺសម្រាប់ជាការបង្ហាញតែប៉ុណ្ណោះ ហើយមិនត្រូវបានយកមកបកស្រាយថាតួលេខប្រាក់ដុល្លារអាមេរិកនេះ ត្រូវបានប្តូរទៅជាប្រាក់រៀល ឬគួរតែត្រូវបានប្តូរជាប្រាក់រៀល ឬនឹងត្រូវបានប្តូរជាប្រាក់រៀលនាពេលអនាគតតាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ផ្សេងទៀតនោះឡើយ ។

កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥

## ៥. ទ្រព្យ សេចក្ដី និងបរិក្ខារ

| ២០១៥ | ដីធ្លី<br>ដុល្លារអាមេរិក | ចំណតនាវា<br>និងអាគារ<br>ដុល្លារអាមេរិក | គ្រឿងចក្រ<br>និងម៉ាស៊ីន<br>ដុល្លារអាមេរិក | គ្រឿងសង្ហារឹម<br>និងគ្រឿងបំពាក់<br>ដុល្លារអាមេរិក | កុំព្យូទ័រ<br>ដុល្លារអាមេរិក | សម្ភារការិយាល័យ<br>និងផ្សេងៗ<br>ដុល្លារអាមេរិក | យានយន្ត<br>ដុល្លារអាមេរិក | ទ្រព្យកំពុងបង្កើត<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក | <br>ពាន់រៀល<br>(កំណត់សំគាល់ ៤) |
|---|---|---|---|---|---|---|---|---|---|---|
| **តម្លៃដើម** | | | | | | | | | | |
| នាថ្ងៃទី ១ខែមករាឆ្នាំ ២០១៥ | ៩៥.៣៥៦.៣៥២ | ៣៨.៣២១.៦៦៦ | ១១.០៣៤.៧៥៨ | ៤៨.៧២២ | ៥៦១.០៦៩ | ៥០៥.៣៦៣ | ៧៩២.៩២១ | - | ១៤៦.៦២០.៨៥១ | ៥៩៥.២៨០.៦៥៥ |
| ការទិញបន្ថែម | ៤០៦.៤៧៥ | ១០៩.៦៩០ | ២២០.៨៤៩ | ៨.១២០ | ១.២៦០ | ៣.៤៩៩ | ៥៤៥.៥៣២ | ៣៣៦.០៤៨ | ១.៦៣១.៤៧៣ | ៦.៦២៣.៧៨១ |
| ផ្ទេរទៅទ្រព្យវិនិយោគ | - | - | - | - | - | - | - | (១០១.៣០៦) | (១០១.៣០៦) | (៤១១.៣០២) |
| ការលក់ | - | - | - | - | - | - | (២០.៦៤៤) | - | (២០.៦៤៤) | (៨៣.៨១៥) |
| ការលុបចោល | - | - | - | - | (២៣.២១២) | (៣.០២១) | - | - | (២៦.២៣៣) | (១០៦.៥០៦) |
| នាថ្ងៃទី ៣១ខែធ្នូ ឆ្នាំ ២០១៥ | ៩៥.៧៦២.៨២៧ | ៣៨.៤៣១.៣៥៦ | ១១.២៥៥.៦០៧ | ៥៦.៨៤២ | ៥៣៩.១១៧ | ៥០៥.៨៤១ | ១.៣១៧.៨០៩ | ២៣៤.៧៤២ | ១៤៨.១០៤.១៤១ | ៦០១.៣០២.៨១៣ |
| ដក:**រំលស់បង្គរ** | | | | | | | | | | |
| នាថ្ងៃទី ១ខែមករាឆ្នាំ ២០១៥ | - | ៣.៧៣៩.៣១៥ | ១.៥៧៧.៩៤៧ | ២៨.១៧១ | ២៥២.៥២៤ | ៨៧.៨៦០ | ១៦៧.៩១៩ | - | ៥.៨៥៣.៧៣៦ | ២៣.៧៦៦.១៦៨ |
| រំលស់ក្នុងឆ្នាំ | - | ១.២៦៣.៩៥២ | ៧៦៩.៩៩៥ | ៦.៨០៣ | ១០៤.២៨៣ | ៤១.៧៨៨ | ៧១.៥៩៤ | - | ២.២៥៨.៤១៥ | ៩.១៦៩.១៦៥ |
| ការលក់ | - | - | - | - | - | - | (១០.៧០៦) | - | (១០.៧០៦) | (៤៣.៤៦៦) |
| ការលុបចោល | - | - | - | - | (៨.២៤៨) | (២.៦០៩) | - | - | (១០.៨៥៧) | (៤៤.០៧៩) |
| នាថ្ងៃទី ៣១ខែធ្នូ ឆ្នាំ ២០១៥ | - | ៥.០០៣.២៦៧ | ២.៣៤៧.៩៤២ | ៣៤.៩៧៤ | ៣៤៨.៥៥៩ | ១២៧.០៣៩ | ២២៨.៨០៧ | - | ៨.០៩០.៥៨៨ | ៣២.៨៤៧.៧៨៨ |
| **តម្លៃយោង** | | | | | | | | | | |
| នាថ្ងៃទី ៣១ខែធ្នូ ឆ្នាំ ២០១៥ | ៩៥.៧៦២.៨២៧ | ៣៣.៤២៨.០៨៩ | ៨.៩០៧.៦៦៥ | ២១.៨៦៨ | ១៩០.៥៥៨ | ៣៧៨.៨០២ | ១.០៨៩.០០២ | ២៣៤.៧៤២ | ១៤០.០១៣.៥៥៣ | ៥៦៨.៤៥៥.០២៥ |

## ៥. ទ្រព្យ រោងចក្រ និងបរិក្ខារ (ត)

| ២០១៤ | ដីធ្លី ដុល្លារអាមេរិក | ចំណតនាវា និងអាគារ ដុល្លារអាមេរិក | គ្រឿងចក្រ និងម៉ាស៊ីន ដុល្លារអាមេរិក | គ្រឿងសង្ហារឹម និងគ្រឿងបំពាក់ ដុល្លារអាមេរិក | កុំព្យូទ័រ ដុល្លារអាមេរិក | សម្ភារការិយាល័យ និងផ្សេងៗ ដុល្លារអាមេរិក | យានយន្ត ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក | សរុប ពាន់រៀល (កំណត់សំគាល់ ៤) |
|---|---|---|---|---|---|---|---|---|---|
| **តម្លៃដើម** | | | | | | | | | |
| នាថ្ងៃទី ១ខែមករាឆ្នាំ ២០១៤ | ៩៤.៩៣៥.៦៨៦ | ៣៨.២៤៩.៨៩៣ | ១០.៩៩៤.៦៨៤ | ៤២.៧០៣ | ៥០៨.៩៤៤ | ៤៧៩.០២៤ | ៥៩២.៣៨៩ | ១៩៥.៨០៣.៣២៣ | ៥៨៨.៧៥៣.៨១៨ |
| ការទិញបន្ថែម | ៤២០.៦៦៦ | ៧១.៧៧៣ | ៤០.០៧៤ | ៦.០១៩ | ៥២.១២៥ | ២៩.១៩២ | ២៣៥.៦០៦ | ៨៥៥.៤៥៥ | ៣.៤៥៤.៣២៧ |
| ការលក់ | - | - | - | - | - | - | (៣៥.០៧៤) | (៣៥.០៧៤) | (១៤១.៦២៩) |
| ការលុបចោល | - | - | - | - | - | (២.៨៥៣) | - | (២.៨៥៣) | (១១.៥២០) |
| នាថ្ងៃទី ៣១ខែធ្នូ ឆ្នាំ ២០១៤ | ៩៥.៣៥៦.៣៥២ | ៣៨.៣២១.៦៦៦ | ១១.០៣៤.៧៥៨ | ៤៨.៧២២ | ៥៦១.០៦៩ | ៥០៥.៣៦៣ | ៧៩២.៩២១ | ១៩៦.៦២០.៨៥១ | ៥៩២.០៥៤.៩៨៦ |
| ដក:**រំលស់បង្គរ** | | | | | | | | | |
| នាថ្ងៃទី ១ខែមករាឆ្នាំ ២០១៤ | - | ២.៤៧១.១២៦ | ៨១៤.៦២៧ | ១៨.៧៣៦ | ១៩៨.០៨០ | ៥២.៨១២ | ១២៤.៨៦៤ | ៣.៦៣០.២៤៥ | ១៤.៦៥៨.៩២៩ |
| រំលស់ក្នុងឆ្នាំ | - | ១.២៦៨.១៨៩ | ៧៦៣.៣២០ | ៩.៤៣៥ | ១០៤.៤៤៤ | ៣៧.៩០១ | ៥១.៩៦៧ | ២.២៣៤.៧៥៦ | ៩.០២៣.៩៤៥ |
| ការលក់ | - | - | - | - | | - | (៨.៩១២) | (៨.៩១២) | (៣៣.៩៦៨) |
| ការលុបចោល | - | - | - | - | - | (២.៨៥៣) | - | (២.៨៥៣) | (១១.៥២០) |
| នាថ្ងៃទី ៣១ខែធ្នូ ឆ្នាំ ២០១៤ | - | ៣.៧៣៩.៣១៥ | ១.៥៧៧.៩៤៧ | ២៨.១៧១ | ២៥២.៥២៤ | ៨៧.៨៦០ | ១៦៧.៩១៩ | ៥.៨៥៣.៧៣៦ | ២៣.៦៣៧.៣៨៦ |
| **តម្លៃយោង** | | | | | | | | | |
| នាថ្ងៃទី ៣១ខែធ្នូ ឆ្នាំ ២០១៤ | ៩៥.៣៥៦.៣៥២ | ៣៤.៥៨២.៣៥១ | ៩.៤៥៦.៨១១ | ២០.៥៥១ | ៣០៨.៥៤៥ | ៤១៧.៥០៣ | ៦២៥.០០២ | ១៩០.៧៦៧.១១៥ | ៥៦៨.៤១៧.៦១០ |

កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥

## ៥. ទ្រព្យ រោងចក្រ និងបរិក្ខារ (ត)

រំលស់ទ្រព្យ រោងចក្រ និងបរិក្ខារ ត្រូវបានបែងចែកដូចខាងក្រោមៈ

| | ២០១៥ | | ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| ថ្លៃដើមនៃការលក់ និងសេវាកម្ម (កំណត់សំគាល់ ១៥) | ១.៩៦៣.០៨២ | ៧.៩៧០.១១៣ | ១.៩៥៦.៧៥២ | ៧.៩០១.៣៦៤ |
| ចំណាយរដ្ឋបាលទូទៅ និងការលក់ | ២៩៥.៣៣៣ | ១.១៩៩.០៥២ | ២៧៨.០០៤ | ១.១២២.៥៨១ |
| | ២.២៥៨.៤១៥ | ៩.១៦៩.១៦៥ | ២.២៣៤.៧៥៦ | ៩.០២៣.៩៤៥ |

## ៦. ទ្រព្យវិនិយោគ

| | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ | | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| **តម្លៃដើម** | | | | |
| នាថ្ងៃទី ១ ខែមករា | ៨.០១៦.៦៩២ | ៣២.៥៤៧.៧៧០ | ៧.៩៨២.៣៥៣ | ៣២.២៣២.៧៤១ |
| ការទិញបន្ថែម | ១១.៣១៤ | ៤៥.៩៣៥ | ៣៤.៣៣៩ | ១៣៨.៦៦១ |
| ផ្ទេរពីទ្រព្យ រោងចក្រ និងបរិក្ខារ | ១០១.៣០៦ | ៤១១.៣០២ | - | - |
| នាថ្ងៃទី ៣១ ខែធ្នូ | ៨.១២៩.៣១២ | ៣៣.០០៥.០០៧ | ៨.០១៦.៦៩២ | ៣២.៣៧១.៤០២ |
| **ដក: រំលស់បង្គរ** | | | | |
| នាថ្ងៃទី ១ ខែមករា | ១៧៤.៥២៨ | ៧០៨.៥៨៤ | ១២៩.៩៣៥ | ៥២៤.៦៧៨ |
| រំលស់ក្នុងឆ្នាំ | ៤៧.១៣១ | ១៩១.៣៥២ | ៤៤.៥៩៣ | ១៨០.០៦៦ |
| នាថ្ងៃទី ៣១ ខែធ្នូ | ២២១.៦៥៩ | ៨៩៩.៩៣៦ | ១៧៤.៥២៨ | ៧០៤.៧៤៤ |
| **តម្លៃយោង** | | | | |
| នាថ្ងៃទី ៣១ ខែធ្នូ | ៧.៩០៧.៦៥៣ | ៣២.១០៥.០៧១ | ៧.៨៤២.១៦៤ | ៣១.៦៦៦.៦៥៨ |

កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥

## ៧. គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ

| | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ | | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| គណនីអតិថិជន | ១.៨៨០.៥៤៧ | ៧.៦៣៥.០២១ | ១.១៣៥.៩០៨ | ៤.៥៨៦.៧៩៧ |
| ប្រាក់កក់ ប្រាក់បង់មុន និងផ្សេងៗ | ៥៨៩.៤១៥ | ២.៣៩៣.០២៥ | ២៣៩.៣២៥ | ៩៦៦.៣៩៤ |
| ឥណទានផ្តល់ដល់បុគ្គលិក(*) | ៣៨៩.៨៣៨ | ១.៥៨២.៧៤២ | - | - |
| បុរេប្រទានផ្តល់ដល់ក្រសួងសាធារណការ និងដឹកជញ្ជូន | ៥៣.៣៨០ | ២១៦.៧២៣ | - | - |
| | ២.៩១៣.១៨០ | ១១.៨២៧.៥១១ | ១.៣៧៥.២៣៣ | ៥.៥៥៣.១៩១ |

(*) នេះគឺជាឥណទានផ្តល់ដល់បុគ្គលិកដើម្បីទិញភាគហ៊ុនរបស់ក្រុមហ៊ុនក្នុងអំឡុងពេល សំណើរលក់មូលបត្រជាសាធារណៈលើកដំបូង។ ឥណទានដែលផ្តល់ដល់បុគ្គលិកនេះ គឺពុំមានគិតការប្រាក់ឡើយ និងត្រូវសងត្រឡប់មកវិញតាមចំនួនស្មើគ្នារៀងរាល់ខែក្នុងរយៈពេល ២៤ ខែ។

តម្លៃសមស្របនៃឥណទានផ្តល់ដល់បុគ្គលិក គឺផ្អែកទៅលើលំហូរសាច់ប្រាក់ដែលត្រូវបានធ្វើការអប្បហារ ដោយប្រើប្រាស់អត្រាការប្រាក់ជាក់ស្តែង ១២% ក្នុង ១ ឆ្នាំ។ អ្នកគ្រប់គ្រងបានធ្វើការវាយតម្លៃថា អត្រាការប្រាក់ ១២% គឺជាអត្រាសមស្របមួយដែលសមមូលនឹងអត្រាការប្រាក់នៃឥណទានប្រាក់រៀលរយៈពេល ២ ឆ្នាំ ដែលបុគ្គលិកអាចទទួលបានពីធនាគារពាណិជ្ជ។

## ៨. សាច់ប្រាក់ និងសាច់ប្រាក់សមមូល

| | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ | | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| សាច់ប្រាក់ក្នុងធនាគារ | ៨.៧៤៥.៥៧៩ | ៣៥.៥០៧.០៥០ | ១.៨១៧.៣៣៣ | ៧.៣៣៨.៣៩១ |
| សាច់ប្រាក់ក្នុងដៃ | ៣.៦៤២ | ១៤.៧៨៧ | ៣.៥៧៧ | ១៤.៤៤៤ |
| | ៨.៧៤៩.២២១ | ៣៥.៥២១.៨៣៧ | ១.៨២០.៩១០ | ៧.៣៥២.៨៣៥ |

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥

## ៩. ដើមទុន

| | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ | | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| ចុះបញ្ជី បោះផ្សាយ និង បង់គ្រប់ចំនួន | ១១០.៣១៦.៦១២ | ៤៤៧.៤៨៥.៤៤៥ | ២៦.៧៧៧.៨៧២ | ១០៨.១២៩.០៤៧ |

នៅថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ២០១៥ ក្រុមប្រឹក្សាភិបាល នៃ ក.ស.ភ បានសម្រេចផ្ទេរប្រាក់ចំណេញរក្សាទុកចំនួន ៨៣.៥៣៨.៧៤០ ដុល្លារអាមេរិក (ប្រហែល ៣៣៨.៥៨២.៥១៣ ពាន់រៀល) ទៅជាដើមទុន។ នៅថ្ងៃទី ១៤ តុលា ឆ្នាំ ២០១៥ ក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានសម្រេចអនុម័តលើការកែប្រែលក្ខន្តិកៈក្រុមហ៊ុន ដើម្បីឆ្លុះបញ្ចាំងពីបម្រែបម្រួលខាងលើ ។ ការផ្ទេរនេះត្រូវបានទទួលការអនុម័ត ពីក្រសួងពាណិជ្ជកម្មនៅថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ ២០១៥។

បន្ទាប់ពីការផ្ទេរខាងលើ ដើមទុនសរុបរបស់ក្រុមហ៊ុនមានចំនួន ១១០.៣១៦.៦១២ ដុល្លារអាមេរិក ចែកជា ១១០.៣១៦.៦១២ ហ៊ុន ដោយមានតម្លៃ ៤.០០០ រៀល ក្នុងមួយហ៊ុន (ស្មើនឹង ១ ដុល្លារអាមេរិក) ហើយត្រូវបានបែងចែកជា ២ ថ្នាក់ដូចខាងក្រោម៖

- ភាគហ៊ុនប្រភេទ “ខ” (ភាគហ៊ុនដែលមានសិទ្ធិបោះឆ្នោត) ចំនួន ១៦.៥៤៧.៤៩២ (ស្មើនឹង ១៥% នៃចំនួនហ៊ុនសរុប) ដែលមានតម្លៃ ១៦.៥៤៧.៤៩២ ដុល្លារអាមេរិក (ប្រហែល ៦៦.១៨៩.៩៦៨ ពាន់រៀល។)

- ភាគហ៊ុនប្រភេទ “គ” (ភាគហ៊ុនដែលគ្មានសិទ្ធិបោះឆ្នោត) ចំនួន ៩៣.៧៦៩.១២០ (ស្មើនឹង ៨៥% នៃចំនួនហ៊ុនសរុប) ដែលមានតម្លៃ ៩៣.៧៦៩.១២០ ដុល្លារអាមេរិក (ប្រហែល ៣៧៥.០៧៦.៤៨០ ពាន់រៀល។)

នៅថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១៥ ក.ស.ភ បានចុះបញ្ជីនៅលើផ្សារមូលបត្រកម្ពុជា (“ផ.ម.ក”)។ ចំនួនភាគហ៊ុនធម្មតា (ដែលមានសិទ្ធិបោះឆ្នោត) សរុបមានចំនួន ២០.៦៨៤.៣៦៥ ហ៊ុន ដោយក្នុងនោះ ភាគហ៊ុនប្រភេទ “ក” មានចំនួន ៤.១៣៦.៨៧៣ បានពីការលក់មូលបត្រជាសាធារណៈលើកដំបូង ដែលមានតម្លៃទីក ៤.០០០ រៀលក្នុងមួយហ៊ុនជាមួយនឹងបុព្វលាភចំនួន១.១៣៦.១៦៩ដុល្លារអាមេរិក។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកាន់កាប់ ភាគហ៊ុនចំនួន ៨០% នៃភាគហ៊ុនសរុប បន្ទាប់ពីការចុះបញ្ជី។ ក្រុមហ៊ុន ទទួលសាច់ប្រាក់ពីការលក់មូលបត្រជាសាធារណៈ បានចំនួន ៥.១៩៣.៩១៥ ដុល្លារអាមេរិក និងបានកើតឡើងនូវចំណាយប្រតិបត្តិការចំនួន ៩០១.៥៤០ ដុល្លារអាមេរិក ។

## ៩. ដើមទុន (ត)

ក.ស.ភ កំពុងតែស្ថិតក្នុងដំណើរការនៃការកែប្រែលក្ខន្តិកៈក្រុមហ៊ុន ដូចនេះហើយ សាច់ប្រាក់សុទ្ធចំនួន ៤.២៩២.៣៧៥ ដុល្លារអាមេរិក ត្រូវបានចាត់ថ្នាក់ជា មូលធនផ្សេងៗ។

ភាគហ៊ុនប្រភេទ "ក" នឹងទទួលបានការធានាជាអប្បបរមា នូវអត្រាភាគលាភចំនួន ៥% ដោយផ្អែកទៅលើ តម្លៃហ៊ុនក្នុងពេលលក់មូលបត្រជាសាធារណៈជាលើកដំបូង សម្រាប់រយៈពេលយ៉ាងហោច ៥ ឆ្នាំ បន្ទាប់ពី ការចុះបញ្ជី ។

ភាគហ៊ុនប្រភេទ "គ" ពុំមានសិទ្ធិទទួលបាននូវប្រាក់ចំណេញរបស់ក្រុមហ៊ុននោះទេ ប៉ុន្តែមានសិទ្ធិបុរិមា ក្នុង ការទទួលទ្រព្យសម្បត្តិរបស់ក្រុមហ៊ុននៅក្នុងករណីដែលក្រុមហ៊ុនជម្រះបញ្ជី។

## ១០. ប្រាក់កម្ចី

| | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ | | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| **រយៈពេលវែង** | | | | |
| ចំណតកុងទ័រនីផែថ្មីភ្នំពេញ ("PPPNCTP") | ២៨.៩៧៩.៦៣៧ | ១១៧.៦៥៧.៣២៦ | ២៨.៩៧៩.៦៣៧ | ១១៧.០១៩.៧៧៤ |

PPPNCTP តំណាងឲ្យកិច្ចព្រមព្រៀងខ្ចីប្រាក់បន្តរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ("កសហវ") និង ក.ស.ភ សម្រាប់ការខ្ចីប្រាក់បានមកពី The Import-Export Bank of China ("the Eximbank") ស្ថិតនៅក្រោមកិច្ចព្រមព្រៀងកម្ចីឥណទានអតិថិជនដែលពេញចិត្ត លេខ (២០១០) ២៩ (១៣៦) នៅថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១០ សម្រាប់ការសាងសង់ចំណតកុងទ័រនីផែថ្មីភ្នំពេញ ។

ចំនួនប្រាក់ដែលបានប្រគល់ឲ្យ ក.ស.ភ ខ្ចីបន្តនេះ ត្រូវបានចាត់ទុកថាបានឲ្យ ក.ស.ភ នៅថ្ងៃដូចគ្នាតាមរូបិយប័ណ្ណ និងក្នុងចំនួនទឹកប្រាក់ដូចដែលបាន បើកដោយធនាគារ Eximbank សម្រាប់កម្មវត្ថុផ្តល់ហិរញ្ញប្បទានដើម្បីអនុវត្តគម្រោង ។ ក.ស.ភ បង់ការប្រាក់ រៀងរាល់ពាក់កណ្តាលឆ្នាំម្តង ដោយអត្រាការប្រាក់ ៤% ក្នុង ១ ឆ្នាំ ។ ប្រាក់កម្ចីបន្តនេះគឺសម្រាប់រយៈពេល ២០ ឆ្នាំ រួមបញ្ចូលទាំងថេរវេលាអនុគ្រោះមិនលើសពី ៧ ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខាកិច្ចព្រមព្រៀងកម្ចីនេះ ។

## ១១. សំវិធានធនលើមូលនិធិសោធននិវត្តន៍

| | | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ | | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| គម្រោងអត្ថប្រយោជន៍ដែលបានកំណត់ | (ក) | ៥០៧.៣៩៩ | ២.០៦០.០៤០ | ៧០២.៤៤២ | ២.៨៣៦.៨៦១ |
| អត្ថប្រយោជន៍ផ្សេងៗ | (ខ) | ១៧.៧៩៣ | ៧២.២៤០ | ១៥.០២០ | ៦០.៦៥១ |
| | | ៥២៥.១៩២ | ២.១៣២.២៨០ | ៧១៧.៤៦២ | ២.៨៩៧.១១២ |

### (ក). គម្រោងអត្ថប្រយោជន៍ដែលបានកំណត់

ក្រុមហ៊ុន ផ្តល់អត្ថប្រយោជន៍ដល់បុគ្គលិកក្នុងលក្ខណៈជាការទូទាត់លើមូលដ្ឋានប្រាក់បៀវត្សរ៍ចុងក្រោយនៅពេលចូលនិវត្តន៍ ឬទូទាត់លើប្រាក់បៀវត្សរ៍សរុបចុងក្រោយសម្រាប់ការលាឈប់ដោយសារបញ្ហាសុខភាព ឬមរណៈភាពក្នុងពេលបំពេញភារកិច្ច ។

គម្រោងនេះ មិនមានមូលនិធិ ឬគម្រោងអត្ថប្រយោជន៍ដែលបានអនុម័តឡើយ ដូច្នេះមិនមានបទប្បញ្ញត្តិដែលពាក់ព័ន្ធ និងមូលនិធិចូលនិវត្តន៍ឡើយ ។

តារាងខាងក្រោមវិភាគអំពីតម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចសោធននិវត្តន៍ ដែលបានទទួលស្គាល់ជាចំណេញ ឬខាត និងការប៉ាន់ស្មាន Actuarial ។

## ១១. សំវិធានធនលើមូលនិធិសោធននិវត្តន៍ (ត)

### (ក). គម្រោងអត្ថប្រយោជន៍ដែលបានកំណត់ (ត)

បម្រែបម្រួលនៃតម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចសោធននិវត្តន៍ មានដូចខាងក្រោម៖

| | ២០១៥ | | ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| នាថ្ងៃ ១ ខែ មករា | ៧០២.៤៤២ | ២.៨៥១.៩១៥ | ៥៩៧.៩៦៤ | ២.៤១៤.៥៧៩ |
| ការទូទាត់ | (២៩.២៥២) | (១១៨.៧៦៣) | (២៣.៤៦០) | (៩៤.៧៣១) |
| ការកំណត់ឡើងវិញ | (៤.៨៣១) | (១៩.៦១៤) | ៤៩.០០៤ | ១៩៧.៨៧៧ |
| ចំណាយបម្រើការ | (២០៤.៣១១) | (៨២៩.៥០៣) | ៣៨.០៧៥ | ១៥៣.៧៤៧ |
| ចំណាយការប្រាក់ | ៤៣.៣៥១ | ១៧៦.០០៥ | ៤០.៨៥៩ | ១៦៤.៩៨៩ |
| នាថ្ងៃទី ៣១ ខែ ធ្នូ | ៥០៧.៣៩៩ | ២.០៦០.០៤០ | ៧០២.៤៤២ | ២.៨៣៦.៤៦១ |

ចំណាយដែលបានទទួលស្គាល់នៅក្នុងចំណេញ ឬខាតមានដូចខាងក្រោម៖

| | ២០១៥ | | ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| ចំណាយបម្រើការ | (២០៤.៣១១) | (៨២៩.៥០៣) | ៣៨.០៧៥ | ១៥៣.៧៤៧ |
| ចំណាយការប្រាក់ | ៤៣.៣៥១ | ១៧៦.០០៥ | ៤០.៨៥៩ | ១៦៤.៩៨៩ |
| | (១៦០.៩៦០) | (៦៥៣.៤៩៨) | ៧៨.៩៣៤ | ៣១៨.៧៣៦ |

**ការសន្មតលើការគណនាតម្លៃ**

ខាងក្រោមនេះ គឺជាការសន្មតលើការគណនាតម្លៃចម្បងៗនាកាលបរិច្ឆេទរាយការណ៍ (បញ្ជាក់តាមមធ្យមទម្ងន់)។

| | |
|---|---|
| អត្រាអប្បហា (*) | ៧.០០% |
| ការកើនឡើងប្រាក់បៀវត្សរ៍នាពេលអនាគត | ២៣.០០% និងថយចុះតាមលំដាប់ ៥.០០% រាល់ឆ្នាំ |
| អាយុរស់រាន | តារាងអាយុរបស់ប្រទេសថៃ ២០០៨ |
| ពិការភាព | ១០.០០% នៃអាយុរស់រាននៅ |
| អាយុចូលនិវត្តន៍ | ៥៥ ៥៨ និង ៦០ ឆ្នាំ ផ្អែកតាមមុខងាររបស់បុគ្គលិក |
| អត្រាបុគ្គលិកលាលែង | ១.៤០% |

## ១១. សំវិធានធនលើមូលនិធិសោធននិវត្តន៍ (ត)

### (ក). គម្រោងអត្ថប្រយោជន៍ដែលបានកំណត់ (ត)

**ការសន្មតលើការគណនាតម្លៃ (ត)**

(*) ដោយសារព័ត៌មានអំពីប័ណ្ណបំណុលពាណិជ្ជកម្ម ឬប័ណ្ណបំណុលរបស់រាជរដ្ឋាភិបាលកម្ពុជា មិនទាន់មានដូច្នេះក្រុមហ៊ុនបានធ្វើការវិភាគជាមធ្យមភាគ លើអត្រាការប្រាក់នៃប្រាក់បញ្ញើរយៈពេលវែងជាប្រាក់រៀលរបស់ធនាគារនៅកម្ពុជាចំនួនពីរ ។

ការសន្មតនៃអាយុរស់នៅនាពេលអនាគត គឺផ្អែកលើតារាងស្ថិតិអាយុដែលបានផ្សាយជាសាធារណៈ ។ ដោយសារតារាងនោះមិនមាននៅកម្ពុជា ក្រុមហ៊ុនបានប្រើប្រាស់តារាងស្ថិតិអាយុរបស់ប្រទេសថៃឆ្នាំ ២០០៨ ដោយមិនមានការកែប្រែឡើយ (សូមមើលព័ត៌មានការប្រៀបធៀបខាងក្រោម) ។ អត្រានេះគឺបានបោះពុម្ភផ្សព្វ ផ្សាយនៅឆ្នាំ ២០០៨ ។ ដោយសារតែនិយោជិតដែលធ្វើការក្នុងវិស័យផ្លូវការ មានអាយុកាលរស់នៅល្អជាង ប្រជាជនទូទៅ សំវិធានធនត្រូវបានធ្វើឡើង ។

អាយុប៉ាន់ស្មាននៅពេលកើត (ប្រទេសកម្ពុជា)

| | |
|---|---|
| បុរស | ៦១ ឆ្នាំ |
| ស្ត្រី | ៦៤ ឆ្នាំ |

អាយុប៉ាន់ស្មាននៅពេលកើត ផ្អែកតាមអត្រាប្រទេសថៃ TM ២០០៨

| | |
|---|---|
| បុរស | ៦៦ ឆ្នាំ |
| ស្ត្រី | ៧៤ ឆ្នាំ |

**ការវិភាគរំញោច**

ការថយចុះនូវអត្រាអប្បហាចំនួន 0.២៥% អាចធ្វើឲ្យកើនឡើងគម្រោងអត្ថប្រយោជន៍ដែលបានកំណត់ចំនួន ២.២១% ។ ការកើនឡើងនូវអត្រាអប្បហាចំនួន 0.២៥% អាចធ្វើឲ្យថយចុះគម្រោងអត្ថប្រយោជន៍ដែលបានកំណត់ចំនួន ២.១៣% ។

ការថយចុះនូវអត្រាកើនឡើងនៃប្រាក់ខែចំនួន 0.៥0% អាចធ្វើឲ្យថយចុះគម្រោងអត្ថប្រយោជន៍ ដែលបានកំណត់ចំនួន ៣.៨៧% ។ ការកើនឡើងនូវអត្រាកើនឡើងនៃប្រាក់ខែចំនួន 0.៥0% អាចធ្វើឲ្យកើនឡើងគម្រោងអត្ថប្រយោជន៍ ដែលបានកំណត់ចំនួន ៤.0៨% ។

## ១១. សំវិធានធនលើមូលនិធិសោធននិវត្តន៍ (ត)

### (ខ). អត្ថប្រយោជន៍ផ្សេងៗ

ក.ស.ភ បានកាត់ទុកចំនួន ៣% នៃមូលដ្ឋានប្រាក់បៀវត្សរ៍ប្រចាំខែ សម្រាប់បង់ទៅបេឡាជាតិរបបសន្តិសុខសង្គម សម្រាប់មន្ត្រីរាជការស៊ីវិល (ប.ជ.ស) ជាប្រចាំឆ្នាំ ។ បន្ទាប់ពីចូលនិវត្តន៍និយោជិតកម្មករនឹងទទួល បានប្រាក់ចូលនិវត្តន៍ជាប្រចាំខែពីបេឡាជាតិរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិលវិញ ។

បម្រែបម្រួលនៃតម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចសោធននិវត្តន៍ មានដូចខាងក្រោម៖

| | ២០១៥ | | ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| នាថ្ងៃ ១ ខែ មករា | ១៥.០២០ | ៦០.៩៨១ | ២១.៨៧៨ | ៨៨.៣៨៣ |
| ការបង់ | (១៣.៣៣៤) | (៥៤.១៣៥) | (២០.១៩២) | (៨១.៥៣៥) |
| ចំណាយបន្ថែម | ១៦.១០៧ | ៦៥.៣៩៤ | ១៣.៣៣៤ | ៥៣.៨៤៣ |
| នាថ្ងៃទី ៣១ ខែ ធ្នូ | ១៧.៧៩៣ | ៧២.២៤០ | ១៥.០២០ | ៦០.៦៥១ |

## ១២. ពន្ធ

### (ក) បំណុលពន្ធពន្យារសុទ្ធ

| | ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៥ | | ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| ពន្ធពន្យារទ្រព្យសកម្ម | ១១៥.១៦២ | ៤៦៧.៥៥៨ | ២២៤.១២០ | ៩០៤.៩៩៧ |
| ពន្ធពន្យារបំណុល | (១.១៩៧.៧៧៩) | (៤.៨៦២.៩៨៣) | (៩១៧.២១៤) | (៣.៧០៣.៧១០) |
| | (១.០៨២.៦១៧) | (៤.៣៩៥.៤២៥) | (៦៩៣.០៩៤) | (២.៧៩៨.៧១៣) |

កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥

## ១២. ពន្ធ (ត)

### (ក) បំណុលពន្ធពន្យារសុទ្ធ (ត)

ពន្ធពន្យារទ្រព្យសកម្ម/(បំណុល) ចូលរួមមាន៖

| | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ | | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| រំលស់ | (១.១៩៧.៧៧៩) | (៤.៨៦២.៩៨៣) | (៩១៧.២១៤) | (៣.៧០៣.៧១០) |
| សំវិធានធនលើមូលនិធិ សោធននិវត្តន៍ | ១០៥.០៣៨ | ៤២៦.៩៥៥ | ១៣២.៦៧៨ | ៥៣៥.៧៥៤ |
| សំវិធានធនលើប្រាក់រង្វាន់ | - | - | ៦៧.៥៣៥ | ២៧២.៧០៦ |
| ចំណូលបង់ទុកមុន | ១០.១២៤ | ៤១.១០៣ | ១៥.៦៤៦ | ៦៣.១៧៩ |
| ខាតពីការប្តូររូបិយប័ណ្ណ ដែលមិនទាន់កើតឡើង | - | - | ៨.២៦១ | ៣៣.៣៥៨ |
| | (១.០៨២.៦១៧) | (៤.៣៩៥.៤២៥) | (៦៩៣.០៩៤) | (២.៧៩៨.៧១៣) |

បម្រែបម្រួលនៃពន្ធពន្យារសុទ្ធមានដូចខាងក្រោម៖

| | ២០១៥ | | ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| នាថ្ងៃទី ១ ខែ មករា | (៦៩៣.០៩៤) | (២.៨១៣.៩៦១) | (៤៧៦.០៤៨) | (១.៩២២.២៨២) |
| បញ្ចូលក្នុងរបាយការណ៍លទ្ធផល | (៣៨៩.៥២៣) | (១.៥៨១.៤៦៤) | (២១៧.០៤៦) | (៨៧៦.៤៣១) |
| នាថ្ងៃទី ៣១ ខែ ធ្នូ | (១.០៨២.៦១៧) | (៤.៣៩៥.៤២៥) | (៦៩៣.០៩៤) | (២.៧៩៨.៧១៣) |

## កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
## សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥

### ១២. ពន្ធ (ត)

### (ខ) សំវិធានធនសម្រាប់ពន្ធលើប្រាក់ចំណេញ

| | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ | | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| នាថ្ងៃទី ១ ខែ មករា | ៣១៩.៩៧៥ | ១.២៩៩.០៩៩ | ២២៥.៨០២ | ៩១១.៧៨៩ |
| ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ | ៧៨១.៧៨១ | ៣.១៧៣.៨៦៨ | ៤៤៣.៦២១ | ១.៧៩១.៣៤២ |
| កង្វះសំវិធានធនពីការិយបរិច្ឆេទមុន | ១៤.០០៣ | ៥៦.៨៥២ | - | - |
| ពន្ធដែលបានបង់ | (៤៧៤.៨៣៨) | (១.៩២៧.៨៤២) | (៣៤៩.៤៤៨) | (១.៤១១.០៧១) |
| នាថ្ងៃទី ៣១ ខែ ធ្នូ | ៦៤០.៨៤១ | ២.៦០១.៩៧៧ | ៣១៩.៩៧៥ | ១.២៩២.០៥៩ |

### (គ) ចំណាយពន្ធលើប្រាក់ចំណេញ

| | ២០១៥ | | ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ | ៧៨១.៧៨១ | ៣.១៧៣.៨៦៨ | ៤៤៣.៦២១ | ១.៧៩១.៣៤២ |
| កង្វះសំវិធានធនពីការិយបរិច្ឆេទមុន | ១៤.០០៣ | ៥៦.៨៥២ | - | - |
| ពន្ធពន្យារ | ៣៨៩.៥២៣ | ១.៥៨១.៦៦៤ | ២១៧.០៤៦ | ៨៧៦.៤៣១ |
| | ១.១៨៥.២៦៧ | ៤.៨១២.៣៨៤ | ៦៦០.៦៦៧ | ២.៦៦៧.៧៧៣ |

ដោយអនុលោមទៅតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ក.ស.ភ មានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណេញ ដោយគណនាតាមអត្រា ២០% នៃប្រាក់ចំណេញជាប់ពន្ធ ឬក៏បង់ពន្ធអប្បបរមាដោយគណនាតាមអត្រា ១% នៃប្រាក់ចំណូលសរុបនៅពេលដែលពន្ធមួយណាមានចំនួនធំជាង ។

កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥

## ១២. ពន្ធ (ត)

### (គ) ចំណាយពន្ធលើប្រាក់ចំណេញ (ត)

ការផ្ទៀងផ្ទាត់ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំដែលគណនាតាមអត្រាពន្ធជាផ្លូវការ ធៀបទៅនឹងពន្ធលើប្រាក់ចំណេញដែលបង្ហាញក្នុងរបាយការណ៍លទ្ធផល មានដូចខាងក្រោម៖

| | ២០១៥ | | ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| ប្រាក់ចំណេញមុនដកពន្ធ | ៤.៣៦៨.៩៩២ | ១៧.៧៣៦.០៧៧ | ២.៨០៥.៧៧៦ | ១១.៣២៩.៧២៤ |
| ពន្ធលើប្រាក់ចំណេញផ្អែកតាមអត្រាពន្ធផ្លូវការ (២០%) | ៨៧៣.៦៩៨ | ៣.៥៤៧.២១៥ | ៥៦១.១៥៥ | ២.២៦៥.៩៤៥ |
| កង្វះសំវិធានធនពីការិយបរិច្ឆេទមុន | ១៤.០០៣ | ៥៦.៨៥២ | - | - |
| ផលប៉ះពាល់ដោយចំណាយមិនអាចកាត់កងបាន | ២៩៧.៥៦៦ | ១.២០៨.១១៧ | ៩៩.៥១២ | ៤០១.៨២៨ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ១.១៨៥.២៦៧ | ៤.៨១២.១៨៤ | ៦៦០.៦៦៧ | ២.៦៦៧.៧៧៣ |

ការគណនាពន្ធលើប្រាក់ចំណេញ ត្រូវមានការពិនិត្យ និងអនុម័តដោយអគ្គនាយកដ្ឋានពន្ធដារ ។

## ១៣. គណនីអ្នកផ្គត់ផ្គង់ និងគណនីបំណុលផ្សេងៗ

| | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ | | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| គណនីអ្នកផ្គត់ផ្គង់ | ២៣៨.៨៧៧ | ៩៦៩.៨៤១ | ២៣៦.០២៤ | ៩៥៣.០៦៥ |
| ប្រាក់កក់ពីអតិថិជន | ២៤១.៥៧៥ | ៩៨០.៧៩៥ | ១៧៨.៧៥៧ | ៧២១.៨២០ |
| ចំណាយប្រតិបត្តិការបង្គរ | ៧៩៧.៩១៩ | ៣.២៣៩.៥៤៨ | ៦៥៧.០៦៧ | ២.៦៥៣.២៣៧ |
| ពន្ធត្រូវបង់ផ្សេងៗ | ១៨០.២៩៨ | ៧៣២.០១០ | ១១៤.៨៥៨ | ៤៦៣.៧៩៧ |
| ការប្រាក់ត្រូវបង់ | ៤៤១.៤២២ | ១.៧៩២.១៧៣ | ៤៤១.៤២២ | ១.៧៨២.៤៦២ |
| | ១.៩០០.០៩១ | ៧.៧១៤.៣៦៧ | ១.៦២៨.១២៨ | ៦.៥៧៤.៣៨១ |

កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥

## ១៤. ចំណូល

| | ២០១៥ | | ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| សេវាលើកដាក់ទំនិញ (Stevedoring) | ៦.០៣១.៣៦១ | ២៤.៤៨៧.៣២៦ | ៥.៦២៧.៥៦៤ | ២២.៧២៤.១០៣ |
| សេវាលើកដាក់ទំនិញ (LoLo) | ៤.៩២៨.៨៩៣ | ២០.០១១.៣០៦ | ៤.៥០៣.៩១៨ | ១៨.១៨៦.៨២១ |
| ចំណូលកិច្ចការផែ | ២.៤៩៤.៧១២ | ១០.១២៨.៥៣១ | ២.១២៦.៥៩៥ | ៨.៥៨៧.១៩១ |
| ចំណូលពីការបូមខ្សាច់ | ៧១៨.៥១៤ | ២.៩១៧.១៦៧ | - | - |
| កំរៃពីច្រកទ្វារ | ៤៨៩.៤២៧ | ១.៩៨៧.០៧៤ | ៤២៩.៤០៣ | ១.៧៣៣.៩២៩ |
| ស្តុកទំនិញ | ២៩១.៨៨៩ | ១.១៨៣.៤៥៥ | ៥៤៩.០១៦ | ២.២១៦.៩២៧ |
| ចំណូលពីការវាស់ស្ទង់ | ១៧៩.៧០៧ | ៧២៩.៦១០ | - | - |
| ផ្សេងៗ | ៣.៣៨១ | ១៣.៧២៧ | ៥៥.៧៥៩ | ២២៥.១៥៥ |
| | ១៥.១៣៧.៨៨៤ | ៦១.៤៥៨.១៨៦ | ១៣.២៩២.២៥៥ | ៥៣.៦៧៤.១២៦ |

## ១៥. ថ្លៃដើមនៃការលក់ និងសេវាកម្ម

| | ២០១៥ | | ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| រំលស់ (កំណត់សំគាល់ ៥) | ១.៩៦៣.០៨២ | ៧.៩៧០.១១៣ | ១.៩៥៦.៧៥២ | ៧.៩០១.៣៦៤ |
| ដងយោង | ១.២៧៦.៦០៨ | ៥.១៨៣.០២៨ | ១.១៨៧.៥២៤ | ៤.៧៩៥.២២២ |
| ប្រាក់បៀវត្សរ៍ និង អត្ថប្រយោជន៍ផ្សេងៗ | ១.០៦១.៧៦៤ | ៤.៣១០.៧៦២ | ៩០៩.៥០០ | ៣.៦៧២.៥៦១ |
| ប្រេងសាំង និងប្រេងឥន្ធនៈ | ៥៦១.០២២ | ២.២៧៧.៧៤៩ | ៦៥៦.៦៦០ | ២.៦៥១.៥៩៣ |
| ការបូមខ្សាច់ | ១១៤.៩៤៧ | ៤៦៦.៦៨៥ | ៣២២.៣៧៤ | ១.៣០១.៧៤៦ |
| ការជួសជុល និងថែទាំ | ៣២២.៩១៧ | ១.៣១១.០៤៣ | ២៥៩.២៨៣ | ១.០៤៦.៩៨៥ |
| ការវាស់ស្ទង់ | ៣៩.៨៧១ | ១៦១.៨៧៦ | - | - |
| ផ្សេងៗ | ៤៨.៣៧៤ | ១៩៦.៣៩៩ | ១៨.៩៦៥ | ៧៦.៥៨១ |
| | ៥.៣៨៨.៥៨៥ | ២១.៨៧៧.៦៥៥ | ៥.៣១១.០៥៨ | ២១.៤៤៦.០៥២ |

កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥

## ១៦. ចំណូលផ្សេងៗ

| | ២០១៥ | | ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| ចំណូលពីការជួល | ២៥១.១៣១ | ១.០១៩.៥៩២ | ២២៥.២៧១ | ៩០៩.៦៤៥ |
| ផ្សេងៗ | ១០៩.១៥៤ | ៤៤៣.១៦៥ | ៧៦.០៦៥ | ៣០៧.១៥០ |
| | ៣៦០.២៨៥ | ១.៤៦២.៧៥៧ | ៣០១.៣៣៦ | ១.២១៦.៧៩៥ |

## ១៧. ចំណាយរដ្ឋបាលទូទៅ និងការលក់

| | ២០១៥ | | ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| ចំណាយប្រាក់បៀវត្សរ៍ និង ប្រាក់ឈ្នួល | ២.២៧១.០៥៣ | ៩.២២០.៤៧៥ | ១.៨៧១.៧៨៥ | ៧.៥៥៨.២៦៨ |
| ចំណាយរិភាគទាន | ២៩៩.៦៤២ | ១.២១៦.៥៤៧ | ៤៣២.១០៣ | ១.៧៤៤.៨៣២ |
| ទឹកភ្លើង និងប្រេងឥន្ធនៈ | ៣៧៥.៦០៩ | ១.៥២៤.៩៧៣ | ៣៩២.៦៦៧ | ១.៥៨៥.៥៨៩ |
| រំលស់លើទ្រព្យវិនិយោគ និង ទ្រព្យរោងចក្រ និងបរិក្ខារ | ៣៤២.៤៦៤ | ១.៣៩០.៤០៤ | ៣២២.៥៩៧ | ១.៣០២.៦៤៧ |
| ការជួសជុល និងថែទាំ | ១២៦.៦៣៦ | ៥១៤.១៤២ | ២៨១.៣១២ | ១.១៣៥.៩៣៨ |
| ចំណាយលើការកំសាន្ត | ២១៧.១៣០ | ៨៨១.៥៤៨ | ១៩៦.៦៣២ | ៧៩៤.០០០ |
| ការធ្វើដំណើរ | ១២១.៩៩៣ | ៤៩៥.២៩២ | ១១៩.០៦៥ | ៤៨០.៧៨៥ |
| ថ្លៃជំនាញវិជ្ជាជីវៈ | ២១.៩៥១ | ៨៩.១២១ | ៨៨.៥៥៧ | ៣៥៧.៥៩៣ |
| កម្រៃក្រុមប្រឹក្សាភិបាល | ១២៧.៤៨៩ | ៥១៧.៦០៥ | ៨២.៧៤៩ | ៣៣៤.១៩០ |
| សម្ភារផ្គត់ផ្គង់ការិយាល័យ | ១០៨.២១៦ | ៤៣៩.៣៥៧ | ៧៧.៥៥៨ | ៣១៣.១៧៩ |
| ទំនាក់ទំនងផ្សេងៗ | ៦៣.៣៩៤ | ២៥៧.៣៨០ | ៥៨.៥១៣ | ២៣៦.២៧៦ |
| ចំណាយពន្ធផ្សេងៗ | ២២៣.៣៦៦ | ៩០៦.៨៦៦ | ២៥.៩០២ | ១០៤.៥៩២ |
| ខាត/(ចំណេញ)ពីការប្តូររូបិយប័ណ្ណ | ១៤.៩៩៦ | ៦០.៨៨៤ | (២.០៩៤) | (៨.៤៥៦) |
| ផ្សេងៗ | ២៦៧.៥៦៧ | ១.០៨៦.៣២២ | ២៤០.៨៧០ | ៩៧២.៦៣៣ |
| | ៤.៥៨១.៥០៦ | ១៨.៦០០.៩១៦ | ៤.១៨៨.២១៦ | ១៦.៩១២.០១៦ |

កំណត់សំគាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥

## ១៨. ប្រតិបត្តិការ និងសមតុល្យជាមួយនឹងសម្ព័ន្ធញាតិ

### (ក) ប្រតិបត្តិការជាមួយសម្ព័ន្ធញាតិសារវន្ត

ក.ស.ភ មានប្រតិបត្តិការសំខាន់ៗជាមួយនឹងសម្ព័ន្ធញាតិនៅក្នុងការិយបរិច្ឆេទដូចខាងក្រោម៖

| | ២០១៥ | | ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ: | | | | |
| ចំណាយហិរញ្ញប្បទាន | ១.១៥៩.១៨៦ | ៤.៧០៦.២៩៥ | ១.១៥៩.១៨៥ | ៤.៦៨០.៧៨៩ |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន: | | | | |
| វិភាគទាន និងសប្បុរសធម៌ | ៦៦.១៤៩ | ២៦៨.៥៦៥ | ២៣១.២៧១ | ៩៣៣.៨៧២ |
| ជាមួយក្រុមប្រឹក្សាភិបាល: | | | | |
| លាភការរបស់ ក្រុមប្រឹក្សាភិបាល | ១២៧.៤៨៩ | ៥១៧.៦០៥ | ៩៣.២០០ | ៣៧៦.៣៤០ |

### (ខ) សមតុល្យជាមួយនឹងសម្ព័ន្ធញាតិសារវន្ត

| | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ | | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| គណនីត្រូវទទួលពីសម្ព័ន្ធញាតិ ក្រសួងសាធារណការនិង ដឹកជញ្ជូន | ៥៣.៣៨០ | ២១៦.៧២២ | - | - |
| ប្រាក់កម្ចីពី Eximbank តាមរយៈ: | | | | |
| ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ២៨.៩៧៩.៦៣៧ | ១១៧.៦៥៧.៣២៦ | ២៨.៩៧៩.៦៣៧ | ១១៧.០១៩.៧៧៤ |
| ការប្រាក់លើប្រាក់កម្ចី | ៤៤១.៤២២ | ១.៧៩២.១៧៣ | ៤១៨.៥៩៥ | ១.៦៩០.២៨៧ |
| | ២៩.៤២១.០៥៩ | ១១៩.៤៤៩.៤៩៩ | ២៩.៣៩៨.២៣២ | ១១៨.៧១០.០៦១ |

គណនីត្រូវទទួលពីឲ្យសម្ព័ន្ធញាតិពុំមានវត្ថុបញ្ចាំ គ្មានការប្រាក់ និងឲ្យទូទាត់សងតាមតម្រូវការ ។ លក្ខខណ្ឌរបស់ កម្ចីគឺបានបង្ហាញក្នុងកំណត់សំគាល់ ១០ ។

# ១៩. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ

## (ក) គោលបំណង និងគោលការណ៍

ហានិភ័យឥណទាន ហានិភ័យរូបិយវត្ថុ និងហានិភ័យសាច់ប្រាក់ងាយស្រួលកើតឡើងជាធម្មតានៅក្នុងដំណើរការអាជីវកម្មរបស់ ក.ស.ភ ។ ហានិភ័យទាំងនេះ ត្រូវបានគ្រប់គ្រងដោយគោលនយោបាយ និងការអនុវត្តលើការគ្រប់គ្រងហិរញ្ញវត្ថុរបស់ ក.ស.ភ ដូចបានចែងខាងក្រោម ។

## (ខ) ហានិភ័យឥណទាន

ហានិភ័យឥណទានដៃគូពាណិជ្ជកម្ម គឺជាហានិភ័យនៃការខាតបង់(កើតឡើង ឬមិនទាន់កើតឡើង) ដែលកើតដោយសារដៃគូពាណិជ្ជកម្ម មិនបំពេញតាមកាតព្វកិច្ចដែលមានចែងនៅក្នុងកិច្ចសន្យា ។ ឧបករណ៍ហិរញ្ញវត្ថុដែលមានសក្តានុពលដល់ហានិភ័យឥណទានរបស់ ក.ស.ភ គឺសមតុល្យធនាគារ និងគណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ ។

### (i) ការប្រឈមនឹងហានិភ័យឥណទាន

តម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាការប្រឈមនឹងហានិភ័យឥណទានជាអតិបរមា ។ ការប្រឈមនឹងហានិភ័យឥណទានអតិបរមារបស់ ក.ស.ភ នាកាលបរិច្ឆេទរាយការណ៍ដូចខាងក្រោម៖

| | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ | | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| គណនីអតិថិជន | ១.៨៨០.៥៤៧ | ៧.៦៣៥.០២១ | ១.១៣៥.៩០៨ | ៤.៥៨៦.៧៩៧ |
| គណនីត្រូវទទួលផ្សេងៗ | ៨៥៤.៨៦៥ | ៣.៤៧០.៧៥២ | ១៨០.០១៣ | ៧២៦.៨៩១ |
| សមតុល្យធនាគារ | ៨.៧៤៥.៥៧៩ | ៣៥.៥០៧.០៥០ | ១.៨១៧.៣៣៣ | ៧.៣៣៨.៣៩១ |
| | ១១.៤៨០.៩៩១ | ៤៦.៦១២.៨២៣ | ៣.១៣៣.២៥៤ | ១២.៦៥២.០៧៩ |

តារាងខាងលើនេះបង្ហាញពីស្ថានភាពអាក្រក់បំផុតនៃហានិភ័យឥណទានរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ និង ២០១៤ ដោយមិនគិតលើវត្ថុបញ្ចាំ ឬការពង្រឹងឥណទានផ្សេងៗ ។

# ១៩. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

## (ខ) ហានិភ័យឥណទាន (ត)

### (i) ការប្រឈមនិងហានិភ័យឥណទាន (ត)

***គណនីអតិថិជន***

| | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ | | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| មិនហួសកាលកំណត់ និង មិនថយចុះតម្លៃ | ១៥៩.៨៥៧ | ៦៤៩.០២១ | ១.០៥៥.២៤៥ | ៤.២៦១.០៧៩ |
| ហួសកាលកំណត់ប៉ុន្តែ មិនថយចុះតម្លៃ | ១.៧២០.៦៩០ | ៦.៩៨៦.០០០ | ៨០.៦៦៣ | ៣២៥.៧១៨ |
| | ១.៨៨០.៥៤៧ | ៧.៦៣៥.០២១ | ១.១៣៥.៩០៨ | ៤.៥៨៦.៧៩៧ |

*មិនហួសកាលកំណត់ និងមិនថយចុះតម្លៃ*

គណនីអតិថិជនដែលមិនហួសកាលកំណត់ និងមិនថយចុះតម្លៃ គឺជាឥណទានទៅឲ្យអតិថិជនដែលគ្មានបទពិសោធន៍ខិនភាព ហើយអ្នកគ្រប់គ្រងយល់ឃើញថា និន្នាការនៃខិនភាពគឺមានកម្រិតទាប ។

*ហួសកាលកំណត់ប៉ុន្តែមិនថយចុះតម្លៃ*

គណនីត្រូវទទួលដែលហួសកាលកំណត់ប៉ុន្តែមិនថយចុះតម្លៃ គឺជាការបង់តាមកិច្ចសន្យាតែបានលើសការកំណត់ប៉ុន្តែនៅមានសកម្មភាពជាមួយក្រុមហ៊ុន និងរំពឹងថានឹងបង់សងវិញគ្រប់ចំនួន ។

| | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ | | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| ជំពាក់លើសពី ១ - ៣០ ថ្ងៃ | ៥៧៤.៩៨៨ | ២.៣៣៤.៤៥១ | ៩.៣៧២ | ៣៧.៨៤៤ |
| ជំពាក់លើសពី ៣០ - ៦០ ថ្ងៃ | ៤៦៨.០៣៧ | ១.៩០០.២៣២ | ១៧.៤៤៣ | ៧០.៤៣៥ |
| ជំពាក់លើសពី ៦០ - ៩០ ថ្ងៃ | ១៧៣.៧៥០ | ៧០៥.៤២៥ | (១៦៣) | (៦៥៨) |
| ជំពាក់លើសពី ៩០ ថ្ងៃ | ៥០៣.៩១៥ | ២.០៤៥.៨៩២ | ៥៤.០១១ | ២១៨.០៩៧ |
| | ១.៧២០.៦៩០ | ៦.៩៨៦.០០០ | ៨០.៦៦៣ | ៣២៥.៧១៨ |

## ១៩. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### (ខ) ហានិភ័យឥណទាន (ត)

#### (i) ការប្រឈមនិងហានិភ័យឥណទាន (ត)

*សមតុល្យធនាគារ*

ក្រុមហ៊ុនបានដាក់ប្រាក់បញ្ញើរយៈពេលខ្លីនៅធនាគារផ្សេងៗ ដែលបណ្តាលឲ្យមានហានិភ័យឥណទាន ។ ក្រុមហ៊ុនគ្រប់គ្រងហានិភ័យដោយធ្វើការត្រួតពិនិត្យតាមដាន (Due Diligence) ភាគីនីមួយៗ ហើយធ្វើការកម្រិត និងបែងចែកប្រាក់បញ្ញើនៅធនាគារផ្សេងៗគ្នា ។ អ្នកគ្រប់គ្រងមានទស្សនៈថា ភវនីយភាពនៃការខកខានមិនបានសងបំណុល ស្ថិតក្នុងកម្រិតមួយដ៏ទាប ។

### (គ) ហានិភ័យរូបិយប័ណ្ណបរទេស

ចំណូលជាចម្បងរបស់ក្រុមហ៊ុន ជាប្រាក់ដុល្លារអាមេរិក ។ ហើយការចំណាយជាចម្បងរបស់ក្រុមហ៊ុនបង់ជាប្រាក់ដុល្លារអាមេរិក ។ ដូច្នេះក្រុមហ៊ុនមិនមានការប្រឈមនឹងហានិភ័យរូបិយប័ណ្ណបរទេសទេ ។

### (ឃ) ហានិភ័យសាច់ប្រាក់ងាយស្រួល

ក.ស.ភ គ្រប់គ្រងនូវហានិភ័យសាច់ប្រាក់ងាយស្រួល និងរក្សានូវកម្រិតសាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅកម្រិតសមស្របមួយដែល ក.ស.ភ គិតថាគ្រប់គ្រាន់ក្នុងការទ្រទ្រង់ប្រតិបត្តិការរបស់ ក.ស.ភ និងដើម្បីសម្រួលនូវផលប៉ះពាល់នៃបម្រែបម្រួលលំហូរទឹកប្រាក់ ។

## ១៩. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### (ឃ) ហានិភ័យសាច់ប្រាក់ងាយស្រួល (ត)

ខាងក្រោមនេះ បង្ហាញនូវកាតព្វកិច្ចលើបំណុលហិរញ្ញវត្ថុទៅតាមកាលវសាន ដែលរួមបញ្ចូលផងដែរនូវការទូទាត់ការប្រាក់៖

| នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៥ | តម្លៃយោង ដុល្លារអាមេរិក | គ្មានការបញ្ចុះតម្លៃលំហូរទឹកប្រាក់ ដុល្លារអាមេរិក | ៦ ខែឬតិចជាង ដុល្លារអាមេរិក | ៦-១២ ខែ ដុល្លារអាមេរិក | ច្រើនជាង ១ ឆ្នាំ ដុល្លារអាមេរិក |
|---|---|---|---|---|---|
| ប្រាក់កម្ចី | ២៨.៩៧៩.៦៣៧ | ៥៤.២៧៨.៣១៧ | - | - | ៥៤.២៧៨.៣១៧ |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីបំណុលផ្សេងៗ | ១.៤៧៨.២១៨ | ១.៤៧៨.២១៨ | ១.៤១៦.៩៤១ | ៦១.២៧៧ | - |
| | ៣០.៤៥៧.៨៥៥ | ៥៥.៧៥៦.៥៣៥ | ១.៤១៦.៩៤១ | ៦១.២៧៧ | ៥៤.២៧៨.៣១៧ |
| **ស្មើនឹងពាន់រៀល**(កំណត់សំគាល់ ៤) | ១២៣.៦៥៨.៨៩១ | ២២៦.៣៧១.៥៣១ | ៥.៧៥២.៧៨០ | ២៤៨.៧៨៥ | ២២០.៣៦៩.៩៦៥ |

| នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៤ | តម្លៃយោង ដុល្លារអាមេរិក | គ្មានការបញ្ចុះតម្លៃលំហូរទឹកប្រាក់ ដុល្លារអាមេរិក | ៦ ខែឬតិចជាង ដុល្លារអាមេរិក | ៦-១២ ខែ ដុល្លារអាមេរិក | ច្រើនជាង ១ ឆ្នាំ ដុល្លារអាមេរិក |
|---|---|---|---|---|---|
| ប្រាក់កម្ចី | ២៨.៩៧៩.៦៣៧ | ៥៦.៤៤៩.៤៤៩ | - | - | ៥៦.៤៤៩.៤៤៩ |
| គណនីអ្នកផ្គត់ផ្គង់ និងគណនីបំណុលផ្សេងៗ | ១.៣៣៤.៥១៣ | ១.៣៣៤.៥១៣ | ១.២៧០.៦១៤ | ៦៣.៨៩៩ | - |
| | ៣០.៣១៤.១៥០ | ៥៧.៧៨៣.៩៦២ | ១.២៧០.៦១៤ | ៦៣.៨៩៩ | ៥៦.៤៤៩.៤៤៩ |
| **ស្មើនឹងពាន់រៀល**(កំណត់សំគាល់ ៤) | ១២២.៤០៨.៥៣៨ | ២៣៣.៣៣១.៦៤០ | ៥.១៣០.៧៣៩ | ២៥៨.០២៤ | ២២៧.៩៤២.៨៧៦ |

## ១៩. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### (ង) ហានិភ័យអត្រាការប្រាក់

ការប្រឈមទៅនឹងហានិភ័យអត្រាការប្រាក់របស់ ក.ស.ភ ពាក់ព័ន្ធទៅនឹងទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុដែលមានការប្រាក់ ។

*ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការប្រាក់*

ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការប្រាក់ រួមមាន សាច់ប្រាក់ក្នុងធានាគារ - គណនីសន្សំ ។

*បំណុលហិរញ្ញវត្ថុដែលមានការប្រាក់*

បំណុលហិរញ្ញវត្ថុដែលមានការប្រាក់រួមមានប្រាក់កម្ចី ។

ក.ស.ភ បានគ្រប់គ្រងលើហានិភ័យអត្រាការប្រាក់ ដោយត្រួតពិនិត្យលើផលប៉ះពាល់ដែលបណ្តាលមកពីហានិភ័យការប្រាក់ជាប្រចាំ ។ អ្នកគ្រប់គ្រងពុំបានធ្វើប្រតិបត្តិការទាក់ទងទៅនឹងការទិញទុកនូវហានិភ័យអត្រាការប្រាក់នេះទេ ដោយយល់ឃើញថា ចំណាយលើការទិញនូវឧបករណ៍ហិរញ្ញវត្ថុទាំងនោះមានចំនួនលើសពីហានិភ័យនៃការផ្លាស់ប្តូរអត្រាការប្រាក់ដែលអាចកើតមានឡើង ។

នាការិយបរិច្ឆេទនេះ ទម្រង់នៃឧបករណ៍ហិរញ្ញវត្ថុអត្រាការប្រាក់ មានដូចខាងក្រោម៖

| | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ | | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| **អត្រាការប្រាក់ថេរ** | | | | |
| បំណុលហិរញ្ញវត្ថុ | ២៨.៩៧៩.៦៣៧ | ១១៧.៦៥៧.៣២៦ | ២៨.៩៧៩.៦៣៧ | ១១៧.០១៩.៧៧៤ |
| ទ្រព្យសកម្មហិរញ្ញវត្ថុ | ២.៣៨៩.៨៣៨ | ៩.៧០២.៧៤២ | ៩.៥៤៦ | ៣៨.៥៤៨ |

*ការវិភាគរំញោចតម្លៃសមស្របសម្រាប់ឧបករណ៍ហិរញ្ញវត្ថុដែលមានអត្រាការប្រាក់ថេរ*

ក.ស.ភ មិនបានកត់ត្រាបំណុលហិរញ្ញវត្ថុដែលមានអត្រាការប្រាក់ថេរតាមតម្លៃសមស្រម ដោយភាពលំអៀង ត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍លទ្ធផលនោះទេ ហើយ ក.ស.ភ ក៏មិនមានឧបករណ៍និស្សន្ទហិរញ្ញវត្ថុ នាចុងការិយបរិច្ឆេទនោះដែរ ។ ដូច្នេះការផ្លាស់ប្តូរអត្រាការប្រាក់នាចុងការិយបរិច្ឆេទពុំមានផលប៉ះពាល់ដល់ប្រាក់ចំណេញ ឬខាតនោះទេ ។

## ១៩. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (ត)

### (ច) តម្លៃសមស្របនៃទ្រព្យសកម្ម និងបំណុល

តម្លៃសមស្របបង្ហាញពីចំនួនទឹកប្រាក់ដែលទ្រព្យសកម្មអាចត្រូវបានគេផ្លាស់ប្តូរ ឬក៏ការកាត់កងបំណុលតាមតម្លៃសមស្របជាក់ស្តែង។ ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានបែងចែកជាកម្រិត ៣ នូវតម្លៃសមស្រប និងមិនត្រូវបានវាស់វែងតាមតម្លៃសមស្របឡើយ ។

| | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ | | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤ | |
|---|---|---|---|---|
| | តម្លៃយោង | តម្លៃសមស្រប | តម្លៃយោង | តម្លៃសមស្រប |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| គណនីអតិថិជន និងគណនី ត្រូវទទួលផ្សេងៗ | ២.៧៣៥.៩១២ | ២.៧៣៥.៩១២ | ១.៣១៥.៩២១ | ១.៣១៥.៩២១ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ៨.៧៤៩.២២១ | ៨.៧៤៩.២២១ | ១.៨២០.៩១០ | ១.៨២០.៩១០ |
| **ទ្រព្យសកម្មហិរញ្ញវត្ថុសរុប** | ១១.៤៨៤.៦៣៣ | ១១.៤៨៤.៦៣៣ | ៣.១៣៦.៨៣១ | ៣.១៣៦.៨៣១ |
| **បំណុលហិរញ្ញវត្ថុ** | | | | |
| ប្រាក់កម្ចី | ២៨.៩៧៩.៦៣៧ | ២៨.៩៧៩.៦៣៧ | ២៨.៩៧៩.៦៣៧ | ២៨.៩៧៩.៦៣៧ |
| គណនីអ្នកផ្គត់ផ្គង់ និង គណនីបំណុលផ្សេងៗ | ១.៤៧៨.២១៨ | ១.៤៧៨.២១៨ | ១.៣៣៤.៥១៣ | ១.៣៣៤.៥១៣ |
| **បំណុលហិរញ្ញវត្ថុសរុប** | ៣០.៤៥៧.៨៥៥ | ៣០.៤៥៧.៨៥៥ | ៣០.៣១៤.១៥០ | ៣០.៣១៤.១៥០ |

**ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុរយៈពេលខ្លី-គណនីអតិថិជន និងគណនីត្រូវទទួលផ្សេងៗ សាច់ប្រាក់ និងសាច់ប្រាក់សមមូល**

ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុរយៈពេលខ្លីត្រូវបានវាស់វែងដោយរំលស់តម្លៃដើម ។ ការប៉ាន់ស្មានតម្លៃសមស្របគឺប្រហាក់ប្រហែលស្មើនឹងតម្លៃយោងដោយសារតែការកំណត់មានរយៈពេលខ្លី ។

**ប្រាក់កម្ចី**

ប្រាក់កម្ចីតម្លៃសមស្របត្រូវបានកំណត់ដោយមូលដ្ឋាននៃអប្បហាលំហូរទឹកប្រាក់ ។ ប៉ុន្តែពុំមានទីផ្សារតម្លៃសមស្រប ដូច្នេះប្រាក់កម្ចីត្រូវបានកំណត់ដោយការសន្មតរបស់អ្នកគ្រប់គ្រង ។ តាមមតិរបស់អ្នកគ្រប់គ្រងតម្លៃយោងនៃប្រាក់កម្ចីនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុមានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្រប ។

## ២០. ការសន្យាភតិសន្យា

ក្រុមហ៊ុនមានការសន្យាដែលទាក់ទិននឹងចំណាយលើការជួលដូចខាងក្រោមនេះ៖

| | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៥ | | ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សំគាល់ ៤) |
| ក្នុងរយៈពេល ១ ឆ្នាំ | ៥៦.៩៣២ | ២៣១.១៩៤ | ២៥.៥៦០ | ១០៣.២១១ |
| ក្នុងរយៈពេល ២ ទៅ ៣ ឆ្នាំ | ១១១.៥២៨ | ៤៥២.៨០៤ | ១.១៦៨ | ៤.៧១៦ |
| | ១៦៨.៤៦០ | ៦៨៣.៩៩៨ | ២៦.៧២៨ | ១០៧.៩២៧ |

## ២១. យថាភាពលើពន្ធ

ប្រព័ន្ធពន្ធដារនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានលក្ខណៈថ្មី ហើយពន្ធទាំងនេះតែងតែមានការផ្លាស់ប្តូរជាញឹកញាប់ហើយតែងតែមានភាពមិនច្បាស់លាស់ ភាពផ្ទុយគ្នា និងស្ថិតនៅក្រោមបំណកស្រាយបំភ្លឺ ។ ជាទូទៅតែងតែកើតឡើងនូវភាពខុសគ្នាចំពោះការបកស្រាយបំភ្លឺក្នុងចំណោមអាជ្ញាធរពន្ធដារ និងយុត្តាធិការ ។ ពន្ធត្រូវស្ថិតក្រោមការត្រួតពិនិត្យ និងធ្វើការតាមដានអង្កេត ដោយក្រុមអាជ្ញាធរជាច្រើនដែលអាចផ្តល់នូវលទ្ធភាពតាមច្បាប់ក្នុងការដាក់ពិន័យ ដាក់ទណ្ឌកម្ម និងបង់ការប្រាក់ ។

បញ្ហាជាក់ស្តែងទាំងនេះ អាចនឹងបង្កើតឲ្យមានហានិភ័យពន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានលក្ខណៈធំជុំជាងនៅប្រទេសដទៃទៀត ។ អ្នកគ្រប់គ្រងជឿជាក់ថា ការធ្វើសំវិធានធនមានលក្ខណៈសមរម្យគ្រប់គ្រាន់ ដោយផ្អែកលើការបកស្រាយនៃនីតិកម្មពន្ធ ។ ក៏ប៉ុន្តែ អាជ្ញាធរពាក់ព័ន្ធអាចនឹងមានបំណកស្រាយខុសគ្នា ហើយផលប៉ះពាល់អាចនឹងមានទំហំធំ ។

## ២២. ប្រាក់ចំណេញក្នុងមួយហ៊ុន

### (i). ចំណេញមូលដ្ឋានក្នុងមួយភាគហ៊ុន

ចំណេញមូលដ្ឋានក្នុងមួយភាគហ៊ុនត្រូវបានគណនាឡើងដោយផ្អែកលើ ប្រាក់ចំណេញដែលអាចចែកចាយឲ្យភាគទុនិកធម្មតា ចែកនឹងមធ្យមទម្ងន់នៃចំនួនហ៊ុនដែលមាន ។

| | ឆ្នាំ ២០១៥ ដុល្លារអាមេរិក | ឆ្នាំ ២០១៥ ពាន់រៀល (កំណត់សំគាល់ ៤) |
|---|---|---|
| ប្រាក់ចំណេញដែលអាចចែកចាយឲ្យភាគទុនិក | ៣.១៨៣.២២១ | ១២.៩២៣.៨៧៧ |
| មធ្យមទម្ងន់នៃចំនួនហ៊ុន | ១៦.៨០០.៣០១ | ១៦.៨០០.៣០១ |
| | ០.១៩ | ០.៧៧ |

មធ្យមទម្ងន់នៃចំនួនហ៊ុន រួមបញ្ចូលភាគហ៊ុន ដែលបានបោះផ្សាយកំឡុងពេលដំណើរការលក់មូលបត្រជាសាធារណៈលើកដំបូង ទោះបីជាភាគហ៊ុនទាំងនោះមិនទាន់បានចុះបញ្ជីជាមួយក្រសួងពាណិជ្ជកម្មក៏ដោយ ។ ភាគហ៊ុនប្រភេទ (គ) មិនត្រូវបានរួមបញ្ចូលនោះទេ ។

### (ii). ចំណេញក្នុងមួយសន្លឹកហ៊ុនថយចុះ

ចំណេញក្នុងមួយសន្លឹកហ៊ុនថយចុះត្រូវបានគណនាឡើងដោយផ្អែកលើ ប្រាក់ចំណេញដែលអាចចែកចាយឲ្យភាគទុនិកធម្មតា ចែកនឹងមធ្យមទម្ងន់នៃចំនួនហ៊ុនដែលមាន បន្ទាប់ពីការកែតម្រូវនូវផលប៉ះពាល់ នៃរាល់ភាគហ៊ុនធម្មតាដែលមានសក្តានុពលថយចុះ ។ គិតត្រឹមកាលបរិច្ឆេទរាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ក.ស.ភ មិនមានភាគហ៊ុនធម្មតាដែលមានសក្តានុពលថយចុះនោះទេ ។ ដូចនេះ ចំណេញក្នុងមួយសន្លឹកហ៊ុនថយចុះ គឺមានតម្លៃស្មើនឹងចំណេញមូលដ្ឋានក្នុងមួយភាគហ៊ុន។

## ផ្នែកទី ៨ : ព័ត៌មានអំពីប្រតិបត្តិការជាមួយភាគីជាប់ពាក់ព័ន្ធ

### ១- ប្រតិបត្តិការជាមួយភាគហ៊ុនិក

ក.ស.ភ. បានទទួលកម្ចីឥណទានចំនួន ២៨,៩ លានដុល្លារអាមេរិកក្នុងអត្រាការប្រាក់ ៩% ក្នុងមួយឆ្នាំពីធនាគារ **Export-Import Bank of China** នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ កម្ចីនេះមានរយៈពេលអនុគ្រោះលើប្រាក់ដើមចំនួន ៧ឆ្នាំ ៣ខែ និង១៦ថ្ងៃ ដោយចាប់ផ្តើមពីថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១០។ ចាប់ពីខែកុម្ភៈ ឆ្នាំ២០១៤ រហូតដល់ខែសីហា ឆ្នាំ២០១៧ ក.ស.ភ. ត្រូវធ្វើការបង់ការប្រាក់ពាក់កណ្តាលឆ្នាំក្នុងទឹកប្រាក់ ៥៤៩.០៤៨,៣២ដុល្លារអាមេរិក។ ចាប់ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០៣១ ក.ស.ភ. ត្រូវធ្វើការបង់ប្រាក់ដើម រួមជាមួយនឹងការប្រាក់នៅពាក់កណ្តាលឆ្នាំនីមួយៗនៃឆ្នាំសារពើពន្ធ នៅថ្ងៃទី២០ ខែកុម្ភៈ និងខែសីហា។

ក.ស.ភ. ទទួលអំណោយជាដីពីរដ្ឋ ដែលមានបណ្ណសម្គាល់ម្ចាស់កម្មសិទ្ធិអចលនវត្ថុដូចខាងក្រោម៖

- ចំណតផែTS៣ មានប្លង់កម្មសិទ្ធិលេខ ១២០២១០១២-០០១២ លេខ ១២០២១០១៥-០០៣៧ លេខ ១២០២១០១៤-០០៨៨ និងលេខ ១២០២១០១៣-០០៣៣
- ចំណតស្តុកកុងតឺន័រ ICD មានប្លង់កម្មសិទ្ធិលេខ ភព ០៦២៩០
- ភ្នំមសំណារ មានប្លង់កម្មសិទ្ធិលេខ ក.ណ ០១៩៨១០
- កោះរកា មានប្លង់កម្មសិទ្ធិលេខ ព.រ ០០៩០៣០ និងព.រ ០០៩០៣១
- ចំណតផែកុងតឺន័រ LM១៧ មានប្លង់កម្មសិទ្ធិលេខ ក.ណ ០១៩៦៧១-៦៨១ និង០១៩៦៨៣-៦៨៦
- ចំណតផែអ្នកដំណើរ និងទេសចរ មានប្លង់កម្មសិទ្ធិលេខ ១២០២១១០៨-០០៩២ និងលេខ ១២០២១១០៩-០០៩៩។

### ២- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាល ឬបុគ្គលិកជាន់ខ្ពស់ ឬប្រតិបត្តិការសំខាន់ៗ ជាមួយបុគ្គលដែលអភិបាល ឬបុគ្គលិកជាន់ខ្ពស់មានផលប្រយោជន៍

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ ក.ស.ភ. ទេ។

### ៣- ប្រតិបត្តិការសំខាន់ៗជាមួយសមាជិកគ្រួសារផ្ទាល់របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ ក.ស.ភ. ទេ។

### ៤- ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលដែលមានទំនាក់ទំនងជាមួយអភិបាលរបស់កំពង់ផែស្វយ័តភ្នំពេញ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬក្រុមហ៊ុនមេរបស់កំពង់ផែស្វយ័តភ្នំពេញ ដែលទំនាក់ទំនងរបស់បុគ្គលទាំងនោះកើតមាននៅក្នុងប្រតិបត្តិការ ឬការចាត់ចែងណាមួយដែលធ្វើឡើងដោយកំពង់ផែស្វយ័តភ្នំពេញ

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ ក.ស.ភ. ទេ។

### ៥- ប្រតិបត្តិការសំខាន់ៗជាមួយបុគ្គលធ្លាប់ជាអភិបាល ឬបុគ្គលជាប់ពាក់ព័ន្ធជាមួយបុគ្គលធ្លាប់ជាអភិបាលក្នុងរយៈពេល ០២ (ពីរ) ឆ្នាំចុងក្រោយ

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ ក.ស.ភ. ទេ។

**៦- ប្រតិបត្តិការសំខាន់ៗជាមួយអភិបាលដែលទទួលបានផលប្រយោជន៍ ឬកម្រៃវិជ្ជាជីវៈ សម្រាប់សេវាដែលខ្លួនបានផ្តល់តាមរយៈក្រុមហ៊ុនណាមួយដល់កំពង់ផែស្វយ័តភ្នំពេញ**

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ ក.ស.ភ. ទេ។

**៧- ប្រតិបត្តិការសំខាន់ៗជាមួយភាគីជាប់ពាក់ព័ន្ធផ្សេងទៀត**

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ពុំមានប្រតិបត្តិការប្រភេទនេះកើតឡើងចំពោះ ក.ស.ភ. ទេ។

## ផ្នែកទី ៩ : ការពិភាក្សា និងការវិភាគរបស់ថ្នាក់ដឹកនាំ

### ១- និន្នាការទូទៅនៃប្រតិបត្តិការ

ក.ស.ភ. គឺជាកំពង់ផែអន្តរជាតិមួយក្នុងចំណោមកំពង់ផែអន្តរជាតិទាំងពីរក្នុងប្រទេសកម្ពុជា។ ក.ស.ភ. មានមណ្ឌលអាជីវកម្ម លាតសន្ធឹងពីភ្នំពេញដល់ទន្លេមេគង្គក្រោម (អ្នកលឿង) និងពីភ្នំពេញ ដល់ទន្លេមេគង្គលើ (ទន្លេបិទ) ដែលកំណត់ក្នុងអនុក្រឹត្យលេខ០១ ចុះថ្ងៃទី៥ ខែមករា ឆ្នាំ២០០៩។ ក.ស.ភ. មានមុខងារជាអាជ្ញាធរ និងជាប្រតិបត្តិករផែ ដូចមានលម្អិតក្នុងផ្នែក១ ចំណុចទី២ នៃរបាយការណ៍ប្រចាំឆ្នាំនេះ។

បរិមាណកុងតឺន័រឆ្លងកាត់ ក.ស.ភ. មានការកើនឡើងខ្លាំងក្នុងរយៈពេល ៣ ឆ្នាំចុងក្រោយនេះ ពីចំនួន១១០.៥០០ TEUs ក្នុងឆ្នាំ២០១៣ ដល់ចំនួន ១៤៩.៨១៣ TEUs ក្នុងឆ្នាំ២០១៥។ បើគិតជាអត្រាកំណើនជាមធ្យមប្រចាំឆ្នាំ (CAGR) គឺមានចំនួន ១៤,៨៨% ក្នុងមួយឆ្នាំៗ។

ការពិភាក្សា និងការវិភាគរបស់ថ្នាក់ដឹកនាំលើស្ថានភាពហិរញ្ញវត្ថុរបស់ ក.ស.ភ. និងលទ្ធផលប្រតិបត្តិការខាងក្រោមនេះ ធ្វើឡើងផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុ ដែលត្រូវបានធ្វើសវនកម្មរួចសម្រាប់ឆ្នាំ២០១៤ និងឆ្នាំ២០១៥ (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ) ដូចបង្ហាញក្នុងផ្នែកទី៧ នៃរបាយការណ៍ប្រចាំឆ្នាំនេះ។

ក.ស.ភ. មានប្រភពចំណូលសំខាន់ៗចំនួន ៥ ប្រភេទ៖

**១. ចំណូលពីការលើកដាក់ក្រោមដងយោង (Stevedore)**៖ សំដៅលើចំណូលដែលបានមកពីសេវាកម្មផ្ទេរ-ផ្ទុកទំនិញ/កុងតឺន័រពីនាវា និងដឹកជញ្ជូនពីស្ពានផែទៅទីលាន និងពីទីលានមកស្ពានផែ។

**២. ចំណូលពីការលើកដាក់លើទីលាន (LOLO)**៖ សំដៅលើចំណូលដែលបានមកពីសេវាកម្មលើកដាក់ទំនិញ/កុងតឺន័រ ពីទីលានដាក់លើរថយន្ត និងពីរថយន្តដាក់លើទីលាន។

**៣. ចំណូលពីកិច្ចការផែ (Port Due & Charge)**៖ សំដៅលើចំណូលដែលបានមកពីសេវាកម្មនាវាចរណ៍ និងការចូលចតនាវា រួមមាន ពន្ធលើចំណុះផ្ទុក ពន្ធសំចត ពន្ធប្រឡាយ ថ្លៃឈ្នួលកណ្តាលធារកិច្ច ថ្លៃឈ្នួលនាវាសណ្តោង ថ្លៃឈ្នួលពាក់-ដោះពួរ ថ្លៃឈ្នួលបើក-បិទឃ្លប់នាវា និងថ្លៃឈ្នួលបោសសម្អាតឃ្លប់នាវា។

**៤. ចំណូលពីថ្លៃឈ្នួលស្តុកទំនិញ/កុងតឺន័រ (Storage Fee)**៖ សំដៅលើចំណូលដែលបានមកពីការស្តុកទំនិញ/កុងតឺន័រ នៅលើទីលាន ឬក្នុងឃ្លាំង។ ទំនិញរាយ មានការអនុគ្រោះថ្លៃស្តុក ៥ថ្ងៃ ទាំងនាំចេញ និងនាំចូល និងទំនិញជាកុងតឺន័រ មានការអនុគ្រោះថ្លៃស្តុក ៥ថ្ងៃ សម្រាប់ការនាំចេញ និង៧ថ្ងៃ សម្រាប់ការនាំចូល។

**៥. ចំណូលពីថ្លៃឈ្នួលគ្រប់គ្រងអាជីវកម្មខ្សាច់ (Sand Dredging of Navigation Channel)**៖ សំដៅដល់ចំណូលដែលបានមកពីសេវាកម្មគ្រប់គ្រងអាជីវកម្មខ្សាច់ (ប្រឡាយនាវាចរណ៍)។

## ក- ការវិភាគចំណូល

### ក.១. ការវិភាគចំណូលសរុប

**<u>ដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ប្រៀបធៀបនឹងដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥</u>**

| បរិយាយ | ៣១ ធ្នូ ២០១៤ | | ៣១ ធ្នូ ២០១៥ | | បំរែបំរួល | | បំរែបំរួល | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | % | ពាន់រៀល | % |
| ចំណូល | ១៣.២៩២.២៥៥ | ៥៣.៦៧៤.១២៦ | ១៥.១៣៧.៤៨៤ | ៦១.៤៥៨.១៨៦ | ១.៨៤៥.២២៩ | ១៣,៨៤% | ៧.៧៨៤.០៦០ | ១៤,៥០% |

ចំណូលបានកើនឡើងចំនួន ៧.៧៨៤.០៦០.០០០រៀល (១.៨៤៥.២២៩ ដុល្លារអាមេរិក) ពី៥៣.៦៧៤.១២៦.០០០រៀល (១៣.២៩២.២៥៥ ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៤ ដល់ ៦១.៤៥៨.១៨៦.០០០រៀល (១៥.១៣៧.៤៨៤ ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៥ ឬស្មើនឹងអត្រាកំណើន ១៤,៥០%។ ការកើនឡើងចំណូលនេះ គឺមកពីកំណើននៃចំនួនកុងតឺន័រ សរុបពី១៣៣.៦៦៦TEUs ក្នុងឆ្នាំ២០១៤ ទៅ១៤៤.៨១៣ TEUs ក្នុងឆ្នាំ២០១៥ គឺស្មើ ៨,៣៩%។ កត្តានេះនាំឱ្យមានកំណើននៃសកម្មភាពលើកដាក់ក្រោមដងយោង (Stevedore) សេវាកម្មលើកដាក់នៅលើទីលាន (LOLO) និងចំណូលកិច្ចការផែ (Port Due & Charge)។

នៅខែមេសា ឆ្នាំ២០១៥ ក.ស.ភ. ទទួលបានការអនុញ្ញាតបូមខ្សាច់ ដែលត្រូវបានចាត់ចែងបន្តទៅឱ្យភាគីទីបីធ្វើប្រតិបត្តិការ ហើយជាលទ្ធផលគិតមកដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ការបូមខ្សាច់ ធ្វើបានចំនួន ៧.៤៩២.៦៩០ម៉ែត្រត្រីគុណ គិតជាទឹកប្រាក់ចំនួន ២.៩១៧.១៦៧.០០០រៀល (៧១៨.៥១៤ ដុល្លារអាមេរិក) ឬស្មើនឹង ៤,៧៥% នៃបរិមាណប្រាក់ចំណូលសរុប។ កម្រៃពីថ្លៃឈ្នួលគ្រប់គ្រងអាជីវកម្មខ្សាច់នេះ គឺជាប្រភពចំណូលមួយផ្សេងទៀត ធ្វើឱ្យមានការកើនឡើងនូវ ចំណូលសរុប ឆ្នាំ២០១៥ ។

**<u>ដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ប្រៀបធៀបនឹងដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤</u>**

| បរិយាយ | ៣១ ធ្នូ ២០១៣ | | ៣១ ធ្នូ ២០១៤ | | បំរែបំរួល | | បំរែបំរួល | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | % | ពាន់រៀល | % |
| ចំណូល | ១១.៤០២.៧៦៣ | ៤៥.៩១៨.៩២៦ | ១៣.២៩២.២៥៥ | ៥៣.៦៧៤.១២៦ | ១.៨៨៩.៤៩២ | ១៦,៥៧% | ៧.៧៥៥.២០០ | ១៦,៨៩% |

ចំណូលសរុបបានកើនឡើងចំនួន ៧.៧៥៥.២០០ រៀល (១.៨៨៩.៤៩២ ដុល្លារអាមេរិក) ពី៤៥.៩១៨.៩២៦.០០០រៀល (១១.៤០២.៧៦៣ ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៣ ដល់ ៥៣.៦៧៤.១២៦.០០០រៀល (១៣.២៩២.២៥៥ ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៤ ឬស្មើនឹងអត្រាកំណើន ១៦,៨៩%។ ការកើនឡើងនេះសំខាន់ គឺដោយសារការកើនឡើងនៃបរិមាណកុងតឺន័រឆ្លងកាត់ ក.ស.ភ. ក្នុងឆ្នាំ២០១៤ គឺ ១៣៣.៦៦៦ TEUs បើប្រៀបធៀបនឹង ១១០.៥០០TEUs ក្នុងឆ្នាំ២០១៣ ដែលមានកំណើនប្រមាណជា ២០,៩៦%។

កំណើនផលិតផលក្នុងស្រុកសរុប (GDP) របស់កម្ពុជា មានប្រមាណជា ៧% ដោយសារមានការកើនឡើងនៃវិស័យឧស្សាហកម្មវាយនភណ្ឌ ឧស្សាហកម្មសំណង់ និងការនាំចេញផលិតផលកសិកម្ម។ ក.ស.ភ. បានកត់ត្រាការកើនឡើងនូវការនាំចេញអង្ករក្នុងចំនួន ២១.១០០តោន ឬ ៣៦,១៧ %នៃការនាំចេញអង្ករក្នុងឆ្នាំ២០១៤ តាមរយៈ ក.ស.ភ. ចាប់ពីចំនួន ៥៨.៣៣៩ តោនក្នុងឆ្នាំ២០១៣ ទៅ ៧៩.៤៣៩ តោនក្នុងឆ្នាំ២០១៤។ ការនាំចេញនូវផលិតផលវាយនភណ្ឌកើនឡើងចំនួន ៥៤.៦៥២តោន ឬ ២៥,៦៩ % ក្នុងឆ្នាំ២០១៤ ពីចំនួន ២១២.៧២៨តោនក្នុងឆ្នាំ២០១៣ ទៅ ២៦៧.៣៨០តោនក្នុងឆ្នាំ២០១៤។

### ក.២. ការវិភាគចំណូលតាមផ្នែក

**តារាងប្រៀបធៀបនឹងប្រាក់ចំណូលសរុបនៅដំណាច់ឆ្នាំ២០១៣ ឆ្នាំ២០១៤ និងឆ្នាំ២០១៥**

| បរិយាយ | ៣១ ធ្នូ ២០១៣ | | ប្រៀបធៀបនឹងប្រាក់ចំណូលសរុប | ៣១ ធ្នូ ២០១៤ | | ប្រៀបធៀបនឹងប្រាក់ចំណូលសរុប | ៣១ ធ្នូ ២០១៥ | | ប្រៀបធៀបនឹងប្រាក់ចំណូលសរុប |
|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | | ដុល្លារអាមេរិក | ពាន់រៀល | | ដុល្លារអាមេរិក | ពាន់រៀល | |
| ចំណូលលើកដាក់ក្រោមដងយោង (Stevedore) | ៤.៦៣៦.៧៨៤ | ១៨.៦៧២.៣២៩ | ៤០,៦៦% | ៥.៦២៧.៥៦៤ | ២២.៧២៤.១០៣ | ៤២,៣៤% | ៦.០៣១.៣៦១ | ២៤.៤៨៧.៣២៦ | ៣៩,៨៤% |
| ចំណូលលើកដាក់នៅទីលាន (LOLO) | ៣.៧៤៦.៦៩៧ | ១៥.០៨៧.៩៤៩ | ៣២,៨៦% | ៤.៥០៣.៩១៨ | ១៨.១៨៦.៨២១ | ៣៣,៨៨% | ៤.៩២៨.៨៩៣ | ២០.០១១.៣០៦ | ៣២,៥៦% |
| ចំណូលកិច្ចការផែ | ១.៩៩៧.៣៩៩ | ៨.០៤៣.៥២៦ | ១៧,៥២% | ២.១២៦.៥៩៥ | ៨.៥៨៧.១៩១ | ១៦,០០% | ២.៤៩៤.៧១២ | ១០.១២៨.៥៣១ | ១៦,៤៨% |
| ចំណូលពីការគ្រប់គ្រងអាជីវកម្មខ្សាច់ | - | - | 0,00% | - | - | 0,00% | ៧១៨.៥១៤ | ២.៩១៧.១៦៧ | ៤,៧៥% |
| ចំណូលពីច្រកទ្វារ | - | - | 0,00% | ៤២៩.៤០៣ | ១.៧៣៣.៩២៩ | ៣,២៣% | ៤៨៩.៤២៧ | ១.៩៨៧.០៧៤ | ៣,២៣% |
| ចំណូលពីស្តុកទំនិញ/កុងតឺន័រ | ២៥៨.២១៥ | ១.០៣៩.៨៣២ | ២,២៦% | ៥៤៩.០១៦ | ២.២១៦.៩២៧ | ៤,១៣% | ២៩១.៤៨៩ | ១.១៨៣.៤៤៥ | ១,៩៣% |
| ចំណូលពីការវាស់ស្ទង់ | - | - | 0,00% | - | - | 0,00% | ១៧៩.៧០៧ | ៧២៩.៦១០ | ១,១៩% |
| ចំណូលពីការដឹកជញ្ជូន | ៤.០៩៧ | ១៦.៤៩៨ | 0,0៤% | - | - | 0,00% | - | - | 0,00% |
| ផ្សេងៗ | ៧៥៩.៥៧១ | ៣.០៥៨.៧៩២ | ៦,៦៦% | ៥៥.៧៥៩ | ២២៥.១៥៥ | 0,៤២% | ៣.៣៨១ | ១៣.៧២៧ | 0,0២% |
| ចំណូលសរុប | ១១.៤០២.៧៦៣ | ៤៥.៩១៨.៩២៦ | ១00,00% | ១៣.២៩២.២៥៥ | ៥៣.៦៧៤.១២៦ | ១00,00% | ១៥.១៣៧.៤៨៤ | ៦១.៤៥៨.១៨៦ | ១00,00% |

ការវិភាគត្រូវបានធ្វើតែទៅលើបម្រែបម្រួលនៃចំណូលទាំងបីសំខាន់ៗប៉ុណ្ណោះ ចំណូលពីការលើកដាក់ក្រោមដងយោង(Stevedore) ចំណូលពីការលើកដាក់លើទីលាន(LOLO) និងចំណូលពីកិច្ចការផែ ស្មើនឹង ៨៨% នៃផលចំណូលសរុបសម្រាប់ឆ្នាំនីមួយៗ។

**ដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ប្រៀបធៀបនឹងដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥**

| បរិយាយ | ៣១ ធ្នូ ២០១៤ | | ៣១ ធ្នូ ២០១៥ | | បំរែបំរួល | | បំរែបំរួល | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | % | ពាន់រៀល | % |
| ចំណូលពីការលើកដាក់ក្រោមដងយោង(Stevedore) | ៥.៦២៧.៥៦៤ | ២២.៧២៤.១០៣ | ៦.០៣១.៣៦១ | ២៤.៤៨៧.៣២៦ | ៤០៣.៧៩៧ | ៧.១៨% | ១.៧៦៣.២២៣ | ៧,៧៦% |
| ចំណូលពីការលើកដាក់នៅទីលាន (LOLO) | ៤.៥០៣.៩១៨ | ១៨.១៨៦.៨២១ | ៤.៩២៨.៨៩៣ | ២០.០១១.៣០៦ | ៤២៤.៩៧៥ | ៩,៤៤% | ១.៨២៤.៤៨៥ | ១០,០៣% |
| ចំណូលពីកិច្ចការផែ | ២.១២៦.៥៩៥ | ៨.៥៨៧.១៩១ | ២.៤៩៤.៧១២ | ១០.១២៨.៥៣១ | ៣៦៨.១១៧ | ១៧,៣១% | ១.៥៤១.៣៤០ | ១៧,៩៥% |
| ចំណូលពីការគ្រប់គ្រងអាជីវកម្មខ្សាច់ | - | - | ៧១៨.៥១៤ | ២.៩១៧.១៦៧ | ៧១៨.៥១៤ | គ្មាន | ២.៩១៧.១៦៧ | គ្មាន |

ចំណូលពីការលើកដាក់ក្រោមដងយោង(Stevedore) បានកើនឡើងចំនួន ១.៧៦៣.២២៣.០០០រៀល (៤០៣.៧៩៧ដុល្លារអាមេរិក) ពី ២២.៧២៤.១០៣.០០០រៀល (៥.៦២៧.៥៦៤ ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៤ ដល់ ២៤.៤៨៧.៣២៦.០០០រៀល (៦.០៣១.៣៦១ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៥ ឬស្មើនឹងអត្រាកំណើន ៧,៧៦%។

ចំណូលពីការលើកដាក់នៅទីលាន (LOLO) បានកើនឡើងចំនួន ១.៨២៤.៤៨៥.០០០រៀល (៤២៤.៩៧៥ ដុល្លារអាមេរិក) ពី១៨.១៨៦.៨២១.០០០រៀល (៤.៥០៣.៩១៨ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៤ ដល់ ២០.០១១.៣០៦.០០០រៀល (៤.៩២៨.៨៩៣ ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៥ ឬស្មើនឹងអត្រាកំណើន ១០,០៣%។ កំណើនចំណូលនេះ កើនឡើងស្របជាមួយនឹងកំណើនបរិមាណកុងតឺន័រ ដែលបានកើនឡើងចំនួន ១១.១៤៧ TEUs ពីចំនួន ១៣៣.៦៦៦ TEUs ក្នុងឆ្នាំ២០១៤ ដល់ ១៤៤.៨១៣ TEUs ក្នុងឆ្នាំ២០១៥ ឬស្មើនឹងអត្រាកំណើន ៨,៣៤%។

ចំណូលទាំងពីរខាងលើ កើនឡើងស្របជាមួយនឹងកំណើនបរិមាណកុងតឺន័រឆ្លងកាត់ ក.ស.ភ. ដែលមានចំនួនពី ១៣៣.៦៦៦TEUs ក្នុងឆ្នាំ២០១៤ ទៅ ១៤៤.៨១៣ TEUs ក្នុងឆ្នាំ២០១៥ គឺប្រហែលជា ៨,៣៤%។ កំណើនបរិមាណកុងតឺន័រឆ្លងកាត់នេះ បណ្តាលមកពីការនាំចូលនៃសម្ភារសំណង់ចំនួន ១២៦.៧១១ តោន ឬ ៤២,៥២% ដែលមានចំនួនពី ២៩៧.៩៩៣ តោន ក្នុងឆ្នាំ ២០១៤ ដល់ចំនួន ៤២៤.៧០៤ តោន ក្នុងឆ្នាំ២០១៥។ ទន្ទឹមនឹងនេះ ការនាំចេញអង្ករមានការកើនឡើងចំនួន ៥៧.៧៣១ តោន ឬ ៧៥,៣៥% ដែលមានចំនួនពី ៧៦.៦៧៣ តោន ក្នុងឆ្នាំ ២០១៤ ដល់ ១៣៤.៤០៥ តោន ក្នុងឆ្នាំ ២០១៥។

ចំណូលពីកិច្ចការផែ គឺអាស្រ័យលើចំនួន និងទំហំនាវាដែលឆ្លងកាត់ ក.ស.ភ.។ ចំណូលពីកិច្ចការផែនេះ បានកើនឡើងចំនួន ១.៥៤១.៣៤០.០០០ រៀល (៣៦៨.១១៧ ដុល្លារអាមេរិក) ពី ៨.៥៨៧.១៩១.០០០ រៀល (២.១២៦.៥៩៥ ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៤ ដល់ ១០.១២៨.៥៣១.០០០ រៀល (២.៤៩៤.៧១២ ដុល្លារអាមេរិក) ក្នុងឆ្នាំ ២០១៥ ឬ ស្មើនឹងអត្រាកំណើន ១៧,៩៥%។ កំណើនចំណូលនេះ កើនឡើងដោយសារចំនួននាវាដឹកទំនិញកើនឡើងពី ១.៤៦២ គ្រឿង នៅក្នុងឆ្នាំ២០១៤ រហូតដល់ ១.៥៩៦ គ្រឿង នៅឆ្នាំ២០១៥ និងចំនួននាវាទេសចរណ៍ កើនឡើងពី ៥២៣ គ្រឿង នៅឆ្នាំ២០១៤ រហូតដល់ ៦០៤ គ្រឿង នៅឆ្នាំ២០១៥។

**<u>ដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ប្រៀបធៀបនឹងដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤</u>**

| បរិយាយ | ៣១ ធ្នូ ២០១៣ | | ៣១ ធ្នូ ២០១៤ | | បំរែបំរួល | | បំរែបំរួល | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | % | ពាន់រៀល | % |
| សេវាលើកដាក់ក្រោមដងយោង (Stevedoring) | ៤.៦៣៦.៧៨៤ | ១៨.៦៧២.៣២៩ | ៥.៦២៧.៥៦៤ | ២២.៧២៤.១០៣ | ៩៩០.៧៨០ | ២១,៣៧% | ៤.០៥១.៧៧៤ | ២១,៧០% |
| សេវាលើកដាក់នៅទីលាន(LOLO) | ៣.៧៤៦.៦៩៧ | ១៥.០៨៧.៩៤៩ | ៤.៥០៣.៩១៨ | ១៨.១៨៦.៨២១ | ៧៥៧.២២១ | ២០,២១% | ៣.០៩៨.៨៧២ | ២០,៥៤% |
| ចំណូលកិច្ចការផែ | ១.៩៩៧.៣៩៩ | ៨.០៤៣.៥២៦ | ២.១២៦.៥៩៥ | ៨.៥៨៧.១៩១ | ១២៩.១៩៦ | ៦,៤៧% | ៥៤៣.៦៦៥ | ៦,៧៦% |

ចំណូលពីការលើកដាក់ក្រោមដងយោង (Stevedore) និងការលើកដាក់នៅទីលាន (LOLO) កើនឡើងជាមួយនឹងកំណើនបរិមាណទំនិញដែលឆ្លងកាត់ ក.ស.ភ.។ ចំណូលពីការលើកដាក់ក្រោមដងយោង បានកើនឡើងចំនួន ៤.០៥១.៧៧៤.០០០ រៀល (៩៩០.៧៨០ ដុល្លារអាមេរិក) ពី ១៨.៦៧២.៣២៩.០០០រៀល (៤.៦៣៦.៧៨៤ ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៣ ដល់ ២២.៧២៤.១០៣.០០០រៀល (៥.៦២៧.៥៦៤ ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៤ ឬ ស្មើនឹងអត្រាកំណើន ២១,៧០%។

ចំណូលពីការលើកដាក់នៅទីលាន (LOLO) បានកើនឡើងចំនួន ៣.០៩៨.៨៧២.០០០រៀល (៧៥៧.២២១ ដុល្លារអាមេរិក) ពី ១៥.០៨៧.៩៤៩.០០០រៀល (៣.៧៤៦.៦៩៧ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៣ ដល់ ១៨.១៨៦.៨២១.០០០រៀល(៤.៥០៣.៩១៨ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៤ ឬស្មើនឹងអត្រាកំណើន ២០,៥៤%។ កំណើននេះ កើនឡើងជាមួយនឹងកំណើនបរិមាណកុងតឺន័រ ដែលបានកើនឡើងចំនួន ២៣.១១៦ TEUs ពីចំនួន ១១០.៥៥០ TEUs ក្នុងឆ្នាំ២០១៣ ដល់ ១៣៣.៦៦៦ TEUs ក្នុងឆ្នាំ២០១៤ ឬស្មើនឹងអត្រាកំណើន ២០,៩៦%។

ចំណូលពីកិច្ចការផែ អាស្រ័យលើចំនួន និងទំហំនៃនាវាដែលបានឆ្លងកាត់ ក.ស.ភ.។ ចំណូលពីកិច្ចការផែ បានកើនឡើងចំនួន ៥៤៣.៦៦៥.០០០រៀល (១២៩.១៩៦ ដុល្លារអាមេរិក) ពី៨.០៤៣.៥២៦.០០០ រៀល (១.៩៩៧.៣៩៩ ដុល្លារអាមេរិក) នៅឆ្នាំ២០១៣ ដល់៨.៥៨៧.១៩១.០០០ រៀល (២.១២៦.៥៩៥ ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៤ ឬ ស្មើនឹងអត្រាកំណើន ៦,៧៦%។ ចំនួននាវា កើនឡើងពី ១.៤៥០ គ្រឿង នៅឆ្នាំ២០១៣ រហូតដល់ ១.៤៦២ គ្រឿង នៅឆ្នាំ២០១៤ ។

## ខ- ការវិភាគគំលាតប្រាក់ចំណេញដុល

### ខ.១.ដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ប្រៀបធៀបនឹងដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥

| **បរិយាយ** | ៣១ ធ្នូ ២០១៤ | | ៣១ ធ្នូ ២០១៥ | | បំរែបំរួល | | បំរែបំរួល | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | % | ពាន់រៀល | % |
| **ចំណូល** | **១៣.២៩២.២៥៥** | **៥៣.៦៧៤.១២៦** | **១៥.១៣៧.៤៨៤** | **៦១.៤៥៨.១៨៦** | **១.៨៤៥.២២៩** | **១៣,៨៨%** | **៧.៧៨៤.០៦០** | **១៤,៥០%** |
| **ថ្លៃដើមនៃការលក់ និង សេវាកម្ម** | | | | | | | | |
| រំលស់ | ១.៩៥៦.៧៥២ | ៧.៩០១.៣៦៤ | ១.៩៦៣.០៨២ | ៧.៩៧០.១១៣ | ៦.៣៣០ | ០,៣២% | ៦៨.៧៤៩ | ០,៨៧% |
| ដងយោង | ១.១៨៧.៥២៤ | ៤.៧៩៥.២២២ | ១.២៧៦.៦០៨ | ៥.១៨៣.០២៨ | ៨៩.០៨៤ | ៧,៥០% | ៣៨៧.៨០៦ | ៨,០៩% |
| ប្រាក់បៀវត្សរ៍ និង អត្ថប្រយោជន៍ផ្សេងៗ | ៩០៩.៥០០ | ៣.៦៧២.៥៦១ | ១.០៦១.៧៦៤ | ៤.៣១០.៧៦២ | ១៥២.២៦៤ | ១៦,៧៤% | ៦៣៨.២០១ | ១៧,៣៨% |
| ប្រេងសាំង និង ប្រេងឥន្ធនៈ | ៦៥៦.៦៦០ | ២.៦៥១.៥៩៣ | ៥៦១.០២២ | ២.២៧៧.៧៤៩ | (៩៥.៦៣៨) | -១៤,៥៦% | (៣៧៣.៨៤៤) | -១៤,១០% |
| ការបូមខ្សាច់ | ៣២២.៣៧៤ | ១.៣០១.៧៤៦ | ១១៤.៩៤៧ | ៤៦៦.៦៨៥ | (២០៧.៤២៧) | -៦៤,៣៤% | (៨៣៥.០៦១) | -៦៤,១៥% |
| ការជួសជុល និង ថែទាំ | ២៥៩.២៨៣ | ១.០៤៦.៩៨៥ | ៣២២.៩១៧ | ១.៣១១.០៤៣ | ៦៣.៦៣៤ | ២៤,៥៤% | ២៦៤.០៥៨ | ២៥,២២% |
| ការវាស់ស្ទង់ | - | - | ៣៩.៨៧១ | ១៦១.៨៧៦ | ៣៩.៨៧១ | គ្មាន | ១៦១.៨៧៦ | គ្មាន |
| ផ្សេងៗ | ១៨.៩៦៥ | ៧៦.៥៨១ | ៤៨.៣៧៤ | ១៩៦.៣៩៩ | ២៩.៤០៩ | ១៥៥,០៧% | ១១៩.៨១៨ | ១៥៦,៤៦% |
| **សរុបថ្លៃដើមនៃការលក់ និង សេវាកម្ម** | **៥.៣១១.០៥៨** | **២១.៤៤៦.០៥២** | **៥.៣៨៨.៥៨៥** | **២១.៨៧៧.៦៥៥** | **៧៧.៥២៧** | **១,៤៦%** | **៤៣១.៦០៣** | **២,០១%** |
| **ចំណេញដុល** | **៧.៩៨១.១៩៧** | **៣២.២២៨.០៧៤** | **៩.៧៤៨.៨៩៩** | **៣៩.៥៨០.៥៣១** | **១.៧៦៧.៧០២** | **២២,១៥%** | **៧.៣៥២.៤៥៧** | **២២,៨១%** |
| **អត្រាគំលាតប្រាក់ចំណេញដុល** | ៦០,០៤% | ៦០,០៤% | ៦៤,៤០% | ៦៤,៤០% | | | | |

-ថ្លៃដើមសេវាកម្ម÷

ចំណាយរំលស់ ក្នុងឆ្នាំ២០១៥ បានកើនឡើងចំនួន ៦៨.៧៤៩.000 រៀល (៦.៣៣០ ដុល្លារអាមេរិក) ឬ ស្មើនឹង 0,៨៧% ដោយសារពុំមានការបញ្ជាទិញគ្រឿងចក្រ និងសម្ភារបរិក្ខាផ្សេងៗ។

ចំណាយលើថ្លៃដងយោង បានកើនឡើងចំនួន ៣៨៧.៨០៦.000 រៀល (៨៩.០៨៤ ដុល្លារអាមេរិក) ឬ ស្មើនឹង ៨,០៩% ក្នុងឆ្នាំ ២០១៥ ដោយសារតែកំណើននៃចំនួនកុងតឺន័រឆ្លងកាត់ចំនួន ១១.១៤៧TEUs ពីចំនួន ១៣៣.៦៦៦TEUs ក្នុងឆ្នាំ២០១៤ ដល់ចំនួន ១៤៤.៨១៣TEUs ក្នុងឆ្នាំ២០១៥។ ចំណាយនេះកើនឡើងប្រហាក់ប្រហែលនឹងចំនួនកុងតឺរឆ្លងកាត់ ក.ស.ភ.សម្រាប់ឆ្នាំ ២០១៥ ។

ចំណាយប្រាក់បៀវត្សរ៍ និងអត្ថប្រយោជន៍ផ្សេងៗ បានកើនឡើងចំនួន ៦៣៨.២០១.០០០ រៀល (១៥២.២៦៤ ដុល្លារអាមេរិក) ឬស្មើនឹង ១៧,៣៨% នៅឆ្នាំ២០១៥ ដោយសារការកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងថ្មី ស្របតាមការចូលផ្សារភាគហ៊ុន និងការផ្តល់ប្រាក់បៀវត្សរ៍ទៅតាមបរិមាណកុងតឺន័រឆ្លងកាត់(TEUs)។

ចំណាយប្រេងសាំង និងប្រេងឥន្ទនៈបានធ្លាក់ចុះចំនួន ៣៧៣.៨៤៤.០០០ រៀល (៩៥.៦៣៨ដុល្លារអាមេរិក) ឬស្មើនឹង ១៤,១០% ពី ឆ្នាំ២០១៤ ចំនួន ២.៦៥១.៥៩៣.000 រៀល ធៀបនឹងឆ្នាំ២០១៥ ចំនួន ២.២៧៧.៧៤៩.០០០ រៀល ដោយសារការធ្លាក់ថ្លៃប្រេងឥន្ទនៈ នៅឆ្នាំ២០១៥។ ជាក់ស្តែង តម្លៃប្រេងឥន្ទនៈក្នុងមួយលីត្រដែល ក.ស.ភ. បានទិញយកមកប្រើប្រាស់ធ្លាក់ពី ០,៨២ ដុល្លារអាមេរិក/លីត្រ នៅខែមករា ទៅ ០,៦៨ ដុល្លារអាមេរិក/លីត្រ ពីខែមីនា ដល់ខែធ្នូ ឆ្នាំ២០១៥។

ចំណាយលើការជួសជុល និងថែទាំ បានកើនឡើងចំនួន ២៦៤.០៥៨.០០០ រៀល (៦៣.៦៣៤ ដុល្លារអាមេរិក) ឬស្មើនឹង ២៥,២២% ដោយសារមានការជួសជុល និងថែទាំទំនប់ទប់ច្រាំងទន្លេ និងទំនប់ទប់ជើងទេរ នៅចំណតផែកុងតឺន័រ LM១៧ ដែលមានប្រវែង ៣មx៥១៨ម ព្រមទាំងថែទាំ និងជួសជុលគ្រឿងចក្រ។

ចំណាយផ្សេងៗ បានកើនឡើងចំនួន ១៥៦,៤៦% ដែលស្មើនឹង ១១៩.៨១៨.០០០ រៀល (២៩.៤០៩ ដុល្លារអាមេរិក) ពីឆ្នាំ ២០១៤ ចំនួន ៧៦.៥៨១.០០០ រៀល ធៀបនឹងឆ្នាំ២០១៥ ចំនួន ១៩៦.៣៩៩.000រៀល ដោយសារមានការសហការប្រើប្រាស់សេវាកម្មដឹកជញ្ជូនកុងតឺន័រក្នុងបរិវេណផែ ក.ស.ភ. របស់ក្រុមហ៊ុន លន់ គ្រេនស្ព័ត & ឡូជីស្ទីក ខូអិលធីឌី។

- <u>អត្រាគំលាតប្រាក់ចំណេញដុល៖</u>

អត្រាគំលាតប្រាក់ចំណេញដុល បានកើនឡើងចំនួន ៤,៣៦% ពីអត្រា ៦០,០៤% នៅក្នុងឆ្នាំ២០១៤ ទៅដល់ ៦៤,៤០% នៅក្នុងឆ្នាំ២០១៥។ ការកើនឡើងនៃអត្រាគំលាតប្រាក់ចំណេញដុល ដោយសារតែចំណូលសរុបមានការកើនឡើង ៧.៧៨៤.០៦០.០០០ រៀល ឬស្មើនឹង ១៤,៥០% ពី៥៣.៦៧៤.១២៦.០០០ រៀលក្នុងឆ្នាំ២០១៤ ទៅដល់ ៦១.៤៥៨.១៨៦.០០០ រៀលក្នុងឆ្នាំ២០១៥។ រីឯ ការចំណាយសរុបលើថ្លៃដើមនៃការលក់ និងសេវាកម្ម មានការកើនឡើងទាបត្រឹមតែ ៤៣១.៦០៣.០០០ រៀល ឬ ស្មើនឹង ២,០១% ពី ២១.៤៤៦.០៥២.០០០ រៀល ក្នុងឆ្នាំ២០១៤ ទៅដល់ ២១.៨៧៧.៦៥៥.០០០ រៀល នៅឆ្នាំ២០១៥។ កត្តាចំបង

ដែលធ្វើឱ្យចំណាយសរុបលើថ្លៃដើមនៃការលក់ និងសេវាកម្ម មានការកើនឡើងទាប បណ្តាលមកពីការធ្លាក់ចុះនៃចំណាយប្រេងសាំង និងប្រេងឥន្ទនៈ និងចំណាយពីការបូមខ្សាច់។

### ខ.២.ដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ប្រៀបធៀបនឹងដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

| បរិយាយ | ៣១ ធ្នូ ២០១៣ | | ៣១ ធ្នូ ២០១៤ | | បំរែបំរួល | | បំរែបំរួល | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | % | ពាន់រៀល | % |
| **ចំណូល** | **១១.៩០២.៧៦៣** | **៤៥.៩១៨.៩២៦** | **១៣.២៩២.២៥៥** | **៥៣.៦៧៤.១២៦** | **១.៨៨៩.៤៩២** | **១៦,៥៧%** | **៧.៧៥៥.២០០** | **១៦,៨៩%** |
| **ថ្លៃដើមនៃការលក់ និង សេវាកម្ម** | | | | | | | | |
| រំលស់ | ១.៥៩០.៥០៨ | ៦.៤០៤.៩៧៦ | ១.៩៥៦.៧៥២ | ៧.៩០១.៣៦៤ | ៣៦៦.២៤៤ | ២៣,០៣% | ១.៤៩៦.៣៨៨ | ២៣,៣៦% |
| ដងយោង | ៧៩៤.៤៩៧ | ៣.១៩៩.៤៣៩ | ១.១៨៧.៥២៤ | ៤.៧៩៥.២២២ | ៣៩៣.០២៧ | ៤៩,៤៧% | ១.៥៩៥.៧៨៣ | ៤៩,៨៨% |
| ប្រាក់បៀវត្សរ៍ និងអត្ថប្រយោជន៍ផ្សេងៗ | ៧៦៦.២៧៣ | ៣.០៨៥.៧៨១ | ៩០៩.៥០០ | ៣.៦៧២.៥៦១ | ១៤៣.២២៧ | ១៨,៦៩% | ៥៨៦.៧៨០ | ១៩,០២% |
| ប្រេងសាំង និងប្រេងឥន្ទនៈ | ៦១៣.៨៨៨ | ២.៤៧២.១២៧ | ៦៥៦.៦៦០ | ២.៦៥១.៥៩៣ | ៤២.៧៧២ | ៦,៩៧% | ១៧៩.៤៦៦ | ៧,២៦% |
| ការបូមខ្សាច់ | ៤៨២.៥៥៦ | ១.៩៤៣.២៥៣ | ៣២២.៣៧៤ | ១.៣០១.៧៤៦ | (១៦០.១៨២) | -៣៣,១៩% | (៦៤១.៥០៧) | -៣៣,០១% |
| ការជួសជុល និងថែទាំ | ២២២.៥៤១ | ៨៩៦.១៧៣ | ២៥៩.២៨៣ | ១.០៤៦.៩៨៥ | ៣៦.៧៤២ | ១៦,៥១% | ១៥០.៨១២ | ១៦,៨៣% |
| ផ្សេងៗ | ១០៤.០៣៦ | ៤១៨.៩៥៣ | ១៨.៩៦៥ | ៧៦.៥៨១ | (៨៥.០៧១) | -៨១,៧៧% | (៣៤២.៣៧២) | -៨១,៧២% |
| **សរុបថ្លៃដើមនៃការលក់ និងសេវាកម្ម** | ៤.៥៧៤.២៩៩ | ១៨.៤២០.៧០២ | ៥.៣១១.០៥៨ | ២១.៤៤៦.០៥២ | ៧៣៦.៧៥៩ | ១៦,១១% | ៣.០២៥.៣៥០ | ១៦,៤២% |
| ចំណេញដុល | **៦.៨២៨.៤៦៤** | **២៧.៤៩៨.២២៤** | **៧.៩៨១.១៩៧** | **៣២.២២៨.០៧៤** | **១.១៥២.៧៣៣** | **១៦,៨៨%** | **៤.៧២៩.៨៥០** | **១៧,២០%** |
| **អត្រាគំលាតប្រាក់ចំណេញដុល** | **៥៩,៨៨%** | **៥៩,៨៨%** | **៦០,០៤%** | **៦០,០៤%** | | | | |

- <u>ថ្លៃដើមសេវាកម្ម៖</u>

ចំណាយលើរំលស់ នៅឆ្នាំ២០១៤ បានកើនឡើងចំនួន ១.៤៩៦.៣៨៨.០០០រៀល (៣៦៦.២៤៤ ដុល្លារអាមេរិក) ឬ ស្មើនឹង ២៣,៣៦% ដោយសារការទិញគ្រឿង សម្ភារបរិក្ខារ សម្រាប់ប្រតិបត្តិការនៅចំណតផែកុងតឺន័រ LM១៧ និងសម្ភារបរិក្ខារមួយចំនួន ដែលបានទិញក្នុងពាក់កណ្តាលឆ្នាំ២០១៣ ត្រូវបានកត់ត្រាជាចំណាយរំលស់ទាំងអស់ នៅឆ្នាំ២០១៤។

ចំណាយលើថ្លៃដងយោង បានកើនឡើងចំនួន ១.៥៩៥.៧៨៣.០០០រៀល (៣៩៣.០២៧ ដុល្លារអាមេរិក) ឬ ស្មើនឹង ៤៩,៨៨% ក្នុងឆ្នាំ២០១៤ ដោយសារកំណើននៃចំនួនកុងតឺន័រឆ្លងកាត់ចំនួន ២៣.១៦៦ TEUs ឬ ស្មើនឹង ២០,៩៦% ពីចំនួន ១១០.៥០០ TEUs ក្នុងឆ្នាំ២០១៣ ដល់ចំនួន ១៣៣.៦៦៦ TEUs ក្នុងឆ្នាំ ២០១៤។

ប្រាក់បៀវត្សរ៍ និងផលប្រយោជន៍ផ្សេងៗ បានកើនឡើងចំនួន ៥៨៦.៧៨០.០០០រៀល (១៤៣.២២៧ ដុល្លារអាមេរិក) ឬស្មើនឹង១៩,០២%ក្នុងឆ្នាំ២០១៤។ កំណើននេះ ដោយសារការតំឡើងតួនាទី និងកំណើនប្រាក់គោន។

ចំណាយលើការបូមខ្សាច់ បានថយចុះចំនួន ៦៤១.៥០៧.០០០ រៀល (១៦០.១៨២ ដុល្លារអាមេរិក) ឬ ស្មើនឹង ៣៣,០១% ក្នុងឆ្នាំ២០១៤ ដោយសារ ក.ស.ភ. បានបញ្ចប់កិច្ចសន្យាផ្គត់ផ្គង់ខ្សាច់ សម្រាប់ការសាងសង់ស្ពានត្បូបាសា (ស្ពានអ្នកលឿង) ក្នុងឆ្នាំ ២០១៣ រួមទាំងបានបញ្ចប់គម្រោងបូមស្តារដទៃទៀត ក្នុងឆ្នាំ២០១៤។

ចំណាយផ្សេងៗទៀត បានថយចុះចំនួន ៣៤២.៣៧២.០០០រៀល (៨៥.០៧១ដុល្លារអាមេរិក) ឬ ស្មើនឹង ៨១,៧២% ក្នុងឆ្នាំ២០១៤ ដោយសារ ក.ស.ភ. បានប្រើប្រាស់គ្រឿងចក្រលើកដាក់ថ្មីៗ ជំនួសវិញ។

- <u>អត្រាគំលាតប្រាក់ចំណេញដុល៖</u>

អត្រាគំលាតប្រាក់ចំណេញដុល បានកើនឡើងចំនួន ០,១៦% ពីអត្រា ៥៩,៨៨% នៅក្នុងឆ្នាំ២០១៣ មកត្រឹម ៦០,០៤% នៅក្នុងឆ្នាំ២០១៤ ដោយសារការចំណាយលើសកម្មភាពបូមខ្សាច់ បានថយចុះ និងការថយចុះនៃចំណាយដទៃទៀត។

**គ- ការវិភាគប្រាក់ចំណេញមុនបង់ពន្ធ**

គ.១.<u>**ដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ប្រៀបធៀបនឹងដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥**</u>

| បរិយាយ | ៣១ ធ្នូ ២០១៤ | | ៣១ ធ្នូ ២០១៥ | | បំរែបំរួល | | បំរែបំរួល | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | % | ពាន់រៀល | % |
| **ប្រាក់ចំណេញដុល** | **៧.៩៨១.១៩៧** | **៣២.២២៨.០៧៤** | **៩.៧៤៨.៨៩៩** | **៣៩.៥៨០.៥៣១** | **១.៧៦៧.៧០២** | **២២,១៥%** | **៧.៣៥២.៤៥៧** | **២២,៨១%** |
| ប្រាក់ចំណូលផ្សេងៗ | ៣០១.៣៣៦ | ១.២១៦.៧៩៥ | ៣៦០.២៨៥ | ១.៤៦២.៧៥៧ | ៥៨.៩៤៩ | ១៩,៥៦% | ២៤៥.៩៦២ | ២០,២១% |
| **ចំណាយរដ្ឋបាល** | | | | | | | | |
| ចំណាយប្រាក់បៀវត្សរ៍ និងប្រាក់ឈ្នួល | ១.៨៧១.៧៨៥ | ៧.៥៥៨.២៦៨ | ២.២៧១.០៥៣ | ៩.២២០.៤៧៥ | ៣៩៩.២៦៨ | ២១,៣៣% | ១.៦៦២.២០៧ | ២១,៩៩% |
| ចំណាយវិភាគទាន | ៤៣២.១០៣ | ១.៧៤៤.៨៣២ | ២៩៩.៦៤២ | ១.២១៦.៥៤៧ | (១៣២.៤៦១) | -៣០,៦៥% | (៥២៨.២៨៥) | -៣០,២៨% |
| ចំណាយទឹកភ្លើង និងប្រេងឥន្ទនៈ | ៣៩២.៦៦៧ | ១.៥៨៥.៥៨៩ | ៣៧៥.៦០៩ | ១.៥២៤.៩៧៣ | (១៧.០៥៨) | -៤,៣៤% | (៦០.៦១៦) | -៣,៨២% |
| ចំណាយរំលស់លើទ្រព្យវិនិយោគ និង ទ្រព្យរោងចក្របរិក្ខារ | ៣២២.៥៩៧ | ១.៣០២.៦៤៧ | ៣៤២.៤៦៤ | ១.៣៩០.៤០៤ | ១៩.៨៦៧ | ៦,១៦% | ៨៧.៧៥៧ | ៦,៧៤% |
| ចំណាយជួសជុល និង ថែទាំ | ២៨១.៣១២ | ១.១៣៥.៩៣៨ | ១២៦.៦៣៦ | ៥១៤.១៤២ | (១៥៤.៦៧៦) | -៥៤,៩៨% | (៦២១.៧៩៦) | -៥៤,៧៤% |
| ចំណាយលើការកំសាន្ត | ១៩៦.៦៣២ | ៧៩៤.០០០ | ២១៧.១៣០ | ៨៨១.៥៤៨ | ២០.៤៩៨ | ១០,៤២% | ៨៧.៥៤៨ | ១១,០៣% |
| ចំណាយការធ្វើដំណើរ | ១១៩.០៦៥ | ៤៨០.៧៨៥ | ១២១.៩៩៣ | ៤៩៥.២៩២ | ២.៩២៨ | ២,៤៦% | ១៤.៥០៧ | ៣,០២% |
| ចំណាយជំនាញវិជ្ជាជីវៈ | ៨៨.៥៥៧ | ៣៥៧.៥៩៣ | ២១.៩៥១ | ៨៩.១២១ | (៦៦.៦០៦) | -៧៥,២១% | (២៦៨.៤៧២) | -៧៥,០៨% |
| ចំណាយកម្រៃក្រុមប្រឹក្សាភិបាល | ៨២.៧៤៩ | ៣៣៤.១៤០ | ១២៧.៤៨៩ | ៥១៧.៦០៥ | ៤៤.៧៤០ | ៥៤,០៧% | ១៨៣.៤៦៥ | ៥៤,៩១% |
| ចំណាយសម្ភារផ្គត់ផ្គង់ការិយាល័យ | ៧៧.៥៥៨ | ៣១៣.១៧៩ | ១០៨.២១៦ | ៤៣៩.៣៥៧ | ៣០.៦៥៨ | ៣៩,៥៣% | ១២៦.១៧៨ | ៤០,២៩% |
| ចំណាយទំនាក់ទំនងផ្សេងៗ | ៥៨.៥១៣ | ២៣៦.២៧៦ | ៦៣.៣៩៤ | ២៥៧.៣៨០ | ៤.៨៨១ | ៨,៣៤% | ២១.១០៤ | ៨,៩៣% |
| ចំណាយពន្ធផ្សេងៗ | ២៥.៩០២ | ១០៤.៥៩២ | ២២៣.៣៦៦ | ៩០៦.៨៦៦ | ១៩៧.៤៦៤ | ៧៦២,៣៥% | ៨០២.២៧៤ | ៧៦៧,០៥% |
| ខាត/(ចំណេញ)ពីការប្តូររូបិយប័ណ្ណ | (២.០៩៤) | (៨.៤៥៦) | ១៤.៩៩៦ | ៦០.៨៨៤ | ១៧.០៩០ | -៨១៦,១៤% | ៦៩.៣៤០ | -៨២០,០១% |
| ផ្សេងៗ | ២៤០.៨៧០ | ៩៧២.៦៣៣ | ២៦៧.៥៦៧ | ១.០៨៦.៣២២ | ២៦.៦៩៧ | ១១,០៨% | ១១៣.៦៨៩ | ១១,៦៩% |
| ចំណាយហិរញ្ញប្បទាន | ១.២៨៨.៥៤១ | ៥.២០៣.១២៩ | ១.១៥៩.១៨៦ | ៤.៧០៦.២៩៥ | (១២៩.៣៥៥) | -១០,០៤% | (៤៩៦.៨៣៤) | -៩,៥៥% |
| **ប្រាក់ចំណេញមុនបង់ពន្ធ** | **២.៨០៥.៧៧៦** | **១១.៣២៩.៧២៤** | **៤.៣៦៨.៤៩២** | **១៧.៧៣៦.០៧៧** | **១.៥៦២.៧១៦** | **៥៥,៧០%** | **៦.៤០៦.៣៥៣** | **៥៦,៥៤%** |

ចំណាយលើប្រាក់បៀវត្សរ៍ និងប្រាក់ឈ្នួល បានកើនឡើងចំនួន ១.៦៦២.២០៧.០០០ រៀល (៣៩៩.២៦៨ ដុល្លារអាមេរិក) ឬស្មើនឹង ២១,៩៩% ក្នុងឆ្នាំ ២០១៥ ដោយសារ ក.ស.ភ. បានរៀបចំកែសម្រួលរចនាសម្ព័ន្ធគ្រប់គ្រងថ្មី ស្របតាមការចូលផ្សារភាគហ៊ុន និងការផ្តល់ប្រាក់បៀវត្សរ៍ទៅតាមបរិមាណកុងតឺន័រឆ្លងកាត់ (TEUs) ។

ចំណាយរិភាគទានបានថយចុះចំនួន ៥២៨.២៨៥.០០០ រៀល (១៣២.៤៦១ ដុល្លារអាមេរិក) ឬស្មើនឹង ៣០,២៨% ក្នុងឆ្នាំ២០១៥ ដោយសារការថយចុះស្របទៅតាមផែនការកាត់បន្ថយចំណាយរិភាគទានប្រចាំឆ្នាំ។

ចំណាយជួសជុល និង ថែទាំ មានការថយចុះចំនួន ៦២១.៧៩៦.០០០ រៀល (១៥៥.៦៧៦ ដុល្លារអាមេរិក) ឬស្មើនឹង ៥៤,៧៤% ក្នុងឆ្នាំ ២០១៥ដោយសារពុំមានចំណាយលើការជួសជុល និងថែទាំស្ពានផែ ដូចបានអនុវត្ត ក្នុងឆ្នាំ២០១៤។

ចំណាយជំនាញវិជ្ជាជីវៈបានថយចុះ ចំនួន ២៦៨.៤៧២.០០០ រៀល (៦៦.៦០៦ ដុល្លារអាមេរិក) ឬស្មើនឹង ៧៥,០៨% ក្នុងឆ្នាំ២០១៥ ដោយសារបានបញ្ចប់ការជួលសេវាប្រឹក្សាគណនេយ្យ និងចំណាយលើការវាយតម្លៃអចលនទ្រព្យ ក៏ដូចជាសេវាផ្សេងៗទៀត សម្រាប់ការត្រៀមចូលទីផ្សារមូលបត្រ។

ចំណាយក្រុមប្រឹក្សាភិបាល មានការកើនឡើងចំនួន ១៨៣,៩៦៥,000.០០០ រៀល (៩៩.៧៩០ដុល្លារអាមេរិក) ឬស្មើនឹង ៥៩,៩១% ក្នុងឆ្នាំ២០១៥ ដោយសារតែការរៀបចំកែសម្រួលលក្ខន្តិកបុគ្គលិក ក.ស.ភ. កាលពីថ្ងៃទី២១ ខែកក្កដា ឆ្នាំ ២០១៥។

ចំណាយផ្សេងៗបានកើនឡើងចំនួន ១១៣.៦៨៩.០០០ រៀល (២៦.៦៩៧ដុល្លារអាមេរិក) ឬស្មើនឹង១១,៦៩% ក្នុងឆ្នាំ២០១៥ ដោយសារតែបានរៀបចំការផ្សព្វផ្សាយដំណឹង និងបានទិញសម្ភារការិយាល័យថ្មីផ្សេងៗទៀត។

ចំណាយហិរញ្ញប្បទានមានការថយចុះចំនួន ៩៩៦.៨៣៩.០០០រៀល (១២៩.៣៥៥ ដុល្លារអាមេរិក) ឬស្មើនឹង៩,៥៥% ក្នុងឆ្នាំ២០១៥ ដោយសារពុំបានប្រើឥណទានវិបារូបន៍។

## គ.២.ដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ប្រៀបធៀបនឹងដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤

| បរិយាយ | ៣១ ធ្នូ ២០១៣ | | ៣១ ធ្នូ ២០១៤ | | បំរែបំរួល | | បំរែបំរួល | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | % | ពាន់រៀល | % |
| **ប្រាក់ចំណេញដុល** | ៦.៨២៨.៤៦៤ | ២៧.៤៩៨.២២៤ | ៧.៩៨១.១៩៧ | ៣២.២២៨.០៧៤ | ១.១៥២.៧៣៣ | ១៦,៨៨% | ៤.៧២៩.៨៥០ | ១៧,២០% |
| ប្រាក់ចំណូលផ្សេងៗ | ៣៥២.៧៥៧ | ១.៤២០.៥៥៣ | ៣០១.៣៣៦ | ១.២១៦.៧៩៥ | (៥១.៤២១) | -១៤,៥៨% | (២០៣.៧៥៨) | -១៤,៣៤% |
| **ចំណាយរដ្ឋបាល** | | | | | | | | |
| ចំណាយប្រាក់បៀវត្សរ៍ និង ប្រាក់ឈ្នួល | ១.៥៦៩.៤៤១ | ៦.៣២០.១៣៩ | ១.៨៧១.៧៨៥ | ៧.៥៥៨.២៦៨ | ៣០២.៣៤៤ | ១៩,២៦% | ១.២៣៨.១២៩ | ១៩,៥៩% |
| ចំណាយវិភាគទាន | ៤៣៥.៦៩១ | ១.៧៥៤.៥២៨ | ៤៣២.១០៣ | ១.៧៤៤.៨៣២ | (៣.៥៨៨) | -០,៨២% | (៩.៦៩៦) | -០,៥៥% |
| ចំណាយទឹកភ្លើង និង ប្រេងឥន្ធនៈ | ៣៥៣.១៤៣ | ១.៤២២.១០៧ | ៣៩២.៦៦៧ | ១.៥៨៥.៥៨៩ | ៣៩.៥២៤ | ១១,១៩% | ១៦៣.៤៨២ | ១១,៥០% |
| ចំណាយរំលស់លើទ្រព្យវិនិយោគ និងទ្រព្យរោងចក្របរិក្ខារ | ២៨៩.៤៧០ | ១.១៦៥.៦៩៦ | ៣២២.៥៩៧ | ១.៣០២.៦៤៧ | ៣៣.១២៧ | ១១,៤៤% | ១៣៦.៩៥១ | ១១,៧៥% |
| ចំណាយ ជួសជុល និងថែទាំ | ៤៨៧.៦៦៤ | ១.៩៦៣.៨២៣ | ២៨១.៣១២ | ១.១៣៥.៩៣៨ | (២០៦.៣៥២) | -៤២,៣១% | (៨២៧.៨៨៥) | -៤២,១៦% |
| ចំណាយលើការកំសាន្ត | ១៩៧.៣០៨ | ៧៩៤.៥៥៩ | ១៩៦.៦៣២ | ៧៩៤.០០០ | (៦៧៦) | -០,៣៤% | (៥៥៩) | -០,០៧% |
| ចំណាយការធ្វើដំណើរ | ១៣៧.៣៦៥ | ៥៥៣.១៦៩ | ១១៩.០៦៥ | ៤៨០.៧៨៥ | (១៨.៣០០) | -១៣,៣២% | (៧២.៣៨៤) | -១៣,០៩% |
| ចំណាយជំនាញវិជ្ជាជីវៈ | ៥៨.១៦១ | ២៣៤.២១៤ | ៨៨.៥៤៧ | ៣៥៧.៥៩៣ | ៣០.៣៨៦ | ៥២,២៦% | ១២៣.៣៧៩ | ៥២,៦៨% |
| ចំណាយកម្រៃក្រុមប្រឹក្សាភិបាល | ៨៣.៤៧៦ | ៣៣៦.១៥៨ | ៨២.៧៤៩ | ៣៣៤.១៤០ | (៧២៧) | -០,៨៧% | (២.០១៨) | -០,៦០% |
| ចំណាយ សម្ភារផ្គត់ផ្គង់ការិយាល័យ | ១៦៤.៦៤៧ | ៦៦៣.០៣៣ | ៧៧.៥៥៨ | ៣១៣.១៧៩ | (៨៧.០៨៩) | -៥២,៨៩% | (៣៤៩.៨៥៤) | -៥២,៧៧% |
| ចំណាយទំនាក់ទំនងផ្សេងៗ | ៧១.៩៦២ | ២៨៩.៧៩១ | ៥៨.៥១៣ | ២៣៦.២៧៦ | (១៣.៤៤៩) | -១៨,៦៩% | (៥៣.៥១៥) | -១៨,៤៧% |
| ចំណាយពន្ធផ្សេងៗ | ៩.៤៩៤ | ៣៨.២៣២ | ២៥.៩០២ | ១០៤.៥៩២ | ១៦.៤០៨ | ១៧២,៨២% | ៦៦.៣៦០ | ១៧៣,៥៧% |
| ខាត/(ចំណេញ)ពីការប្តូររូបិយបណ្ណ | ១៦.៧០៦ | ៦៧.២៧៥ | (២.០៩៤) | (៨.៤៥៦) | (១៨.៨០០) | -១១២,៥៣% | (៧៥.៧៣១) | -១១២,៥៧% |
| ផ្សេងៗ | ៤៤១.៨៥១ | ១.៧៧៩.៣៣៤ | ២៤០.៨៧០ | ៩៧២.៦៣៣ | (២០០.៩៨១) | -៤៥,៤៩% | (៨០៦.៧០១) | -៤៥,៣៤% |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ចំណាយហិរញ្ញប្បទាន | ១.៣៣៩.៨១១ | ៥.៣៩៣.៨០៨ | ១.២៨៨.៥៤១ | ៥.២០៣.១២៩ | (៥០.៨៧០) | -៣,៨០% | (១៩០.៦៧៩) | -៣,៥៤% |
| **ប្រាក់ចំណេញមុនបង់ពន្ធ** | **១.៥២៥.៤៣១** | **៦.១៤២.៩១១** | **២.៨០៥.៧៧៦** | **១១.៣២៩.៧២៤** | **១.២៨០.៣៤៥** | **៨៣,៩៣%** | **៥.១៨៦.៨១៣** | **៨៤,៤៤%** |

ប្រាក់ចំណេញមុនបង់ពន្ធ របស់ ក.ស.ភ. មានចំនួន ៦.១៤២.៩១១.000 រៀល (១.៥២៥.៤៣១ដុល្លារអាមេរិក ) ក្នុងឆ្នាំ ២០១៣ និង១១.៣២៩.៧២៤. ០០០ រៀល (២. ៨០៥. ៧៧៦ដុល្លារអាមេរិក) ក្នុងឆ្នាំ ២០១៤ ដែលបង្ហាញកំណើនចំនួន ៥.១៨៦.៨១៣. ០០០រៀល (១. ២៨០. ៣៤៥ ដុល្លារអាមេរិក) ឬស្មើនឹង ៨៤,៤៤% ក្នុងឆ្នាំ២០១៤។ មូលហេតុចម្បងនៃកំណើនគឺ÷

ចំណាយហិរញ្ញប្បទាន បានថយចុះចំនួន ១៩០.៦៧៩.០០០ រៀល (៥០.៨៧០ ដុល្លារអាមេរិក) ឬស្មើនឹង៣,៥៤% ក្នុងឆ្នាំ២០១៤ ដោយសារពុំបានប្រើ ឥណទានវិបារូបន៍។

ចំណាយផ្សេងៗ ថយចុះចំនួន ៨០៦.៧០១.000 រៀល (២០០.៩៨១ ដុល្លារអាមេរិក) ឬស្មើនឹង៤៥,៣៤% ក្នុងឆ្នាំ២០១៤ (ដោយសារការថយចុះលើការងារជួសជុល និងថែទាំ) និងការកាត់បន្ថយលើចំណាយទិញសម្ភារផ្គត់ផ្គង់ការិយាល័យថ្មី។

ចំណាយប្រាក់បៀវត្សរ៍ និងប្រាក់ឈ្នួល បានកើនឡើងចំនួន១.២៣៨.១២៩.០០០រៀល (៣០២.៣៤៤ ដុល្លារអាមេរិក) ឬស្មើនឹង១៩,៥៩% ក្នុងឆ្នាំ២០១៤ ដោយសារការបង្កើនប្រាក់ខែគោលរបស់បុគ្គលិក តាមគោលការណ៍រដ្ឋ និងការផ្តល់ប្រាក់បៀវត្សរ៍ទៅតាមបរិមាណកុងតឺន័រ (គិតជាតោន)។

ចំណាយទឹកភ្លើង និងប្រេងឥន្ធនៈបានកើនឡើងចំនួន ១៦៣.៨៤២.០០០រៀល (៣៩.៥២៤ ដុល្លារអាមេរិក) ឬស្មើនឹង១១,៥០% ក្នុងឆ្នាំ២០១៤ ដោយសារកំណើននៃការប្រើប្រាស់ក្នុងប្រតិបត្តិការនៅចំណតផែ LM១៧ និងចំណតផែពហុបំណង TS៣ ព្រមទាំងលើមធ្យោបាយដឹកជញ្ជូនបុគ្គលិកទៅចំណតផែកុងតឺន័រ LM១៧។

### ឃ- ការវិភាគចំណេញក្រោយការបង់ពន្ធ

#### ឃ.១.ដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ប្រៀបធៀបនឹងដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥

| បរិយាយ | ៣១ ធ្នូ ២០១៤ | | ៣១ ធ្នូ ២០១៥ | | បំរែបំរួល | | បំរែបំរួល | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | % | ពាន់រៀល | % |
| ប្រាក់ចំណេញមុនបង់ពន្ធ (ក) | ២.៨០៥.៧៧៦ | ១១.៣២៩.៧២៤ | ៤.៣៦៨.៤៩២ | ១៧.៧៣៦.០៧៧ | ១.៥៦២.៧១៦ | ៥៥,៧០% | ៦.៤០៦.៣៥៣ | ៥៦,៥៤% |
| ចំណាយពន្ធលើប្រាក់ចំណេញ(ខ) | ៦៦០.៦៦៧ | ២.៦៦៧.៧៧៣ | ១.១៨៥.២៦៧ | ៤.៨១២.១៨៤ | ៥២៤.៦០០ | ៧៩,៤០% | ២.១៤៤.៤១១ | ៨០,៣៨% |
| ប្រាក់ចំណេញសុទ្ធ | ២.១៤៥.១០៩ | ៨.៦៦១.៩៥១ | ៣.១៨៣.២២៥ | ១២.៩២៣.៨៩៣ | | | | |
| អត្រាពន្ធមធ្យម(ខ)/(ក) | ២៣,៥៥% | ២៣,៥៥% | ២៧,១៣% | ២៧,១៣% | | | | |

ក.ស.ភ. ទទួលបានប្រាក់ចំណេញសុទ្ធចំនួន ៨.៦៦១.៩៥១.០០០រៀល (២.១៩៥.១០៩ ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៤ និងចំនួន ១២.៩២៣.៨៩៣.០០០ រៀល (៣.១៨៣.២២៥ ដុល្លារអាមេរិក) ក្នុងឆ្នាំ២០១៥ ដែលបង្ហាញឱ្យឃើញនូវកំណើនប្រាក់ចំណេញសុទ្ធចំនួន ៤,២៦១,៩៤២.០០០ រៀល (១,០៣៨,១១៦ ដុល្លារអាមេរិក) ឬ ស្មើនឹង ៤៩,២០%។

ការកើនឡើងនៃអត្រាពន្ធមធ្យមចំនួន ៣,៥៨% ដោយសារមានការកត់ត្រាពន្ធពន្យារបំណុល (Deffered Tax Liability) ពីការទិញបន្ថែមនូវអចលនទ្រព្យ រោងចក្រ និងគ្រឿងបរិក្ខារ (PP&E) នៅឆ្នាំ២០១៥ ដែលស្របតាមការអនុវត្តផែនការអនាគត ស្តីពីគម្រោងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផែ ដំណាក់កាលទី២ ជំហានទី១ នៅឆ្នាំ២០១៥។

**ឃ.២.ដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ប្រៀបធៀបនឹងដំណាច់ឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤**

| បរិយាយ | ៣១ ធ្នូ ២០១៣ | | ៣១ ធ្នូ ២០១៤ | | បំរែបំរួល | | បំរែបំរួល | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារ | រៀល’000 | ដុល្លារ | រៀល’000 | ដុល្លារ | % | រៀល’000 | % |
| ប្រាក់ចំណេញមុនបង់ពន្ធ (ក) | ១.៥២៥.៨៣១ | ៦.១៩២.៩១១ | ២.៨០៥.៧៧៦ | ១១.៣២៩.៧២៤ | ១.២៨០.៣៩៥ | ៨៣,៩៣% | ៥.១៨៦.៨១៣ | ៨៤,៩៤% |
| ចំណាយពន្ធលើប្រាក់ចំណេញ(ខ) | ៧៥៣.២៩៦ | ៣.០៣៣.៣២២ | ៦៦០.៦៦៧ | ២.៦៦៧.៧៧៣ | (៩២.៥៧៩) | -១២,២៩% | (៣៦៥.៥៤៩) | -១២,០៥% |
| ប្រាក់ចំណេញសុទ្ធ | ៧៧២.១៨៥ | ៣.១០៩.៥៨៩ | ២.១៩៥.១០៩ | ៨.៦៦១.៩៥១ | | | | |
| អត្រាពន្ធមធ្យម(ខ)/(ក) | ៤៩,៣៨% | ៤៩,៣៨% | ២៣,៥៥% | ២៣,៥៥% | | | | |

ក.ស.ភ. ទទួលបានប្រាក់ចំណេញសុទ្ធចំនួន ៣.១០៩.៥៨៩.០០០ រៀល (៧៧២.១៨៥ ដុល្លារអាមេរិក) នៅឆ្នាំ២០១៣ និងចំនួន ៨.៦៦១.៩៥១.០០០ រៀល (២.១៤៥.១០៩ ដុល្លារអាមេរិក) នៅឆ្នាំ ២០១៤ ដែលបង្ហាញឱ្យឃើញនូវកំណើនប្រាក់ចំណេញសុទ្ធចំនួន ៥.៥៥២.៣៦២.០០០ រៀល (១.៣៧២.៩២៤ ដុល្លារអាមេរិក) ឬស្មើនឹង ១៧៨,៥៦%។

ការថយចុះនៃអត្រាពន្ធមធ្យម ២៥,៨៣% (ពី ៤៩,៣៨% នៅឆ្នាំ២០១៣ ដល់ ២៣,៥៥% នៅឆ្នាំ ២០១៤) ដោយសារការកត់ត្រាពន្ធពន្យារបំណុល នៅឆ្នាំ២០១៣ កើតចេញពីការរំលស់អចលនទ្រព្យ រោងចក្រ និងគ្រឿងបរិក្ខារ ដែលបានទិញក្នុងប្រតិបត្តិការផែកុងតឺន័រ LM១៧។

## ង- ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ដល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

### ង.១. កំរិតនៃការជួញដូរក្នុងតំបន់ និងជាសកល និងសកលភាវូបនីយកម្ម

លក្ខខណ្ឌហិរញ្ញវត្ថុ និងលទ្ធផលប្រតិបត្តិការនៃ ក.ស.ភ. អាស្រ័យលើបរិមាណកុងតឺន័រឆ្លងកាត់ និងសកម្មភាពដឹកជញ្ជូនឆ្លងកាត់កំពង់ផែ ដែលពឹងផ្អែកលើទំហំពាណិជ្ជកម្មក្នុងស្រុក និងទូទាំងពិភពលោក ព្រមទាំងបរិមាណនៃការនាំចេញ និងការនាំចូលក្នុងតំបន់ដែលត្រូវបានធ្វើប្រតិបត្តិការ។ បរិមាណនៃការជួញដូរក្នុងស្រុក និងទូទាំងពិភពលោក និងបរិមាណនៃការនាំចេញ និងនាំចូលក្នុងស្រុកដែលបានធ្វើប្រតិបត្តិការនេះ ទទួលរងផលប៉ះពាល់ដោយសារការផ្លាស់ប្តូរលក្ខខណ្ឌសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងនយោបាយក្នុងតំបន់ និងសកលដែលហួសពីការគ្រប់គ្រងរបស់យើង។

### ង.២. សមត្ថភាពទទួលកុងតឺន័រនៅចំណតផែកុងតឺន័រ LM១៧

ការលើកដាក់ចំបងៗ ត្រូវបានធ្វើឡើងនៅចំណតផែកុងតឺន័រLM១៧។ ក.ស.ភ. មានសមត្ថភាពលើកដាក់ទំនិញជាកុងតឺន័រប្រមាណ ១៥០.០០០ TEUs ក្នុងមួយឆ្នាំ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។ បរិមាណកុងតឺន័រឆ្លងកាត់កំពង់ផែស្វយ័តភ្នំពេញ បានកើនឡើងពីចំនួន ១១០.០០០ TEUs ក្នុងឆ្នាំ ២០១៣ ដល់ ចំនួន ១៤៤.៨១៣ TEUs ក្នុងឆ្នាំ ២០១៥ ដែលមានអត្រាកំណើនជាមធ្យមប្រចាំឆ្នាំ១៤,៤៨%។ ក.ស.ភ. រំពឹងថាចំនួនកុងតឺន័រឆ្លងកាត់ នៅក្នុងឆ្នាំ២០១៦ នឹងកើនឡើងដល់១៦៥.០០០ TEUs។ ដើម្បីឆ្លើយតបនឹងកំណើននេះ ក.ស.ភ. មានគម្រោងអភិវឌ្ឍន៍បន្ថែមទៀត នៅចំណតផែកុងតឺន័រ LM១៧ ដែលនឹងបង្កើនសមត្ថភាពលើកដាក់ ដល់ចំនួន ២២៥.០០០ TEUs ក្នុងមួយឆ្នាំ នៅបំណាច់ឆ្នាំ២០១៦។ បន្ថែមពីនេះ ក.ស.ភ. មានគម្រោងនឹងបញ្ចប់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផែ ដំណាក់កាលទី ២ ដែលនឹងបង្កើនសមត្ថភាពលើកដាក់កុងតឺន័រនៅចំណតផែកុងតឺន័រLM១៧ ដល់ចំនួន ៣០០.០០០ TEUs ក្នុងមួយឆ្នាំ នៅបំណាច់ឆ្នាំ ២០១៨ (*សូមអានផែនការអនាគត នៅចំណុចទី៥ នៃផ្នែកទី១ នៃរបាយការណ៍ប្រចាំឆ្នាំ២០១៥នេះ*)។

| បរិយាយ | នៅថ្ងៃទី៣១ ខែធ្នូ | | | | | |
|---|---|---|---|---|---|---|
| | ឆ្នាំ ២០១៣ | | ឆ្នាំ ២០១៤ | | ឆ្នាំ ២០១៥ | |
| | លទ្ធផល | សមត្ថភាពលើកដាក់ | លទ្ធផល | សមត្ថភាពលើកដាក់ | លទ្ធផល | សមត្ថភាពលើកដាក់ |
| ចំណតផែកុងតឺន័រ LM១៧ (TEUs) | ១១០.៥០០ | ១៥០.០០០ | ១៣៣.៦៦៦ | ១៥០.០០០ | ១៤៤.៨១៣ | ១៥០.០០០ |

### ង.៣. ប្រសិទ្ធភាពនៃប្រតិបត្តិការ

ក្រៅពីការបន្ថែមដើមទុនវិនិយោគដើម្បីបង្កើនសមត្ថភាពលើកដាក់ ក.ស.ភ. មានគោលការណ៍បន្ថយថ្លៃគោលរបស់កំពង់ផែ ក្នុងគោលដៅសម្រេចឱ្យមានប្រសិទ្ធភាពខ្ពស់ក្នុងប្រតិបត្តិការ ដោយប្រើធនធានដែលមានស្រាប់។ ដូចនេះ ក.ស.ភ. អាចកាត់បន្ថយការចំណាយក្នុងប្រតិបត្តិការ ក៏ដូចជាកាត់បន្ថយការចំណាយថ្លៃដើមរបស់អតិថិជនរបស់ ក.ស.ភ. ផងដែរ។

ការបង្កើនប្រសិទ្ធភាពប្រតិបត្តិការ អាចសម្រេចបានដោយកត្តាខាងក្រោម៖

- បន្តបំពាក់គ្រឿងចក្រលើកដាក់ទំនើបៗ ដើម្បីបង្កើនល្បឿននៃការលើកដាក់ទំនិញ និងកាត់បន្ថយការរង់ចាំដោយសារការខូចខាតគ្រឿងចក្រ
- បន្តជម្រុញសមត្ថភាពផ្នែកប្រតិបត្តិការ តាមរយៈការបណ្តុះបណ្តាល
- ពង្រីកចំណតផែ ដើម្បីធានាថានាវាដឹកកុងតឺន័រ អាចដឹកជញ្ជូនចេញចូលបានលឿន និងប្រកបដោយប្រសិទ្ធភាព
- ការប្រើទីលានស្តុកទុកទំនិញខាងក្រៅ ដើម្បីបង្កើនសមត្ថភាពផ្ទុកកុងតឺន័រ ដូចជានៅអង្គភាពផែស្ងួតICD នៅចំណតផែ KM៦ នៅចំណតផែ TS៣ នៅMSL សម្រាប់ LM១៧
- គ្រប់គ្រងទីលានស្តុកកុងតឺន័រ ឱ្យមានប្រសិទ្ធភាព ដោយកាត់បន្ថយការរក្សាទុកកុងតឺន័រនៅលើទីលានក្នុងរយៈពេលយូរ
- ប្រើប្រាស់ចំណតផែឲ្យមានប្រសិទ្ធភាព ដោយការរៀបចំទីតាំងចូលចតនាវាទៅតាមផែនការច្បាស់លាស់។

### ង.៤. តម្លៃ

ក្រៅពីមានសមត្ថភាពគ្រប់គ្រាន់ និងប្រសិទ្ធភាពប្រតិបត្តិការខ្ពស់ លទ្ធភាពរបស់ក.ស.ភ. ក្នុងការទាក់ទាញ និងរក្សាអតិថិជន អាស្រ័យលើតារាងតម្លៃ ការលើកទឹកចិត្ត និងការសន្សំសំចៃ ផ្តល់ជូនអតិថិជន។ ជាក់ស្តែង ក.ស.ភ. អាចសម្របតាមតម្លៃដែលផ្តល់ជូនទៅអតិថិជន ដូចជាការបញ្ចុះតម្លៃសរុបសម្រាប់នាវាទេសចរណ៍ចេញចូល បញ្ចុះតម្លៃលើកដាក់សម្រាប់ការដឹកជញ្ជូនទំនិញរាយ និងផ្តល់ជូនកញ្ចប់លើកទឹកចិត្តទៅកាន់ក្រុមហ៊ុនសេវាកម្មដឹកជញ្ជូនតាមនាវា អាស្រ័យលើបរិមាណនៃការដឹកជញ្ជូន។

### ង.៥. ការតភ្ជាប់រវាងផែរណប

ការតភ្ជាប់រវាងផែរណប ដើរតួនាទីយ៉ាងសំខាន់ ដែលក្រុមហ៊ុនដឹកជញ្ជូនធ្វើការជ្រើសរើសកំពង់ផែសម្រាប់ការដឹកជញ្ជូនទំនិញ។ ការតភ្ជាប់រវាងផែរណបដែលមានប្រសិទ្ធភាព អាចជម្រុញឱ្យអ្នកដឹកជញ្ជូនកាត់បន្ថយពេលវេលាដឹកជញ្ជូន។ ប្រសិទ្ធភាពចរាចរណ៍រវាងផែរណប អាស្រ័យទៅលើសេវាកម្ម ផែរណបផ្សេងទៀតដែលគ្រប់គ្រងលើចរាចរណ៍នៃការដឹកជញ្ជូនទំនិញ ព្រោះថាទីតាំងរបស់ ក.ស.ភ. មានអំណោយផលសម្រាប់ការប្រមូលទំនិញ ដើម្បីដឹកជញ្ជូនតាមផ្លូវទឹក។

### ង.៦. ការរំលស់

ការរំលស់ កើតឡើងពីការរំលស់ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារកំពង់ផែ រួមទាំងចំណតនាវា អគារឃ្លាំង និងគ្រឿងចក្រលើកដាក់។ ការប៉ាន់ស្មានអាយុកាលប្រើប្រាស់ទ្រព្យសំខាន់ៗ មានដូចជា ចំណតនាវា អគារ (១០-៥០ឆ្នាំ) គ្រឿងចក្រ គ្រឿងម៉ាស៊ីន (១០-១៥ឆ្នាំ) គ្រឿងសង្ហារឹម និងគ្រឿងបំពាក់ (៥ឆ្នាំ)

កុំព្យូទ័រ (៥-១៥ឆ្នាំ) សម្ភារការិយាល័យ និងផ្សេងៗ (៥-១៥ឆ្នាំ) និងយានយន្ត (៨-១៥ឆ្នាំ)។ វិធីសាស្ត្ររំលស់ អាយុកាលប្រើប្រាស់ និងតម្លៃកាកសំណល់ ត្រូវបានពិនិត្យ នៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ ហើយ ត្រូវកែសម្រួលប្រសិនបើសមស្រប។

## ២- កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ក- កត្តាសេដ្ឋកិច្ចជាតិ តំបន់ និងសកល

បរិមាណទំនិញឆ្លងកាត់ ក.ស.ភ. ទាក់ទងដោយផ្ទាល់ទៅនឹង កត្តាសេដ្ឋកិច្ចជាតិ តំបន់ ឬសកល។ ជាការចាំបាច់ដែល ក.ស.ភ. ត្រូវធ្វើការវិភាគសេដ្ឋកិច្ច និងពាណិជ្ជកម្ម ដើម្បីបានដឹងនូវនិន្នាការ កំណើន ឬការធ្លាក់ចុះនៃតម្រូវការដឹកជញ្ជូន។ នេះជាមូលដ្ឋាន ដើម្បីរៀបចំឆ្លើយតបបានទាន់ពេលវេលា ក៏ដូចជា ធ្វើផែនការវិនិយោគហេដ្ឋារចនាសម្ព័ន្ធ ឬក៏បំពាក់គ្រឿងចក្រ បានសមស្រប។ នេះក៏អាចជួយឲ្យ ក.ស.ភ. ជៀសបានពីការវិនិយោគហួសតម្រូវការ ដែលធ្វើឲ្យខាតប្រយោជន៍ពីការប្រើប្រាស់ទុន ឬកប់ទុន ក្នុង ករណីដែលតម្រូវការដឹកជញ្ជូនអាចធ្លាក់ចុះ។

### ខ- ការគ្រប់គ្រងថ្លៃដើមនៃការលក់/សេវាកម្ម

ការរក្សាបាននូវភាពប្រកួតប្រជែងខ្ពស់ក្នុងទីផ្សារ ជាកត្តាសំខាន់សម្រាប់និរន្តភាពនៃការរីកលូតលាស់ របស់ ក.ស.ភ. ក្នុងនោះគឺ គុណភាពសេវាកម្ម និងតម្លៃសេវាកម្មសមរម្យ។ ដើម្បីធានាបាននូវតម្លៃថ្លៃដើម នៃសេវាកម្មប្រកួតប្រជែង ក.ស.ភ. យកចិត្តទុកដាក់លើការគ្រប់គ្រងចំណាយប្រតិបត្តិការ ដូចខាងក្រោម៖

**- ចំណាយលើបុគ្គលិក**

ផ្នែកមួយនៃការចំណាយច្រើន គឺទៅលើបៀវត្សរ៍បុគ្គលិក (ផ្នែកប្រតិបត្តិការ និងផ្នែករដ្ឋបាល) ដែល មានអត្រា ២២,០១% នៃប្រាក់ចំណូលសរុបឆ្នាំ២០១៥ ដែលយើងចាត់ទុកថា ជាថ្លៃដើមនៃសេវាកម្ម ព្រមទាំងការចំណាយលើប្រតិបត្តិការផ្សេងទៀត។ ទោះជាយ៉ាងណា ក.ស.ភ. បានរៀបចំផែនការធនធាន មនុស្សត្រឹមត្រូវតាមទំហំការងារ និងការរៀបចំប្រាក់បៀវត្សយោងតាមបរិមាណកុងតឺន័រឆ្លងកាត់ ដែល ជួយឲ្យការចំណាយលើបុគ្គលិក មិនប៉ះពាល់ខ្លាំងលើប្រាក់ចំណេញ។

**- ចំណាយថ្លៃដងយោង**

ចំណាយថ្លៃដើមសេវាកម្មដ៏ធំមួយផ្នែកទៀតគឺ ចំណាយថ្លៃដងយោងដែលមានចំនួន ៨,៨៣% ធៀបទៅនឹងចំណូលសរុបឆ្នាំ២០១៥។ ក.ស.ភ. បានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនជាដៃគូអាជីវកម្មចំនួន បី ក្នុងការប្រើប្រាស់ដងយោងសម្រាប់សេវាកម្មលើកដាក់ និងជាថ្នូរមកវិញ ក.ស.ភ. ត្រូវបែងចែកប្រាក់ ចំណូលទៅកាន់ក្រុមហ៊ុនជាដៃគូទាំងនោះ។ យោងតាមកិច្ចសន្យា ភាគរយនៃការបែងចែកប្រាក់ចំណូល ទៅកាន់ក្រុមហ៊ុនជាដៃគូលើសពី៨០% បន្ទាប់ពីការធ្វើប្រតិបត្តិការបានរយៈពេល ៣ ទៅ ៥ឆ្នាំ។ ក.ស.ភ. រំពឹងថាចំណាយថ្លៃដងយោងនឹងបន្តកើនឡើង ព្រោះកំណើនបរិមាណទំនិញឆ្លងកាត់ត្រូវបានព្យាករណ៍ ថា បន្តឡើងខ្ពស់ក្នុងពេលខាងមុខ។ យ៉ាងណាមិញ ការចំណាយនេះ គឺប៉ះពាល់ដល់ផលចំណេញតិចតួច ប៉ុណ្ណោះ។ តារាងខាងក្រោមនេះ បង្ហាញពីភាគរយនៃការបែងចែក៖

| ម្ចាស់ដងយោង | ឈ្មោះដងយោង | ចំនួន | សមត្ថភាព (តោន) | ចំណែកប្រាក់ចំណូលរបស់ម្ចាស់ដងយោង | ចំណែកប្រាក់ចំណូលរបស់ ក.ស.ភ. | កាលបរិច្ឆេទកុងត្រា |
|---|---|---|---|---|---|---|
| Sovereign | ដងយោងបណ្តែតទី ១ | ១ | ៨០ | ៨០% | ២០% | ៣០/១២/២០១០-ដល់បច្ចុប្បន្ន |
| | ដងយោងបណ្តែតទី ២ | ១ | ៦០ | ៨០% | ២០% | |
| Kamsab | ដងយោងចល័ត ៨០T | ១ | ៨០ | ៩០% | ១០% | ១១/០៣/០៨-១០/០៣/០៩ |
| | | | | ៨៥% | ១៥% | ១១/០៣/០៩-១០/០៣/១០ |
| | | | | ៨០% | ២០% | ១១/០៣/១០ ដល់បច្ចុប្បន្ន |
| | ដងយោងចល័តទី ២ | ១ | ៨១ | ៩០% | ១០% | ០១/០៧/១៣-៣១/០៦/១៥ |
| | | | | ៨៥% | ១៥% | ០១/០៧/១៥-៣១/០៦/១៦ |
| | | | | ៨០% | ២០% | ០១/០៧/១៦-ចប់កុងត្រា |
| | ដងយោងចល័តទី ៣ | ១ | ៨១ | ៩០% | ១០% | ០១/០៧/១៣-៣១/០៦/១៥ |
| | | | | ៨៥% | ១៥% | ០១/០៧/១៥-៣១/០៦/១៦ |
| | | | | ៨០% | ២០% | ០១/០៧/១៦-ចប់កុងត្រា |
| Sungkwang | ដងយោងចល័តទី ១ | ១ | ៨១ | ៩០% | ១០% | ០១/០១/១៣-៣១/១២/១៣ |
| | | | | ៨៥% | ១៥% | ០១/០១/១៤-៣១/១២/១៤ |
| | | | | ៨០% | ២០% | ០១/០១/១៥-៣១/១២១៥ ចប់កុងត្រា |

### គ- ការគ្រប់គ្រងកាតព្វកិច្ចពន្ធផ្សេងៗ

ក.ស.ភ. ស្ថិតក្រោមច្បាប់សហគ្រាសពាណិជ្ជកម្ម ពាក់ព័ន្ធនឹងបញ្ហាបង់ពន្ធនៅកម្ពុជា។ ក.ស.ភ. មានកាតព្វកិច្ចបង់ប្រាក់ពន្ធ និងអាករ តាមការកំណត់នៃច្បាប់ និងបទបញ្ញត្តិជាធរមាន។ អគ្គនាយកដ្ឋានពន្ធដារ កំណត់ឱ្យ ក.ស.ភ. ធ្វើការបង់ពន្ធតាមរបបស្វ័យប្រកាស និងជាអ្នកជាប់ពន្ធធំ។

### គ.១. ពន្ធលើប្រាក់ចំណេញ

ក.ស.ភ. មានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណេញក្នុងអត្រា២០% ដោយបង់ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ១% នៃផលរបរប្រចាំខែ។ ប្រាក់រំដោះពន្ធលើប្រាក់ចំណេញ១% ប្រចាំខែ នឹងត្រូវទូទាត់កាត់កងជាមួយពន្ធលើប្រាក់ចំណេញ២០% នៃចុងឆ្នាំសារពើពន្ធនីមួយៗ។ ក.ស.ភ. ធ្វើការបោះផ្សាយលក់មូលបត្រកម្មសិទ្ធិនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥។ យោងតាមអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ ស្តីពីការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រ សហគ្រាសបោះផ្សាយលក់មូលបត្រកម្មសិទ្ធិទទួលបានការលើកទឹកចិត្តដោយបន្ថយពន្ធលើប្រាក់ចំណេញចំនួន ៥០ (ហាសិប) ភាគរយនៃពន្ធលើប្រាក់ចំណេញត្រូវបង់សម្រាប់រយៈពេល ៣(បី) ឆ្នាំគិតចាប់ពីថ្ងៃដែលអនុក្រឹត្យនេះចូលជាធរមាន។ ដូច្នេះ ក្រោយពីការអនុគ្រោះនេះត្រូវបានបញ្ចប់ នោះ ក.ស.ភ. នឹងអនុវត្តកាតព្វកិច្ចពន្ធលើប្រាក់ចំណេញដូចធម្មតាវិញ។

### គ.២. អាករលើតម្លៃបន្ថែម

ក.ស.ភ. ជាក្រុមហ៊ុនដែលចុះបញ្ជីអាករលើតម្លៃបន្ថែម។ ក.ស.ភ. បានគិតអាករលើតម្លៃបន្ថែមតាមអត្រា ១០% នៃចំនួនទឹកប្រាក់លើវិក្កយបត្រ ពេលដែលចេញវិក្កយបត្រទៅអតិថិជន។ ក.ស.ភ. ជាភ្នាក់ងារប្រមូលពន្ធនេះជូនរាជរដ្ឋាភិបាល ព្រោះនេះជាអាករលើធាតុចេញរបស់ ក.ស.ភ.។ អាករលើធាតុចេញនេះ នឹងត្រូវកាត់កងជាមួយអាករលើធាតុចូល ១០% នៅពេលដែល ក.ស.ភ. បង់ប្រាក់ទៅអ្នកផ្គត់ផ្គង់សម្រាប់ការទិញ។ យោងតាមគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផែដំណាក់កាលទី២ នៅចំណតផែកុងតឺន័រ (LM១៧) នាឆ្នាំ២០១៦ ក.ស.ភ. នឹងធ្វើការនាំចូលគ្រឿងចក្រលើកដាក់កុងតឺន័រ។

### គ.៣. ពន្ធកាត់ទុកលើចំណូលការប្រាក់

ក.ស.ភ. មានកាតព្វកិច្ចបង់ពន្ធកាត់ទុកលើចំណូលការប្រាក់តាមអត្រា៤% លើបញ្ញើទូទៅ និង៦% លើបញ្ញើមានកាលកំណត់។ ពន្ធកាត់ទុក ត្រូវកាត់ដោយធនាគារ និងត្រូវបង់បន្តតាមអគ្គនាយកដ្ឋានពន្ធដារជូនទៅរាជរដ្ឋាភិបាល។ បច្ចុប្បន្ន ក.ស.ភ. មានបញ្ញើមានកាលកំណត់នៅធនាគារពាណិជ្ជកម្មក្រៅប្រទេស (Foreign Trade Bank) និង ABA (Advanced Bank of Asia)។

### គ.៤. ពន្ធនាំចូល

ក.ស.ភ. មានកាតព្វកិច្ចបង់ពន្ធនាំចូលលើសម្ភារ និងវត្ថុធាតុដើមតាមអត្រាចន្លោះពី៧% ទៅ ៣៥% អាស្រ័យលើប្រភេទទំនិញនីមួយៗ ដែលកំណត់ដោយអគ្គនាយកដ្ឋានគយ និងរដ្ឋាករ។ យោងតាមគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផែដំណាក់កាលទី២ នៅចំណតផែកុងតឺន័រ (LM១៧) នៅឆ្នាំ២០១៦ ក.ស.ភ. នឹងនាំចូលគ្រឿងចក្រលើកដាក់កុងតឺន័រ ដូចនេះ ចំណាយលើពន្ធនាំចូលនឹងមានការកើនឡើង។

## ៣-ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

ចំណូលសំខាន់របស់ ក.ស.ភ. រួមមានប្រាក់ចំណូលពីការលើកដាក់ក្រោមដងយោង (Stevedore) ការលើកដាក់នៅទីលាន (LOLO) និងចំណូលកិច្ចការផែដែលពាក់ព័ន្ធនឹងការដឹកជញ្ជូនកុងតឺន័រ ដែលមានចំនួនច្រើនជាង៨៨% ធៀបនឹងប្រាក់ចំណូលសរុប។ កត្តាសំខាន់នៃការកើនឡើងប្រាក់ចំណូល បណ្តាលមកពីកំណើនចំនួនកុងតឺន័រ និងនាវាឆ្លងកាត់ ស្របតាមការលូតលាស់ផ្នែកឧស្សាហកម្មសាងសង់ និងឧស្សាហកម្មពាណិជ្ជកម្មដូចជា ឧស្សាហកម្មផលិតវាយនភណ្ឌ សំលៀកបំពាក់ និង ស្បែកជើង។ បន្ថែមពីនេះទៀត ការបើកឱ្យប្រើប្រាស់នូវកំពង់ផែមេកៃម៉េប ក្នុងប្រទេសវៀតណាម ក៏បណ្តាលឱ្យមានកំណើននៃចំនួនកុងតឺន័រឆ្លងកាត់ ក.ស.ភ. ដោយសារវាអាចចំណេញពេលវេលា និងអាចដឹកជញ្ជូនទៅដោយផ្ទាល់ ទៅកាន់ប្រទេសក្នុងតំបន់ប៉ាស៊ីហ្វិកប៉ែកខាងកើត និងសហរដ្ឋអាមេរិកប៉ែកខាងលិច។

## ៤- ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

### ក. ផលប៉ះពាល់ពីអត្រាប្តូរប្រាក់

ក.ស.ភ. បានកត់ត្រាបញ្ជីគណនេយ្យដោយប្រើប្រាស់រូបិយបណ្ណដុល្លារអាមេរិក ដោយសារចំណូលពីប្រតិបត្តិការអាជីវកម្មភាគច្រើន ជាប្រាក់ដុល្លារអាមេរិក និងការទូទាត់លើការងារជួសជុលគ្រឿងចក្រធំៗ ប្រេងឥន្ធនៈ និងចំណាយផ្សេងៗមួយចំនួនទៀត ក៏ជាប្រាក់ដុល្លារអាមេរិកដែរ លើកលែងតែការចំណាយ

លើប្រាក់បៀវត្ស និងការបង់ពន្ធ។ ហេតុដូចនេះ ផលប៉ះពាល់ពីអត្រាប្តូរប្រាក់សម្រាប់ ក.ស.ភ. គឺមានកម្រិតអប្បបរមា។

**ខ. ផលប៉ះពាល់ពីអត្រាការប្រាក់**

ក.ស.ភ. មិនបានកត់ត្រាបំណុលហិរញ្ញវត្ថុដែលមានអត្រាការប្រាក់ថេរតាមតម្លៃទីផ្សារ ដោយភាពលំអៀងត្រូវបានបញ្ចូលទៅក្នុងរបាយការណ៍លទ្ធផលនោះទេ ហើយ ក.ស.ភ ក៏មិនមានឧបករណ៍ហិរញ្ញវត្ថុដេរីវេទីវ នាចុងការិយបរិច្ឆេទនេះដែរ។ ដូច្នេះ ការផ្លាស់ប្តូរអត្រាការប្រាក់នាចុងការិយបរិច្ឆេទពុំមានផលប៉ះពាល់ដល់ប្រាក់ចំណេញ-ខាតនោះទេ។

**គ. ផលប៉ះពាល់ពីការប្រែប្រួលតម្លៃប្រេងឥន្ធនៈ**

ប្រតិបត្តិការរបស់ ក.ស.ភ. ពឹងផ្អែកយ៉ាងខ្លាំងទៅលើគ្រឿងចក្រ ដែលមានតម្រូវការប្រើប្រាស់ប្រេងឥន្ធនៈខ្ពស់។ ការប្រែប្រួលតម្លៃប្រេងឥន្ធនៈ នឹងប៉ះពាល់ដល់ថ្លៃដើមសេវាកម្ម។ អាស្រ័យហេតុនេះ ក.ស.ភ. បានព្យាយាមបង្កើនប្រសិទ្ធភាពការលើកដាក់ ការរៀបចំទីលានស្តុក ដែលអាចកាត់បន្ថយការប្រើប្រាស់ប្រេង កាត់បន្ថយការចល័តគ្រឿងចក្រច្រើនដែលមិនចាំបាច់ និងព្យាយាមទៅប្រើប្រាស់ថាមពលអគ្គិសនី។

## ៥- ផលប៉ះពាល់ពីអតិផរណា

កំណើននៃត្រាអតិផរណាអាចមានផលប៉ះពាល់ដល់ការចំណាយ និងការវិនិយោគរបស់ក្រុមហ៊ុន ព្រោះតម្លៃទំនិញមានការកើនឡើង ហើយអំណាចទិញបានថយចុះ។ ប៉ុន្តែ យោងតាមរបាយការណ៍របស់ធនាគារពិភពលោក កម្ពុជាមានអត្រាអតិផរណាជាមធ្យម ៣.៨% ពីឆ្នាំ ២០១១ ដល់ឆ្នាំ ២០១៤ ដែលកម្រិតអតិផរណានេះ មិនប៉ះពាល់ធ្ងន់ធ្ងរដល់ស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលប្រតិបត្តិការរបស់ ក.ស.ភ. នោះទេ។

## ៦- គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

ក.ស.ភ. បាន និងកំពុងទទួលផលពីគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាលមានដូចខាងក្រោម៖

- គោលនយោបាយស្តីពីការជម្រុញការនាំចេញអង្ករ បាននិងកំពុងផ្តល់ផលវិជ្ជមានដល់កំណើននៃការនាំចេញផលិតផលនេះតាម ក.ស.ភ.
- គោលនយោបាយក្នុងការអនុគ្រោះពន្ធលើការនាំចូលឧបករណ៍/គ្រឿងចក្រកសិកម្ម នាំឱ្យមានការវិនិយោគខ្លាំងលើវិស័យកសិកម្ម
- កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការស្វែងរកការអនុគ្រោះពន្ធ និងកូតា ពីប្រទេសជាដៃគូបានជម្រុញឱ្យមានការនាំចេញខ្ពស់
- ការរៀបចំឱ្យមានតំបន់សេដ្ឋកិច្ចពិសេស និងភណ្ឌាគារគយមានដែនកំណត់ បានទាក់ទាញឱ្យមានការវិនិយោគដោយផ្ទាល់ពីបរទេស
- គោលនយោបាយឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ បានកំពុងទាក់ទាញវិនិយោគិនឱ្យមកវិនិយោគនៅក្នុងប្រទេសកម្ពុជា និងការបង្កើតរោងចក្រធុនធ្ងន់ ព្រមទាំងសហគ្រាសធុនតូច និងមធ្យម

- គោលនយោបាយរបស់រាជរដ្ឋាភិបាលជម្រុញការដឹកជញ្ជូនតាមផ្លូវទឹក
- ធនាគារជាតិនៃកម្ពុជាបានបន្តអនុវត្តគោលនយោបាយរូបិយវត្ថុតឹងរឹង និង អត្រាប្តូរប្រាក់សេរីដែលមានការគ្រប់គ្រង។ គោលនយោបាយនេះ កំពុងតែចូលរួមចំណែកក្នុងការបង្កើនទំនុកចិត្តសាធារណៈនៅក្នុងបរិស្ថានម៉ាក្រូសេដ្ឋកិច្ចនៃប្រទេសកម្ពុជា និងជម្រុញការធ្វើអាជីវកម្មពីវិស័យឯកជន
- ការលើកទឹកចិត្តពន្ធដារក្នុងវិស័យមូលបត្រដល់សហគ្រាសបោះផ្សាយលក់មូលបត្រនៅកម្ពុជាបានជម្រុញឱ្យក្រុមហ៊ុនឯកជន និងសហគ្រាសរដ្ឋចូលទីផ្សារមូលបត្រកាន់តែច្រើន ដែលចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។

-

# ផ្នែកទី ១០ : ស្ថិតិប្រចាំឆ្នាំសខេមបពីលទ្ធផលរបស់ ក.ស.ភ.

## ស្ថិតិនាវាដឹកទំនិញឆ្លងកាត់ ក.ស.ភ.

(គ្រឿង)

| ឆ្នាំ | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|---|
| នាវាអន្តរជាតិ | ៤៧២ | ៥២១ | ៥៥០ | ៦០១ | ៦២៨ |
| សាឡង់អន្តរជាតិ | ១០៧ | ១៦២ | ២០៧ | ២៦៤ | ៣៦២ |
| នាវាប្រេង | ៨៩៣ | ៨៣៣ | ៥៧៦ | ៤៨៤ | ៥០៥ |
| នាវាកម្ពុជា | ១១០ | ១១៣ | ១១៦ | ១១៣ | ១០១ |
| សាឡង់កម្ពុជា | ១ | ១ | ១ | ០ | ០ |
| **សរុប** | **១.៥៨៣** | **១.៦៣០** | **១.៤៥០** | **១.៤៦២** | **១.៥៨៦** |

## ស្ថិតិកុងតឺន័រឆ្លងកាត់ ក.ស.ភ.

(TEUs)

| ឆ្នាំ | | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|---|---|
| នាំចូល | គ្មានទំនិញ | ១០.១២៤ | ១២.៨៧៧ | ២២.០៦៨ | ២២.៦៩៣ | ២៨.៥៧៥ |
| | មានទំនិញ | ២៥.៣៤៤ | ២៩.៦២៧ | ២៨.៩២៤ | ៣៩.៤១២ | ៤៥.៧៥១ |
| សរុបនាំចូល | | ៣៥.៤៦៨ | ៤២.៥០៤ | ៥០.៩៩២ | ៦២.១០៥ | ៧៤.៣២៦ |
| នាំចេញ | គ្មានទំនិញ | ១០.៤៦៧ | ១០.៨៦៨ | ១០.០០៧ | ១២.៥៥៨ | ១១.៧៣១ |
| | មានទំនិញ | ៣៥.៦៩៦ | ៤១.៩៦១ | ៤៩.៥០១ | ៥៩.០០៣ | ៥៨.៧៥៦ |
| សរុបនាំចេញ | | ៤៦.១៦៣ | ៥២.៨២៩ | ៥៩.៥០៨ | ៧១.៥៦១ | ៧០.៤៨៧ |
| **សរុប** | | **៨១.៦៣១** | **៩៥.៣៣៣** | **១១០.៥០០** | **១៣៣.៦៦៦** | **១៤៤.៨១៣** |

## ស្ថិតិនាវាទេសចរណ៍អន្តរជាតិឆ្លងកាត់ ក.ស.ភ.

| ឆ្នាំ | | ២០១១ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ |
|---|---|---|---|---|---|---|
| នាវាទេសចរណ៍អន្តរជាតិ | អ្នកដំណើរ(នាក់) | ១២.៣១៥ | ១៩.៣៦១ | ២២.៥៨៤ | ២៤.៣១៧ | ២៥.០៣៣ |
| | នាវា(គ្រឿង) | ២៧២ | ៤៣៨ | ៤៩៧ | ៥២៣ | ៦០៤ |

# ផ្នែកទី ១១ : ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន

គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៥ ក.ស.ភ. ពុំទាន់មានព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិនទេ។

## ហត្ថលេខារបស់អភិបាលរបស់កំពង់ផែស្វយ័តភ្នំពេញ

ថ្ងៃទី២៩ ខែ មេសា ឆ្នាំ២០១៦
បានអាន និងឯកភាព

ហត្ថលេខា
**ហ៊ី បាវី**
ប្រធានក្រុមប្រឹក្សាភិបាល និងជាអគ្គនាយក

ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ២០១៦
បានអាន និងឯកភាព

ហត្ថលេខា
**សួន រចនា**
សមាជិកក្រុមប្រឹក្សាភិបាល

ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ២០១៦
បានអាន និងឯកភាព

ហត្ថលេខា
**លី ស៊ីវណ្ណា**
សមាជិកក្រុមប្រឹក្សាភិបាល

ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ២០១៦
បានអាន និងឯកភាព

ហត្ថលេខា
**កែន សម្បត្តិ**
សមាជិកក្រុមប្រឹក្សាភិបាល

ថ្ងៃទី២៩ ខែ មេសា ឆ្នាំ២០១៦
បានអាន និងឯកភាព

ហត្ថលេខា
**ប៉ែន សុទិដ្ឋាតិ**
សមាជិកក្រុមប្រឹក្សាភិបាល

ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ២០១៦
បានអាន និងឯកភាព

ហត្ថលេខា
**ហួត ហៃ**
សមាជិកក្រុមប្រឹក្សាភិបាល

ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ២០១៦
បានអាន និងឯកភាព

ហត្ថលេខា
**ព្រុំ សុខានី**
សមាជិកក្រុមប្រឹក្សាភិបាល

PHNOM PENH AUTONOMOUS PORT

**កំពង់ផែស្វយ័តភ្នំពេញ “ក.ស.ភ”**

អាសយដ្ឋានអគារលេខ 649 តិរវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ